# វិបស្សនាន័យ

ភាគទី ៣ (ភាគបញ្ចប់)




រៀបរៀងដោយ

អមរាភិវំសៈ ថោន សីលា

ត្រួតជម្រះដោយ

ភិក្ខុហានចារោ: ទ៉ាត ប៊ុនរដ្ឋ


ព.ស.២៥៥៨

# វិបស្សនាន័យ

## ភាគទី ៣ (ភាគបញ្ចប់)



រៀបរៀងដោយ

**អមរាភិវំសៈ ថោន សីលា**

ត្រួតជម្រះដោយ

**ភិក្ខុហានចារោៈ វ៉ាត ប៊ុនរដ្ឋ**

ព.ស.២៥៥៨

សៀវភៅឈ្មោះ **វិបស្សនានយ ភាគទី ៣** (ភាគបញ្ចប់)

រៀបរៀងដោយ ថោន សីលា, ភិក្ខុវ៉ាត ប៊ុនវឌ្ឍ

វាយអត្ថបទដោយ **អមរាកិរិសៈ** ថោន សីលា

រចនាក្របដោយ **អមរាកិរិសៈ** ថោន សីលា

ផ្ទៀងផ្ទាត់ដោយ ក្រុមអ្នកមានឧបការក្នុងការផាធម្មទាន

កែសម្រួលដោយ ភិក្ខុវ៉ាត ប៊ុនវឌ្ឍ,ភិក្ខុលី សាពឌី, ភិក្ខុណុប ណេង

កាលបរិច្ឆេទ កើត១៥ ខែកត្តិក ឆ្នាំមមីធស័ក ព.ស.២៥៥៨

បោះពុម្ព លើកទី ១ ចំនួន ១០០០ ច្បាប់

ធម្មទានដោយ ពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

ស្ថានទីធ្វើ ល្អាងភ្នំតាគ្រាម(ខេត្តបាត់ដំបង)និងបញ្ចប់រូបជា ស្ថាបពរនៅវត្តរាជបូណ៌ខេត្តសៀមរាប

រក្សាសិទ្ធ ដោយគ្រប់យ៉ាង

# ពាក្យប្រារព្ធ

គម្ពីរវិបស្សនាន័យភាគទី១ ទី២ ដល់ភាគទី ៣ នេះ គឺជាការប្រមូលសេចក្តីសំខាន់ៗ ដែលមាននៅក្នុងគម្ពីរព្រះពុទ្ធដីកា អដ្ឋកថា និងដីកាទាំងឡាយ ដែលមានសេចក្តីជាប់ទាក់ទងជាមួយនឹងវត្តបដិបត្តិរបស់ពុទ្ធបរិស័ទ គម្ពីរនេះ ច្បាប់ដើមជា **ភូមាភាសា** ដែលបានរៀបរៀងចងក្រងដោយព្រះមហាថេរនាម **អគ្គមហាបណ្ឌិត មហាស៊ីស្សាជ៏** រចនាឡើងក្នុងពុទ្ធសករាជ: ២៤៨៧ ហើយលោកក៏ជាព្រះមហាថេរ:១អង្គ ដែលជាក្រុមត្រួតជម្រះគម្ពីរព្រះត្រៃបិដក ( **ឆសង្គាយនា** ) និងអដ្ឋកថា ហើយរឿងជីវប្រវត្តិរបស់លោក ខ្ញុំក៏បានសរសេរនៅក្នុងសៀវភៅវិបស្សនាន័យ ភាគទី ១ រួចហើយ ។

ក្នុងវរោកាសនេះ ខ្ញុំព្រះករុណា ខ្ញុំបាទរៀបចំប្រែចប់សព្វគ្រប់ហើយ ដោយរយ:ពេលកន្លងមានបញ្ហាឧបស័គ្គជាច្រើន ដូចជាបាត់បង់ឯសារពីកុំព្យូទ័រ ហើយនិងបញ្ហាបាត់បង់សេចក្តីក្នុងអំឡុងកំពុងពេលរៀបចំ ហើយនឹងដោយសារភាពជាយរាវាស មិនសូវជាសំបូរពេលវេលា ទើបបន្ទាយពេលរហូតមកដល់សព្វថ្ងៃនេះ ដោយរួមសហការជាយព្រះតេជព្រះគុណ **ហានចារោ** វ៉ាត ប៊ុនវឌ្ឍ គង់នៅក្នុងវត្តរាជបូណ៌ ខេត្តសៀមរាប ទើបបានចប់ជាស្ថាបពរ ។

សូមអធ្យាស្រ័យផងដែរ ចំពោះពុទ្ធបរិស័ទទាំងឡាយ ដែលបានចូលរួមបោះពុម្ពសៀវភៅវិបស្សនាន័យនេះ ដោយមិនបានសរសេរាយនាមឈ្មោះពុទ្ធបរិស័ទដាក់ក្នុងសៀវភៅ ដោយសារមូលហេតុ បាត់បង់ឯកសារព្រមទាំងឈ្មោះអ្នកចូលរួមមុនៗ ផង ហើយនឹងកុំឲ្យចំណាយថវិការច្រើន...។ ដោយហេតុនេះជាដើម សូមពុទ្ធបរិស័ទទាំងឡាយ មេត្តាជ្រះថ្លាអនុមោទនា ចំពោះបុណ្យកុសល

តែម្យ៉ាងចុះ **ទទតោ បុញ្ញំ បវឌ្ឍតិ** បុណ្យរមែងចំរើនដល់អ្នកដែលឲ្យទាន ។

ហើយបករណ៍នេះ ខ្ញុំសង្ឃឹមថា នឹងជាប្រយោជន៍ដល់ជនានុជនច្រើន ដែលជាអ្នកមានវត្តបដិបត្តិល្អចង់ស្វែងរកព្រះនិព្វាននោះ ។

**បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ**

**សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។**

មច្ចុ គឺសេចក្តីស្លាប់ តែងរកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ នុ៎ះឯង ដូចទឹកជំនន់ធំដែលគួចយកអ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះឯង ។

សៀមរាប ថ្ងៃ ១៥ កើតខែកត្តិក ឆ្នាំមមីធស័ក ពុទ្ធសករាជ ២៥៥៨

ធម្មុបាសក **ថោន សីលា**



## អ្នកមានឧបការក្នុងកិច្ចការងារធម្មទាន

១-ព្រះភិក្ខុវ៉ាត ប៊ុនវឌ្ឍ
២-ព្រះភិក្ខុគង់ សុភាព
៣-ព្រះភិក្ខុមុត សំបូរ
៤-ព្រះតេជគុណ ម៉ន សាមៀន
៥-ភិក្ខុ លី សារ៉ាឌី (វត្តចាក់ដេងបាងកក)
៦-ភិក្ខុអ៊ី ចាន់អៀង (វត្តតាផេម ក.ព.)
៧-ឧ.សិ. លឹម ចន្ទន
៨ -ឧ.សិ. ប៊ូ យ៉ុន
៩-លោកគ្រូវ៉ាយ វឌ្ឍា
១០-ឧ.សិ. អ៊ីវ ឈីវហ៊ុន
១១-ឧ.សិ. សូរីឡា
១២-ឧ.សិ. ឱម សារ៉ូន
១៣-ឧ.សិ. យ៉ាវ កុសល
១៤-ឧ.សិ. លី ដែត
១៥-ឧ.សិ. ណៃ ស៊ីម (កំពង់ស្ពឺ)
១៦-ឧ.សិ. សៅ ណាន
១៧-ឧ.សិ. គឹម ម៉ាក់វ៉ៃ
១៨-ឧ.សិ.សួន សារ៉េន
១៩-ឧ.សិ. ចន្ធូ (វត្តអណ្ដើក)
២០-ឧ.ស. វ៉ិត ថេន (តាគ្រាម)
២១-ឧ. សិ. ទិត្រ ដារី (សាលាសតិប្បដ្ឋានា)
២២-ឧ.សិ. ស៊ីម ស៊ីណាត
២៣-ឧ.សិ. ប៉ូច ស៊ីធូ
២៤.ឧ.សិ. វណ្ណៈ ភាព
២៥-ព្រះតេជគុណ. ញឹម សុគា
២៦-ឧ.សិ. គួន ស៊ីណាន
២៧-អ្នកគ្រូពេទ្យ ចន្ថា ( ប៉ោយប៉ែត )
២៨-អ្នកគ្រូ មីន ( ប៉ោយប៉ែត )
៣០-ឧ.ស. ព្រហ្មលី ( USA)
៣១- ឧ.ស. ធាត ឈុន្នី
៣២-ឧ.សិ. ខេង ចរិយា
៣៣-ឧ.សិ. ខេង ច័ន្ទលីណា
៣៤- ឧ.សិ. ព្រាប បុប្ផា
៣៥-ពុទ្ធបរិស័ទក្នុងប្រពន្ធផលបក
៣៦-ឧ.សិ. ស្រីណា (ក.ព.)
៣៧-ឧ.សិ. ស្រីលក្ខណ៍ (ក.ព.)
៣៨-ឧ.សិ. ស្រីនាងតូច (ក.ព.)
៣៩-ឧ.សិ. ស្រីនាងធំ

**និងពុទ្ធបរិស័ទខេត្តសៀមរាបទាំងអស់ ។**

–··–··–··–··–··–··–··

# មាតិកា

ទំព័រ

**ញាណទី៩-១១ មុញ្ចិតុកម្យតាញាណ បដិសង្ខាញាណ**
**សង្ខារុបេក្ខាញាណ** .................... .................. ០១
មុញ្ចិតុកម្យតាញាណ បដិសង្ខាញាណ សង្ខារុបេក្ខាញាណ
និងបដិបទាញាណទស្សនវិសុទ្ធិ .......... .................. ០២
អនិច្ចលក្ខណៈ ១០ .................... .................. ០៨
ទុក្ខលក្ខណៈ ២៥ .................... .................. ១១
អនត្តលក្ខណៈ ៥ .................... .................. ១៥
**ញាណទី១២ អនុលោមញាណ** .............. .................. ៤៣
អនុលោមញាណនិងបដិបទាញាណទស្សនវិសុទ្ធិ ......... ៤៤
**ញាណទី១៣ គោត្រភូញាណ** ................ .................. ៥២
គោត្រភូញាណ .................... .................. ៥៣
**ញាណទី១៤-១៥ មគ្គញាណ ផលញាណ** .................. ៥៤
មគ្គញាណ ផលញាណនិងញាណទស្សនវិសុទ្ធិ ........... ៥៥
**ញាណទី១៦ បច្ចវេក្ខណញាណ** ............ .................. ៧២
បច្ចវេក្ខណញាណ .................... .................. ៧៣
-កិលេសដែលលះបានហើយ ............ .................. ៧៧
-អង្គរបស់ព្រះសោតាបន្ន .................. .................... ៩៧

-ព្រះអរិយៈមានសទ្ធាមិនកំរើក .......... .................... ១០២
-ព្រះអរិយៈមានសីលដ៏ផូរផង់ ........... .................... ១១០
-ព្រះអរិយៈមិនដឹងថាខ្លួនរួចផុតពីអបាយហើយ ........... ១១៣
-មហាបច្ចវេក្ខណៈ ៧ .................... .................... ១២១
**ការចូលផលសមាបត្តិ** ....................... .................... ១៣៤
-អានិសង្សនៃផលសមាបត្តិ ............. .................... ១៣៨
-លក្ខណៈនៃការចូលផលសមាបត្តិ .... .................... ១៣៩
-ការតាំងនៅនៃផលសមាបត្តិ ........... .................... ១៤២
-ការរលត់រូបនាមក្នុងផលសមាបត្តិ .... .................... ១៤៣
-ការចេញអំពីផលសមាបត្តិ ............. .................... ១៤៧
**និព្វានកថា** ....... ........ ......... .................... ១៥៣
-និព្វានមិនមែនជាសភាវបញ្ញតិ .......... .................... ១៥៩
-និព្វានផុយគ្នាជាមួយសង្ខារ ............. .................... ១៦៣
-និព្វាន ២ ប្រភេទ ..................... .................... ១៦៦
-និព្វានជាអារម្មណ៍របស់មគ្គផល ....... .................... ១៧១

## បរិច្ឆេទទី ៧

**បរិច្ឆេទទី ៧ មហាវិបស្សនា ១៨** ..... .................... ១៨០
**មហាវិបស្សនា ១៨** ....................... .................... ១៨១

១.អនិច្ចានុបស្សនា .......................... ..................... ១៨៥
-ពេលប្រាកដនៃអនិច្ចានុបស្សនា ........ ..................... ១៩៧
-ការលះកិលេសដោយវិបស្សនាញាណនិងមគ្គញាណ... ២០៤
-អនុស័យដែលដេកសម្ងំ ................. ..................... ២០៤
-អារម្មណានុសយ .......................... ..................... ២០៥
-សន្តានុសយ .......................... ..................... ២១៥
-កាលបុគ្គលដឹងច្បាស់តាមពិតមិនទៀង ហើយដឹងថា
ជាទុក្ខ និងមិនមែនជាតួខ្លួន .............. ..................... ២២១
២. ទុក្ខានុសបស្សនា ......................... ..................... ២២៩
៣. អនត្តានុបស្សនា .......................... ..................... ២៣៥
៤. និព្វិទានុបស្សនា ......................... ..................... ២៤៨
៥. វិរាគានុបស្សនា .......................... ..................... ២៥០
៦. និរោធានុបស្សនា ......................... ..................... ២៥២
៧. បដិនិស្សគ្គានុបស្សនា .......................... ..................... ២៥៨
-មហាវិបស្សនា១៨ រាប់បូកក្នុងអនុលោម ៧ ................. ២៦៤
៨. ខយានុបស្សនា ........................... ..................... ២៧០
៩. វយានុបស្សនា ............................ ..................... ២៧២
១០.វិបរិណាមានុបស្សនា ..................... ..................... ២៧៥
១១. អនិមិត្តានុបស្សនា ..................... .................. ២៧៨

១២. អប្បណិហិតានុបស្ស ...................... .................. ២៨០

១៣. សុញ្ញតានុបស្សនា ...................... ...................... ២៨១

១៤. អធិបញ្ញាធម្មវិបស្សនា ..................... ..................... ២៨១

១៥. យថាភូតញ្ញាទស្សន ..................... ..................... ២៨៣

១៦. អាទីនវានុបស្សនា ...................... ...................... ២៨៤

១៧. បដិសង្ខានុបស្សនា ...................... ..................... ២៨៦

១៨. វិវដ្តានុបស្សនា ........................ ..................... ២៨៨

**ពាក្យសរុប** ........................ ..................... ២៩១

**និគមគាថា** ........................ ..................... ២៩២

**ពាក្យចុងក្រោយ** ........................ ..................... ២៩៣

**ការលះសក្កាយទិដ្ឋិរបស់ព្រះសោតាបន្ន** ..................... ២៩៤

# ញាណទី៩,១០,១១
# មុញ្ចិតុកម្យតាញាណ
# បដិសង្ខាញាណ
# សង្ខារុបេក្ខាញាណ

ចប់

# មុញ្ចិតុកម្យតាញាណ
# បដិសង្ខាញាណ
# សង្ខារុបេក្ខាញាណ
# និង
# បដិបទាញាណទស្សនវិសុទ្ធិ

## *ក្នុងគម្ពីរវិសុទ្ធមគ្គពោលដល់មុញ្ចិតុកម្យតាថា :*

**[១]** ឥមិនា បន និព្វិទាញាណេន ឥមស្ស កុលបុត្តស្ស និព្វិន្ទន្តស្ស ឧក្កណ្ឋន្តស្ស អនភិរមន្តស្ស សព្វភវយោនិគតិវិញ្ញាណដ្ឋិតិសត្តាវាស-គតេសុ សភេទកេសុ សង្ខារេសុ ឯកសង្ខារេបិ ចិត្តំ ន សជ្ជតិ ន សគ្គតិ ន ពជ្ឈតិ, សព្វស្មា សង្ខារគតា មុច្ចិតុកាមំ និស្សរិតុកាមំ ហោតិ។ល។

**[២]** អត្ថស្ស ឯវំ សព្វសង្ខារេសុ វិគតាលយស្ស សព្វសង្ខារគតា មុច្ចិតុកាមស្ស ឧប្បជ្ជតិ មុញ្ចិតុកម្យតញាណំ។

*“១. កាលកុលបុត្រនេះធុញទ្រាន់នឿយណាយ មិនត្រេកអរជាអ្នកតាំងនៅដោយនិព្វិទាញាណនេះ ចិត្តក៏មិនរសាប់រសល់ មិនភ្ជើតភ្ជិន មិនគិតទៅក្នុងសង្ខារដែលកើតរលត់ជាប់បន្តគ្នានៅក្នុងភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ និងសត្តាវាស ៩ ទាំងអស់សូម្បីណាមួយ ជាចិត្តដែលប្រាថ្នានឹងរួចផុតចាក់សង្ខារទាំងពួង ។ល។*

*២. លំដាប់នោះ មុញ្ចិតុកម្យតាញាណរមែងកើតឡើងគ្រាដំបូង*

កុលបុត្រអ្នកប្រាសចាកសេចក្តីសង្ស័យក្នុងសង្ខារទាំងពួង អ្នកត្រូវការនឹងរួចផុតទៅអំពីសង្ខារទាំងពួង។

**មុញ្ចិតុកម្យតាញាណ** គឺ ញាណដែលត្រូវការនឹងរួចផុតទៅអំពីសង្ខារដែលប្រព្រឹត្តទៅក្នុងស្ថានទីពួកនោះ គឺ :-

**ភព ៣ បានដល់ :-**

-កាមភព

-រូបភព

-អរូបភព

**កំណើត ៤ បានដល់ :-**

**-អណ្ឌជ :** សត្វដែលកើតក្នុងពង បានដល់ សត្វបក្សីជាដើម។

**-ជលាពុជ :** សត្វដែលកើតក្នុងគភ៌ បានដល់ មនុស្ស ជាដើម ។

**-សំសេទជ:** សត្វដែលកើតអំពីញើសក្អែល បានដល់ដង្កូវជាដើម ។

**-ឱបបាតិក:** សត្វដែលកើតឡើងធំឯង បានដល់ ទេវតា ជាដើម។

**គតិ ៥ បានដល់ :-**

**-នរក**

**-សត្វតិរច្ឆាន**

**-ប្រេត**

**-មនុស្ស**

**-ទេវតា** ។

**វិញ្ញាណដ្ឋិតិ ៧ បានដល់ :-**

-មនុស្សនិងទេវតាជាន់កាមាវចរ ជាសត្វជំពូកដែលមានរាងកាយផ្សេងគ្នា មានបដិសន្ធិក៏ផ្សេងគ្នា ទើបហៅថា **នានត្តកាយនានត្តសញ្ញី** (អ្នកមានរាងកាយផ្សេងគ្នា មានបដិសន្ធិក៏ផ្សេងគ្នា) ។

-ព្រហ្មជាន់បឋមឈានភូមិ និងសត្វក្នុងអបាយភូមិ ជាសត្វជំពូកដែលមានរាងកាយផ្សេងគ្នា តែមានបដិសន្ធិដូចគ្នា ទើបហៅថា **នានត្ត-កាយឯកត្តសញ្ញី**(អ្នកមានរាងកាយផ្សេងគ្នា តែមានបដិសន្ធិដូចគ្នា ) ។

-ព្រហ្មជាន់ទុតិយឈានភូមិ ដែលមានរាងកាយដូចគ្នា តែមានបដិសន្ធិដូចគ្នា ទើបហៅថា **ឯកត្តកាយនានត្តសញ្ញី** ( អ្នកមានរាងកាយដូចគ្នា តែមានបដិសន្ធិផ្សេងគ្នា ) ។

-ព្រហ្មជាន់តតិយឈានភូមិ និងវេហប្ផលា មានរាងកាយនិងបដិសន្ធិដូចគ្នា ទើបហៅថា **ឯកត្តកាយឯកត្តសញ្ញី** ( អ្នកមានរាងកាយដូចគ្នា និងមានបដិសន្ធិក៏ដូចគ្នា ) សូម្បីព្រហ្មជាន់ សុទ្ធាវាសក៏រាប់ចូលក្នុងន័យនេះ ។

-អាកាសាណញ្ចាយតនព្រហ្ម ឈ្មោះថា អាកាសាណញ្ចាយតនសញ្ញី។

-វិញ្ញានញ្ចាយតនព្រហ្ម ឈ្មោះថា វិញ្ញានញ្ចាយតនសញ្ញី ។

-អាកិញ្ចញ្ញាយតនព្រហ្ម ឈ្មោះថា អាកិញ្ចញ្ញាយតនសញ្ញី។

-នេវសញ្ញានាសញ្ញាយតនព្រហ្ម ឈ្មោះថា នេវសញ្ញានាសញ្ញាយតសញ្ញី។

សត្តាវាស ៩ គឺ វិញ្ញាណដ្ឋិតិ ៧ ដែលរាប់ពីអសញ្ញាព្រហ្ម និង

នេវសញ្ញានាសញ្ញាយតនព្រហ្មខាងចុង ។

កាលបើអ្នកបដិបត្តិព្រួកដឹងហើយនឿយណាយ ត្រូវការនឹងរួចផុតអំពីភព ៣ ក៏រាប់ថា វិបស្សនាញាណជាលំដាប់បានបរិបូរណ៍ហើយ ព្រោះកំណើត ៤ ជាដើមត្រឹមតែជាវេវចនៈពាក្យរបស់ភព ៣ ប៉ុណ្ណោះ ។ អាចារ្យខ្លះអនុមានដឹងដោយពិចារណាដល់កំណើត ៤ និងគតិ ៥ ជាដើមតាមដែលខ្លួនបានឮ បានស្តាប់ទៀតផង ។

អ្នកដែលឃើញទោសក្នុងស្ថានទីណានិមួយ ហើយនឿយណាយ រមែងត្រូវការនឹងទៅឲ្យរួចផុតចាកស្ថានទីនោះ សូម្បីអ្នកចម្រើនវិបស្សនាក៏ដូចគ្នា កាលប្រចក្សច្បាស់ថារូបនាមគួរខ្លាច ហើយមានសតិព្រួកដឹងនឿយណាយ រមែងត្រូវការនឹងឃ្លាតឆ្ងាយអំពីសង្ខារ គឺអារម្មណ៍ដែលខ្លួនកំណត់ដឹង វិបស្សនាចិត្ត និងស្ថានទីបានដល់ ភព, កំណើត, គតិ ជាដើម។ ការត្រូវការនឹងរួចផុតអំពីសង្ខារយ៉ាងរួតរាស់ឈ្មោះថា **មុញ្ចិតុកម្យតាញាណ** ក្នុងខណៈនោះ អ្នកបដិបត្តិធម៌រមែងព្រួកដឹង ហើយត្រូវការនឹងរួចផុតអំពីអាកប្បកិរិយាផ្លូវកាយបានដល់ ការដេក ដើរ ឈរ អង្គុយ លាត បត់។ល។ និងសភាវៈផ្លូវចិត្តបានដល់ ការឃើញ បានឮ ដឹងខ្លិន ដឹងរស ដឹងផោដ្ឋព្វៈ នឹកគិតផ្សេងៗ ។ល។ ម្យ៉ាងទៀត ចិត្តក៏នឿយណាយ ចង់រួចផុតអំពី ភព គឺភាពជាមនុស្ស ទេវតា ព្រហ្ម បុរស ស្ត្រី ។ល។ អ្នកខ្លះអាចធុនទ្រាន់ បើមិនត្រូវការកំណាត់ដឹងក៏នឹងល្អជាងនេះ និងអាចឈប់បដិបត្តិធម៌មួយគ្រា ។

[ក្នុងច្បាប់ផ្សេងៗ មានរូបថា **មុច្ចិតុកម្យតាញាណខ្លះ មុញ្ចិតុកម្យតាញាណខ្លះ**

*សេចក្តីសម្រេចរូបថា* : **មុច្ចិតុកម្យតា** *ប្រែថា “សេចក្តីត្រូវការនឹងរួចផុតទៅអំពីសង្ខារ”* (**មុច្ចិតុំ= មុចៈ** *ធាតុ ប្រែថារួចផុត* +**តុំ***បច្ច័យ) សម្រេចរូបជា មុច្ចិតុកម្យតា ប្រែថា សេចក្តីត្រូវការនឹងផុតអំពីសង្ខារ”* ( **មុញ្ចិតុំ = មុចៈ** *ធាតុ ប្រែថា បន្ទេង +* **តុំ***បច្ច័យ ) ។ យ៉ាងណាក៏ដោយ រូបថា មុញ្ចិតុកម្យតញាណ គួរជារូបដើម ព្រោះធ្លាប់ជួបជាបទកម្មរបស់***មុច***ធាតុ ក្នុងគម្ពីរបដិសម្ភិទាមគ្គ (ទំព័រ៦២) ថា* **ឧប្បាទំ មុញ្ចិតុ កម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ** *( បញ្ញាដែលត្រូវការនឹងបោះបង់ចោល កំណត់ដឹងទៀតហើយ ប្រងើយកន្តើយកើតឡើង ជា***សង្ខារុបេក្ខាញាណ** *។ សូម្បីគម្ពីរដីកា ក៏សម្តែងរូបវិគ្គហៈរបស់មុញ្ចិតុកម្យតាញាណថា :*

**មុញ្ចិតុំ ឥច្ឆតីតិ មុញ្ចិតុកម្យំ, ចិត្តំ បុគ្គលោ វា ។ តស្ស ភាវោ មុញ្ចិតុកម្យតា។ តទេវ ញាណំ មុញ្ចិតុកម្យតាញាណំ។**

*“ អ្នកដែលត្រូវការនឹងរួចផុតឈ្មោះថា* **មុញ្ចិតុកម្យ** *សំដៅសដល់ចិត្ត ឬបុគ្គលអ្នកជាអ្នកត្រូវការនឹងរួចផុត ហៅថា* **មុញ្ចិតុកម្យតា** *ភាវៈជាអ្នកត្រូវការនឹងរួចផុតយ៉ាងពិតប្រាកដ នេះជាញាណ ទើបបានឈ្មោះថា* **មុញ្ចិតុកម្យតា-ញាណ**”។

**មុញ្ចិតុំ កាមេតិ មុញ្ចិតុកាមំ, វិបស្សនាចិត្តំ ។ តំយេវ មុញ្ចិតុកម្យំ ។ តស្ស ភាវោ ។ សាយេវ ញាណន្តិ សមាសោ ។**

*គប្បីធ្វើសមាសថា សភាពដែលត្រូវការនឹងកំណត់ដឹង ឈ្មោះថា* “**មុញ្ចិតុកាមៈ** *សំដៅដល់វិបស្សនាចិត្ត សភាពដែលត្រូវការនឹងកំណត់ដឹង*

*នោះឯង ឈ្មោះថា* **មុញ្ចិតុកម្យៈ** *( ដោយចុះ* **ណ្យ** *បច្ច័យ ក្នុងសកត្ថតទ្ធិត )សេចក្ដីជាសភាវៈដែលត្រូវការនឹងកំណត់ដឹង ( ឈ្មោះថា* **មុញ្ចិតុកម្យតា** *) សេចក្ដីជាអ្នកត្រូវការនឹងកំណត់ដឹង នោះឯង ជា***ញាណ** *ទើបបានឈ្មោះថា* **មុញ្ចិតុកម្យតាញាណ** *) ក្នុងគម្ពីរវិសុទ្ធិមគ្គ ពោលដល់បដិសង្ខាញាណថា :-*

**សោ ឯវំ សព្វភវយោនិគតិឋិតិនិវាសគតេហិ សភេទកេហិ សង្ខារេហិ មុញ្ចិតុកាមោ សព្វស្មា សង្ខារគតា មុញ្ចិតុំ បុន តេ ឯវំ សង្ខារេ បដិសង្ខានុបស្សនាញាណេន តិលក្ខណំ អារោបេត្វា បរិគ្គណ្ហាតិ ។**

*"កុលបុត្រនោះ អ្នកប្រាថ្នា នឹងរួចផុតអំពីភព, កំណើត, គតិ វិញ្ញាណឋិតិ និងសត្តាវាស គ្រប់កន្លែងដូចពោលនោះ ទើបលើកសង្ខារនោះ ទុំះឯង ចូលកាន់ត្រៃលក្ខណ៍ ហើយកំណត់ដឹង ដោយបដិសង្ខានុបស្សនាញាណ តទៅទៀត ដើម្បីរួចផុតអំពីសង្ខារទាំងពួង"។*

*អ្នកដែលប្រាស់ចាកនូវការប្រកាន់មាំក្នុងសង្ខារ គឺរូបនាមថា ទៀងជាទុក្ខជាតួខ្លួនហើយ រមែងសម្រេចការរលត់សង្ខារ គឺនិព្វានបាន កាលមិនមានសេចក្ដីកង្វល់ ឬជាទុក្ខ ជាប់ដោយសង្ខារ ក្នុងខណៈនៅមានជីវិតរស់នៅ ក៏ចាត់ថាបានរួចផុតអំពីសង្ខារ ដោយមិនមានសេសសល់ ព្រោះមិនមានរូបនាមយ៉ាងណាមនិមួយប្រាកដក្នុងភព ៣ នោះ អ្នកដែល*

ប្រាថ្នានឹងរួចផុត អំពីសង្ខារ ទើបមិនមានវិធីដទៃ ក្រៅពីត្រូវតាមកំណត់ដឹង សង្ខារឲ្យឃើញច្បាស់ថា មិនទៀង ជាទុក្ខ មិនមែនតួខ្លួន ។

ដោយហេតុនោះ អ្នកដែលត្រូវការនឹងរួចផុតអំពីសង្ខារ ដោយ **មុញ្ចិតុកម្យតាញាណ** ទើបត្រឡប់មកកកំណត់ដឹងនូវសង្ខារទៀត ការកំណត់ដូចពោល ឈ្មោះថា **បដិសង្ខារញាណ** គឺបញ្ញាកំណត់ដឹងទៀត ដើម្បីលះបង់សង្ខារ ដោយលើកឡើង កាន់ព្រះត្រៃលក្ខណ៍ ដោយការឃើញច្បាស់លក្ខណៈ ៤០ យ៉ាងណានិមួយ ដែលប្រាកដច្បាស់បានដល់ អនិច្ចលក្ខណៈ ១០ ទុក្ខលក្ខណៈ ២៥ ពោលដោយសង្ខេប ជាការឃើញច្បាស់នូវត្រៃលក្ខណ៍ គឺការមិនទៀង ជាទុក្ខ មិនមែនជាតួខ្លួន ។

**លក្ខណៈ ៤០ យ៉ាងខាងដើម បែកចែញជា :**

## (ក) អនិច្ចលក្ខណៈ ១០ យ៉ាង

**១-មិនទៀង** ( អនិច្ចំ ) គឺឃើញច្បាស់ថាកើតឡើង ហើយរលត់ទៅ ។

**២-បែកធ្លាយ**ទៅដោយការចាស់ ការឈឺ និង ការស្លាប់ ( បរលោក ) **គឺឃើញច្បាស់**ថា រូបនាម ដែលកំណត់ដឹង បែកធ្លាយ ទៅភ្លាមក្នុងខណៈនោះ ដូចជាប្រាំងខ្សាចបែកធ្លាយ កាលបើត្រូវទឹកបក់បោក ឬដូចជាក្រដាស់ដែលត្រូវខ្ចាត់ខ្ចាយ, ដូចគំនរភ្លើង ដែលធ្លាក់ចុះទៅមួយរំពេច កាលបើត្រូវចាក់ទឹកដាក់ ឬដូចជា ផ្សែងភ្លើងដែលបាត់ទៅមួយរំពេច កាលបើត្រូវខ្យល់បក់ ។

៣- កម្រើកផ្លាស់ប្តូរ ដោយការចាស់ ឈឺ ស្លាប់ ( ចល ) គឺឃើញច្បាស់ថា រូបនាមមិនបានតាំងនៅយឺនយូរ ប្រែប្រួលដោយការកើតរលត់ជានិច្ច ។

៤-បែកធ្លាយទៅរហ័ស ( បភង្គុ ) គឺ ឃើញច្បាស់ថា រូបនាមរលត់ទៅមុននឹងកំណត់ដឹងទៀត ។

៥-មិនយឺនយូរ ( អធុវ ) គឺឃើញច្បាស់ថា រូបនាមរលត់ទៅរឿយៗ មិនយឺនយូរ ។

៦-មានសេចក្តីប្រែប្រួលជាធម្មតា ដោយការមិនតាំងនៅ ក្នុងសភាពដើម ដោយការចាស់ ឈឺ និងស្លាប់ ( វិបរិណាមធម្ម ) គឺឃើញច្បាស់រូបនាមមានសភាព មិនដូចដើម ដែលចាប់ផ្តើមនឹងកើតឡើងដោយការប្រែប្រួលរលត់ទៅវិញ ។

៧-មិនមានខ្លឹមសារ ( អសារក ) គឺឃើញច្បាស់ថា រូបនាម មិនមានខ្លឹមសារ ដែលគួរប្រកាន់មាំថា ជាយើង ជារបស់យើង ។

៨-ប្រាសចាកសេចក្តីចម្រើន ( វិភវ ) គឺក្នុងវេលាមុនការបដិបត្តិធម៌ នឹងមិនអាចបែកសន្តតិបញ្ញត្តិ ( បញ្ញត្តិដែលអាស្រ័យតំណរ ) **ឃនបញ្ញត្តិ** ( បញ្ញត្តិដែលអាស្រ័យក្រុម ឬដុំ ) ចេញពី រូបនាមបានបុគ្គលរមែងយល់ថា រាងកាយ និងចិត្តរបស់ខ្លួន ប្រព្រឹត្តមកតាំងតែពីវ័យក្មេង សន្សើមៗ ធំធាត់រហូតដល់បច្ចុប្បន្ន ដូចជាដើមឈើដែលកើតពី

គ្រាប់ពូជ ហើយធំធាត់បែកមែកធាង ចេញទៅ តែបើគេអាចចែករូបនាម ចេញពីបញ្ញត្តិបាន គេរមែងយល់ថា សភាវធម៌ផ្លូវកាយ និងចិត្ត ដែលកើតឡើងមុន មិនដូចនឹងសភាវធម៌ ដែលកើតពីសភាវធម៌ ដែលកើតឡើងមុន មិនមានរូបនាម កាលបើកើតឡើងហើយមិនបានតាំងនៅយូរ ក៏រលត់ទៅវិញ សូម្បីដែលកើតមក ក៏បានកើតមកពីសភាវធម៌ ដែលកើតមុន មិនមានរូបនាមណាៗ ដែលបន្តពីរូបនាមមុនឡើយ ។

៩-ត្រូវបច្ច័យតាក់តែង ដោយអំណាច **កម្ម ចិត្ត ឧតុ** និង **អាហារ** ( សង្ខត ) គឺឃើញ ច្បាស់ថា រូបនាមកើតឡើង កាលបើមានបច្ច័យបរិបូណ៌ ។

១០- មានការបែកធ្លាយ ជាធម្មតា ( មរណធម្ម ) គឺ ឃើញថា រូបនាមរលត់ទៅរឿយៗ ។

ក្នុងគម្ពីរបដិសម្ភិទាមគ្គ ពោលដល់**អនិច្ចលក្ខណៈ ១០** ខាងដើម ទុកតាមលំដាប់ក្នុងគម្ពីរអដ្ឋកថា នៅសម្តែងអនិច្ចលក្ខណៈ ៣ ប្រការ ទៀត ដែលរាប់បញ្ចូលក្នុងលក្ខណៈ **១**ដំបូង ក្នុងលក្ខណៈទាំង ១០ យ៉ាង គឺ :

១-មិនកន្ទង់ផុតពីទីបំផុត គឺមិនស្ថិតស្ថេរ យឺនយូរ ( អនច្ចន្តិក ) ។

២-តាំងនៅមួយខណៈ ( តាវកាលិកៈ ) ។

៣- នៅក្នុងអំណាចរបស់ការកើតរលត់ គឺ នៅរវាងនៃការកើត និងការរលត់ទៅ កាលបើកើតឡើងហើយ រមែងរលត់ទៅវិញ មិនមាន

នៅមុនកើតឡើង ឬក្រោយរលត់ទៅ ( ឧប្បាទវយបរិច្ឆិន្នេ ) ។

**(ខ) ទុក្ខលក្ខណៈមាន ២៥ យ៉ាង គឺ :**

១-ជាទុក្ខ មិនមែនសុខមាំមួន ( ទុក្ខ ) ។

២-ជារោគ ដែលចាក់ដោតរឿយៗ ( រោគ ) ។

៣- ជាបូស ( គណ្ឌ ) ព្រោះមានការឈឺចុកចាប់ គឺ ការអត់ធន់បានដោយលំបាក សេចក្ដីមិនទៀង និងការប្រែប្រួល មានន័យថា រូបនាមដែលកំណាត់ដឹងបានកើតឡើងហើយ តាំងនៅមួយខណៈ ហើយរលត់ទៅ ដូចជាបូស ដែលហើមឡើងជាដំបៅ មានខ្ទុះនៅខាងក្នុង ហើយបែកចេញទៅ ឬមានអាការជាបូសព្រោះហូរទឹកខ្ទុះ គឺ កិលេស ។

៤-ជាសរចាក់ ( សល្ល ) ព្រោះដោតរហូតអត់ធន់បានដោយលំបាក បៀតបៀននៅខាងក្នុងរាងកាយ និងចិត្ត នឹងដកចេញ បានដោយលំបាក ។

៥-ជាការអាក្រក់ថោកទាប (អឃ ) ដូចបាបព្រោះអរិយៈ តិះដៀលញ៉ាំងឲ្យមានទោស និងជាជាទីតាំងនៃបាបផ្សេងៗ ។

៦-ជាឫសគល់នៃសេចក្ដីអាក្រក់ថោកទាប ( អឃមូល ) ។

៧-ជាការឈឺ (អាពាធ) ព្រោះបៀតបៀន មិនឲ្យជាឥស្សរៈតាមតម្រូវការរបស់ខ្លួន ឬជាហេតុជិតនាំឲ្យកើតរោគផ្សេងៗ ។

៨-ជាការបំផ្លាញ ( ឦតិ ) ព្រោះបង្កឲ្យកើតការបំផ្លាញនៃ

ញាតិជាដើម ។

៩-ជាឧបទ្ទវ ( ឧបទ្ទវ ) ព្រោះញុំាងឲ្យកើតទោស ដ៏ធំមួយរំពេច ដូចជាការបៀតបៀនរបស់ព្រះរាជាជាដើម ។

១០-ជាភ័យដែលគួរឲ្យខ្លាច ( ភយ ) ព្រោះដូចជាភ័យខាងក្នុងជាការញុំាងកើតភ័យផ្សេងៗ មានសភាពផ្ទុយគ្នាជាមួយ នឹងព្រះនិព្វានដែលរួចអំពីភ័យទាំងឡាយទាំងពួង ។

១១- ជាឧបសគ្គ ( ឧបសគ្គ ) គឺជាវត្ថុដែលរារាំង ខាងក្នុងមានការបំផ្លាញរបស់ពពួកញាតិជាដើម និងជាវត្ថុរារាំងខាងក្រៅ មានរោគ ជាដើម ។

១២-មិនជាទីទប់ទល់ ( អតាណា ) គឺមិនអាចទប់ទល់នូវឧបសគ្គ និងអន្តរាយផ្សេងៗ បានទេ ។

១៣-មិនជាទីជ្រក់ពួន ( អលេណ ) គឺមិនអាចជ្រកអំពីភ័យ បានផ្សេងៗ បាណទេ ។

១៤- មិនជាទីពឹង ( អសរណា ) គឺអាចពឹងពាក់អាស្រ័យ បានឲ្យផុតពីទុក្ខភ័យ អន្តរាយផ្សេងៗ បានទេ ពោលគឺ សូម្បីនឹង ជារូបនាមដែលល្អលើសត្រឹមណា ក៏មិនាអាចរលត់ទុក្ខភ័យបាន ទេ សង្ខារ គឺរូបនាមទាំងអស់ ទើបមិនជាទីទប់ទល់ មិនជាទីជ្រក កោន ពួនអាស្រ័យនឹងបានឡើយ ។

១៥-ជាទោស ( អាទីនវ ) គឺ គ្រាំគ្រា មិនគួរត្រេកអរ ព្រោះមិនទៀង ប្រែប្រួល នឹងជាទុក្ខរឿយៗ ។

១៦-ជាពេជ្ឈាត ( វធក ) ព្រោះពពួកសត្វស្លាប់រឿយៗ កាលបើរូបនាមរលត់ទៅគ្រប់ៗ ខណៈ ។

១៧-ជាអារម្មណ៍របស់អាសវៈ ( អាសវ ) ។

១៨-ជាចំណីរបស់មារ ( មារាមិស ) គឺដូចជាចំណីរបស់កិលេស ។

១៩-មានការកើតជាធម្មតា ( ជាតិធម្ម ) ។

២០- មានការចាស់ជាធម្មតា (ជរាធម្ម ) ។

២១- មានការឈឺជាធម្មតា ( ព្យាធិធម្ម ) ។

២២- មានសេចក្តីសោក ជាធម្មតា ( សោកធម្ម ) ។

២៣- មានសេចក្តីខ្សឹកខ្សួលជាធម្មតា (បរិទេវធម្ម ) ។

២៤ មានការចង្អៀតចង្អល់ជាធម្មតា ( ឧបាយាសធម្ម ) ។

២៥. មានការសៅហ្មងជាធម្មតា ( សំកិលេសធម្ម ) គឺ ឃើញច្បាស់ថា រូបនាមជាអារម្មណ៍របស់កិលេសដ៏សៅហ្មង ឬជាទីមិនស្អាតរបស់កិលេស ។

ក្នុងគម្ពីរបដិសម្ភិទាមគ្គ ពោលដលលក្ខណៈ ២៥ ខាងដើម ទុកតាមលំដាប់ក្នុងគម្ពីរអដ្ឋកថានៅសម្ដែងលក្ខណៈទុក ៣ ប្រការទៀត ដែលរាប់

បញ្ចូលក្នុងលក្ខណៈខាងដើម គឺៈ

១. ជាវត្ថុ ដែលត្រូវការកើតរលត់បៀតបៀនរឿយៗ (អភិណ្ហសម្ប-ដិបីឡន ) ។

២. ជាវត្ថុ ដែលទ្រាំបានដោយលំបាក ( ទុក្ខម ) ។

៣. ជាទីតាំងរបស់ទុក្ខ ( ទុក្ខវត្ថុ ) ។

ក្នុងខណៈដែលសម្រេច**សម្មសនញាណ** និង **បដិសង្ខាញាណ**យ៉ាងទន់ខ្សី អ្នកបដិបត្តិធម៌ រមែងប្រឈមមុខជាមួយនឹងទុក្ខ ដែលជាក់ច្បាស់ ដោយមានលក្ខណៈ ដែលទ្រាំបានដោយលំបាក ( ទុក្ខម ) ជាទីតាំងរបស់ទុក្ខ ( ទុក្ខវត្ថុ) ជារោគ ដែលចាក់ដោតរឿយៗ ( រោគ ) ជាបូស ( គណ្ឌ ) ជាសរ ( សល្ល ) ជាសភាវៈអាក្រក់ថោកទាប ( អឃ ) ជាឫសគល់នៃសេចក្តីអាក្រក់ ( អឃមូល ) ជាការឈឺ ( អាពាធ ) ជាដើម ដូច្នោះ ក្នុងគម្ពីរវិសុទ្ធិមគ្គ ទើបពោលដល់លក្ខណៈទាំងនេះទុកទាំងក្នុង**សម្មសនញាណ** និង**បដិសង្ខាញាណ**, ញាណទាំងពីរនេះ មានសេចក្តីផ្សេងគ្នា គឺអ្នកបដិបត្តិធម៌ មិនអាចកំណត់ដឹងទុក្ខ ឲ្យរលត់យ៉ាងឆាប់រហ័ស ក្នុងសម្មសនញាណទេ ប៉ុន្តែក្នុងបដិសង្ខាញាណនឹងអាចកំណត់ដឹងបាន ពេលរលត់មួយរំពេចនោះ ។

## អនត្តលក្ខណៈ ៥ យ៉ាង គឺ :

១. ជាវត្ថុមិនមែនតួខ្លួន ( អនត្ត ) គឺត្រឹមតែជាសភាវធម៌ ដែលប្រព្រឹត្តទៅតាមហេតុបច្ច័យ មិនមែនតួខ្លួន ជាធំដែលស្ថិតស្ថេរ នៅជានិច្ច និងធ្វើអាកប្បកិរិយា ដើរជាដើម ឬ ជាអ្នកសោយផលកម្ម ឃុំឃាំងរាងកាយ ឬ នៅក្នុងអំណាចរបស់ខ្លួន ។

២. ជារបស់អ្នកដទៃ ( បរ ) ព្រោះមិនប្រព្រឹត្តទៅតាម ដែលខ្លួនត្រូវការ សូម្បីត្រូវការរារាំងកុំឲ្យចាស់ ឬ កុំស្លាប់ ក៏មិនអាចធ្វើបាន ។

៣. ជាវត្ថុទទេ ( រិត្ត ) ព្រោះមិននៅជដែល មិនមានសេចក្តីសុខមាំមួន មិនល្អ ស្អាត និង មិនមែនតួខ្លួន ។

៤. ជាវត្ថុដែលទំនេរ ( តុច្ឆ ) គឺជាសភាវធម៌ ដែលទំនេរសូន្យចាកតួខ្លួនយើង របស់យើង ។

៥. ជារបស់សូន្យ ( សុញ្ញ ) គឺជាសភាវធម៌ ដែលមិនមែនអត្តា ឬ វិញ្ញាណ ដែលយល់ខុសគ្នាថា ជាកាយទិព្វ ដែលនៅក្នុងរាងកាយ ។

ក្នុងគម្ពីរបដិសម្ភិទាមគ្គ ពោលដល់អនត្តលក្ខណៈ ៥ ខាងដើមទុកតាមលំដាប់ និង ក្នុងគម្ពីរអដ្ឋកថា នៅសម្តែងអនត្តលក្ខណៈទុក ៣ ប្រការទៀត ដែលរាប់ចូល ក្នុងលក្ខណៈខាងដើម គឺ:

១. មិនមានម្ចាស់របស់ ( អស្សាមិក ) គឺជាសភាវធម៌ ដែលកើតតាមហេតុបច្ច័យ មិននៅក្នុងអំណាចរបស់អ្នកណា ឬ វត្ថុណា ។

២. មិនមានអ្នកជាធំ ( អនិស្សរ) គឺជាសភាវធម៌ ដែលមិនមាន អ្នកណាអាចបង្គាប់បញ្ជាបាន ។

៣. មិនប្រព្រឹត្តទៅតាមសេចក្ដីត្រូវការ ( អវសវត្តិ ) គឺជាសភាវធម៌ ដែលសូម្បីចង់នឹង ឲ្យស្ថិតនៅរហូតទៅ ក៏មិនប្រព្រឹត្តទៅតាមដែលបុគ្គល ត្រូវការ ។

អនិច្ចលក្ខណៈជាដើម ទាំង ៤០ នេះ បោរាណាចារ្យអ្នកស្រុកកូមា ហៅថា ធំ ៤០ ព្រោះត្រាស់ទុក ដោយបទ ដែលចុះ **តោ** បច្ច័យថា **អនិច្ចតោ ទុក្ខតោ** ជាដើម និងនៅហៅថា **វិបស្សនា ៤០** ដែលឃើញច្បាស់ រូបនាម ដោយលក្ខណៈទាំងនោះ អ្នកដែលសិក្សាគោលធម៌ មិនងាយ អាចដឹងច្បាស់លក្ខណៈនោះ ត្រឹមបន្តិចបន្តួច តែអ្នកដែលសិក្សាគោលធម៌ មកពីមុន នឹងមានបញ្ញាច្រើន អាចដឹងច្បាស់បានច្រើន ។

ម្យ៉ាងទៀត លក្ខណៈខាងដើម រមែងប្រាកដច្បាស់ក្នុងវិបស្សនា របស់មគ្គថ្នាក់ខ្ពស់ តែក្នុងវិបស្សនារបស់មគ្គខាងដើម ក៏កើតឡើងបានខ្លះ ពោលគឺ បុគ្គលដែលឃើញច្បាស់អនិច្ចលក្ខណៈយ៉ាងណាមួយ ដោយ វុឌ្ឍានគាមិនីវិបស្សនាហើយ រមែងសម្រេចមគ្គញាណ បន្ទាប់ពីនោះ ការ បានឃើញច្បាស់លក្ខណៈយ៉ាងណាមួយ ទើបរាប់ថា បរិបូណ៌ហើយ ព្រោះ ធ្វើឲ្យសម្រេចមគ្គញាណបាន ដូចសេចក្ដីក្នុងគម្ពីរ បដិសម្ភិទាមគ្គថា :

[១] បញ្ចក្ខន្ធេ អនិច្ចតោ បស្សន្តោ អនុលោមិកំ ខន្តិ បដិលភតិ ។ [២] បញ្ចន្នំ ខន្ធានំ និរោធោ និច្ចំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ ។

*“១. អ្នកឃើញច្បាស់ខន្ធ ៥ ថាមិនទៀង រមែងសម្រេចវិបស្សនាញាណ ដែលស្របតាមមគ្គញាណក្នុងថ្នាក់ទាបពីសោតាបត្តិមគ្គ ។*

*២. អ្នកដែលឃើញច្បាស់ថា ការរលត់របស់ខន្ធ ៥ ជានិព្វាន ដែលទៀង រមែងចុះកាន់សម្មត្តនិយាម( គឺសោតាបត្តិមគ្គ )” ។*

*អ្នកចម្រើនវិបស្សនាខ្លះ សម្រេចបដិសង្ខាញាណហើយ មានសេចក្តីចាស់ក្លាមួយរំពេច អ្នកខ្លះ អាចត្រូវប្រើរយៈពេលមួយថ្ងៃ មួយយប់ខ្លះ ពីរបីថ្ងៃខ្លះ កាលញាណនៅមិនទាន់ចាស់ក្លា សូម្បីនឹងកំណត់ដឹងបានល្អ ក៏នៅតែមានការត្រិះរិះថា ដូចជាមិនល្អ ព្រោះថា រូបនាមមិនគួរត្រេកអរ និងនៅតែមិនអាចកំណត់បានរឿយៗ ដូចក្នុងសង្ខារុបេក្ខាញាណ បន្ទាប់ពីញាណនេះ ចាស់ក្លាហើយ ទើបដឹងច្បាស់ថា កំណត់បានល្អ ជាដើម លក្ខណៈដូចនេះ ស្រដៀងគ្នានឹងឧទយព្វយញាណ និងភង្គញាណ ពោលគឺក្នុងឧទយព្វយញាណលំដាប់ទន់ខ្ចី រមែងច្របូកច្របល់ដោយឧបក្កិលេស ចំណែកឧទយព្វយញាណ ដែលចាស់ក្លាហើយ រមែងមិនច្របូកច្របល់ដោយឧបក្កិលេស ក្នុងទំនងដូចគ្នា ភង្គញាណលំដាប់ទន់ខ្ចី មិនអាចដឹងច្បាស់ការរលត់បានជាក់ច្បាស់ ចំណែកភង្គញាណលំដាប់ចាស់ក្លា រមែង*

ដឹងច្បាស់នូវការរលត់បានជាក់ច្បាស់ ។

កាលបដិសង្ខាញាណចាស់ក្លាហើយ អ្នកបដិបត្តិធម៌ រមែងសម្រេចវិបស្សនាញាណទី ១០ ឈ្មោះថា សង្ខារុបេក្ខាញាណ គឺ បញ្ញាព្រងើយក្នុងសង្ខារ មានន័យថា គេមិនត្រូវផ្តោតអារម្មណ៍ឲ្យឃើញច្បាស់ការរលត់ ឬការមិនទៀង ជាទុក្ខ មិនមែនតួ ខ្លួនរបស់រូបនាម តែអាចកំណត់ដឹងបានដោយខ្លួនឯងតាមធម្មជាតិ ដោយមិនដឹងច្បាស់ថា មានតួខ្លួន អ្នកកំណត់ដឹងនិង អាចឃើញច្បាស់ការរលត់ ឬ ការមិនទៀង ជាដើម យ៉ាងណាមួយបានជាក់ច្បាស់គ្រប់ខណៈ ដូចសេចក្តីពោលថា:

សង្ខារេ សង្ខារេ វិបស្សន្តិ ។

"សង្ខារនោះឯង ឃើញច្បាស់ក្នុងសង្ខារ" ។

អ្នកដែលសម្រេចសង្ខារុបេក្ខាញាណហើយ រមែងមិនឃើញច្បាស់សេចក្តីខ្លាចទោស សេចក្តីនឿយណាយ សេចក្តីត្រូវការនឹងរួចផុត ឬសេចក្តីដឹងច្បាស់ថា មិនគួរត្រេកអរ ដូចក្នុងវិបស្សនាញាណមុន តែនឹងជួបថា ចិត្តរបស់ខ្លួនបរិសុទ្ធស្អាត និង បានទទួលសុខ ដែលមិនធ្លាប់ដឹងមកពីមុន និង ប្រាសចាកសេចក្តីជាប់ចិត្តក្នុង សុខ ដូចក្នុងខណៈផ្តើមកើតឧទយព្វយញាណ មានត្រឹមសតិ ដែលកំណត់ដឹងដ៏ស្ងប់ ប្រណិតកើតឡើង យ៉ាងបន្តបន្ទាប់អស់កាលយូរ និង ក្នុងខណៈនោះ មិនចាំបាច់ត្រូវផ្តោតអារម្មណ៍ច្រើន ក៏អាចបម្រើនសតិដឹងទាន់បាន មិនមានជាប់ចន្លោះ

*ដូចក្នុងគម្ពីរវិសុទ្ធិមគ្គពោលថា:*

**[១]** ឯវមេវាយំ សព្វសង្ខារេហិ មុញ្ចិតុកាមោ ហុត្វា បដិសង្ខានុបស្សនាយ សង្ខារេ បដិគ្គណ្ហន្តោ " អហំ មមា" តិ គហេតព្វំ អទិស្វា ភយញ្ច នន្ទិញ្ច វិប្បហាយ សព្វសង្ខារេសុ ឧទាសីនោ ហោតិ មជ្ឈត្តោ ។

**[២]** តស្ស ឯវំ ជានតោ ឯវំ បស្សតោ តីសុ ភវេសុ ចតូសុ យោនីសុ បញ្ចសុ គតីសុ សត្តសុ វិញ្ញាណដ្ឋិតីសុ នវសុ សត្តាវាសេសុ ចិត្តំ បតិលីយតិ បតិកុដតិ បតិវត្តតិ ន សម្បសារិយតិ ។ ឧបេក្ខា វា បាដិកុល្យតា វា សណ្ឋាតិ ។បេ។

*"១. អ្នកបដិបត្តិធម៌នេះ ក៏ដូចជាបុរស ដែលលះប្រពន្ធដាច់ហើយ មានអារម្មណ៍ព្រងើយៗ កាលបានជួបឬឃើញ ជាអ្នកត្រូវការនឹងរួចផុតពីសង្ខារ ទើបកំណត់ដឹងសង្ខារ ដោយបដិសង្ខានុបស្សនាញាណ មិនឃើញវត្ថុដែលគួរកាន់យកថា ជាយើង របស់យើង លះបង់សេចក្តីខ្លាច និងសេចក្តីពេញចិត្តបានហើយ ជាអ្នកព្រងើយ មានចិត្តជាកណ្តាលក្នុងសង្ខារទាំងពួង ។*

*២. កាលគេឃើញច្បាស់យ៉ាងនេះ ចិត្តក៏ថយត្រឡប់ រួញត្រឡប់ មិនបែកខ្ញាយទៅក្នុងភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧*

សត្តាវាស ៩ នៅព្រងើយ ឬ ថយត្រឡប់មកតាំងនៅមាំ ។ ល ។

៣. ដោយប្រការដូចនេះ វិបស្សនាញាណ ឈ្មោះថា សង្ខារុបេក្ខាញាណបានកើតឡើងដល់អ្នកបដិបត្តិធម៌នោះ ” ។

ក្រៅពីនេះ ក្នុងគម្ពីរវិសុទ្ធិមគ្គ ពោលដល់ការប្រាកដនៃសង្ខារុបេក្ខាញាណ ដោយការឃើញច្បាស់នូវការព្រងើយដោយលក្ខណៈ ២ យ៉ាង ( ទ្វិកោដិក ) លក្ខណៈ ៤ យ៉ាង ( **ចតុក្កោដិក** ) ជាដើមទៀត មានរាយល្អិតល្អន់ដូចតទៅនេះ ។

ការឃើញច្បាស់សេចក្តីព្រងើយ ដោយអង្គ ២ ស្របតាមព្រះសូត្រក្នុងគម្ពីរមជ្ឈិមនិកាយថា:

បុន ច បរំ ភិក្ខវេ អរិយសាវកោ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ សុញ្ញមិទំ អត្តេន វា អត្តនិយេន វាតិ ។

“ម្នាលភិក្ខុទាំងឡាយ ប្រការដទៃនៅមានទៀត អរិយសាវកនៅក្នុងព្រៃក្តី នៅត្រង់គល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី រមែងឃើញច្បាស់ដូច្នេះថា រូបនាមនេះ សូន្យចាក ភាពជាខ្លួន ឬ ភាពជារបស់ខ្លួន” ។

---

[ពាក្យថា អត្តេន ប្រែថា “ភាពជាខ្លួន” អត្តនិយេន ប្រែថា “ភាពជារបស់ខ្លួន” តាមគោល ភាសាឲ្យបុះ **ត្ត** បច្ច័យ ក្នុងភាវតទ្ធិតហើយលុបដោយសូត្រក្នុងមោគ្គល្លានវេយ្យាករណ៍ ( បរិច្ឆេទទី ៤ សូត្រ ១២៣ ) ថា លោបោ ( លុបតទ្ធិតបច្ច័យ ) ដូចពាក្យថា **រតនំ** ( ភាពជារតនៈ ) មកពី **រតនត្ត** ដូចសេចក្តីក្នុងមោគ្គល្លានវេយ្យាករណ៍ថា

ពុទ្ធេ រតនំ បណីតំ, ចក្ខុំ សុញ្ញំ អត្តេន វា អត្តនិយេន វាតិ ភវប្បច្ចយលោចោ *“លុប ការបច្ច័យក្នុងឧទាហរណ៍ថា* ពុទ្ធេ រតនំ បណីតំ *( ភាពជារតនៈ ដ៏ប្រណិត ក្នុងព្រះសម្ពុទ្ធ )* ចក្ខុំ សុញ្ញំ អត្តេន វា អត្តនិយេន វា *( ចក្ខុសូន្យចាក ភាពជាខ្លួន ឬ សេចក្តីជា របស់ខ្លួន )”*។

*ពាក្យអធិប្បាយខាងដើម ពោលតាមគម្ពីរអដ្ឋកថារបស់ខុទ្ទកបាឋៈ ថា*

***[១]*** ចក្ខុ ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វាតិ ឯវមាទីសុ អត្តភាវេន វា អត្តនិយភាវេន វា វាតិ អត្ថោ ។ ***[២]*** ឥតរថា ហិ ចក្ខុ អត្តា វា អត្តនិយំ វាតិ អប្បដិនិសិទ្ធមេវ សិយា ។

*“១. ប្រយោគនេះ មានន័យថា* ចក្ខុ ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា *( ម្នាលអានន្ទ ចក្ខុសូន្យចាកភាពជាខ្លួន ) ជាដើម មានន័យថា ( សូន្យទទេ ) ចាកភាព ជាខ្លួន ឬ ភាពជារបស់ខ្លួន ។*

*២. មិនដូច្នោះហើយ មិនអាចជំទាស់ថា ចក្ខុជាខ្លួន ឬ ជារបស់ខ្លួន” ]*។

*អ្នកបដិបត្តិធម៌ រមែងឃើញច្បាស់ក្នុងខណៈកំណត់ដឹង ឬ អនុមានដឹង ដោយការពិចារណាថា រូបនាមសូន្យចាកភាពជាខ្លួន គឺការប្រព្រឹត្តទៅតាមសេចក្តីត្រូវការ ឬ សូន្យចាកភាពជារបស់ខ្លួន គឺ ត្រឹមតែជាសភាវធម៌ដែលមិនជាប់ដោយខ្លួន ការឃើញច្បាស់ថា រូបនាមសូន្យចាកភាពជារបស់ខ្លួននឹងប្រាកដបាន ក៏បន្ទាប់ពីយល់ថា រូបនាមសូន្យចាកភាពជាខ្លួន និងកាលអ្នកបដិបត្តិធម៌ យល់ថា រូបនាមសូន្យចាកភាពជាខ្លួន ក៏មិនសម្គាល់ថា រូបនាមជារបស់ខ្លួន ដូច្នោះ អ្នកដែលយល់ថា មិនមែន យើង មិនមែនរបស់យើង ទើបជាការកំណត់ដឹងរូបនាម ដោយវិធី**ទ្វិកោដិ***

គឺមានលក្ខណៈ ២ យ៉ាង ។

ការឃើញច្បាស់សេចក្ដីសូន្យទទេ ដោយលក្ខណៈ ៤ យ៉ាង ( **ចតុក្កោដិក** ) ស្របតាមព្រះសូត្រក្នុងគម្ពីរមជ្ឈិមនិកាយថា:

**បុន ច បរំ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ នាហំ ក្វចនិ កស្សចិ កិញ្ចនតស្មិំ, ន ច មម ក្វចនិ កិស្មិញ្ចិ កិញ្ចនតត្ថីតិ។**

“ម្នាលភិក្ខុទាំងឡាយ ប្រការដទៃនៅមានទៀត អរិយសាវករមែងដឹងច្បាស់ ដូច្នេះថា :

១. យើងមិនមាននៅក្នុងទីណាៗ

២. យើងមិនមែននៅក្នុងការកង្វល់របស់នរណាៗ

៣. បុគ្គលដទៃមិនមាននៅក្នុងទីណាៗ

៤. បុគ្គលដទៃមិននៅក្នុងសេចក្ដីកង្វល់របស់យើង” ។

សេចក្ដីខាងដើម មានពាក្យអធិប្បាយតាមលំដាប់ដូច្នេះ

១. យើងមិនមាននៅក្នុងទីណាៗ ( នាហំ ក្វចនិ ) គឺ អ្នកបដិបត្តិធម៌រមែងមិនឃើញខ្លួនក្នុងទីណាៗ ពោលគឺ អ្នកដែលឃើញច្បាស់ការរលត់របស់រូបនាមក្នុងបច្ចុប្បន្នខណៈហើយ រមែងមិនជួបអត្តា ដែលប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនបាន ទើបយល់បានថា អត្តា ដែលសំគាល់ថាជាយើងនោះ មិនមាននៅក្នុងទីកន្លែងណា គឺ ខាងក្នុង ឬ ខាងក្រៅរាងកាយក្នុងរូប ឬ នាម ក្នុងអាកប្បកិរិយាតាមផ្លូវកាយ ដូចជា ការដើរ ឈរ

អត្ថិយ ដេក បត់ លា ឬ ក្នុងសភាវធម៌តាមផ្លូវចិត្ត ដូច ការឃើញ បានឮ និង មិនមានអត្តារបស់យើងក្នុងកាលណា ទាំងដែលជាអតីត អនាគត ឬ បច្ចុប្បន្ន ។

២. យើងមិននៅក្នុងការកង្វល់របស់នរណាៗ ( **ន កស្សចិ កិញ្ចនតស្មិំ** ) គឺគេ រមែងមិនឃើញអត្តា របស់ខ្លួន ដែលគួរនៅក្នុងការ កង្វល់របស់អ្នកណា ពោលគឺ អ្នកដែលឃើញច្បាស់នូវការរលត់របស់ រូបនាមដោយជាក់ច្បាស់ ឬ ដោយអនុមានដឹង ក្រោយអំពីឃើញច្បាស់ ដោយប្រចក្សហើយ រមែងយល់បានថា មានត្រឹមតែជាសភាវធម៌ ដែល រលត់ទៅយ៉ាងនេះ មិនមានអត្តាតួខ្លួន បុគ្គល យើង របស់យើង ផ្សេងពី កាលមុន ដែលឃើញដូចនេះ ទើបសម្គាល់ថា ញាតិ បងប្អូន ព្រួយ បារម្ភអំពីខ្លួនយើងក្នុងឋានៈ ដែលជាបិតា បុត្រ ឬ បងប្អូន ពិតហើយ មិនមានអត្តាតួខ្លួនពិត ដែលបុគ្គលទាំងនោះព្រួយបារម្ភឡើយ ម្យ៉ាងទៀត គឺវត្ថុដែលគិតថា ជាខ្លួនយើងនេះ មិនបានទាក់ទងនឹងបុគ្គលដទៃឡើយ ។

៣. បុគ្គលដទៃមិនមាននៅក្នុងទីណាៗ ( **ន ក្វចនិ** ) គឺ គេរមែងមិន ឃើញអត្តា របស់បុគ្គលដទៃ ពោលគឺ ក្នុងខណៈដែលគេឃើញរូប ឬ បានឮសម្លេងរបស់បុគ្គលដទៃ ហើយកំណត់ដឹង ឬក៏អនុមានដឹងតាម ការកំណត់ដឹងនោះ រមែងយល់បានថា អត្តា ដែលសម្គាល់ថា ជាបុគ្គលដទៃ មិនមានក្នុងទីកន្លែងណា មិនថាខាងក្នុង ឬខាងក្រៅរាងកាយ រូប ឬ នាម មិនមានក្នុងរូប ដែលឃើញ ឬ ក្នុងសម្លេង ដែលបានឮ ។ល។ និងមិនមាន

*អត្តា របស់បុគ្គលដទៃក្នុងកាលណា ទាំងដែលជាអតីត អនាគត ឬ បច្ចុប្បន្ន ។*

*៤. បុគ្គលដទៃមិននៅក្នុងសេចក្ដីកង្វល់ របស់យើង (* **ន មម កិស្មិញ្ចិ កិញ្ចនតត្ថិ** *) គឺ គេរមែងមិនឃើញអត្តា របស់អ្នកដទៃ ដែលគួរនៅក្នុងសេចក្ដីកង្វល់របស់ខ្លួន ពោលគឺ គេរមែងយល់ថា មានត្រឹមសភាវធម៌ដែលរលត់ទៅយ៉ាងនេះ មិនមានអត្តាតួខ្លួន របស់បុគ្គលណា ដែលយើងគួរព្រួយបារម្ភហើយកង្វល់ ។*

*សរុបសេចក្ដីថា ការឃើញច្បាស់សេចក្ដីសូន្យទទេ ដោយលក្ខណៈ ៤ គឺ មិនមានយើង, មិនមានបុគ្គលដទៃ, មិនមានបុគ្គលដទៃដែលជាប់ទាក់ទងជាមួយនឹងយើង, និងមិនមានយើងដែលជាប់ទាក់ទងជាមួយនឹងបុគ្គលដទៃ។ ការឃើញច្បាស់សេចក្ដីដំបូង គឺ មិនមានយើងជាគោលសំខាន់ក្នុងរឿងនេះ ព្រោះកាលឃើញច្បាស់ថា មិនមានយើង ហើយទើបអាចឃើញច្បាស់លក្ខណៈតទៅបានដោយងាយថា មិនមានបុគ្គលដទៃ ដែលទាក់ទងជាមួយនឹងយើង និងមិនមានយើងដែលទាក់ទងនឹងបុគ្គលដទៃ ។*

*ការឃើញច្បាស់ភាពសូន្យទទេ ដោយលក្ខណៈ ៦ យ៉ាង (* **ឆអាការៈ** *) ស្របតាមគម្ពីរមហានិទ្ទេសថា:*

**ចក្ខុំ សុញ្ញំ អត្តេន វា អត្តនិយេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា។**

“ចក្ខុសុខុមប្រសាទ :

១. សភាពជាខ្លួន

២. សភាពជារបស់ខ្លួន

៣. សភាវៈទៀង

៤. សភាពយឺនយូរ

៥. សភាពគង់វង់

៦. សេចក្តីមិនប្រែប្រួលជាធម្មតា” ។

សេចក្តីនេះ មានន័យថា កាលអ្នកបដិបត្តិធម៌ ចម្រើនសតិរឭកដឹងសភាវៈ ឃើញក្នុងខណៈឃើញ ខណៈខ្លះ អាចយល់ថា ចក្ខុបសាទដែលជាទីអាស្រ័យរបស់ការឃើញ សុខុមប្រសាទភាពជាខ្លួន គឺមិនមែនតួខ្លួន សុខុមប្រសាទភាពជារបស់ខ្លួន គឺមិនមែនរបស់ខ្លួន សុខុមប្រសាទភាពទៀងគឺ មិនទៀង មិនយឺនយូរ មិនគង់វង់ មិនតាំងនៅ តាមសភាពដើម សូម្បីការទទួលដឹងក្នុងខណៈបានឮជាដើម ក៏ដូចគ្នាទៅនឹងក្នុងទ្វារដ៏សេសព្រមទាំងអារម្មណ៍, វិញ្ញាណ, ផស្សៈ និង វេទនាជាដើមទៅរហូតដល់ជរាមរណៈ ក្នុងន័យនេះដូចគ្នា ។

ម៉្យាងទៀត បទទាំង ៤ បទ គឺ **និច្ច** ( ភាពទៀង ) **ធុវ** ( ភាពយឺនយូរ ) **សស្សត** ( ភាពគង់វង់ ) និង **អវិបរិណាមធម្ម** ( សេចក្តីមិនប្រែប្រួលជាធម្មតា ) ជាពាក្យវេវចនៈ ដែលមានន័យដូចគ្នា ។

*ការឃើញច្បាស់នូវសេចក្តីព្រងើយ ដោយលក្ខណៈ ៨ យ៉ាង ( **អដ្ឋអាការ** ) ស្របតាមគម្ពីរមហានិទ្ទេសថា:*

***រូបំ អសារំ និស្សារំ សារាបគតំ និច្ចសារសារេន វា ធុវសារសារេន វា សុខសារសារេន វា អត្តសារាសារេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា ។***

*“រូបមិនមានខ្លឹមសារ រកខ្លឹមសារមិនបាន ប្រាសចាកខ្លឹមសារ*

*១. ដោយខ្លឹមសារ គឺ សារៈថា ទៀង*

*២. ដោយខ្លឹមសារ គឺ សារៈថា យឺនយូរ*

*៣. ដោយខ្លឹមសារ គឺ សារៈថា ជាសុខ*

*៤. ដោយខ្លឹមសារ គឺ សារៈថា ជាអត្តាតួខ្លួន*

*៥. ដោយភាពទៀង*

*៦. ដោយភាពយឺនយូរ*

*៧. ដោយភាពគង់វង់*

*៨. ដោយសេចក្តីមិនប្រែប្រួលជាធម្មតា ( មិនបាន )” ។*

*ការឃើញច្បាស់សភាពសូន្យទទេ ដោយលក្ខណៈ ៨ យ៉ាងរបស់នាមខន្ធ ៤ ទ្វារ អារម្មណ៍ វិញ្ញាណ ផស្ស វេទនាជាដើមទៅរហូតដល់ជរាមរណៈ ក៏ដូចគ្នានេះ ម្យ៉ាងទៀត បទទាំង ៦ បទ គឺ* **និច្ចសារៈ** *( ខ្លឹមសារ គឺសារៈថា ទៀង )* ធុវសារៈ *( ខ្លឹមសារ គឺ សារៈថា យឺនយូរ )*

និច្ច ( ភាពទៀង ) ធុវ ( ភាពយឺនយូរ ) សស្សត ( ភាពគង់វង់ ) និង **អវិបរិណាមធម្ម** ( សេចក្ដីមិនប្រែប្រួលជាធម្មតា ) ជាពាក្យវេវចនៈ ដែល មានន័យដូចគ្នា ។

ការឃើញច្បាស់សេចក្ដីសូន្យទទេ ដោយលក្ខណៈ ១០ យ៉ាង ( **ទសអាការ** ) ពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គថា :

**រូបំ រិត្តតោ បស្សតិ តុច្ឆតោ, សុញ្ញតោ, អនិស្សរិយតោ, អកាមការិយតោ, អលព្ភនីយតោ អវសវត្តនតោ, បរតោ, វិវិត្តតោ បស្សតិ ។**

"អ្នកបដិបត្តិធម៌ រមែងឃើញរូបថា

១. ជារបស់ទំនេរ ( ចាកសេចក្ដីទៀង សេចក្ដីសុខ សេចក្ដីព្រងើយ និង សេចក្ដីប្រព្រឹត្តទៅតាមសេចក្ដីត្រូវការមិនបាន ) ។

២. ជារបស់សោះទទេ ។

៣. ជារបស់សូន្យ ។

៤. ជារបស់មិនមែនតួខ្លួន ។

៥. មិនមានអ្នកជាធំ ។

៦.មិនមែនជារបស់ដែលគប្បីធ្វើបានតាមត្រូវការ ( ដូចនាំពពុះទឹកយកមកពូតធ្វើជាកែវមិនបាន ឬព្រោះកើតឡើងតាមហេតុបច្ច័យ មិនកើតតាម សេចក្ដីត្រូវការរបស់ខ្លួន ) ។

៧. ជារបស់ដែលមិនបានតាមសេចក្ដីត្រូវការ ។

៨. ជារបស់ដែលមិនប្រព្រឹត្តទៅតាមសេចក្ដីត្រូវការ ។

៩. ជាវត្ថុដទៃ ( គឺ បង្គាប់បញ្ជាមិនបាន ) ។

១០. ជារបស់ដែលបោះបង់ចោលអំពីហេតុហេតុ និង ផល ( គឺមិនមានផល ក្នុងហេតុ ដូចមិនមានកម្មក្នុងវិបាក ) ។

ការឃើញច្បាស់សេចក្ដីសូន្យទទេចាកតួខ្លួន ដោយលក្ខណៈ ១០ យ៉ាង របស់នាមខន្ធ ៤ មានវេទនាខន្ធជាដើម ក៏ន័យនេះដូចគ្នា ។

លក្ខណៈ ១០ យ៉ាង ដែលសម្ដែងទុកក្នុងគម្ពីរវិសុទ្ធិមគ្គនោះ ផ្សេងពីលក្ខណៈ ដែលប្រាកដក្នុងគម្ពីរបដិសម្ភិទាមគ្គ ដូចសេចក្ដីក្នុងគម្ពីរបដិសម្ភិទាថា:

**អបិច ទសហាការេហិ សុញ្ញតោ លោកំ អវេក្ខតិ រូបំ រិត្តតោ តុច្ឆតោ សុញ្ញតោ អនត្តតោ អសារកតោ វធកតោ វិភវតោ អឃមូលតោ សាសវតោ សង្ខតតោ អវេក្ខតិ ។**

“ម្យ៉ាងទៀត អ្នកបដិបត្តិធម៌ រមែងឃើញថា សូន្យទទេ ដោយលក្ខណៈ ១០ គឺ:

១. ជារបស់ទំនេរ

២. ជារបស់ទទេ

៣. ជារបស់សូន្យ

៤. ជារបស់មិនមែនតួខ្លួន

៥. មិនមានខ្លឹមសារ

៦. ជាពេជ្ឈឃាត (អ្នកសម្លាប់)

៧. ប្រាសចាកសេចក្ដីចម្រើន

៨. ជាឫសគល់នៃអំពើអាក្រក់

៩. ជាអារម្មណ៍របស់អាសវៈ

១០. ជារបស់ដែលត្រូវបច្ច័យតាក់តែង" ។

លក្ខណៈ ៦ ប្រការក្រោយ ដែលពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គ មិនស្របជាមួយនឹងសេចក្ដីក្នុងគម្ពីរវិសុទ្ធិមគ្គ លោកអ្នកតែងគម្ពីរវិសុទ្ធិមគ្គ នឹងប្រាថ្នាសម្ដែងថា លក្ខណៈសុញ្ញតា មិនមែនជាវត្ថុ ដែលអ្នកបដិបត្តិធម៌ ត្រូវទន្ទេញចាំស្វាធ្យាយ ហើយកំណត់ដឹងតាមលំដាប់ ដែលពោលទុក តែជាការឃើញច្បាស់លក្ខណៈណានីមួយ ឬ ច្រើនលក្ខណៈ ដែលរាប់បញ្ចូលក្នុងត្រៃលក្ខណ៍យ៉ាងពិតប្រាកដ ការឃើញច្បាស់សេចក្ដីសុញ្ញតា ដោយលក្ខណៈ ១០ ប្រការនោះ ទើបពោលតាមសភាវធម៌ ដែលប្រាកដតាមបារមី និង អធ្យាស្រ័យរបស់បុគ្គលច្រើនជំពូក ទើបធ្វើឲ្យមានសេចក្ដីផ្សេងគ្នាបាន ។

ប្រសិនបើអ្នកបដិបត្តិធម៌ ទន្ទេញចាំស្វាធ្យាយហើយ កំណត់ដឹងតាមន័យដែលពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គ ក៏នឹងស្របជាមួយសេចក្ដីដែលពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គ និង អដ្ឋកថាចារ្យ ក៏មិនគួរនឹង

ពោលជំទាស់ជាមួយនឹងគម្ពីរបូឡូនិទ្ទេសដូច្នោះ សេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គ ទើបគួរនឹងពោលទុកដើម្បីសម្តែងសភាវធម៌ ដែលជាក់ច្បាស់ដល់អ្នកដែលបដិបត្តិធម៌ ជាអ្នកឃើញច្បាស់លោកទស្សនៈខាងក្នុងខ្លួន មិនមែនដើម្បីប្រើក្នុងការទន្ទេញចាំហើយ ពិចារណាដឹងច្បាស់តាមពាក្យបរិកម្ម ។

ការឃើញច្បាស់សេចក្តីសូន្យទទេ ដោយលក្ខណៈ ១២ យ៉ាង ( **ទ្វាទសអាការ** ) ពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គថា:

រូបំ ន សត្តោ, ន ជីវោ, ន នរោ, ន មាណវោ, ន ឥត្ថី, ន បុរិសោ, ន អត្តា, នាហំ, ន អត្តនិយំ, ន មម, ន អញ្ញស្ស, ន កស្សចិ ។

"១. រូបមិនមែនសត្វ

២. រូបមិនមែនជីវៈ

៣. រូបមិនមែនមនុស្ស

៤. រូបមិនមែនមាណព

៥. រូបមិនមែនស្រី

៦. រូបមិនមែនប្រុស

៧. រូបមិនមែនខ្លួន

៨. រូបមិនមែនអញ

៩. រូបមិនមែនរបស់ខ្លួន

១០. រូបមិនមែនរបស់អញ

១១. រូបមិនមែនរបស់អ្នកដទៃ

១២. រូបមិនមែនរបស់នរណាៗ" ។

សូម្បីការឃើញច្បាស់សេចក្តីសូន្យទទេ ដោយលក្ខណៈ ១២ យ៉ាង របស់វេទនាខន្ធជាដើម ក៏ដូចគ្នា ។ ទាំង ១២ បទនេះ ៨ បទខាងដើម ប្រាថ្នាជំទាស់អាត្ម័ន ឬ វិញ្ញាណ តាមដែលមានអ្នកយល់ថា តាំងនៅជានិរន្ត និងជាអ្នកបញ្ជាឲ្យធ្វើអាកប្បកិរិយាផ្សេងៗ មានការដើរ អង្គុយ បត់ លា ឃើញ បានឮជាដើម មិនមែនប្រាថ្នាជំទាស់ភាពជាបុគ្គលតាមភាសាក្នុងលោកដែលប្រើវត្ថុចម្លងទាក់ទងគ្នា ចំណែក ៤ បទក្រោយ ប្រាថ្នាជំទាស់ ភាពជាវត្ថុដែលជាប់ដោយអាត្ម័ន ដែលពោលថា មិនមានវត្ថុណាជាប់ទាក់ទងជាមួយនឹងអាត្ម័ននោះឡើយ មិនមែនប្រាថ្នាជំទាស់តាមសេចក្តីសំដៅរបស់ភាសាខាងសង្គម ដែលយល់ថា ជាទ្រព្យរបស់អ្នកដទៃ ទ្រព្យរបស់យើង អវយវៈរបស់អ្នកដទៃ អវយវៈរបស់យើង បុត្រធីតារបស់អ្នកដទៃ បុត្រធីតារបស់យើង ដូចនេះជាដើម ។

យ៉ាងណាក៏ដោយ មានអ្នកជួបសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គនេះហើយ តិះដៀល គម្ពីរអដ្ឋកថាថា ព្រះពុទ្ធទ្រង់ជំទាស់អាត្ម័ន ដែលអ្នកស្រុកប្រកាន់មាំថា ជាម្ចាស់របស់នៃខន្ធ ( **សាមិ** ) និងស្ថិតនៅរហូតអស់កាលយូរ ( **និវាសី** ) ជាដើមទុកក្នុងគម្ពីរព្រះត្រៃបិដក តែក្នុងគម្ពីរអដ្ឋកថារបស់ព្រះពុទ្ធឃោសាចារ្យ បានជំទាស់តាមសេចក្តីនៃការចម្លងតៗក្នុងលោកដែលពោលថា ជាបុគ្គល បុរស ស្ត្រី ។ល។ ពាក្យតិះដៀល

ដូចដែលពោល មកពីការមិនដឹងថា ព្រះអដ្ឋកថាចារ្យបានពោលតាមគម្ពីរ ចូឡនិទ្ទេស និង លោកមិនបានប្រាថ្នានឹងជំទាស់តាមកាសាបតចម្ងងក្នុង សង្គម ដូច្នោះ នឹងឃើញបានថា លោកប្រាថ្នានឹងជំទាស់អាត្ម័ន ជាគោល សំខាន់ ដូចសេចក្តីក្នុងរឿងអនត្តារបស់ សម្មសនញ្ញាណថា:

អសារកដ្ឋេនាតិ សាមី និវាសី ការកោ វេទកោ សយំវាសីតិ ឯវំ បរិកប្បិ តស្ស អត្តសារស្ស អភាវេន ។

“ពាក្យថា អសារកដ្ឋេន ( ព្រោះជាវត្ថុ ដែលមិនមានខ្លឹមសារ ) មានន័យថា ព្រោះមិនមានខ្លឹមសារ គឺអត្តាដែលមនុស្សល្ងង់ខ្លៅ តិះដៀល យ៉ាងនេះថា អត្តា ម្ចាស់របស់នៃខន្ធ វត្ថុដែលស្ថិតនៅជារៀងរហូត វត្ថុ ដែលធ្វើកម្ម វត្ថុដែលសោយផលកម្ម វត្ថុដែលមានអំណាចនៅលើ រាងកាយ” ។

[១] សាមិនិវាសិការកវេទកាធិដ្ឋាយកវិរហិតតាយ សុញ្ញតោ,

[២] សយញ្ច អស្សាមិកភាវាទិតាយ អនត្តតោ ។

“១. ដោយសភាពសូន្យទទេ ព្រោះប្រាសចាកម្ចាស់របស់នៃខន្ធ វត្ថុដែលស្ថិតនៅជារៀងរហូត វត្ថុដែលធ្វើកម្ម វត្ថុដែលសោយផលកម្ម និងវត្ថុដែលឃុំឃាំងរាងកាយ ។

២. ដោយមិនមានអត្តា ព្រោះមិនមានភាពជាម្ចាស់របស់ដោយ ខ្លួនឯងជាដើម”។

ព្រះដីកាចារ្យ អ្នកយល់សេចក្ដីនៃព្រះពុទ្ធវចនៈ និងពាក្យអធិប្បាយក្នុងគម្ពីរអដ្ឋកថាយ៉ាងច្បាស់លាស់ បានអធិប្បាយរឿងនេះថាៈ

[១] រូបំ ន សត្តោតិអាទីសុ យោ លោកវោហារេន សត្តោ, រូបំ សោ ន ហោតីតិ អយមត្ថោ ឥធ នាធិប្បេតោ តស្សានុត្តសិទ្ធត្តា។

[២] ន ហិ លោកោ រូបមត្តំ សត្តោតិ អធិប្បេតោ ។

[៣] ពាហិរកបរិកប្បិតោ បន អត្តា សត្តោ អធិប្បេតោ ។

[៤] សោ ហិ តេហិ រូបាទីសុ សត្តវិសត្តតាយ បរេ ច សញ្ញាបនដ្ឋេនន សត្តតោតិ វុច្ចតិ ។

[៥] រូបំ សោ ន ហោតីតិ អត្ថោ ។

[៦] សុញ្ញតាបរិគ្គណ្ហនញ្ហោតន្តិ ។

[៧] ឯស នយោ ន ជីវោតិអាទីសុបិ ។

“១. ក្នុងការកំណត់ដឹងថា រូបមិនមែនសត្វជាដើមនោះ មិនបានសំដៅយកសេចក្ដីនេះថា រូបមិនមែនជាសត្វ តាមពាក្យហៅរបស់អ្នកស្រុកក្នុងរឿងនេះ ព្រោះសេចក្ដីនោះប្រាកដហើយ ដោយមិនបានពោលទុក ។

២. បន្ទាប់ពីអ្នកស្រុកមិនបានសំដៅយករូបប៉ុណ្ណោះជាសត្វ ។

៣. តែសំដៅយកអត្តាដែលមនុស្សក្រៅសាសនា គិតទុកឡើង ។

៤. ដោយពិតហើយ អត្តានោះបានឈ្មោះថា សត្វ ព្រោះជាវត្ថុ

*ដែលប្រកាន់ខ្ជាប់នឹងញ៉ាំងអ្នកដទៃឲ្យប្រកាន់ខ្ជាប់ក្នុងរូបជាដើម ។*

*៥. សេចក្ដីសំដៅក៏គឺ រូប [ ដែលអ្នកបដិបត្តិធម៌ឃើញច្បាស់ការរលត់ទៅក្នុងបច្ចុប្បន្ន ] មិនមែនអត្តានោះ ។*

*៦. ពិតហើយ ការកំណត់ដឹងថា រូបមិនមែនជីវៈជាដើម ក៏មានន័យដូចគ្នា" ។*

*ពាក្យអធិប្បាយទាក់ទងជាមួយនឹងសង្ខារុបេក្ខាញាណ គប្បីជ្រាបដូចតទៅនេះ ។*

***[១]*** កថំ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេ-ក្ខាសុ ញាណំ ។

***[២]*** ឧប្បាទំ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុ-បេក្ខាសុ ញាណំ ។ល។ បវត្តតិ ។ល។ និមិត្តំ ។ល។ អយូហានំ ។ល។ បដិសន្ធី ។ល។ ឧបាយាសំ មុញ្ចិតុកម្យតា បដិសង្ខា សន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ។

***[៣]*** ឧប្បាទោ ទុក្ខន្តិ ។លបេ។ ភយន្តិ ។បេ។ សាមិសន្តិ ។បេ។ ឧប្បាទោ សង្ខារាតិ ។បេ។ ឧបាយាសោ សង្ខារាតិ មុញ្ចិតុកម្យតា បដិសង្ខា សន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ។

*"១. សួរថា បញ្ញាដែលត្រូវការនឹងកំណត់ដឹងទៀត និងនៅព្រងើយជាសង្ខារុបេក្ខាញាណបានយ៉ាងណា?*

២. ធ្វើយថា បញ្ញាដែលត្រូវការនឹងកំណត់ដឹងទៀត និងនៅព្រងើយ ថាការកើតឡើង... ការប្រព្រឹត្តទៅ... និមិត្ត ( សង្ខាររូបនាម)... សេចក្តីខ្វល់ខ្វាយ... បដិសន្ធិ... បញ្ញាដែលត្រូវការនឹងកំណត់ដឹងទៀត និងនៅព្រងើយ ថា សេចក្តីបង្អៀតបង្អល់ចិត្ត ជាសង្ខារុបេក្ខាញាណ ។

៣. បញ្ញាដែលត្រូវការនឹងកំណត់ដឹងទៀត និងនៅព្រងើយថា ការកើតឡើងជា ទុក្ខ... ជាវត្ថុគួរភ័យ... មានអាមិសៈ ( នុយ គឺ វដ្តទុក្ខ កាមគុណ និង កិលេស )... ការកើតឡើងជាសង្ខារ [ ដែលមិនសុខស្ងប់]... សេចក្តីបង្អៀតបង្អល់ចិត្តជាសង្ខារជា សង្ខារុបេក្ខាញាណ” ។

**[១]** តត្ថ មុញ្ចិតុកម្យតា ច សា បដិសង្ខា ច សន្តិដ្ឋន ចាតិ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា ។

**[២]** ឥតិ បុព្វភាគេ និព្វិទាញាណេន និព្វិន្នស្ស ឧប្បាទាទីនិ បរិច្ចជិតុកាមតា មុញ្ចិតុកម្យតា ។

**[៣]** មុញ្ចនស្ស ឧបាយករណត្ថំ មជ្ឈេ បដិសង្ខានំ បដិសង្ខា ។

**[៤]** មុញ្ចិត្វា អវសានេ អជ្ឈុបេក្ខានំ សន្តិដ្ឋនា ។

“១. ក្នុងរឿងនោះ ពាក្យថា មុញ្ចិតុកម្យតាបដិសង្ខាសន្ទិដ្ឋនា គឺ សេចក្តីត្រូវការនឹងកំណត់ដឹងទៀត និងនៅព្រងើយ ។

២. កាលអ្នកបដិបត្តិធម៌ នឿយណាយ ដោយនិព្វិទាញាណ

ក្នុងខាងដើមយ៉ាងនេះថា សេចក្ដីប្រាថ្នាដែលនឹងលះចោលការកើតឡើងជាដើម ឈ្មោះថា សេចក្ដីត្រូវការនឹងកំណត់ ។

៣. ការកំណត់ដឹងទៀតក្នុងចំណែកកណ្ដាល ដើម្បីជាហេតុនៃការកំណត់ ឈ្មោះថា ការកំណត់ដឹងទៀត ។

៤. ការកំណត់ ហើយព្រងើយក្នុងទីបំផុត ឈ្មោះថា ការនៅព្រងើយ ។

សេចក្ដីត្រូវការនឹងកំណត់ការកើតឡើងជាដើម ជាសេចក្ដីត្រូវការនឹងកំណត់សង្ខារ ដែលជាប់ដោយការកើតឡើងជាដើម និងសេចក្ដីប្រាថ្នាដែលនឹងលះចោលនូវការកើតឡើងជាដើម ក៏ជាសេចក្ដីត្រូវការនឹងលះចោលសេចក្ដីត្រេកអរពេញចិត្ត ដែលជាប់ដោយសង្ខារ ដូចគម្ពីរមហាដីការបស់វិសុទ្ធិមគ្គ អធិប្បាយថា:

ឧប្បាទាទីនីតិ ឧបាទបវត្តាទិអបទេសេន វុត្តេ សង្ខារេ បរិច្ចជិ-តុកាមតាតិ តប្បដិពទ្ធឆន្ទរាគប្បហានេន វិសជ្ជិតុកាមតា ។

“ពាក្យពោលថា ឧប្បាទាទីនិ ( ការកើតឡើងជាដើម ) គឺសង្ខារដែលពោលទុក ដោយការកើតឡើង និងសេចក្ដីប្រព្រឹត្តទៅជាដើម ។

ពាក្យពោលថា: បរិច្ចជិតុកាមតា ( សេចក្ដីប្រាថ្នាដែលនឹងលះចោល ) អធិប្បាយថា សេចក្ដីប្រាថ្នា ដែលនឹងលះចោល ដោយការលះ

សេចក្តីត្រេកអរពេញចិត្ត ដែលជាប់ដោយសង្ខារនោះ” ។

ម៉្យាងទៀត ញាណទាំង ៣ គឺ មុញ្ចិតុកម្យតាញាណ បដិសង្ខាញាណ និង សង្ខារុបេក្ខាញាណមានលក្ខណៈដូចគ្នា គឺឃើញច្បាស់ថា អារម្មណ៍ដែលខ្លួនកំណត់ដឹង និង វិបស្សនាចិត្ត ត្រឹមតែជា រូបនាម ដែលមិនមែនតួខ្លួនផ្សេងគ្នាដោយជាភាព ញាណទន់ខ្ចី កណ្តាល និង ចាស់ក្លា ដូចគម្ពីរបដិសម្ភិទាមគ្គពោលថា:

យា ច មុញ្ចិតុកម្យតា, យា ច បដិសង្ខានុបស្សនា, យា ច សង្ខារុបេក្ខា, ឥមេ ធម្មា ឯកត្ថា ។ ព្យញ្ជនមេវ នានំ ។

“ញាណទាំងនេះ គឺ មុញ្ចិតុកម្យតាញាណ បដិសង្ខាញាណ និង សង្ខារុបេក្ខាញាណ មានសភាពដូចគ្នា ផ្សេងគ្នាដោយសព្ទប៉ុណ្ណោះ” ។ ដោយហេតុដែលញាណទាំងនោះ ជាញាណតែមួយ ដោយសភាវៈនោះ អ្នកបដិបត្តិធម៌ខ្លះ ដែលសម្រេចមុញ្ចិតុកម្យតាញាណ និង បដិសង្ខាញាណ ហើយទើបអាចសម្រេចនូវសង្ខារុបេក្ខាញាណបានមួយរំពេច អ្នកខ្លះ សម្រេចសង្ខារុបេក្ខាញាណ ហើយបានសម្រេចនូវអនុលោមញាណ មគ្គញាណ និងផលញាណ យ៉ាងឆាប់រហ័ស អ្នកខ្លះក៏ស្ថិតនៅក្នុងសង្ខារុបេក្ខាញាណជាកាលយូរ ញាណដូចពោលអាចប្រព្រឹត្តទៅតាមប្រក្រតី ឬប្រព្រឹត្តទៅល្អ ច្រើនដោយការឃើញច្បាស់ សភាវធម៌ល្អិតច្រើនឡើង ដូចគម្ពីរវិសុទ្ធិមគ្គពោលថា:

*[ ១ ]* តំ បនេតំ សចេ សន្តិបទំ និព្វានំ សន្តោ បស្សតិ, សព្វំ សង្ខារប្បវត្តំ វិស្សជ្ជេត្វា និព្វានមេវ បក្ខន្ទតិ ។ នោ ចេ និព្វានំ សន្តោ បស្សតិ, បុនប្បុនំ សង្ខារារម្មណមេវ ហុត្វា បវត្តតិ សាមុទ្ទិកានំ ទិសាកាកោ វិយ ។ *[២]* សាមុទ្ទិកា កិរ វាណិជកា នាវំ អារោហន្តា ទិសាកាកំ នាម គណ្ហន្តិ ។ តេ យទា នាវា វាតក្ខិត្តា វិទេសំ បក្ខន្តិ តីរំ ន បញ្ញាយតិ, តទា ទិសាកាកំ វិស្សជ្ជេន្តិ ។ សោ កូបកយដ្ឋិតោ អាកាសំ លង្ឃិត្វា សព្វា ទិសា ច វិទិសា ច អនុគន្ត្វា សចេ តីរំ បស្សតិ, តទភិមុខោវ គច្ឆតិ ។ នោ ចេ បស្សតិ, បុនប្បុនំ អាគន្ត្វា កូបកយដ្ឋិំយេវ អល្លីយតិ ។ *[៣]* ឯវមេវ សចេ សង្ខារុបេក្ខាញាណំ សន្តិបទំ និព្វានំ សន្តោ បស្សតិ, សព្វំ សង្ខារប្បវត្តំ វិស្សជ្ជេត្វា និព្វានមេវ បក្ខន្ទតិ ។*[៤]* នោ ចេ បស្សតិ, បុនប្បុនំ សង្ខារារម្មណមេវ ហុត្វា បវត្តតិ ។ *[៥]* យថិទំ សុប្បគ្គេ បិដ្ឋំ វដ្ដិយមានំ វិយ និព្វដ្ដិតកប្បាសំ វិហនមានំ វិយ នានប្បការតោ សង្ខារេ បរិគណ្ហិត្វា ភយញ្ច នន្ទិញ្ច បហាយ សង្ខារវិចិនេន មជ្ឈត្តំ ហុត្វា តិវិធានុបស្សនាវសេន តិដ្ឋតិ ។

*“១. ម្យ៉ាងទៀត សង្ខារុបេក្ខាញាណ ដែលកើតឡើងហើយនោះ បើឃើញព្រះនិព្វានដែលជាផ្លូវស្ងប់ ដោយសេចក្ដីស្ងប់ ក៏នឹងបោះបង់បោលក្រសែសង្ខារទាំងពួង ហើយរត់ចូលទៅកាន់ព្រះនិព្វានតែម្ដង ប្រសិន*

បើនៅមិនឃើញព្រះនិព្វាន ដោយសេចក្ដីស្ងប់ ក៏មានសង្ខារជាអារម្មណ៍តែម្យ៉ាង ហើយប្រព្រឹត្តទៅ ប្រៀបដូចសត្វក្អែករបស់ពួកអ្នកជំនួញធ្វើដំណើរតាមទូកសមុទ្រ ដូច្នេះ ។

បានឮមកថា ពួកអ្នកជំនួញធ្វើដំណើរតាមទូកសមុទ្រ ខណៈឡើងទូកបានចាប់សត្វក្អែកដែលហៅថា **ទិសាកាក** ( សត្វក្អែកស្គាល់ទិស ) ទៅផង ពេលណា ទូកត្រូវខ្យល់ព្យុះបក់ទៅកាន់ប្រទេសផ្សេងពីទីលំនៅ ប្រាំងក៏មិនប្រាកដ គ្រានោះ ពួកអ្នកជំនួញទាំងនោះ ក៏កំណត់ការដឹងទិសទៅក្អែកនោះ ក៏លោតឡើងពីឈើនុកទ្វារសសរក្ដោងទូកឡើង កាន់អាកាស ហើយហើរទៅតាមទិសធំ ទិសតូចគ្រប់ទិស បើវាឃើញប្រាំង វាក៏ហើរឆ្ពោះមុខទៅកាន់ ប្រាំងនោះផុត បើវាមិនឃើញប្រាំង វាក៏ហើរត្រឡប់មកកោះ នៅត្រង់ឈើនុកទ្វារសសរក្ដោងទូកនោះឯងម្ដងហើយម្ដងទៀត ។

៣. សង្ខារុបេក្ខាញាណ ក៏ដូចសត្វក្អែករកប្រាំងដូច្នោះ បើឃើញព្រះនិព្វាន ដែលជាផ្លូវសន្តិដោយសេចក្ដីស្ងប់ ក៏បោះបង់ចោលនូវក្រសែសង្ខារទាំងអស់ហើយ រត់ចូលកាន់ព្រះនិព្វានតែម្ដង ។

៤. ប្រសិនបើនៅមិនទាន់ឃើញ ក៏មានសង្ខារជាអារម្មណ៍នោះឯងវិលវល់ ប្រព្រឹត្តទៅជាមួយគ្នា ។

៥. ញាណនេះ ដូចម្សៅដែលត្រូវរែងទុកត្រង់មាត់ចង្អេរ និងសំឡីគដែល ធ្មៀលគ្រាប់ចេញហើយរែង គ្រាកំណត់ដឹងសង្ខារដោយប្រការ ផ្សេងៗហើយ ក៏បោះបង់ចោលនូវភ័យ និង សេចក្ដីពេញចិត្ត មានចិត្តជាកណ្ដាល

ក្នុងការកំណត់ដឹងសង្ខារ តាំងនៅដោយអំណាចអនុបស្សនា ៣ ប្រការ [ គឺ **អនិច្ចានុបស្សនា** ( ការតាមដឹងថា មិនទៀង ) **ទុក្ខានុបស្សនា** ( ការតាមដឹងថា ជាទុក្ខ ) និង **អនត្តានុបស្សនា** ( ការតាមដឹងថាមិនមែន តួខ្លួន )] ។

ការពោលទុកក្នុងគម្ពីរអដ្ឋកថា ខាងដើមថា សង្ខារុបេក្ខាញាណ ឃើញច្បាស់ ព្រះនិព្វានបាន បញ្ជាក់ដល់សង្ខារុបេក្ខាញាណដែលចាស់ក្លា ប្រព្រឹត្តទៅដោយសេចក្តីជា**វុដ្ឋានគាមិនី** (វិបស្សនាដែលនាំទៅដល់មគ្គ) ដែលអាចញ៉ាំងឲ្យកើតអនុលោមញាណរាប់ថា រួមយកសង្ខារុបេក្ខាញាណ អនុលោមញាណ និង គោត្រភូញាណ ទុកជាញាណជាមួយគ្នា ដោយវោហារផ្លូវភាសា ដែលហៅថា **ឯកត្តន័យ** គឺការទាក់ទងគ្នា ដោយសេចក្តីជាហេតុ និង ជាផល ក្នុងក្រសែរូបនាមប្រភេទតែមួយ ពោលដោយត្រង់ គឺ សង្ខារុបេក្ខាញាណប្រាកដឡើង ច្រើនខណៈហើយសម្រេចសេចក្តីចាស់ក្លា ជាក់ច្បាស់ជាពិសេស ទើបញ៉ាំងឲ្យកើតអនុលោមញាណ ក្រោយពីនោះ គោត្រភូញាណ រមែងកើតឡើង ដោយកម្លាំងរបស់អនុលោមញាណ ហើយឃើញច្បាស់ព្រះនិព្វាន ឬ រត់ចូលទៅកាន់ព្រះនិព្វាននោះឯង ដូចសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គមហាដីកាថា :

**[១]** តិក្ខវិសទសូរភាវេន សង្ខារេសុ អជ្ឈុបេក្ខនេ សិជ្ឈមានេ តំ សង្ខារុបេក្ខាញាណំ អនេកវារំ បវត្តមានំ បរិបាកគមនេន អនុលោមញាណស្ស បច្ចយភាវំ គច្ឆន្តំ និព្វានំ សន្តតោ បស្សតិ

នាម ។ [២] តថា ភូតញ្ច សង្ខារប្បវត្តំ វិសជ្ជេត្វា និព្វានមេវ បក្ខន្ទតិ ។ [៣] តយិទំ ឥធ ញាណំ អនុលោមគោត្រភុញ្ញាណេហិ សទ្ធឹ ឯកត្តំ នេត្វា វុត្តំ ឯកត្តនយវសេន ។

“១. កាលសេចក្តីព្រងើយក្នុងសង្ខារ ប្រាកដដោយភាពចាស់ក្លា ជាក់ច្បាស់ និង ក្លាហាន សង្ខារុបេក្ខាញាណនេះប្រព្រឹត្តទៅច្រើនខណៈ ក៏ដល់ភាពជាបច្ច័យដល់អនុលោមញាណ ដោយការសម្រេចសេចក្តីចាស់ក្លា ឈ្មោះថា ឃើញច្បាស់ព្រះនិព្វាន ដោយសេចក្តីស្ងប់ ។

២. នឹងញាណដែលប្រព្រឹត្តទៅយ៉ាងនោះ ឈ្មោះថា លះបោលក្រសែសង្ខារ ហើយរត់ចូលកាន់ព្រះនិព្វាន ។ ញាណដូចពោលត្រូវនាំទៅកាន់ភាពជាញាណមួយ ជាមួយគ្នានឹងអនុលោមញាណ និង គោត្រភូញាណ ពោលទុកដោយប្រភេទរបស់ឯកត្តន័យ” ។

---

[ន័យ ៤ ប្រការ មាននៅក្នុងគម្ពីរអដ្ឋកថា និង ដីកា គឺ :

១. ឯកត្តន័យ សេចក្តីជាប់ទាក់ទងគ្នាដោយភាពជាហេតុ និង ជាផល ក្នុងក្រសែរូបនាមដូចគ្នា ដែលពោលថា មរណាសន្នជវនចិត្ត ចុតិចិត្ត និង បដិសន្ធិចិត្ត ជាចិត្តមួយដួងជាមួយគ្នា ឬការពោលដល់សង្ខារុបេក្ខាញាណ ដោយសំដៅដល់ញាណ ទាំង ៣ ដែលកើតតភ្ជាប់គ្នា គឺ សង្ខារុបេក្ខាញាណ អនុលោមញាណ និង គោត្រភូញាណ ។

២. នានត្តន័យ ការបែកសេចក្តីផ្សេងគ្នារបស់ហេតុ និង ផល ដូចការពោលថា មរណាសន្នជវនចិត្ត ចុតិចិត្ត និង បដិសន្ធិចិត្ត ជាចិត្តម្តងមួយដួង បំបែកចេញពីគ្នា ។

៣. ព្យាបារន័យ ការប្រាសចាកសេចក្តីខ្វល់ខ្វាយរបស់ហេតុ និងផលថា ហេតុញ៉ាំងផលឲ្យកើតឡើង ឬ ផលកើតពីហេតុ ។

៤. អនុរូបផលន័យ *ការកើតឡើងរបស់ផលតាមសមគួរដល់ហេតុ មានឈ្មោះហៅទៀតថា* ឯវំធម្មតាន័យ *គឺ ន័យដែលជាធម្មជាតិយ៉ាងនោះ ]* ។

# ញាណទី ១២
# អនុលោមញាណ

**ទុន្និគ្គហស្ស លហុនោ យត្ថកាមនិបាតិនោ**
**ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។**

*ការទូន្មានចិត្ត ដែលសង្កត់សង្កិន បានដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះ ទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណជាតញ៉ាំងប្រយោជន៍ ឲ្យសម្រេច ( ព្រោះថា ) ចិត្តដែលហ្វឹកហាត់បានហើយ រមែងនាំសេចក្តីសុខមកឲ្យ ។*

# អនុលោមញាណ
# និង
# បដិបទាញាណទស្សនវិសុទ្ធិ

កាលសង្ខារុបេក្ខាញាណចាស់ក្លាហើយ មានកម្លាំងល្មមនឹងញុំាងឲ្យកើតអនុលោមញាណ ឥន្ទ្រិយ៍ ៥ រមែងប្រព្រឹត្តទៅស្មើគ្នា គឺ :

១- សទ្ធា ដែលមានកម្លាំងធ្វើឲ្យចិត្តថ្លាស្អាតជាពិសេស ។

២- វិរិយៈ ដែលមិនក្រៃលែង ឬបន្ធូរទៅជាងសមាធិ ។

៣- សតិ ដែលកំណត់ដឹងទាន់យ៉ាងជាក់ច្បាស់ ។

៤- សមាធិ ដែលតាំងមាំក្នុងសភាវធម៌បច្ចុប្បន្នមិនរាយមាយ ។

៥- បញ្ញា គឺសង្ខារុបេក្ខាញាណដែលប្រាកដច្បាស់ ។

ក្នុងខណៈនោះ អ្នកបដិបត្តិរមែងដឹងច្បាស់ថា ខ្លួនអាចដឹងទាន់សភាវធម៌យ៉ាងជាក់ច្បាស់ ការបដិបត្តិធម៌ត្រោះមុខជាដើម ហើយគេនឹងឃើញច្បាស់រូបនាម ដែលកំពុងកើតរលត់នោះ ដោយលក្ខណៈមិនទៀង ជាទុក្ខ មិនមែនតួខ្លួន យ៉ាងណាមួយ ដោយវីថិចិត្តដែលកើតរឿយៗ ( សម្មសនានុបស្សនាវីថិ) ២ ឬ ៣ គ្រា ជាយ៉ាងតិច គឺ

-បើវីថិចិត្តទី ១ ឃើញច្បាស់ថាមិនទៀង វីថិចិត្តទី ២ និងទី ៣ ក៏ឃើញច្បាស់ថា មិនទៀង ។

-បើវីថិចិត្តទី ១ ឃើញច្បាស់ថា ជាទុក្ខ វីថិចិត្តទី ២ និងទី ៣

ក៏ឃើញច្បាស់ថា ជាទុក្ខ ។

-បើវិថិចិត្តទី ១ ឃើញច្បាស់ថា មិនមែនតួខ្លួន វិថិចិត្តទី ២ និងទី ៣ ក៏ឃើញ ច្បាស់ថា មិនមែនតួខ្លួន ។

សេចក្តីមិនទៀងដូចពោល គឺ **អនិច្ចលក្ខណៈ** ១០ យ៉ាងណាមួយ ដែលពោលមកហើយ ជាទុក្ខ គឺ **ទុក្ខលក្ខណៈ** ២៥ យ៉ាងណាមួយ សេចក្តីមិនមែនតួខ្លួន គឺ **អនត្តលក្ខណៈ** ៥ យ៉ាងណាមួយ ។

សង្ខារុបេក្ខាញាណចុងបំផុតដែលរាប់ចូលក្នុងវិថិចិត្តដែលកើតរឿយ ៗ ២ ឬ ៣ គ្រា ឈ្មោះថា សង្ខារុបេក្ខាញាណ ដែលដល់ទីបំផុតហើយ ( សិខាប្បត្តសង្ខារុបេក្ខា ) និងបានឈ្មោះថា វុដ្ឋានគាមិនីវិបស្សនា ព្រោះនាំទៅដល់មគ្គ សេចក្តីពិត ញាណ ៣ ប្រការ គឺ សង្ខារុបេក្ខាញាណ អនុលោមញាណ និង គោត្រភូញាណ បានឈ្មោះថា វុដ្ឋានគាមិនី ព្រោះនាំទៅដល់មគ្គ ដែលឈ្មោះថា **វុដ្ឋាន** ព្រោះបានចេញពីនិមិត្ត គឺ សង្ខារពីព្រោះមិនទទួលយកសង្ខារ ( ដែលជាអារម្មណ៍របស់វិបស្សនា ) ជាអារម្មណ៍ និងចេញពីក្រសែកិលេស និង វិបាក បន្ទាប់ពីរម្ងាប់ក្រសែទាំងនោះ ដូចគម្ពីរអភិធម្មត្ថសង្គហៈពោលថា:

យា សិខាប្បត្តា, សា សានុលោមា សង្ខារុបេក្ខា វុដ្ឋាន គាមិនីវិបស្សនាតិ ច បវុច្ចតិ ។

“សង្ខារុបេក្ខាញាណ ដែលដល់ទីបំផុតហើយ ព្រមទាំងអនុលោម-ញាណ ហៅថា វុដ្ឋានគាមិនីវិបស្សនា ( វិបស្សនាដែលនាំទៅដល់មគ្គ )” ។

*[១]* តស្មា យទិ វុដ្ឋានគាមិនី វិបស្សនា អនត្តតោ វិបស្សតិ, សុញ្ញតោ វិមោក្ខោ នាម ហោតិ មគ្គោ ។ *[២]* យទិ អនិច្ចតោ វិបស្សតិ, អនិមិត្តោ វិមោក្ខោ នាម ។ *[៣]* យទិ ទុក្ខតោ វិបស្សតិ, អប្បណិហិតោ វិមោក្ខោ នាម ។

*“១. ព្រោះហេតុនោះ បើវុដ្ឋានគាមិនីវិបស្សនា ឃើញច្បាស់ដោយភាពជាអនត្តា ក៏នឹងជាមគ្គ ដែលហៅថា* សុញ្ញតវិមោក្ខ ។

*២. បើឃើញច្បាស់ដោយសេចក្ដីមិនទៀង ក៏ជាមគ្គដែលហៅថា* អនិមិត្តវិមោក្ខ ។

*៣. បើឃើញច្បាស់ដោយភាពជាទុក្ខ ក៏ហៅថា* អប្បណិហិត-វិមោក្ខ”។

*សេចក្ដីនេះមានន័យថា ទាំងសង្ខារុបេក្ខាញាណលំដាប់ចាស់ក្លាខ្ពស់បំផុត និង អនុលោមញាណបានឈ្មោះថា វុដ្ឋានគាមិនីវិបស្សនា និងបើសង្ខារុបេក្ខាញាណ ធ្វើឲ្យឃើញច្បាស់ថាជា**អនត្តា** អនុលោមញាណក៏ធ្វើឲ្យឃើញច្បាស់ថា ជា**អនត្តា** ដូចនេះជាដើម ដោយសំដៅយកវីថិចិត្ត ដែលកើតរឿយៗ នោះឯង សូម្បីគម្ពីរវិសុទ្ធិមគ្គ ក៏អធិប្បាយរឿងនេះថា:*

*[ ១ ]* សិខាប្បត្តាវិបស្សនាតិ វា វុដ្ឋានគាមិនីតិ វា សង្ខារុបេ-ក្ខាទិញាណត្តយស្សេវ ឯតំ នាម ។ *[២]* សា ហិ សិខំ ឧត្តមភាវំ

បត្តត្តា សិខាបត្តា ។ [៣] វុដ្ឋានំ គច្ឆតីតិ វុដ្ឋានគាមិនី ។[៤] វុដ្ឋានំ វុច្ចតិ ពហិទ្ធានិមិត្តភូតតោ អភិនិវិដ្ឋវត្ថុតោ ចេវ អជ្ឈត្តបវត្តតោ ច វុដ្ឋហនតោ មគ្គោ, តំ គច្ឆតីតិ វុដ្ឋានគាមិនី ។ [៥] មគ្គេន សទ្ធឹ យុជ្ជតីតិ អត្ថោ ។

*“១. ពាក្យថា សិខាប្បត្តវិបស្សនា ក្តី វុដ្ឋានគាមិនីវិបស្សនា ក្តី ពាក្យទាំងពីរនេះ ជាឈ្មោះរបស់ញាណទាំង ៣ មានសង្ខារុបេក្ខាញាណជាដើមនោះឯង ។*

*២. ព្រោះសង្ខារុបេក្ខាញាណនោះ ឈ្មោះថា ដល់ទីបំផុតហើយ ព្រោះសម្រេចដល់ទីបំផុត គឺ សេចក្តីខ្ពង់ខ្ពស់ ។*

*៣. និងឈ្មោះថា វុដ្ឋានគាមិនី ព្រោះនាំទៅដល់មគ្គ ។*

*៤. មគ្គបានឈ្មោះថា វុដ្ឋាន ព្រោះចេញពីវត្ថុ ( សង្ខារ ) ដែលកំណត់ដឹង ដោយភាពជាអារម្មណ៍ខាងក្រៅ [ គឺឃើញច្បាស់ថាជាវត្ថុដទៃដោយវិបស្សនាញាណ ] និងចេញអំពីក្រសៃ [ កិលេស និងវិបាក ] ខាងក្នុង ។*

*៥. សេចក្តីសំដៅក៏គឺ នៅបន្តជាមួយមគ្គ” ។*

*[ ពាក្យថា វុដ្ឋាន មានសេចក្តី ២ ប្រការ គឺ :*

*-សភាពចេញចាកសង្ខារនិមិត្ត=* សង្ខារនិមិត្តតោ វុដ្ឋាតីតិ វុដ្ឋានំ ( **វិ** បុព្វបទ+**ឧ** បុព្វបទ+ **ឋា**ធាតុ+ **យុ**បច្ច័យ) ។

*-សភាពចេញចាកក្រសៃកិលេស និង* វិបាក=បវត្តតោវុដ្ឋាតីតិវុដ្ឋានំ(**វិ**បុព្វបទ+**ឧ** បុព្វបទ+**ឋា**ធាតុ+យុបច្ច័យ) *]* ។

*វិថីចិត្តរបស់សង្ខារុបេក្ខាញាណដែលដល់ទីបំផុតហើយ ដែលរាប់បញ្ចូលក្នុងវុដ្ឋានគាមិនីវិបស្សនា គឺ ភវង្គចលនៈ ២ គ្រា មនោទ្វារាវជ្ជនចិត្ត មហាកុសលញ្ញាណសម្បយុត្តជវន ៧ ដួង និងភវង្គចិត្តដែលកើតតទៅ វិថីចិត្តនេះ កើតឡើងបន្តគ្នា ដោយមិនមាន តទារម្មណចិត្តបន្តពីវិបស្សនាជវនចិត្ត ដែលមានកម្លាំង ដូចអដ្ឋកថា របស់គម្ពីរវិភង្គពោលថា:*

*[១]* តិលក្ខណារម្មណិកាវិបស្សនាយ តទារម្មណំ ន លព្ភតិ ។

*[២]* វុដ្ឋានគាមិនិយា ពលវវិបស្សនាយ តទារម្មណំ ន លព្ភតិ ។

*“១. តទារម្មណ៍ រមែងមិនមានដល់វិបស្សនាដែលមានអារម្មណ៍ជាត្រៃលក្ខណ៍ ។*

*២. តទារម្មណ៍ រមែងមិនមានដល់វិបស្សនា ដែលមានកម្លាំង ឈ្មោះថា* វុដ្ឋានគាមិនី*” ។*

*កាលវិថីចិត្តដែលកើតរឿយៗ ២ ឬ ៣ គ្រាហើយ ភវង្គចិត្តរមែងកើតឡើង តពីជវនចិត្តដួងទី ៧ ហើយកើតមនោទ្វារាវជ្ជនចិត្តដែលរិះគិតសេចក្តីមិនទៀង សេចក្តីជាទុក្ខ ឬសេចក្តីមិនមែនតួខ្លួន របស់រូប ឬ នាម ដែលប្រាកដការកើតរលត់ដូចអារម្មណ៍របស់វិថីចិត្ត កើតរឿយៗមុន ក្រោយពីនោះ ក៏កើតជវនចិត្ត ៣ ដួង ដែលឃើញច្បាស់រូប ឬ នាមយ៉ាងណាមួយជាអារម្មណ៍ដូចវិថីចិត្ត ដែលកើតឡើងមុននោះ ដោយជវនចិត្តដួងដំបូង ឈ្មោះថា* ***បរិកម្ម*** *( ចិត្តតាក់តែងឲ្យកើត អប្បនាជវន គឺ មគ្គ ) ដួងទី ២ ឈ្មោះថា* ***ឧបចារ*** *( ចិត្តនៅជិតអប្បនា ជវន គឺ មគ្គ )*

*ជួនទី ៣ ឈ្មោះថា **អនុលោម** ( ចិត្តដើរស្របតាមវិបស្សនាញាណ ខាងដើម មានឧទយព្វយញ្ញាណជាដើម និង ពោធិបក្ខិយធម៌ខាងក្រោយ ដែលរាប់បញ្ចូលក្នុងមគ្គចិត្តុប្បាទ ) ។*

*ឈ្មោះទាំង ៣ ខាងដើម ជាឈ្មោះចំពោះរបស់កាមជវនចិត្ត ៣ ជួន ដោយទូទៅ ហៅថា **អាសេវន បរិកម្ម ឧបចារ** និង **អនុលោម** បញ្ញាកើតឡើងក្នុងអនុលោម ៣ ជួនទាំងនេះ ឈ្មោះថា អនុលោមញ្ញាណ ។*

*ម៉្យាងទៀតអាវជ្ជនចិត្ត និងអនុលោម ចិត្តទាំងនេះ រមែងប្រាកដដល់អ្នកបដិបត្តិធម៌ ដូចការឃើញច្បាស់ត្រឹមមួយគ្រា ដូចគ្នាជាមួយការដែលគេដឹងច្បាស់ ត្រឹមតែមួយគ្រា ក្នុងខណៈកំណត់ថា "ឃើញហ្ន៎" "បានឮហ្ន៎" ជាដើម ដោយមិនអាចចែកជាអាវជ្ជនចិត្ត និង ជវនចិត្ត ៧ ជួន ។*

*សាធកៈដែលពោលដល់វិបស្សនាចិត្ត ៧ ជួន និងវិថីចិត្ត ដែលកើតរឿយៗ ( **សទិសានុបស្សនាវិថី** ) ២ ឬ ៣ វិថី ជួបក្នុងគម្ពីរអដ្ឋកថា និងដីកាដូចនេះថា:*

**[១]** តស្ស ឯានិ មគ្គោ ឧប្បជ្ជិស្សតីតិ សង្ខារុបេក្ខា សង្ខារេ អនិច្ចាតិ វា ទុក្ខាតិ វា អនត្តាតិ វា សម្មសិត្វា ភវង្គំ ឱតរតិ ។ **[២]**ភវង្គានន្តរំ សង្ខារុបេក្ខាយ កាតនយេនេវ សង្ខារេ អនិច្ចាតិ វា ទុក្ខាតិ វា អនត្តាតិ វា អារម្មណំ កុរុមានំ ឧប្បជ្ជតិ មនោទ្វារាវជ្ជនំ ។

**[៣]** តតោ ភវង្គំ អាវដ្ដេត្វា ឧប្បន្នស្ស តស្ស កិរិយចិត្តស្សានន្តរំ អវីចិកំ សន្តតិមនុប្បពន្ធមានំ តថេវ សង្ខារេ អារម្មណំ កត្វា ឧប្បជ្ជតិ បឋមជវនចិត្តំ, យំ បរិកម្មន្តិ វុច្ចតិ ។

*"១. សង្ខារុបេក្ខាញាណ ក្នុងខណៈដែលមគ្គនឹងកើតឡើងដល់អ្នកបដិបត្តិធម៌នោះ ក្នុងពេលនេះ រមែងឃើញច្បាស់ថា សង្ខារមិនទៀង ជាទុក្ខ ឬ មិនមែនតួខ្លួន ហើយចុះកាន់ភវង្គ ។*

*២. ក្នុងលំដាប់បន្ទាប់ពីភវង្គ មនោទ្វារាវជ្ជនចិត្ត រមែងកើតឡើងធ្វើសង្ខារជាអារម្មណ៍ថា មិនទៀង ជាទុក្ខ ឬមិនមែនតួខ្លួន ក្នុងន័យតែមួយដូចគ្នា ដែលសង្ខារុបេក្ខាញាណធ្វើមកហើយ ។*

*៣. ក្រោយពីនោះ ជវនចិត្តដួងទី ១ [ គឺអនុលោមញាណទី ១ ] ដែលហៅថា **បរិកម្ម** ដែលកើតបន្តជាប់តាមមិនមានចន្លោះ ធ្វើសង្ខារជាអារម្មណ៍ដូចការ ឃើញច្បាស់របស់សង្ខារុបេក្ខាញាណក្នុងវីថិចិត្ត ២ ឬ ៣ វីថិមុននោះ រមែងកើតតពីកិរិយាចិត្តនោះ [ គឺមនោទ្វារាវជ្ជនចិត្ត ] ដែលកាត់ភវង្គកើតឡើង" ។*

**[១]** អនិច្ចាតិ វា ទុក្ខាតិ វា អនត្តាតិ វា សម្មសិត្វា ភវង្គំ ឱតរតីតិ អនិច្ចាទីសុ ឯកេនាការេន សម្មសន្តី សត្តក្ខត្តុំ បវត្តិត្វា ភិជ្ជន្តី ភវង្គំ ឱតិណ្ណា នាម ហោតិ ។ **[២]** តតោ បរំ ភវង្គស្ស វារោតិ កត្វា ។ **[៣]** តថេវាតិ យថា អតីតាសុ ទ្វត្តិជវនវីថីសុ សង្ខារុបេក្ខា អនិច្ចាតិ

វា ទុក្ខាតិ វា អនត្តាតិ វា សង្ខារេ អារម្មណាមកាសិ, តថេវ ។

“១. **ពាក្យថា:** អនិច្ចាតិ វា ទុក្ខាតិ វា អនត្តាតិ វា សម្មសិត្វា ភវង្គំ ឱតរតិ ( *រមែងឃើញច្បាស់សង្ខារថា មិនទៀង ជាទុក្ខ ឬ មិនមែនតួខ្លួន ហើយចុះកាន់ភវង្គ* ) មានន័យថា សង្ខារុបេក្ខាញាណ *រមែងឃើញច្បាស់ដោយលក្ខណៈមួយក្នុងអនិច្ចលក្ខណៈជាដើម ប្រព្រឹត្តទៅ ៧ គ្រា [ បញ្ញាក្នុងជវនចិត្ត ]ហើយ ឈ្មោះថា ចុះកាន់ ភវង្គ ។*

២. *ព្រះអដ្ឋកថាចារ្យពោលទុកដោយប្រាថ្នាថា វារៈរបស់ភវង្គ រមែងមានតពីជវនចិត្តដែលជាសង្ខារុបេក្ខាញាណ ដែលជាវុដ្ឋានគាមិនីនោះ ។*

៣. *ពាក្យថា:* តថេវ ( *ដូចការឃើញច្បាស់របស់សង្ខារុបេក្ខាញាណ ក្នុងវីថិចិត្ត ២ ឬ ៣ មុននោះ* ) *មានន័យថា សង្ខារុបេក្ខាញាណក្នុងវីថិចិត្ត ២ ឬ ៣ វីថិមុនបាន ទទួលយកសង្ខារជាអារម្មណ៍ថា មិនទៀង ជាទុក្ខ ឬមិនមែនតួខ្លួនយ៉ាងណា ជវនចិត្ត ដូងទី ១ ក៏ធ្វើសង្ខារជាអារម្មណ៍យ៉ាងនោះ” ។*

# ញាណទី ១៣
# គោត្រភូញ្ញាណ

យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ។

*បុគ្គលរស់នៅអស់ ១០០ ឆ្នាំ មិនឃើញការកើតឡើង និងការវិនាសទៅ ការរស់នៅ សូម្បីតែមួយថ្ងៃ របស់លោក ដែលឃើញការកើតឡើង និងការវិនាសទៅ ប្រសើរជាង ។*

# គោត្រភូញាណ

ក្នុងលំដាប់តពីអនុលោមញាណ ជវនចិត្តរមែងកើតឡើងទទួលយកការរលត់សង្ខារ គឺព្រះនិព្វាន ជាអារម្មណ៍ដោយលះបោលសង្ខារដែលកំណាត់ដឹង បញ្ញាដែលកើតរួមជាមួយជវនចិត្តនេះ ឈ្មោះថា គោត្រភូញាណ ការទទួលយកសេចក្តីរលត់សង្ខារជាអារម្មណ៍នោះ ដូចគ្នាជាមួយនឹងការរួចផុតពីសង្ខារហើយរត់ចូលទៅកាន់សេចក្តីរលត់សង្ខារ មិនមែនជាការដឹងអារម្មណ៍របស់ចិត្តទូទៅ ដែលជាចំណែកមួយ ដូចក្នុងកាលមុន ។

ដូចគម្ពីរបដិសម្ភិទាមគ្គពោលថា:

**[១]** ឧប្បាទំ អភិភុយ្យិត្វា អនុប្បាទំ បក្ខន្ទតីតិ គោត្រភុ ។ **[២]** ពហិទ្ធា សង្ខារនិមិត្តំ អភិភុយ្យិត្វា និរោធំ និព្វានំ បក្ខន្ទតីតិ គោត្រភុ ។

"១. ចិត្តដែលគ្របសង្កត់ការកើតឡើងហើយ រត់ចូលកាន់ការមិនកើតឡើង ឈ្មោះថា គោត្រភូ។

២. ចិត្តដែលគ្របសង្កត់និមិត្ត គឺសង្ខារខាងក្រៅ ហើយរត់ចូលកាន់ព្រះនិព្វាន ដែលរលត់សង្ខារ ឈ្មោះថា គោត្រភូ" ។

ម្យ៉ាងទៀត គោត្រភូញាណនេះ រាប់ចូលក្នុងញាណទស្សនវិសុទ្ធិ ព្រោះបានទទួលយកព្រះនិព្វានជាអារម្មណ៍ ដូចមគ្គញាណដែលចាត់ជាជាញាណទស្សនវិសុទ្ធិ ( ការឃើញដ៏បរិសុទ្ធ ) ដោយត្រង់ ។

# ញាណទី ១៤_ ១៥

# មគ្គញាណ ផលញាណ

# មគ្គញ្ញាណ ផលញ្ញាណ
# និង
# ញ្ញាណទស្សនវិសុទ្ធិ

ក្នុងលំដាប់តពីគោត្រភូចិត្ត មគ្គចិត្ត រមែងកើតឡើងមួយគ្រា ហើយទទួលយកព្រះនិព្វាន ជាអារម្មណ៍ បញ្ញាដែលកើតរួមជាមួយមគ្គចិត្តនេះ ឈ្មោះថា មគ្គញ្ញាណ និង ឈ្មោះថា ញ្ញាណទស្សនវិសុទ្ធិ ក្រោយពីនោះ ទើបកើតផលចិត្ត ២ គ្រា វៀរបរិកម្ម ទទួលយកព្រះនិព្វាននោះឯង ជាអារម្មណ៍ ចំណែកអ្នកមានបញ្ញាច្រើន នឹងកើតអនុលោមជវនចិត្ត ២ គ្រា ហើយកើតផលចិត្ត ៣ គ្រា តពីមគ្គ ក្នុងពេលចូលផលសមាបត្តិ ផលជវនចិត្ត រមែងកើតបានច្រើន មិនមានកំណត់បញ្ញា ដែលកើតរួមជាមួយផលចិត្តនេះ ឈ្មោះថា ផលញ្ញាណ។

ម៉្យាងទៀត ការរលត់សង្ខារ ដែលជាអារម្មណ៍របស់មគ្គផលនេះ ដូចជាមួយការរួចផុតពីសង្ខារហើយ រត់ចូលកាន់ការរលត់សង្ខារ មិនមែនការដឹងអារម្មណ៍ របស់ចិត្តទូទៅដែលជាចំណែកមួយជាមួយនឹងអារម្មណ៍ ដូចក្នុងកាលមុន ដូច្នោះ មគ្គចិត្ត និង ផលចិត្ត ទើបបាន ឈ្មោះថា អប្បនា គឺ ធម៌ដែលសម្រេចព្រះនិព្វាន ឬ ធម៌ ដែលដូចរត់ចូលកាន់ព្រះនិព្វាន តពីផលចិត្ត ២ ឬ ៣ គ្រា ក៏កើតភវង្គចិត្តតាមសមគួរ ក្រោយពីនោះ ទើបកើតបច្ចវេក្ខណញ្ញាណវីថិ ដែលធ្វើនាទីពិចារណា មគ្គ ផល និព្វាន

កិលេសដែលលះបានហើយ និង កិលេស ដែលនៅសល់កើតឡើងច្រើន ជុំវិញ តាមសមគួរតទៅ ។

រយៈការកើតឡើងរបស់គោត្រភូចិត្ត មគ្គចិត្ត និង ផលចិត្តដែល ប្រាកដក្នុងមគ្គវិថិ ទទួលយកព្រះនិព្វានជាអារម្មណ៍នេះ ប្រើពេលត្រឹមតែ មួយខណៈ ដូច្នោះចិត្ត ទាំង ៣ ដួង ទើបមិនប្រាកដដល់អ្នក សម្រេចធម៌ ក្នុងលក្ខណៈរបស់ចិត្តមួយដួង តែប្រាកដដោយការកើតឡើងថា :

-ការលះបោលសង្ខារ គឺរូបនាមដែលខ្ជួនកំណត់ដឹង និង សង្ខារគឺ ការកំណត់ដឹង រមែងប្រាកដ ។

-ការតាំងនៅមួយខណៈ ដូចរត់ចូលកាន់សភាវៈរលត់សង្ខារ រមែង ប្រាកដ ។

-ការពិចារណាដែលហៅថា **បច្ចវេក្ខណវិថិ** រមែងប្រាកដបន្ទាប់ ពីការសម្រេចសភាពរលត់សង្ខារហើយ ដូចមនុស្សដែលភ្ញាក់ពីការដេក លក់ស៊ប់ហើយ ឬ មនុស្សដែលលោតឡើងពីទឹក ។

-ក្នុងខណៈនោះ អ្នកដែលបានសិក្សា គោលធម៌យ៉ាងល្អ រមែង យល់ថា:

-សភាពដែលសម្រេចការរលត់សង្ខារ ជាគ្រាដំបូង គឺ គោត្រភូចិត្ត ។

-សភាពរលត់សង្ខារដែលតាំងមួយខណៈ គឺ មគ្គចិត្ត

-សភាពរលត់សង្ខារ មុននឹងកើតការពិចារណា ដោយបច្ចវេក្ខណវិថិ គឺ ផលចិត្ត ។

-សភាពពិចារណា គឺបច្ចវេក្ខណវីថិចិត្ត ។

✴មានសេចក្ដីទាក់ទងរឿងនេះ ក្នុងគម្ពីរវិសុទ្ធិមគ្គថា:

**[១]** យថា ហិ មហាមាតិកំ លង្ឃិត្វា បរតីរេ បតិដ្ឋាតុកាមោ បុរិសោ វេគេន ធាវិត្វា មាតិកាយ ឱរិមតីរេ រុក្ខសាខាយ ពន្ធិត្វា ឱលម្ពិតំ រជ្ជុំ វា យដ្ឋឹ វា គហេត្វា ឧល្លង្ឃិត្វា បរតីរនិន្នបោណបព្ភារកាយោ ហុត្វា បរតីរស្ស ឧបរិភាគំ បត្តោ តំ មុញ្ចិត្វា វេធមានោ បរតីរេ បតិត្វា សណិកំ បតិដ្ឋាតិ ។ **[២]** ឯវមេវាយំ យោគាវចរោបិ ភវយោនិគតិដ្ឋិតិនិវាសានំ បរតីរភូតេ និព្ពានេ បតិដ្ឋាតុកាមោ ឧទយព្វយានុបស្សនាទិនា វេគេន ធាវិត្វា អត្តភាវរុក្ខសាខាយ ពន្ធិត្វា ឱលម្ពិតំ រូបរជ្ជុំ វា វេទនាទីសុ អញ្ញតរទណ្ឌំ វា អនិច្ចន្តិ វា ទុក្ខន្តិ វា អនត្តាតិ វា អនុលោមាវជ្ជនេន គហេត្វា តំ អមុញ្ចមានោវ បឋមេន អនុលោមចិត្តេន ឧល្លង្ឃិត្វា ទុតិយេន បរតីរនិន្នបោណបព្ភារកាយោ វិយ និព្ពាននិន្នបោណបព្ភារមានសោ ហុត្វា តតិយេន បរតីរស្ស ឧបរិភាគំ បត្តោ វិយ ឥទានិ បត្តព្វស្ស និព្ពានស្ស អាសន្នោ ហុត្វា តស្ស ចិត្តស្ស និរោធេន តំ សង្ខារារម្មណំ មុញ្ចិត្វា គោត្រភុចិត្តេន វិសង្ខារេ បរតីរភូតេ និព្ពានេ បត្តិ ។ ឯការម្មណេ បន អលទ្ធាសេវនតាយ វេធមានោ សោ បុរិសោ វិយ ន តាវ សុប្បតិដ្ឋិតោ ហោតិ ។

តតោ មគ្គញ្ញាណេន បតិដ្ឋាតិ ។

“១. ឧបមាថា បុរសអ្នកត្រូវការនឹងលោតលេងប្រឡាយទឹកធំហើយទៅឈរនៅត្រង់ច្រាំងមួយទៀត ទើបរត់មកដោយរហ័ស ហើយចាប់សសៃខ្សែដែលចងព្យួរ នៅត្រង់មែកឈើ ឬទល់ជន្ទល់ ហើយលោតរំលងឡើងបន្ទន់ខ្លួន ទៅកាន់ច្រាំងផ្ទុយគ្នា កាលនៅលើច្រាំងហើយ ទើបដាក់សសៃខ្សែ ឬឈើជន្ទល់ និងត្រេតទៅត្រេតមកធ្លាក់ចុះ លើច្រាំងនោះហើយសន្សឹមៗ ត្រង់ខ្លួនឈរឡើង យ៉ាងណា ។

២. សូម្បីលោកអ្នកបដិបត្តិធម៌នេះ ក៏យ៉ាងនោះដូចគ្នា មានសេចក្ដីត្រូវការនឹងស្ថិតនៅក្នុងព្រះនិព្វាន ដែលជាច្រាំងផ្ទុយគ្នារបស់ភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ និងសត្តាវាស ៩ ទើបរត់មករហ័សដោយញាណ មាន**ឧទយព្វយញ្ញាណ**ជាដើម ហើយចាប់សសៃខ្សែគឺរូបដែលចងព្យួរទុកជាមួយនឹងមែកឈើ គឺ អត្តភាព ឬទល់ជន្ទល់ មានវេទនាខន្ធជាដើម យ៉ាងណាមួយថា មិនទៀង ជាទុក្ខ ឬ មិនមែនតួខ្លួនដោយអាវជ្ជនចិត្ត ដែលនៅខាងមុខអនុលោមញាណ នៅមិនទាន់លះសសៃខ្សែ គឺ រូប ឬ ជន្ទល់គឺ វេទនា ជាដើម ដោយអនុលោមចិត្ត ដួងទី ១ ( បរិកម្ម ) ហើយជាអ្នកមានចិត្តបង្អោនទៅកាន់ព្រះនិព្វាន ដោយអំណាចនៃអនុលោមចិត្តដួងទី ២ ( ឧបចារ ) ដូចបុរសអ្នកមានកាយច្អេង ទៅកាន់ច្រាំងខាងណោះ [ របស់ប្រឡាយទឹក ] ជាអ្នកនៅជិតព្រះនិព្វាន

*ដែលខ្វនទឹងគប្បីដល់ដោយអនុលោមចិត្ត ដួងទី ៣ ( អនុលោម ) ដូចបុរស ដែលលោតរំលងទៅដល់ចំណែកខាងលើរបស់ប្រាំងនោះ ហើយលះអារម្មណ៍ គឺ សង្ខារកាលអនុលោមចិត្តដួងទី ៣ នោះរលត់ចុះ ហើយធ្លាក់ចុះទៅក្នុងព្រះនិព្វាន ដែលរលត់សង្ខារដែលជាប្រាំងនោះ ដោយគោត្រភូចិត្ត តែព្រោះនៅមិនមាន ការធ្លាប់ឃើញក្នុងអារម្មណ៍ ព្រះនិព្វានត្រឹមមួយគ្រា ទើបនៅកម្រើក មិនតាំងមាំបានល្អ កាលទទួលលើកទី ១ ដូចបុរស អ្នកត្រេតទៅត្រេត មកនោះ បន្ទាប់ពីនោះ ទើបតាំងមាំ ដោយមគ្គញាណ" ។*

*ពាក្យឧបមាឧបមេយ្យដែលពោលទុកក្នុងគម្ពីរអដ្ឋកថា ជាក់ច្បាស់ យល់ងាយ ក្នុង**មជ្ឈិមបណ្ណាសកៈ មហាមាលុក្យបុត្តសូត្រ** និង **អង្គុត្តរ-និកាយ នវកនិបាត បញ្ចមសូត្រ** ជួបរឿងការកើតមគ្គញាណ ដូចត ទៅនេះ :*

**[១]** ឥធានន្ទ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ **[២]** សោ យទេវ តត្ថ ហោតិ រូបគតំ វេទនាគតំ សង្ខារគតំ វិញ្ញាណគតំ, តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ **[៣]** សោ តេហិ ធម្មេហិ ចិត្តំ បដិវាបេតិ ។**[៤]** សោ តេហិ ធម្មេហិ ចិត្តំ បដិវាបេត្វា អមតាយ ធាតុយា ចិត្តំ ឧបសំហរតិ

ឯតំ សន្តំ ឯតំ បណីតំ, យទិទំ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។

“១. ម្នាលអានន្ទ ភិក្ខុក្នុងធម្មវិន័យនេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ ហើយរមែងសម្រេចបឋមជ្ឈាន ដែលមានវិតក្កៈ មានវិចារៈ មានបីតិ និង សុខ ដែលកើតអំពីវិវេក ។

២. អ្នករមែងឃើញច្បាស់សភាវធម៌ទាំងនោះ គឺ រូប វេទនា សញ្ញា សង្ខារ និង វិញ្ញាណក្នុងខណៈសម្រេចបឋមឈាននោះថា មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាសរ ជាសេចក្ដីអាក្រក់ ជោកទាប ជាអាពាធ ជាវត្ថុដទៃ បែកធ្លាយទៅ សូន្យទទេ មិនមែនតួខ្លួន ។

៣. លោករមែងដកចិត្តចេញពីសភាវធម៌ទាំងនោះហើយ បង្អោនចិត្តទៅក្នុងអមតធាតុថា សេចក្ដីរលត់នេះស្ងប់ ប្រណិត ដ៏ជាទីស្ងប់នៃសង្ខារទាំងពួង លះឧបធិទាំងអស់ [ គឺ ខន្ធ កិលេស អភិសង្ខារ ដែលជាបុណ្យ បាប និង កាមគុណ ] អស់តណ្ហា ប្រាសចាកតម្រេក រលត់ទុក្ខ ។

សេចក្ដីនេះមិនមែនសំដៅដល់ការបរិកម្មថា ព្រះនិព្វានជាសភាវធម៌ស្ងប់ ប្រណិត តែជាការឃើញច្បាស់សភាពរលត់សង្ខារថា ស្ងប់ ប្រណិត និងប្រាកដ ច្បាស់ កាលកើតបច្ចវេក្ខណញ្ញាណ ដែលពិចារណា

ឃើញការរលត់ដូចពោល ដូចពាក្យអធិប្បាយក្នុងគម្ពីរអដ្ឋកថា របស់មជ្ឈិមបណ្ណាសកថា:

[១] មគ្គចិត្តំ និព្វានំ អារម្មណករណវសេនេវ ។[២] ឯតំ សន្តំ ឯតំ បណីតន្តិ ន ឯវំ វទតិ ។[៣] ឥមិនា បន អាការេន តំ បដិវិជ្ឈន្តោ តត្ថ ចិត្តំ ឧបសំហរតិ ។

“១. អ្នកសម្រេចធម៌ រមែងបង្អោនមគ្គចិត្ត ទៅកាន់ព្រះនិព្វាន ដោយការទទួលយកជាអារម្មណ៍នោះឯង ។

២. គេមិនបានបរិកម្ម យ៉ាងនេះថា ព្រះនិព្វានជាសភាពស្ងប់ប្រណិត ។

៣. តែកាលចាក់ធ្លុះព្រះនិព្វាននោះ ដោយលក្ខណៈស្ងប់ ប្រណិតនោះ រមែងឈ្មោះថា បង្អោនចិត្តទៅរកព្រះនិព្វាននោះ” ។

កាលអនុលោមញាណកើតឡើង ឃើញច្បាស់លក្ខណៈ ៤០ យ៉ាងណាមួយ ក្នុងអនិច្ចលក្ខណៈ ១០ ទុក្ខលក្ខណៈ ២៥ និង អនត្តលក្ខណៈ ៥ ហើយមគ្គញាណ រមែងកើតឡើងឃើញច្បាស់នូវព្រះនិព្វាន ដោយផ្ទុយគ្នា ជាមួយនឹងលក្ខណៈទាំងអស់នោះ ដូចគម្ពីរបដិសម្ភិទាមគ្គពោលថា:

[១] បញ្ចក្ខន្ធេ អនិច្ចតោ បស្សន្តោ អនុលោមិកំ ខន្តិំ បដិលភតិ ។

[២] បញ្ចន្នំ ខន្ធានំ និរោធោ និច្ចំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ ។

“១. អ្នកដែលឃើញច្បាស់ខន្ធ ៥ ថាមិនទៀង រមែងសម្រេច អនុលោមញាណ ។

២. អ្នកដែលឃើញច្បាស់ថា ការរលត់របស់ខន្ធ ៥ ជាព្រះនិព្វាន ដែលទៀង រមែងចុះកាន់អរិយមគ្គ” ។

ពាក្យថា បញ្ចក្ខន្ធេ ( ខន្ធ ៥ ) ក្នុងប្រយោគនេះ ជាពាក្យពោល រួមខន្ធទាំងអស់ ដែលបុគ្គលផ្សេងៗ គប្បីកំណត់ដឹង មិនមែនប្រាថ្នា សម្ដែងដល់ការឃើញច្បាស់ខន្ធ ៥ ក្នុងខណៈជាមួយគ្នា ជាការពិតហើយ អនុលោមញាណ រមែងកើតឡើងឃើញ ច្បាស់ខន្ធយ៉ាងណាមួយក្នុងខន្ធ ៥ ដែលជារូប ឬ នាមយ៉ាងណាមួយ ដូចក័ស្តុតាង ពីគម្ពីរវិសុទ្ធិមគ្គ ខាងដើមថា: រូបវន្តំ វា វេទនាទីសុ អញ្ញតរធម្មំ វា ( ចាប់សសៃខ្សែ គឺរូប ឬទល់ជន្ទល់មានវេទនាខន្ធជា ដើមយ៉ាង ណា មួយ )

ក្រៅពីនោះ ក្នុងគម្ពីរអដ្ឋកថា ច្រើនកន្លែងនៅពោលដល់គោត្រភូញាណ និង មគ្គញាណដែលកើតឡើងបន្ទាប់ពីអនុលោមញាណ ដែលឃើញ ច្បាស់រូប ឬនាមថា រូបាវុដ្ឋាតិ ( ចេញពីរូប ) អរូបាវុដ្ឋាតិ ( ចេញពីនាម ) មិនបានពោលទុកដោយត្រង់ថា មគ្គញាណកើតឡើងបន្ទាប់ពីគោត្រភូញាណ ដែលកើតបន្ទាប់ពីអនុលោមញាណ ដែលឃើញច្បាស់រូបនាម ទាំងអស់ ក្នុងខណៈជាមួយគ្នា យ៉ាងណាក៏ដោយ សេចក្ដីក្នុងគម្ពីរវិសុទ្ធិមគ្គថា: ឯកប្បហារេន បញ្ចហិ ខន្ធេហិ វុដ្ឋាតិ ( រមែងចេញពីខន្ធ ៥ ដោយខណៈ

តែមួយ ) ជាពាក្យពោលដោយអម ( សន្ធាយភាសិត ) ស្របតាមបុគ្គល អ្នកមានបញ្ញាចាស់ក្លា ដែលអាចសម្រេចវិបស្សនាញាណ និង មគ្គញាណ ដោយការបដិបត្តិ ត្រឹមមួយខណៈ ឬដោយការអង្គុយ ត្រឹមមួយភ្លែត ពិតហើយ ធម្មជាតិរបស់ចិត្តត្រូវទទួលយក អារម្មណ៍មួយក្នុងខណៈតែមួយ មិនអាចទទួលយកអារម្មណ៍ពីរក្នុង ខណៈតែមួយ ជាមួយគ្នាទេ ដូចគម្ពីរ មហាដីការបស់វិសុទ្ធិមគ្គពោលថា:

*[១]* យថាឧបដ្ឋិតេ បន រូបារូបធម្មេ តេសញ្ច បច្ចយេ បរិគ្គហេត្វា សង្ខេបេនេវ វិបស្សនាញាណំ ចារេន្តោ ឈាណុត្តរោ យថានិសន្នោវ ញាណាបដិបាដិយា ខិប្បមេវ សច្ចានិ បដិវិជ្ឈន្តោ ឯកប្បហារេន បញ្ចហិ ខន្ធេហិ វុដ្ឋាតិ នាម ។ *[២]* អញ្ញថា ឯកេនេវ លោកិយចិត្តេន បញ្ចន្នំ ខន្ធានំ បរិគ្គហបរិជាននាទីនំ អសម្ភវតោ ។ *[៣]* ន ហិ សនិទស្សនស-ប្បដិឃាទី ឯកជ្ឈំ អារម្មណំ កាតុំ សក្កា ។

“១. អ្នកដែលមានបញ្ញាចាស់ក្លាកំណត់ដឹងរូបធម៌ និងនាមធម៌ តាមដែលប្រាកដ ច្បាស់ព្រមដោយហេតុបច្ច័យរបស់ធម៌ទាំងនោះ ហើយ សម្រេចវិបស្សនាញាណ ចាក់ធ្លុះសច្ចៈដោយមួយរំពេចតាមលំដាប់ញាណ ដោយការអង្គុយមួយគ្រា ឈ្មោះថា ចេញពីខន្ធ ៥ ដោយខណៈតែ មួយ ។

២. មិនដូច្នោះហើយ បុគ្គលរមែងមិនអាចចេញពីខន្ធ ៥ បានព្រោះ មិនមានការទទួលដឹង និងការកំណត់ដឹងខន្ធ ៥ ដោយលោកិយចិត្តមួយ

ដូនប៉ុណ្ណោះ ។

៣. បន្ទាប់ពីបុគ្គលមិនអាចធ្វើអារម្មណ៍ដែលឃើញប៉ះខ្ទប់បានជាដើម ឲ្យជាអារម្មណ៍ព្រមគ្នាបាន" ។

សរុបសេចក្ដីក្នុងគម្ពីរបដិសម្ភិទាមគ្គ ដូចតទៅនេះ :-

-អនុលោមញាណ រមែងកើតឡើងឃើញច្បាស់រូបនាមយ៉ាងណានីមួយ ដែលកំពុងកើតរលត់ថា មិនទៀង ។

-គោត្រភូញាណ និង មគ្គញាណ រមែងកើតឡើងបន្ទាប់ពីអនុលោមញាណ ធ្វើនាទីឃើញច្បាស់សេចក្ដីរលត់របស់រូបនាម ដែលមិនទៀងទាំងអស់ ។

ក្នុងខណៈកើតវិបស្សនាញាណនោះ សេចក្ដីមិនទៀង ប្រាកដដោយការឃើញច្បាស់នូវការកើតរលត់របស់រូបនាម ដែលកំណត់ដឹង តែក្នុងខណៈកើតគោត្រភូញាណ មគ្គញាណ និង ផលញាណ ដែលទទួលយកព្រះនិព្វានជាអារម្មណ៍ សភាពរលត់សង្ខារប៉ុណ្ណោះ រមែងប្រាកដ ដោយមិនមានការកើតរលត់ទៀត ដូច្នោះ អ្នកឃើញច្បាស់ព្រះនិព្វាន ទើបឃើញថា ព្រះនិព្វានជាសភាពទៀង ព្រោះមិនមានការកើត រលត់តទៅទៀត ។

សេចក្ដីប្រាកដរបស់អនុលោមញាណ និង មគ្គញាណ ពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គទៀតថា:

**[១]** បញ្ចក្ខន្ធេ បលោកតោ បស្សន្តោ អនុលោមិកំ ខន្តិំ បដិលភតិ

។**[២]** បញ្ចន្នំ ខន្ធានំ និរោធោ អបលោកធម្មោ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ ។

*“១. អ្នកដែលឃើញច្បាស់ខន្ធ ៥ ថា បែកធ្លាយទៅ រមែងសម្រេចនូវអនុលោមញាណ ។*

*២ អ្នកដែលឃើញច្បាស់ថា ការរលត់នៃខន្ធ ៥ ជាព្រះនិព្វានដែលមានសភាពមិនបែកធ្លាយទៅ រមែងឈានចុះកាន់អរិយមគ្គ” ។*

**[១]**បញ្ចក្ខន្ធេ ទុក្ខតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ ។

**[២]** បញ្ចន្នំ ខន្ធានំ និរោធោ សុខំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ ។

*“១. អ្នកដែលឃើញខន្ធ ៥ ថាជាទុក្ខ រមែងលះអនុលោមញាណ ។*

*២. អ្នកដែលឃើញថា ការរលត់របស់ខន្ធ ៥ ជាព្រះនិព្វានដ៏ជាសុខ រមែងឈានចុះកាន់អរិយមគ្គ” ។*

**[១]**បញ្ចក្ខន្ធេ ភយតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ ។

**[២]** បញ្ចន្នំ ខន្ធានំ និរោធោ អភយំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ ។

*“១. អ្នកដែលឃើញខន្ធ ៥ ថា គួរភ័យ រមែងសម្រេចអនុលោមញាណ ។*

*២. អ្នកដែលឃើញថា ការរលត់របស់ខន្ធ ៥ ជាព្រះនិព្វាន ដែលមិនគួរភ័យ រមែងឈមចុះកាន់អរិយមគ្គ” ។*

**[១]**បញ្ចក្ខន្ធេ អនត្តតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ ។

*[២]* បញ្ចន្នំ ខន្ធានំ និរោធោ បរមត្ថំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ ។

*“១. អ្នកដែលឃើញខន្ធ ៥ ថា មិនមែនតួខ្លួន រមែងសម្រេចនូវអនុលោមញាណ ។*

*២. អ្នកដែលឃើញច្បាស់ថា ការរលត់ខន្ធ ៥ ជាព្រះនិព្វានដែលជាសភាពខ្ពស់បំផុត រមែងឈានចុះកាន់អរិយមគ្គ” ។*

*[១]*បញ្ចក្ខន្ធេ តុច្ឆតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ ។

*[២]* បញ្ចន្នំ ខន្ធានំ និរោធោ អតុច្ឆំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ ។

*“១. អ្នកដែលឃើញខន្ធ ៥ ថា សូន្យទទេ រមែងសម្រេចអនុលោមញាណ ។*

*២. អ្នកដែលឃើញច្បាស់ថា ការរលត់របស់ខន្ធ ជាព្រះនិព្វានដែលសូន្យទទេ រមែងឈានចុះកាន់អរិយមគ្គ” ។*

*សេចក្តីពីគម្ពីរបដិសម្ភិទាមគ្គ ៦ ផ្នែកខាងដើមនេះ ចែកបានដូចនេះ*

*-ពីរផ្នែកដំបូង សម្តែងការកើតឡើងរបស់មគ្គ ដែលជា**អនិមិត្តវិមោក្ខ** ដោយឃើញច្បាស់អនិច្ចលក្ខណៈ ជាអនុលោមញាណ ។*

*-ពីរផ្នែកកណ្តាល សម្តែងការកើតឡើងរបស់មគ្គ ដែលជា **អប្បណិហិតវិមោក្ខ** ដោយឃើញច្បាស់ទុក្ខលក្ខណៈ ជាអនុលោមញាណ ។*

*-ពីរផ្នែកខាងចុង សម្តែងការកើតឡើងរបស់មគ្គ **ដែលជាសុញ្ញតវិមោក្ខ** ដោយឃើញច្បាស់អនត្តលក្ខណៈ ជាអនុលោមញាណ ។*

នៅក្នុងគម្ពីរបដិសម្ភិទាមគ្គ នៅពោលដល់សេចក្ដីនេះ ៣៤ ផ្នែកទៀតទុកក្នុងវិបស្សនាកថា បើពោលដោយសង្ខេប គឺការឃើញច្បាស់លក្ខណៈ ៤០ គឺ អនិច្ចលក្ខណៈ ១០ ទុក្ខលក្ខណៈ ២៥ និងអនត្តលក្ខណៈ ៥ តាមដែលពោលទុកក្នុង បដិសង្ខាញាណ ( បរិច្ឆេទទី ៦ ទំព័រ.......) ។

សេចក្ដីប្រាកដរបស់មគ្គ និង ផល ដែលទទួលយកនូវព្រះនិព្វានជាអារម្មណ៍ ពោលទុកក្នុងគម្ពីរមិលិន្ទបញ្ហាថា:

**[១]** តស្ស តំ ចិត្តំ អបរាបរំ មនសិការោតិ បវត្តំ សមតិក្កមិត្វា អប្បវត្តំ ឱក្កមតិ ។ **[២]** អប្បវត្តមនុប្បត្តោ មហារាជ សម្មាបដិបន្នោ និព្វានំ សច្ឆិករោតីតិ វុច្ចតិ។

“១. ចិត្តនោះ របស់អ្នកបដិបត្តិធម៌ ដែលកំណត់ដឹងយ៉ាងតក្ជាប់នោះ រមែងឆ្លងផុតនូវក្រសែរូបនាម ឈានចុះកាន់សភាវៈប្រាសចាកក្រសែរូបនាម ។

២. មហាបពិត្រ បុគ្គលដែលបដិបត្តិដោយប្រពៃ ដែលសម្រេចសភាវៈប្រាសចាកក្រសែរូបនាម រមែងហៅថា ឃើញច្បាស់ព្រះនិព្វាន” ។

ក្នុងខណៈកើតវិបស្សនាញាណ មុននឹងឃើញព្រះនិព្វាន អ្នកបដិបត្តិធម៌បានកំណត់ដឹងក្រសែរូបនាមដែលកើតឡើង និងរលត់ទៅយ៉ាងតក្ជាប់ មិនអស់ទីបំផុត ដូចមើលក្រសែទឹក ដែលហូរទៅមិនដាច់ចន្លោះ លំដាប់នោះបញ្ញា ដែលនាំទៅកាន់ព្រះនិព្វាន ប្រាកដច្បាស់ជាពិសេស ធ្វើឲ្យគេមិនឃើញច្បាស់ក្រសែរូបនាម តាមដែលកំណត់ដឹង ដូចរត់ចូលទៅរកសភាព

*ដែលផុយគ្នាជាមួយនឹងក្រសែរូបនាម គឺ សេចក្ដីរលត់ទៅរបស់រូបនាម និងការកំណត់ដឹង ចិត្តដែលរត់ចូលរកព្រះនិព្វាន ក៏គឺគោត្រភូចិត្ត មគ្គចិត្ត និងផលចិត្ត បុគ្គលអ្នកប្រកបដោយចិត្ត ដូចពោល ឈ្មោះថា ឃើញច្បាស់ព្រះនិព្វាន ។*

*ក្នុងព្រះសូត្រជាច្រើន មានអម្ពដ្ឋសូត្រជាដើម ព្រះបរមសាស្ដាត្រាស់ដល់សេចក្ដីប្រាកដរបស់មគ្គញាណថា:*

សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ, ឯវមេវ ព្រាហ្មណស្ស ពោក្ខរសាតិស្ស តស្មិញ្ញេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ, សព្វន្តំ និរោធធម្មន្តិ។

*“ភ្នែកឃើញធម៌ដែលប្រាសចាកធូលីប្រាសចាកមន្ទិល បានកើតឡើងហើយ ដល់ព្រាហ្មណ៍***ពោក្ខរសាតិ*** ថា ធម៌ណាមួយ មានសភាពកើតឡើងជាធម្មតា ធម៌ទាំងពួងនោះ មានសភាពរលត់ទៅជាធម្មតា ក្នុងទីអង្គុយនោះឯង ដូចសំពត់សាដក ប្រាសចាកមន្ទិល គួរទទួលទឹកជ្រលក់ពណ៌ដោយល្អ ដូច្នោះ” ។*

*ក្នុងខណៈដែលមគ្គប្រាកដឡើង អ្នកសម្រេចធម៌ មិនបានពិចារណាថា “ធម៌ដែលមានសភាព កើតឡើងទាំងអស់ មានសភាពរលត់ទៅ ជាពិតប្រាកដ” តែជាការឃើញច្បាស់ព្រះនិព្វាន ដែលរលត់សង្ខារ មានសភាពកើតឡើងទាំងអស់ លោករមែងជ្រាបក្នុងខណៈកើតនូវបច្ចវេក្ខណញាណ*

ដែលពិចារណាតមកថា បានសម្រេចការរលត់សង្ខារ គឺ អារម្មណ៍ ខ្ទង់ កំណាត់ដឹង និងវិបស្សនាចិត្ត និងជ្រាបទៀតថា នឹងឃើញច្បាស់ ការរលត់សង្ខារទាំងអស់ ក្នុងខណៈដែលរលត់ខន្ធបរិនិព្វាន ទាំងនៅជ្រាបថា សង្ខារ ដែលកើតឡើងទាំងអស់ មានសភាពរលត់ទៅជាពិតប្រាកដ ដូច្នោះ អ្នកដែលសម្រេចមគ្គផលហើយ ទើបឃើញច្បាស់នូវការកើតរលត់ ដោយឧទយព្វយញាណ ក្រោយពីពិចារណា ដោយបច្ចវេក្ខណញាណហើយ និង ឧទយព្វយញាណ ក៏ជាញាណដំបូងរបស់ព្រះអរិយបុគ្គល ។

សេចក្តីសំដៅរបស់ភ្នែកឃើញធម៌ **(ធម្មចក្ខុ)** ជួបក្នុងគម្ពីរអដ្ឋកថា ថា:

**[១]** ធម្មចក្ខុន្តិ ឯត្ថ សោតាបត្តិមគ្គោ អធិប្បេតោ ។ **[២]** តស្ស ឧប្បត្តិអាការទស្សនត្ថំ យំ កិញ្ចិ សមុទយធម្មំ, សព្វន្តំ និរោធធម្មន្តិ អាហ។ **[៣]** តញ្ហិ និរោធំ អារម្មណំ កត្វា កិច្ចវសេន ឯវំ សព្វសង្ខតំ បដិវិជ្ឈន្តំ ឧប្បជ្ជតិ ។

“១. ពាក្យថា **ធម្មចក្ខុ** ក្នុងអម្ពដ្ឋសូត្រនេះ សំដៅដល់ សោតាបត្តិមគ្គ ។

២. ព្រះអង្គទ្រង់ត្រាស់ថា យំ កិញ្ចិ សមុទយធម្មំ, សព្វន្តំ និរោធធម្មំ ( ធម៌ណាមួយ មានសភាពកើតឡើងជាធម្មតា ធម៌ទាំងពួងនោះ មានសភាពរលត់ទៅជាធម្មតា) ដើម្បីសម្តែងលក្ខណៈ នៃការកើតឡើងរបស់ សោតាបត្តិមគ្គនោះ ។

៣. ពិតហើយ មគ្គញាណនោះ ទទួលយកព្រះនិព្វានជាអារម្មណ៍ កើតឡើង ចាក់ធ្លុះសង្ខតធម៌ទាំងអស់យ៉ាងនេះ ដោយសេចក្ដីជានាទី” ។

ការសម្ដែងមគ្គវីថិទុកក្នុងគម្ពីរអដ្ឋកថា និងគម្ពីរនេះ មានប្រយោជន៍ ដើម្បីឲ្យ អ្នកបដិបត្តិបានយល់រឿងវីថិចិត្ត តែមិនមានអ្នកណា ដឹងច្បាស់ ចំនួនចិត្ត ដែលមានអារម្មណ៍ដូចគ្នា ក្នុងវីថិចិត្តមួយៗ ដូច្នោះ ក្នុងទីនេះ ទើបមិនពោលដល់រឿងចំនួន ជវនចិត្ត ដែលកើតឡើងក្នុងមគ្គវីថិជាដើម សូមឲ្យអ្នកអានប្រៀបធៀបចំណុចសំខាន់ តាមដែលប្រាកដក្នុងព្រះបាលី និង អដ្ឋកថា ជាមួយនឹងការជំនាញរបស់ខ្លួន ដូច្នេះ :

-ការកើតឡើង របស់វិបស្សនា តាមលំដាប់ តាំងពីដើមរហូតដល់ **អនុលោមញាណ** ។

-ការកើតឡើង របស់**វុដ្ឋានគាមិនីវិបស្សនា** ។

-ការប្ដូរទៅកាន់អារម្មណ៍ ដែលរលត់រូបនាម បន្ទាប់ពីវិបស្សនាចិត្ត ដួងចុងក្រោយ ដែលឈ្មោះថា **អនុលោម** ។

-ការកើតឡើង របស់បច្ចវេក្ខណញាណ ។

-ការតាំងនៅក្នុងឧទយព្វយញាណ កាលកំណត់ដឹងរូបនាម បន្ទាប់ពីបច្ចវេក្ខណញាណ ។

# បច្ចវេក្ខណញ្ញាណ

# បច្ចវេក្ខណញ្ញាណ

អ្នកឃើញច្បាស់ព្រះនិព្វាន ដោយមគ្គញ្ញាណ និង ផលញ្ញាណហើយ រមែងត្រឡប់មកពិចារណាមគ្គ ផល និងនិព្វាន ដែលខ្លួនសម្រេចហើយ អ្នកដែលមានការដឹងគោលធម៌ រមែងពិចារណាកិលេស ដែលត្រូវលះ និងកិលេសដែលនៅសល់ បន្ទាប់ពីនោះ បញ្ញាដែលកើតរួមជាមួយនឹងការពិចារណាដូចពោល ឈ្មោះថា បច្ចវេក្ខណញ្ញាណ ដូចគាថាសរុបក្នុងគម្ពីរអភិធម្មត្ថសង្គហៈថា :

**មគ្គំ ផលញ្ច និព្វានំ បច្ចវេក្ខតិ បណ្ឌិតោ**
**ហីនេ កិលេសេ សេសេ ច បច្ចវេក្ខតិ វា ន វា ។**

“បណ្ឌិតរមែងពិចារណាមគ្គ ផល និងនិព្វាន និងអ្នកខ្លះ ក៏ពិចារណាកិលេស ដែលខ្លួនលះបានហើយ និងដែលនៅសល់ [គឺដែលនៅលះមិនទាន់បាន] ក៏មានខ្លះ” ។

ម៉្យាងទៀត បច្ចវេក្ខណញ្ញាណនេះ នៅរាប់បញ្ចូលក្នុងញ្ញាណ-ទស្សនវិសុទ្ធិទៀតផង ក្រៅពីនោះ បច្ចវេក្ខណញ្ញាណ ៣ យ៉ាងដំបូង គឺការពិចារណាមគ្គ ផល និង និព្វាន ត្រូវកើតឡើងយ៉ាងពិតប្រាកដ តែការពិចារណា ២ យ៉ាងក្រោយ គឺការ ពិចារណាកិលេស ដែលខ្លួនលះបានហើយ និងដែលនៅលះមិនទាន់បាន មិនបានកើតឡើងយ៉ាងពិតប្រាកដ ព្រោះអ្នកដែលយល់ថា មគ្គណា លះកិលេសបាន ទើបនឹង ពិចារណាកិលេសដែលខ្លួនលះបានហើយ ចំណែកអ្នកមិនធ្លាប់យល់មកពីមុន ក៏នឹងពិចារណា

មិនបាន ។ រឿងនេះ ពោលទុក ដោយត្រង់ ក្នុងគម្ពីរអដ្ឋកថា ច្រើនកន្លែង ដូចនាំសាធកៈពីព្រះសូត្រ និងអដ្ឋកថាមកអាងទុកដូចតទៅនេះ :

[១] តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ " កោសុ នាម មេ ធម្មោ អជ្ឈត្តំ អប្បហីនោ យេន មេ ឯកទា លោភធម្មាបិ ចិត្តំ បរិទាយ តិដ្ឋន្តិ, ទោសធម្មាបិ ចិត្តំ បរិទាយ តិដ្ឋន្តិ, មោហធម្មាបិ ចិត្តំ បរិទាយ តិដ្ឋន្តី"តិ ។

[២] សោ ឯវំ ខោ តេ មហានាម ធម្មោ អជ្ឈត្តំ អប្បហីនោ យេន យេន តេ ឯកទា លោភធម្មាបិ ចិត្តំ បរិទាយ តិដ្ឋន្តិ, ទោសធម្មាបិ ចិត្តំ បរិទាយ តិដ្ឋន្តិ, មោហធម្មាបិ ចិត្តំ បរិទាយ តិដ្ឋន្តិ ។

"១. [ព្រះបាទសក្យ ព្រះនាមថា មហានាម អ្នកជាព្រះសកទាគាមី បានក្រាប ទូលព្រះដ៏មានព្រះភាគថា] ខ្ញុំព្រះអង្គ កើតសេចក្ដីសង្ស័យ យ៉ាងនេះថា ធម៌ឈ្មោះអ្វីទៅ ដែលខ្ញុំព្រះអង្គនៅលះមិនទាន់បានដាច់ស្រឡះ ក្នុងខាងក្នុង ដែលជាហេតុឲ្យលោភធម៌ក្ដី ទោសធម៌ក្ដី មោហធម៌ក្ដី នៅគ្របសង្កត់ចិត្តរបស់ខ្ញុំព្រះអង្គទុកអស់កាលយូរ ។

២. [ព្រះដ៏មានព្រះភាគត្រាស់ថា] ម្នាលមហានាម ធម៌ដែលអ្នក លះមិនទាន់បានដាច់ស្រឡះ ខាងក្នុង ដែលជាហេតុឲ្យលោភធម៌ក្ដី ទោសធម៌ក្ដី មោហធម៌ក្ដី នៅគ្របសង្កត់ចិត្តក្ដី របស់អ្នកទុកបានអស់កាលយូរ ក៏គឺ លោភធម៌ ទោសធម៌ និង មោហធម៌នោះឯង" ។

[១] យំ កិរ រាជា សកទាគាមិមគ្គេន លោភទោសមោហា និរវសេសា បហីយន្តីតិ សញ្ញី អហោសិ ។ អយំ អប្បហីនំ មេ អត្ថីតិ

ជានាតិ ។ អប្បហីនកំ ឧបាទាយ បហីនកំ បុន បច្ចុទ្តោ វា វត្តតី"តិ សញ្ញី ហោតិ ។[២] អរិយសាវកស្ស ឯវំ សន្ទេហោ ឧប្បជ្ជតីតិ ។[៣] អាម ឧប្បជ្ជតិ ។ កស្មា ។ បណ្ណត្តិយា អកោវិទត្តា ។ អយំ កិលេសោ អសុមគ្គវជ្ឈោតិ" ឥមិស្សា បណ្ណត្តិយា អកោវិទស្ស ហិ អរិយ-សាវកស្សាបិ ឯវំ ហោតិ ។ [៤] កឹ តស្ស បច្ចវេក្ខណា នត្ថីតិ ។ [៥] អត្ថិ ។ សា បន ន សព្វេសំ បរិបុណ្ណា ហោតិ ។ [៦] ឯកោ ហិ បហិនកិលេសមេវ បច្ចវេក្ខតិ, ឯកោ អវសិដ្ឋកិលេសមេវ, ឯកោ មគ្គមេវ, ឯកោ ផលមេវ, ឯកោ និព្វានមេវ ។[៧] ឥមាសុ បញ្ចសុ បច្ចវេក្ខណាសុ ឯកោ វា ទ្វេ វា នោ លទ្ធុំ ន វដ្ដន្តិ ។

*"១. ដូចបានស្ដាប់មកថា ព្រះរាជាព្រះអង្គនេះ ទ្រង់សម្គាល់ថា សកទាគាមិមគ្គ លះសេចក្ដីលោភ សេចក្ដីក្រោធ និង សេចក្ដីវង្វេងបាន មិនមានសេសសល់ ព្រះអង្គទ្រង់ជ្រាបថា នៅមានកិលេស ដែលលះមិនទាន់បានដាច់ស្រឡះ ទើបសម្គាល់ថា កិលេសដែលលះបានហើយ វិលត្រឡប់មកទៀត ក្នុងខាងក្រោយ ដោយអាស្រ័យ កិលេសដែលនៅលះមិនទាន់បាន ។*

*២. សួរថា សេចក្ដីសង្ស័យយ៉ាងនេះ រមែងកើតបានដល់អរិយសាវកឬ?*

*៣. ឆ្លើយថា ត្រឹមត្រូវហើយ រមែងកើតបាន ព្រោះជាអ្នកមិនឈ្លាសក្នុង [ ទេសនា ] បញ្ញត្តិ បន្ទាប់ពីអរិយសាវក អ្នកមិនឆ្លាតក្នុងទេសនាបញ្ញត្តិនេះ ថាជា កិលេសដែលត្រូវលះបានដាច់ស្រឡះ ដោយ*

មគ្គឯណោះ រមែងកើតការសង្ស័យបាន ។

៤. សួរថា លោកមិនមានបច្ចវេក្ខណញ្ញាណឬ?

៥. ឆ្លើយថា មានតែបច្ចវេក្ខណញ្ញាណនោះ មិនបានបរិបូណ៌ ដល់គ្រប់រូប ។

៦. ព្រោះអ្នកខ្លះពិចារណាចំពោះកិលេស ដែលខ្លួនលះបានហើយ អ្នកខ្លះ ពិចារណាចំពោះកិលេសដែលនៅសល់ អ្នកខ្លះពិចារណាចំពោះមគ្គ អ្នកខ្លះពិចារណា ចំពោះផល អ្នកខ្លះពិចារណាចំពោះព្រះនិព្វាន ។

៧. ការពិចារណាមួយ ឬពីរយ៉ាង ក្នុងការពិចារណា ៥ យ៉ាងនេះ គួរមានបាន យ៉ាងពិតប្រាកដ" ។

សេចក្តីខាងដើម ពោលទុកក្នុងគម្ពីរអដ្ឋកថារបស់**មូលបណ្ណាសក** ដែលឃើញថា បច្ចវេក្ខណវិធី មានបានមួយវិថីជាយ៉ាងតិច តែក្នុងគម្ពីរអដ្ឋកថាច្បាប់ដទៃពោល ទុកផ្ទុយគ្នាថា ការពិចារណាមគ្គ ផល និង និព្វាន មានយ៉ាងពិតប្រាកដ ចំណែកការ ពិចារណាកិលេស ដែលខ្លួនលះបានហើយ និងកិលេសដែលនៅលះមិនបាននោះ មិនប្រាកដថា នឹងមាន ឬមិនមាន ក៏បានយ៉ាងណាក៏ដោយ ការដឹងច្បាស់ថា មានព្រះអរិយ ដែលកើតនូវបច្ចវេក្ខណវិថីមួយប៉ុណ្ណោះ មិនមែនជាវិស័យរបស់មនុស្សទូទៅទេ តែជាវិស័យរបស់អ្នក ដែលអាចដឹងវារចិត្តរបស់ព្រះអរិយៈគ្រប់រូប ក្នុងព្រះសាសនានេះបាន ដូច្នោះ ទើបមិនគួរបដិសេធ សេចក្តីក្នុងគម្ពីរអដ្ឋកថារបស់មូលបណ្ណាសក ដោយអាងថា មិនស្របជាមួយនឹងគម្ពីរអដ្ឋកថា

ច្បាប់ដទៃ ។



# កិលេសដែលខ្លួនលះបានហើយ

តទៅនេះ នឹងពោលដល់កិលេស ដែលត្រូវលះដោយមគ្គ ៤ តាមសមគួរ ដើម្បីឲ្យអ្នកបដិបត្តិធម៌ងាយយល់ ទេសនាបញ្ញត្តិ ដែលទាក់ទងជាមួយនឹងការលះកិលេស ដូចសេចក្តីក្នុង គម្ពីរអដ្ឋកថាថា :

[១] សំយោជនេសុ តាវ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ បហាយគមនីយា ច កាមរាគបដិឃាតិ ឯតេ បញ្ច ធម្មា បឋមញាណវជ្ឈា ។ [២] សេសា កាមរាគបដិឃា ឱឡារិកា ទុតិយញាណវជ្ឈា ។[៣] សុខុមា ញាណវជ្ឈា ។[៤] រូបរាគឧយោ បញ្ចបិ ទុតិយញាណវជ្ឈា ឯវំ ។

"លំដាប់ខាងដើម ក្នុងសំយោជនៈ គប្បីជ្រាបថា :-

១. ធម៌ ៥ ពួកនេះ គឺ **សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស** ព្រមទាំង **កាម រាគ** និង **បដិឃ** ដែលឲ្យទៅកើតក្នុងអបាយ លះបង់បានដោយញាណទី ១ ( សោតាបត្តិ មគ្គញាណ ) ។

២. **កាមរាគ** និង**បដិឃ** ដែលដ៏គ្រោតគ្រាត ដែលនៅសល់ លះបង់បាន ដោយញាណទី ២ ( សកទាគាមិមគ្គញាណ ) ។

*៣. **កាមរាគ និងបដិឃ**យ៉ាងល្អិត លះបានដោយញាណទី ៣ ( អនាគាមិមគ្គញាណ ) ។*

*៤. **សំយោជន ៥** យ៉ាង មានរូបរាគជាដើម **[រូបរាគ អរូបរាគ មាន ឧទ្ធច្ច** និង **វិចិកិច្ឆា]** លះបង់បាន ដោយញាណទី ៤ ដោយពិត ( អរហត្តមគ្គញាណ )” ។*

*[១]* កិលេសេសុ ទិដ្ឋិវិចិកិច្ឆា បឋមញាណវជ្ឈា ។*[២]* ទោសោ តតិយញាណវជ្ឈោ ។ *[៣]* លោភមោហមានថីនឧទ្ធច្ចអហិរិកអនោត្តប្បានិ ចតុត្ថញាណវជ្ឈានិ ។

*“ក្នុងកិលេសទាំងឡាយ គប្បីជ្រាបថា :*

*១. **ទិដ្ឋិ** និង **វិចិកិច្ឆា** លះបង់បាន ដោយញាណទី ១ ។*

*២. **ទោស** លះបង់បាន ដោយញាណទី ៣ ។*

*៣. **លោភ មោហ មាន ថីន ឧទ្ធច្ច អហិរិក និង អនោត្តប្ប** លះបង់បានដោយ ញាណទី ៤” ។*

*[១]* មិច្ឆត្តេសុ មិច្ឆតេសុ មិច្ឆាទិដ្ឋិ មុសាវាទោ មិច្ឆាកម្មន្តោ មិច្ឆាអាជីវោតិ ឥមេ បឋមញាណវជ្ឈា ។*[២]* មិច្ឆាសង្កប្បោ មិសុណាវាចា ផរុសវាចា ឥមេ តតិយញាណវជ្ឈា ។ *[៣]* សម្ផប្បលាបមិច្ឆាវាយាម-សតិសមាធិវិមុត្តិញាណានិ ចតុត្ថញាណវជ្ឈានិ ។

*“ក្នុងមិច្ឆត្តធម៌ទាំងឡាយ គប្បីជ្រាបថា :-*

*១. **មិច្ឆាទិដ្ឋិ មុសាវាទ មិច្ឆាកម្មន្ត** និង**មិច្ឆាអាជីវ** ៤ យ៉ាងនេះ*

២. លះបង់បាន ដោយញាណទី ១ ។

២. **មិច្ឆាសង្កប្ប បិសុណាវាចា និងផរុសវាចា** ៣ យ៉ាងនេះ លះបង់បានដោយញាណទី ៣ ។ ម្យ៉ាងទៀត គប្បីជ្រាបថា ចេតនាជាវាចា ក្នុងរឿងនេះ ។

៣. **សម្ផប្បលាប មិច្ឆាវាយាម មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាវិមុត្តិ** និង**មិច្ឆាញាណ** លះបង់បានដោយញាណទី ៤" ។

ពាក្យថា "ម្យ៉ាងទៀត គប្បីជ្រាបថា ចេតនាជាវាចា ក្នុងរឿងនេះ" មានន័យថា សម្ដេងនិយាយ គឺវាចាដោយត្រង់ជារូប ដែលមិនអាចលះបង់ដោយមគ្គបាន តែកុសលចេតនា ដែលញុំាងឲ្យកើតសម្ដេងនិយាយជាធម៌ដែលលះបានដោយមគ្គ ដូច្នោះទើប ពោលថា អកុសលចេតនា ជាមុសាវាទ បិសុណាវាចា និងផរុសវាចា ព្រោះកាលមិន មានអកុសលចេតនា ក៏កើតមុសាវាទជាដើម មិនបាន វៀរតែការពោលផរុសវាចា របស់ព្រះបិលិន្ទវច្ឆ ដែលកើតពីទម្លាប់ ( វាសនា ) ។

ពាក្យថា "**សម្ផប្បលាប មិច្ឆាវាយាម មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាវិមុត្តិ** និង **មិច្ឆាញាណ** លះបង់បាន ដោយញាណទី ៤" ។

គប្បីជ្រាបសេចក្ដីសំដៅនោះ ថា :

-មិច្ឆាវាចា គឺអកុសលចេតនាដែលជាវចីទុច្ចរិត ៤ ។

-មិច្ឆាកម្មន្ត គឺអកុសលចេតនាដែលជាកាយទុច្ចរិត ៣ ។

-មិច្ឆាអាជីវ គឺអកុសលចេតនាដែលជាកាយទុច្ចរិត ៣ វចីទុច្ចរិត

*៤ ដែលជាប់ទាក់ទងជាមួយការចិញ្ចឹមជីវិត ។*

*-មិច្ឆាសតិ គឺអកុសលចិត្តុប្បាទ ដែលមានសញ្ញាជាប្រធាន កើតឡើង ដោយរឭកដល់វត្ថុ ដែលមិនល្អទាក់ទងនឹងផ្លូវលោក ដូច បុត្រ ភរិយា សេចក្តីសុខសប្បាយ ការឈ្លោះទាស់ទែង ដូចនេះ ជាដើម ។*

*-មិច្ឆាញាណ គឺមោហៈ ដែលគិតរកផ្លូវធ្វើអកុសល ឬរិះគិតដល់វិធីធ្វើអកុសល ដែលកើតឡើងហើយថា ជាវត្ថុ ដែលត្រឹមត្រូវ ( ការដឹងដែលប្រព្រឹត្តទៅមិនត្រឹមត្រូវ ) ។*

*-មិច្ឆាវិមុត្តិ គឺសេចក្តីសម្គាល់ខ្លួន ដែលនៅមិនទាន់រួចផុតពីកិលេសថារួចផុតហើយ ឬសម្គាល់ធម៌ ដែលនៅមិនទាន់រួចផុតថា ជាធម៌ រួចផុត ដោយអត្ថធម៌គឺ លោកចិត្តុប្បាទ បែកបាន ២ យ៉ាង គឺ :*

*-មិច្ឆាវិមុត្តិ ដែលឲ្យទៅកើតក្នុងអបាយ លះបានដោយញាណទី ១*

*-មិច្ឆាវិមុត្តិ ដែលមិនឲ្យទៅកើតក្នុងអបាយ ដែលជាប់ដោយកាមរាគៈប្រភេទគ្រោតគ្រាត និង ល្អិត លះបានដោយញាណទី ២ និងទី ៣ ។*

*-មិច្ឆាវិមុត្តិ ដែលជាប់ដោយភវរាគ លះបានដោយញាណទី ៤ អត្ថធម៌របស់ មិច្ឆត្តធម៌ដ៏សេសប្រាកដច្បាស់ហើយ ។*

*[១]* លោកធម្មេសុ បដិឃោ តតិយញាណវជ្ឈោ ។*[២]* អនុសយោ ចតុត្ថញាណវជ្ឈោ ។ *[៣]* យសេ ច បសំសាយ ច អនុសយោ តតិយ-ញាណវជ្ឈោតិ ឯកោ ។

*"ក្នុងលោកធម៌ទាំងឡាយ គប្បីជ្រាបថា :*

១. បដិឃៈ ( ការថ្នាំងថ្នាក់ចិត្ត ) លះបានដោយញាណទី ៣ ។

២. អនុសយ (ការដេកត្រាំ ) លះបានដោយញាណទី ៤

៣. អាចារ្យពួកខ្លះពោលថា ការដេកសម្ងំក្នុងឈ្មោះ សម្មេង និងការសរសើរ លះបង់បានដោយញាណទី ៣" ។

[គម្ពីរវិសុទ្ធិមគ្គច្បាស់ខ្លះ មានសេចក្តីថា **យសេ ច បសំសាយ ច អនុនយោ ចតុត្ថញាណវជ្ឈោតិ ឯកេ** ( អាចារ្យពួកខ្លះ ពោលថា សេចក្តីត្រេកអរក្នុងឈ្មោះសម្មេង និង ការសរសើរ លះបង់បាន ដោយញាណទី ៤ ) សេចក្តីនេះ មិនផ្សេងគ្នាពីប្រយោគខាងដើម ដែលជាមតិដោយទូទៅ **( សម្មាវទ )** ទើបគួរ មានរូបថា **តតិយញាណវជ្ឈោ** ( លះបង់បាន ដោយញាណទី ៣ ) តាមមតិរបស់អាចារ្យពួកខ្លះ ( ឯកេវាទ )] ។

ម្យ៉ាងទៀត សេចក្តីកំណាញ់ដែលហៅថា **មច្ឆរិយ** លះបង់បានដោយសោតាបត្តិមគ្គញាណ ។ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :

មច្ឆរិយានិ បឋមញាណវជ្ឈានេវ ។

"មច្ឆរិយ លះបង់បានដោយញាណទី ១ នោះឯង" ។

## "មច្ឆរិយៈ ៥ ប្រភេទ"

( ពោលទុកក្នុងគម្ពីរអដ្ឋសាលិនីថា: )

១. **អាវាសមច្ឆរិយ** ការកំណាញ់ទីលំនៅ គឺសេចក្តីមិនត្រូវការឲ្យបុគ្គលដទៃ ចូលមកនៅក្នុងវត្ត ឬកន្លែងរបស់ខ្លួន ឬត្រូវការឲ្យអ្នកដែលមកនៅហើយ ប្តូរទៅទីដទៃ មិនមែនសេចក្តីមិនត្រូវការឲ្យមនុស្សអាក្រក់

មកស្នាក់អាស្រ័យ ។

**២. កុលមច្ឆរិយ** សេចក្តីកំណាញ់ត្រកូល គឺ សេចក្តីមិនត្រូវការឲ្យមនុស្សស្និទ្ធស្នាលរបស់ខ្លួន ដែលជាទាយក ទាយិកា ញាតិមិត្ត ជាដើម ទៅគប់រកបុគ្គលដទៃ មិនមែនសេចក្តីមិនត្រូវការឲ្យមនុស្សអាក្រក់មកគប់រកខ្លួន ។

**៣. លាភមច្ឆរិយ** សេចក្តីកំណាញ់លាភ គឺ សេចក្តីត្រូវការបានលាភ តែម្នាក់ឯង មិនត្រូវការឲ្យអ្នកដទៃបានលាភដូចខ្លួន មិនមែនការមិនត្រូវការនឹងបានលាភ របស់ភិក្ខុដែលផ្តាប់ផ្គុនត្រកូលហើយធ្វើឲ្យឧបាសកឧបាសិកា មានសទ្ធាជ្រះថ្លា និង មិនមែនការធាធៅបុគ្គលដទៃ កាលខ្លួនបានលាភហើយ ក្រៅពីនោះ នៅជាការមិន បែងចែកបច្ច័យ ៤ ដែលខ្លួនមានគ្រប់ល្មមហើយ ដល់មិត្តសព្រហ្មចារី ចំណែកការមិនឲ្យវត្ថុ ដែលខ្លួនហួងហែង មិនចាត់ជាមច្ឆរិយ តែត្រឹមជាលោភ ព្រោះមច្ឆរិយមានលក្ខណៈអត់ធន់មិនបាន ដែលបុគ្គលដទៃ គ្រប់គ្រងសម្បត្តិ របស់ខ្លួន ចំណែកលោភ មានលក្ខណៈហួងហែងទ្រព្យសម្បត្តិរបស់ខ្លួន ម៉្យាងទៀត ការមិនឲ្យវត្ថុដែលខ្លួនចាំ បាច់ត្រូវប្រើ ចាត់ជាបដិសង្ខាញាណ ដូចដែលពោលទុកក្នុងវិបស្សនានយ័ ( ភាគ ១ ) រឿងសំយោជន ក្នុងបរិច្ឆេទទី ៤ ។

៤. **វណ្ណមច្ឆរិយ** ការកំណាញ់សេចក្តីល្អ គឺការមិនត្រូវការនិយាយ ឬស្តាប់សេចក្តីល្អ របស់បុគ្គលដទៃ ឬមិនត្រូវការឲ្យអ្នកដទៃ បានសេចក្តីល្អដូចខ្លួន មិនមែនការមិនចង់និយាយ ឬស្តាប់ពាក្យ សរសើរសេចក្តីល្អ

ដែលមិនមានពិត ។

៥. **ធម្មមច្ឆរិយ** សេចក្ដីកំណាញ់ធម៌ គឺ ការមិនត្រូវការឲ្យអ្នកដទៃយល់គោលធម៌ ឬវិជ្ជាដឹងច្បាស់ដូចខ្លួន មិនមែនសេចក្ដីមិនត្រូវការឲ្យមនុស្សពាលសិក្សា ចេះដឹង ។

**[១]** វិបល្លាសេសុ អនិច្ចេសុ និច្ចំ អនត្តនិ អត្តាតិ ច សញ្ញាចិត្ត-ទិដ្ឋិវិបល្លាសា, ទុក្ខេ សុខំ អសុភេ សុភន្តិ ទិដ្ឋិវិបល្លាសោ ចាតិ ឥមេ បឋមញាណវជ្ឈា ។**[២]** អសុភេ សុភន្តិ សញ្ញាចិត្តវិបល្លាសា តតិយ-ញាណវជ្ឈា។**[៣]** ទុក្ខេ សុខន្តិ សញ្ញាចិត្តវិបល្លាសា តតិយញាណវជ្ឈា ។

"ក្នុងវិបល្លាសទាំងឡាយ គប្បីជ្រាបថា:-

**សញ្ញា ចិត្ត** និង**ទិដ្ឋិ** ដែលប្រែប្រួលក្នុងវត្ថុ ដែលមិនទៀង ថាទៀង ក្នុងសេចក្ដីមិនមានអត្តាថា មានអត្តា ព្រមដោយការឃើញដែលប្រែប្រួលក្នុងទុក្ខ ថាជាសុខ និងក្នុងវត្ថុដែលមិនស្អាត ថាជាវត្ថុស្អាតវិបល្លាស ៤ ពួកនេះ លះបង់បានដោយញាណ ទី ១ ។

២. **សញ្ញា** និង**ចិត្ត** ដែលប្រែប្រួលក្នុងវត្ថុ មិនស្អាត ថា ស្អាត វិបល្លាស ២ ពួក នេះ លះបង់បានដោយញាណទី ៣ ។

៣. **សញ្ញា** និង**ចិត្ត** ដែលប្រែប្រួលក្នុងទុក្ខ ថា សុខ វិបល្លាស ២ ពួកនេះ លះបង់បានដោយញាណទី ៤" ។

ព្រះសោតាបន្ន និងព្រះសកទាគាមី នៅមានសញ្ញាវិបល្លាស គឺ សេចក្ដីសម្គាល់ខុស និងចិត្តវិបល្លាស គឺការទទួលដឹងខុសថា រាងកាយ

*របស់ខ្លួន និងអ្នកដទៃល្អ ស្អាត និងជាសុខ ដូច្នោះ ទើបកើតកើនត្រេកអរកាមគុណ តែលោកមិនមានទិដ្ឋិវិបល្លាស គឺការឃើញខុសថា ជាវត្ថុដែលល្អស្អាត និងជាសុខយ៉ាងពិតប្រាកដ កាលបើលោកពិចារណាមើលក៏នឹងជួបត្រឹមរូបនាម មិនជួបរូបរាងសណ្ឋាន ដែលស្រស់ស្អាត និង ជាសុខ ។*

*ព្រះអនាគាមី នៅមានសញ្ញាវិបល្លាស និងចិត្តវិបល្លាសថា ជាសុខ ដូច្នោះ ទើបមានសេចក្តីអាល័យ ក្នុងខន្ធរបស់ខ្លួន ហើយរីករាយក្នុងរូបភព និង អរូបភព ។*

*ម្យ៉ាងទៀត ការលំអៀង ដែលហៅថា អគតិ គប្បីលះបង់បានដោយសោតាបត្តិមគ្គញាណ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :*

អគតិ បឋមញាណវជ្ឈា ។

*“អគតិ លះបង់បានដោយញាណទី ១ នោះឯង” ។*

*សេចក្តីលំអៀង មាន ៤ ប្រភេទ គឺ :*

***១. ឆន្ទាគតិ*** *លំអៀងព្រោះស្រឡាញ់ក្នុងពេលកាត់ក្តី បែងចែកវត្ថុរបស់របរ លើកសរសើរ តិះដៀល ណែនាំ ឬ ឧបត្ថម្ភជាដើម ។*

*២. **ទោសាគតិ** លំអៀងព្រោះស្អប់មនុស្សដែលខ្លួនមិនពេញចិត្ត ។*

*៣. **មោហាគតិ** លំអៀង ព្រោះវង្វេង ដោយការមិនដឹងពិត ។*

*៤. **ភយាគតិ** លំអៀង ព្រោះខ្លាច អ្នកដែលមានអំណាច ។*

*[១]* អាសវេសុ ទិដ្ឋាសវោ បឋមញាណវជ្ឈោ ។*[២]* កាមាសវោ

តតិយញាណវជ្ឈោ។ [៣] ឥតរេ ទ្វេ ចតុត្ថញាណវជ្ឈោ ។

“ក្នុងអាសវៈទាំងឡាយ គប្បីជ្រាបថា :

១. អាសវៈគឺទិដ្ឋិ លះបានដោយញាណទី ១ ។

២. អាសវៈគឺកាម លះបានដោយញាណទី ៣

៣. អាសវៈពីរយ៉ាងដទៃ [ ភវាសវៈ និងអវិជ្ជាសវៈ] លះបង់បានដោយញាណទី ៤” ។

✶អាសវៈ ៤ តាមន័យព្រះសូត្រ និង ព្រះអភិធម្ម គឺ :

**១. កាមាសវៈ** លោភៈ ដែលពេញចិត្តកាមគុណ ៥ តាមន័យព្រះសូត្រ ឬ តាមន័យព្រះអភិធម្ម គឺ លោភៈ ដែលមានការកើតឡើងក្នុងលោភមូលចិត្ត ទាំងអស់ក្រៅពីភវាសវៈ ។

២. **ភវាសវៈ** លោភៈដែលពេញចិត្តរូបភព អរូបភព រូបឈាន អរូបឈាន លោភៈដែលប្រកបដោយសស្សតទិដ្ឋិ លោភៈ ដែលពេញចិត្តកាមភព គឺភាពជាមនុស្ស ទេវតា នាគ គ្រុឌ បុរស ស្ត្រីជាដើម ។

តាមន័យព្រះសូត្រ ឬ តាមន័យព្រះអភិធម្ម គឺ លោភៈ ដែលប្រាសចាកទិដ្ឋិ ដែលត្រេកអររូបភព អរូបភព រូបឈាន និង អរូបឈាន ។

៣. **ទិដ្ឋាសវៈ** ទិដ្ឋិ គឺការយើញខុស ។

៤. **អវិជ្ជាសវៈ** មោហៈ គឺ សេចក្តីវង្វេង សេចក្តីល្ងង់ខ្លៅ ។

[១] នីវរណេសុ វិចិកិច្ឆានីវរណំ បឋមញាណវជ្ឈោ ។

[២] កាមច្ឆន្ទោ ព្យាបាទោ កុក្កុច្ចន្តិ តីណិ តតិយញាណវជ្ឈានិ ។

**[៣]** ថីនមិទ្ធុទ្ធច្ចានិ ចតុត្ថញាណវជ្ឈា ។

“ក្នុងនីវរណៈទាំងឡាយ គប្បីជ្រាបថា :-

**១. វិចិកិច្ឆានីវរណៈ** លះបង់បានដោយញាណទី ១

**២. នីវរណៈ** គឺ**កាមច្ឆន្ទ ព្យាបាទ** និង **កុក្កុច្ច** ៣ យ៉ាងនោះ លះបង់បានដោយ ញាណទី ៣ ។

**៣. ថីនមិទ្ធ** និង**ឧទ្ធច្ច** លះបង់បានដោយញាណទី ៤” ។

**កាមច្ឆន្ទ** ដែលលះបង់បានដោយញាណទី ៣ ជាកាមច្ឆន្ទយ៉ាងល្អិត ដែលត្រេកអរ ពេញចិត្តកាមគុណ ពោលទុកតាមន័យព្រះសូត្រ ចំណែកតាមន័យព្រះអភិធម្ម **រូបរាគ** និង**អរូបរាគ** ថាជា **កាមច្ឆន្ទ រូបរាគ** និង **អរូបរាគ** ដូចពោល លះបង់បានដោយអរហត្តមគ្គញាណ ។

**[១]** ឧបាទានេសុ សព្វេសម្បិ លោកិយធម្មានំ វត្ថុកាមវសេន កាមាតិ អាគតត្តា រូបារូបរាគោបិ កាមុបាទានេ បតតិ, តស្មា តំ ចតុត្ថញាណវជ្ឈំ ។ **[២]** សេសានិ បឋមញាណវជ្ឈានិ ។

“ក្នុងឧបាទានទាំងឡាយ គប្បីជ្រាបថា:

១. សូម្បីរូបរាគៈ និងអរូបរាគៈ ក៏រួមនៅក្នុងកាមុបាទាន ព្រោះជាលោកិយធម៌ ទាំងអស់ ពោលទុកក្នុងពាក្យថា **កាម** ដោយជាវត្ថុកាម ដូច្នោះ កាមុបាទាននោះ ទើបលះបង់បានដោយមគ្គទី ៤ ។

២. ឧបាទានដ៏សេស លះបង់បានដោយញាណទី ១” ។

# ឧបាទាន មាន ៤ យ៉ាង គឺ :

១. **កាមុបាទាន** ការប្រកាន់មាំក្នុងកាមគុណ គឺ លោភៈ ដែលត្រេកអរពេញចិត្ត លោកិយធម៌ទាំងអស់ដែលជាវត្ថុកាម ។

២. **សីលព្វតុបាទាន** សេចក្ដីប្រកាន់មាំក្នុងសីលព្វត ក្រៅសាសនា ដូចជាការប្រព្រឹត្តិខ្លួន ដូចគោ និង សុនខ ជាដើម ថាជាផ្លូវរួចផុតពីទុក្ខ ឬជាសេចក្ដីប្រកាន់មាំថា អាចរួចផុតបានដោយការបំពេញសីល ចំណែកលោភៈ ដែលប្រាសចាកអរិយមគ្គ មានអង្គ ៨ យ៉ាងគឺ:

៣. **អត្តវាទុបាទាន** សេចក្ដីប្រកាន់មាំក្នុងតួខ្លួន គឺសក្កាយទិដ្ឋិ ២០ [សក្កាយទិដ្ឋិ គឺការឃើញខុសថា មានតួខ្លួន បែកចេញជា ២០ យ៉ាង ដោយខន្ធ ៥ ចេញជា ១ ខន្ធ មាន ៥ គឺ :

**-រូបំ អត្តា** ( រូបជាអត្តា )

**-រូបវា អត្តា** ( អត្តា មានរូប )

**-អត្តនិ រូបំ** ( រូបមាននៅក្នុងអត្តា )

**-រូបស្មឹ អត្តា** ( អត្តាមាននៅក្នុងរូប )វេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏ន័យនេះ] ។

៤. **ទិដ្ឋុបាទាន** សេចក្ដីប្រកាន់មាំក្នុងទិដ្ឋិដទៃទាំងអស ។

[១] អនុសយេសុ ទិដ្ឋិវិចិកិច្ឆានុសយា បឋមញាណវជ្ឈា ។

[២] កាមរាគបដិឃនុសយោ តតិយញាណវជ្ឈា ។

[៣] មានភវរាគាវិជ្ជានុសយា ចតុត្ថញាណវជ្ឈា ។

“ក្នុងអនុស័យទាំងឡាយ គប្បីជ្រាបថា :-

១. អនុស័យ គឺទិដ្ឋិ និង វិចិកិច្ឆា លះបានដោយញាណទី ១

នោះឯង ។

២. អនុស័យ គឺកាមរាគ បដិឃ លះបានដោយញាណទី ៣

៣. អនុស័យ គឺមានះ ភវរាគះ និងអវិជ្ជា លះបានដោយញាណទី ៤” ។

ម៉្យាងទៀត សេចក្ដីស្ងប់ទៅរបស់អនុស័យ ជាការមិនកើតឡើងរបស់បរិយុដ្ឋានកិលេស បើនៅមានបរិយុដ្ឋានកិលេស ក៏សម្ដែងថាអនុស័យនៅមិនស្ងប់ទៅ ។

[១] អកុសលកម្មបថេសុ ចាណាតិបាតោ អទិន្នាទានំ មិច្ឆាចារោ មុសាវាទោ មិច្ឆាទិដ្ឋីតិ ឥមេ បឋមញាណវជ្ឈា ។ [២] បិសុណាវាចា ផរុសវាចា ព្យាបាទោតិ តយោ តតិយញាណវជ្ឈា ។ [៣] សម្ផលាបាភិជ្ឈា ចតុត្ថញាណវជ្ឈា ។

“ក្នុងអកុសលធម៌ទាំងឡាយ គប្បីជ្រាបថា :-

១. **បាណាតិបាត** ( ការសម្លាប់សត្វ ) **អទិន្នាទាន** ( ការលួចទ្រព្យ ) **កាមេសុមិច្ឆាចារ** ( ការប្រព្រឹត្តខុសក្នុងកាម ) **មុសាវាទ** ( ការនិយាយកុហក ) **និងមិច្ឆាទិដ្ឋិ** ( ការឃើញខុស ) **អកុសលកម្មបថ** ៥ យ៉ាងនេះ លះបង់បានដោយញាណទី ១ ។

២. **បិសុណាវាចា** ( ការនិយាយចាក់ដោត ) ផរុសវាចា ( ការនិយាយពាក្យគ្រោតគ្រាត ) និង**ព្យាបាទ** ( សេចក្ដីព្យាបាទ ) **អកុសលកម្មបថ** ៣ យ៉ាងនេះ លះបង់បានដោយញាណទី ៣ ។

៣. **សម្ផប្បលាប** ( ការនិយាយពាក្យរោយរាយ ឥតប្រយោជន៍ ) និង **អភិជ្ឈា** ( សេចក្តីលោភលន់ ) លះបង់បាន ដោយញាណទី ៤” ។

មានពាក្យអធិប្បាយបន្ថែម ក្នុងរឿងនេះថា :

-អកុសលកម្មបថ ៥ គឺ **បិសុណវាចា ផរុសវាចា ព្យាបាទ សម្ផប្បលាប** និង **អភិជ្ឈា** ដែលនាំទៅកាន់អបាយ លះបង់បាន ដោយសោតាបត្តិមគ្គញាណ ។

-អកុសលកម្មបថ ៥ ដែលមិននាំទៅកាន់អបាយភូមិ ដែលជាប់ដោយកាមរាគៈ និងព្យាបាទយ៉ាងគ្រោតគ្រាត លះបង់បាន ដោយសកទាគាមិមគ្គញាណ ។

-អកុសលកម្មបថ ៥ ដែលមិននាំទៅកាន់អបាយ ដែលជាប់ដោយកាមរាគៈ និង ព្យាបាទយ៉ាងល្អិត លះបង់បានដោយអនាគាមិមគ្គញាណ ។

-សម្ផប្បលាប និងអភិជ្ឈា ដែលជាប់ដោយភវរាគៈ លះបង់បានដោយអរហត្តមគ្គញាណ ។

**[១]** អកុសលចិត្តុប្បាទេសុ ចត្តារោ ទិដ្ឋិសម្បយុត្តា វិចិកិច្ឆា-សម្បយុត្តា ចាតិ បញ្ច បឋមញាណវជ្ឈា **[២]** ទ្វេ បដិឃសម្បយុត្តា តតិយញាណវជ្ឈា ។ **[៣]** សេសា ចតុត្ថញាណវជ្ឈា ។

“ក្នុងអកុសលចិត្តុប្បាទទាំងឡាយ គប្បីជ្រាបថា :

១. ទិដ្ឋិសម្បយុត្តចិត្ត ៤ និងវិចិកិច្ឆាសម្បយុត្តចិត្ត ១ រួម ៥ ដួង លះបង់បាន ដោយញាណទី ១ នោះឯង ។

២. បដិឃសម្បយុត្តចិត្ត ២ លះបានដោយញាណទី ៣ ។

៣. ចិត្តុប្បាទដ៏សេស [ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ឧទ្ធច្ចសហគតចិត្ត ១] លះបង់បាន ដោយញាណទី ៤” ។

មានពាក្យអធិប្បាយបន្ថែម ក្នុងរឿងនេះថា:

-អកុសលចិត្តុប្បាទ ៦ ដួង គឺ ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ទោសមូលចិត្ត ២ ដែលនាំទៅកាន់អបាយ លះបានដោយសោតាបត្តិមគ្គញាណ ដូចមានសាធក: ក្នុងគម្ពីរធម្មសង្គណីថា :

ចត្តារោ ទិដ្ឋិគតវិប្បយុត្តា លោភសហគតចិត្តុប្បាទា, ទ្វេ ទោមនស្សសហគតចិត្តុប្បាទានិ ។ ឥមេ ធម្មា សិយា ទស្សនេន បហាតព្វា សិយា ភាវនាយ បហាតព្វា ។

“ចិត្តុប្បាទ ដែលកើតរួមជាមួយលោភ: ជាទិដ្ឋិគតិវិប្បយុត្ត ៤ ចិត្តុប្បាទ ដែលកើតរួមជាមួយទោមនស្ស ២ ធម៌ទាំងនេះ គប្បីលះបង់បានដោយសោតាបត្តិមគ្គខ្លះ គប្បីលះបង់ដោយមគ្គថ្នាក់ខ្ពស់ខ្លះ” ។

-អកុសលចិត្តុប្បាទ ៦ ដួងនោះ ដែលនាំទៅកាន់អបាយមិនបាន ដែលជាប់ទាក់ទងដោយកាមរាគ: និងព្យាបាទយ៉ាងគ្រោតគ្រាត ព្រមដោយឧទ្ធច្ចសម្បយុត្តចិត្ត ដែលមានបុគ្គលជាទីតាំងដូចគ្នា ដោយការលះបង់ជាមួយនឹងកាមរាគ: និងព្យាបាទយ៉ាងគ្រោតគ្រាត លះបង់បានដោយសកទាគាមិមគ្គញាណ ។

-អកុសលចិត្តុប្បាទ ៦ ដួង ដែលនាំទៅកាន់អបាយមិនបាន មានជាប់ដោយកាមរាគៈ និងព្យាបាទយ៉ាងល្អិត ព្រមដោយឧទ្ធច្ចសម្បយុត្តចិត្ត ដែលមានបុគ្គលជាទីតាំង ដូចគ្នា ដោយការលះបង់ជាមួយកាមរាគៈ និងព្យាបាទយ៉ាងល្អិត លះបង់បានដោយ អនាគាមិមគ្គញ្ញាណ ។

ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ កើតរួមជាមួយភវរាគៈ និង ឧទ្ធច្ចសហគតចិត្តដ៏សេសក្រៅពីប្រភេទខាងដើម លះបង់បានដោយអរហត្តមគ្គញ្ញាណ ដូចសាធកៈ ក្នុងគម្ពីរធម្មសង្គណីថា :

កតមេ ធម្មា ន ទស្សនេន បហាតព្វា ។ ឧទ្ធច្ចសហគតោ ចិត្តុប្បាទោ ។

“ធម៌ណា មិនគប្បីលះដោយសោតាបត្តិមគ្គ គឺ ចិត្តុប្បាទ ដែលកើតរួមជាមួយឧទ្ធច្ចៈ” ។

គតមេ ធម្មា ភាវនាយ បហាតព្វា ។ ឧទ្ធច្ចសហគតោ ចិត្តុប្បាទោ។

“ធម៌ណា គប្បីលះបង់ដោយមគ្គថ្នាក់ខ្ពស់ គឺ ចិត្តុប្បាទ ដែលកើតរួមជាមួយឧទ្ធច្ច”។

សេចក្តីពិតហើយ ឧទ្ធច្ចសម្បយុត្តចិត្ត មិនបានត្រូវលះបង់ ដោយអរហត្តមគ្គញ្ញាណ តែម្យ៉ាង ព្រោះសេចក្តីរវើរវាយរបស់ព្រះសកទាគាមី និងព្រះអនាគាមី មិនគួរមានសភាពគ្រោតគ្រាត ដូចសេចក្តីរវើរវាយរបស់ព្រះសោតាបន្ន ដូច្នោះ មគ្គថ្នាក់ខ្ពស់ទាំង ៣ ទើបលះឧទ្ធច្ចសម្បយុត្តចិត្តយ៉ាងល្អិតសុខុម និងដោយមិនមានសេសសល់ ។

*ពាក្យពោលថា “មានបុគ្គលជាទីតាំងដូចគ្នា ដោយការលះបង់” ( បហានេកដ្ឋ ) មានន័យថា កាលកិលេសម្យ៉ាងរលត់ទៅ ដោយមគ្គានុភាព ក្នុងក្រសែចិត្តរបស់បុគ្គលម្យ៉ាង កិលេសដទៃ ដែលនៅក្នុងលំដាប់តែមួយ ជាមួយកិលេសនោះ ក៏រលត់ទៅផង ជាកិលេសលំដាប់តែមួយ ជាមួយគ្នា ដែលរលត់ទៅព្រមគ្នា មិនមែនជាកិលេស ដែលកើតរួមគ្នា ។*

*សេចក្តីនេះ គឺ កិលេសដែលរលត់ទៅព្រមគ្នា ក្នុងក្រសែចិត្ត របស់បុគ្គល [ គឺកិលេស ដែលមានក្នុងទីតាំង គឺបុគ្គលតែមួយជាមួយគ្នា នៅក្នុងលំដាប់តែ មួយជាមួយកិលេស ដែលត្រូវលះដោយមគ្គ នឹងត្រូវ លះបានព្រមគ្នា ] ។*

*ក្នុងគម្ពីរវិសុទ្ធិមគ្គ និងគម្ពីរនេះមិនបានពោលដល់អកុសលធម៌ ខ្លះម្យ៉ាង ដែលលះបានដោយមគ្គញាណ ៤ ខ្លះ អកុសលធម៌នោះ មានអត្ថធម៌ដោយចំពោះនិង មានលក្ខណៈការលះដូចសំយោជនៈដែល ពោលទុកហើយ ចំណែកអកុសលធម៌ ដែលមិនមានអត្ថធម៌ ដោយ ចំពោះ គប្បីរាប់ចូលក្នុងអកុសលចិត្តុប្បាទដែលជាប់ទាក់ទងគ្នា និងត្រូវលះ ដោយមគ្គញាណ ៤ តាមសមគួរ ដូចគម្ពីរមហាដីកាវិសុទ្ធិមគ្គពោលថា:*

ចិត្តុប្បាទគ្គហណេន ចេត្ថ មក្ខបឡាសមាយាសាឋេយ្យបមាទថម្ភ- សារម្ភាទីនំ សង្គហោ កតោតិ ទដ្ឋព្វំ ។

*“ម្យ៉ាងទៀត ដោយការកាន់យកចិត្តុប្បាទក្នុងរឿងនោះ គប្បីជ្រាប ថា ព្រះអដ្ឋកថាចារ្យធ្វើការរួបរួមការមើលគុណ ( មក្ខ ) ការវាយឫក*

ស្មើ ( បឡាស ) ការធ្វើពុត ( មាយា ) ការបោកបញ្ឆោត ( សាឋេយ្យ ) សេចក្ដីប្រមាទ ( បមាទ ) ការចចេស ( ថម្ភ ) និងការប្រ ណាំងប្រជែង ( សារម្ភ ) ជាដើម" ។

ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក វត្ថសូត្រ ព្រះអង្គទ្រង់សម្ដែងឧបកិលេស ដែលគួរលះ ១៦ ប្រភេទ ដូច្នេះ

១. សេចក្ដីលោភ ដែលមិនសម្បរម្យដោយអភិជ្ឈា ( អភិជ្ឈាវិសមលោភ )

២. សេចក្ដីព្យាបាទ ( ព្យាបាទ )

៣. សេចក្ដីក្រោធ ( កោធ )

៤. សេចក្ដីចងគំនុំគំគួន ( ឧបនាហ )

៥. ការលុបគុណ ( មក្ខៈ ) គឺចិត្តុប្បាទដែលកើតរួមជាមួយទោមនស្ស ប្រព្រឹត្តទៅដោយលក្ខណៈលុបគុណរបស់អ្នកដែលធ្វើឧបការៈទុក ដូចគម្ពីរអដ្ឋកថាអធិប្បាយ ទុកដូច្នេះថា:

អត្តនោ បន បរេសំ គុណេ មក្ខនាការេន បវត្តោ

ទោមនស្ស សហគតចិត្តុប្បាទោតិ ទដ្ឋព្វំ ។

"គប្បីជ្រាបថា ដោយអង្គធម៌ជាចិត្តុប្បាទ ដែលកើតរួមជាមួយទោមនស្សដែលប្រព្រឹត្តទៅដោយលក្ខណៈលុបគុណរបស់បុគ្គលដទៃ" ។

៦. ការវាយឫកស្មើ ( បលាស ) គឺចិត្តុប្បាទដែលកើតរួមជាមួយទោមនស្ស ប្រព្រឹត្តទៅដោយលក្ខណៈវាយឫកស្មើជាមួយ បុគ្គល

ដទៃដែលប្រសើរជាងខ្លួន ដោយគុណធម៌មានសទ្ធា និងសីលជាដើម ។

៧. សេចក្តីប្រណែន ( ឥស្សា )

៨. សេចក្តីកំណាញ់ ( មច្ឆរិយៈ )

៩. ការលាក់ពុត ( សាឋេយ្យៈ ) គឺចិត្តុប្បាទដែលកើតរួមជាមួយលោភៈ ប្រព្រឹត្តទៅដោយការអួងអាងគុណធម៌ដែលមិនមានពិតក្នុងខ្លួន ។

១០. សេចក្តីរឹងត្អឹង ( ថម្ភៈ) គឺ ចិត្តុប្បាទដែលកើតរួមជាមួយនឹងមានៈ ប្រព្រឹត្តទៅដោយលក្ខណៈរឹងរូស មិនគោរពកោតខ្លាច អ្នកដែលគួរគោរពកោតខ្លាចដូចគម្ពីរមូលដីកាអធិប្បាយថា:

ចិត្តស្ស ថទ្ធតា តថាបវត្តចិត្តមេវាតិ វទន្តិ ។ មានវិសេសោ វា ថទ្ធត្តំ ។

“អាចារ្យទាំងឡាយពោលថា ការរឹងរូសរបស់ចិត្ត ក៏គឺចិត្តដែលប្រព្រឹត្តទៅ យ៉ាងនោះនុ៎ះឯង ន័យម្យ៉ាងទៀត គប្បីជ្រាបថា ជាមានៈដោយពិសេស” ។

១២. ការប្រណាំងប្រជែង ( **សារម្ភ** ) គឺចិត្តុប្បាទ ដែលជា ទិដ្ឋិគតវិប្បយុត្តមាន **មានៈ** ជាប្រធាន ប្រព្រឹត្តទៅ ដោយលក្ខណៈ ត្រូវការនឹងយកឈ្នះបុគ្គលដទៃ ។

១៣. សេចក្តីប្រកាន់ខ្លួន ( មានៈ )

១៤. សេចក្តីប្រកាន់ខ្លួនហួសហេតុ គឺមើលងាយគេ ( អតិមានៈ )

១៥. សេចក្តីស្រវឹង ( ការបណ្តែតបណ្តោយខ្លួន= មទៈ )

១៦. សេចក្ដីប្រមាទ ( បមាទៈ ) គឺលោភមូលចិត្តុប្បាទ ឬទោសមូលចិត្តុប្បាទ ប្រព្រឹត្តទៅដោយលក្ខណៈពេញចិត្ត កាមគុណ ៥ និងទុច្ចរិត ព្រមទាំងវង្វេងភ្លេចការ ធ្វើនូវគុណ គឺសេចក្ដីល្អ ។

ឧបក្កិលេសទាំងនោះ លះបានដោយមគ្គញាណ ៤ តាមសមគួរ ដូចគម្ពីរអដ្ឋកថាពោលថាៈ

**[១]**សោតាបត្តិមគ្គេន មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាថេយ្យន្តិ ឥមេ ឆ បហីយន្តិ ។ **[២]** អនាគាមិមគ្គេន ព្យាបាទោ កោធោ ឧបនាហោ បមាទោតិ ឥមេ ចត្តារោ ។**[៣]** អរហត្តមគ្គេន អភិជ្ឈាវិសម–លោភោ ថម្ភោ សារម្ភោ មានោ អតិមានោ មទោតិ ឥមេ ឆ បហីយន្តិ។

“១. ឧបកិលេស ៦ ពួកនេះ គឺការលុបគុណ ការវាយឫកស្មើ ឥស្សា មច្ឆរិយ មាយា និងសាថេយ្យ លះបានដោយសោតាបត្តិមគ្គញាណ ។

២. **ឧបក្កិលេស ៤** ពួកនេះ គឺ **ព្យាបាទ កោធ** ការចងគំនុំ និង **បមាទ** លះបានដោយអនាគាមិមគ្គញាណ ។

៣. ឧបក្កិលេស ៦ ពួកនេះ គឺ អភិជ្ឈាវិសមលោភៈ សេចក្ដីរឹងត្អឹង ការប្រណាំងប្រជែង មានៈ អតិមានៈ និងសេចក្ដីស្រវឹង លះបង់បានដោយអរហត្តមគ្គញាណ” ។

ម្យ៉ាងទៀត ការលះឧបកិលេស ១០ ដោយអនាគាមិមគ្គញាណ និងអរហត្តមគ្គញាណ ជាការលះដោយដាច់ស្រឡះ ពិតហើយ មគ្គញា–

ណថ្នាក់ទាប គឺ សោតា បត្តិមគ្គញាណ និង សកទាគាមិ មគ្គញាណ អាចនឹងលះឧបកិលេសទាំងនោះ ដែលនាំទៅកាន់ អបាយបាន ។!

# “អង្គប្រកបរបស់ព្រះសោតាបន្នបុគ្គល”

តស្មាតិហានន្ទ ធម្មាទាសំ នាម ធម្មបរិយាយំ ទេសេស្សាមិ, យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនាវ អត្តានំ ព្យាករេយ្យ ខីណតិរច្ឆានយោនិ ខីណបេត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ ។ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។ កតមោ ច សោ អានន្ទ ធម្មាទសោ ធម្មបរិយាយោ ។

*[១]* ឥធានន្ទ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ *[២]* ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនាយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ *[៣]* សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ សុបដិបន្នោ ភគវតោ សាវកសង្ឃោ ។ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។ សាមិចិ-ប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។ យទិទំ ចត្តារិ បុរិសបុគ្គលា អដ្ឋ បុរិសបុគ្គលា ។ ឯស ភគវតោ សាវកសង្ឃោ ។ អាហុនេយ្យោ

ចាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ ។ អនុត្តរំ បុញ្ញាខេត្តំ លោកស្សាតិ ។ ***[៤]*** អរិកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ ភុជិស្សេហិ វិញ្ញុប្ប-សត្ថេហិ អបរាមដ្ឋេហិ សមាធិសំវត្តនិកេហិ ។

អយំ ខោ សោ អានន្ទ ធម្មាទាសោ ធម្មបរិយាយោ, យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនាវ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ។បេ។ សម្ពោធិបរាយណោតិ ។

*“ម្នាលអានន្ទ ព្រោះហេតុដូច្នោះ តថាគតនឹងសម្តែងធម៌ទេសនា ឈ្មោះថា ធម្មាទាស ( ធម៌ដូចជាកញ្ចក់ ) ដើម្បីឲ្យអរិយសាវកអ្នកមានព្រមដោយធម៌ ដែលដូចជាកញ្ចក់ កាលបើត្រូវការគប្បីព្យាករខ្លួនដោយខ្លួនឯងបានថា យើងមាននរកអស់ហើយ មាន កំណើតសត្វតិរច្ឆានអស់ហើយ មានបេតវិស័យអស់ហើយ ទុគ្គតិវិនិបាតអស់ហើយ យើងជាអ្នកដល់អរិយមគ្គគ្រាដំបូង មានការមិនអន់ថយចុះជាធម្មតា ជាអ្នកទៀងហើយ មានការត្រាស់ដឹងជាខាងមុខ ។*

*ម្នាលអានន្ទ ធម៌ទេសនា ឈ្មោះថា **ធម្មាទាស**នោះ គឺអ្វី? ម្នាលអានន្ទ អរិយសាវក ក្នុងធម្មវិន័យនេះ :*

*១. ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា ដែលមិនកម្រើកក្នុងព្រះពុទ្ធថា សូម្បីព្រោះហេតុនេះ ព្រះដ៏មានព្រះភាគព្រះអង្គនោះ ជាអ្នកឆ្ងាយពីកិលេស ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ដល់ព្រមដោយការដឹង*

និងការប្រព្រឹត្ត ស្តេចទៅដោយល្អ ហើយទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ជាសារថីទូន្មាននូវបុគ្គល ដែលគួរទូន្មានបាន មិនមានអ្នកណាក្រៃលែងជាង ទ្រង់ជាសាស្តារបស់ទេវតា និងមនុស្សទាំងឡាយ ទ្រង់ជាអ្នកជ្រាបច្បាស់ ទ្រង់ជាអ្នកអធិប្បាយធម៌ ។

២. ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា ដែលមិនកម្រើក ក្នុងព្រះធម៌ថា ព្រះធម៌ ដែលព្រះមានព្រះភាគត្រាស់ទុកល្អហើយ ជាធម៌ដែលឃើញបានដោយខ្លួនឯង មិនរង់ចាំកាល ជាធម៌ដែលគួរហៅអ្នកដទៃ ឲ្យចូលមកមើល គួរបង្អោនមកដើម្បីបដិបត្តិ ជាធម៌ដែលវិញ្ញូជន គប្បីដឹងបានដោយខ្លួនឯង ។

៣. ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះសង្ឃថា ព្រះអរិយ សង្ឃសាវករបស់ព្រះដ៏មានព្រះភាគ ជាអ្នកបដិបត្តិល្អ ជាអ្នកបដិបត្តិត្រង់ [ តាមមជ្ឈិមាបដិបទា ] ជាអ្នកបដិបត្តិ ដើម្បីព្រះនិព្វាន ជាអ្នកបដិបត្តិដ៏សមគួរ ដល់សាមីចិកម្ម លោកទាំងនោះ បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ ពោលគឺព្រះអរិយបុគ្គល ៨ ជំពូកនោះឯងព្រះអរិយសង្ឃសាវក របស់ព្រះដ៏មានព្រះភាគ ជាអ្នកគួរទទួលសក្ការៈ ជាអ្នកគួរដល់ការទទួលរាក់ទាក់ ជាអ្នកគួរទទួលនូវទក្ខិណាទាន ជាអ្នកគួរដល់អញ្ជលិកម្ម សាមិចិកម្ម ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។

៤. ជាអ្នកប្រកបដោយសីល មិនដាច់មិនធ្លុះ មិនពព្រុស មិនពពាល ជាអរិយសីល ជាសីល ដែលព្រះអរិយប្រាថ្នា ជាសិរី ដែលអ្នកប្រាជ្ញ

សសើរហើយ មិនត្រូវតណ្ហា និងមានះគ្របសង្កត់ នឹងញ៉ាំងឲ្យកើតសមាធិ ។

ម្នាលអានន្ទ សទ្ធាដ៏មុតមាំ និងសីលដ៏ផូរផង់នេះ គឺធម្មទេសនា ឈ្មោះថា **ធម្មាទាស** ដើម្បីឲ្យអរិយសាវក អ្នកដល់ព្រមដោយធម៌ ដែលដូចជាកញ្ចក់ កាលបើត្រូវការ គប្បីព្យាករខ្លួនដោយខ្លួនឯងថា យើងមាននរកអស់ហើយ មានកំណើតសត្វតិរច្ឆាន អស់ហើយ មានបេតវិស័យអស់ហើយ មានអបាយទុគ្គតិវិនិបាតអស់ហើយ យើងជាអ្នកដល់អរិយ-មគ្គគ្រាដំបូង មានការមិនថយចុះ ជាធម្មតាជាអ្នកទៀងហើយ មានការត្រាស់ដឹងជាខាងមុខ” ។

គ្រហស្ថជាព្រះសោតាបន្នពិចារណាធម៌ ៤ ប្រការគឺ សទ្ធាដែលមុតមាំក្នុងព្រះរតនត្រ័យ និងសីលដ៏ផូរផង់ ដែលកើតពីការសម្រេចធម៌ ប្រសិនបើត្រូវការនឹង ប្រាប់អ្នកដទៃក៏ប្រាប់ថា ខ្លួនជាព្រះសោតាបន្នបាន ដោយមិនចាំបាច់សួមពាក្យវិនិច្ឆ័យ ពីអ្នកដទៃ ព្រោះបុគ្គលដទៃក្រៅពីព្រះពុទ្ធមិនអាចប្រាប់រឿងនេះបាន ។

យ៉ាងណាក៏ដោយ ព្រះវិបស្សនាចារ្យ គួរអធិប្បាយរឿងវិបស្សនាញាណមគ្គញាណ ផលញាណ និងបច្ចវេក្ខណាញាណ ព្រមដោយធម៌ទេសនាមានធម្មាទាសសូត្រ ជាដើមដល់អ្នកបដិបត្តិធម៌ ព្រោះអ្នកដែលសម្រេចធម៌ ដែលជាសាវកធម្មតា មិនអាចយល់ឈ្មោះរបស់វិបស្សនាញាណបានយ៉ាងត្រឹមត្រូវ ដូចមនុស្សដើរផ្លូវក្នុងកន្លែង ដែលខ្លួនមិនធ្លាប់នៅសូម្បីនឹងដឹងដល់ស្ថានភាពរបស់កន្លែងនោះ ក៏មិនអាចដឹង ឈ្មោះយ៉ាង

ច្បាស់លាស់បានខ្លួនឯងដោយមិនបានស្តាប់ពីបុគ្គលដទៃ លោកទាំងនោះ នៅមិនអាចដឹងគុណធម៌របស់ព្រះសោតាបន្ន យ៉ាងបរិបូណ៌ដូច្នោះ ព្រះអង្គទើបត្រាស់សម្តែង អង្គប្រកបរបស់ព្រះសោតាបន្ន ដែលស្រេបជាមួយធម្មាទាសសូត្រនេះ ដល់ព្រះអរិយបុគ្គលទាំងឡាយ មានអនាថ-បិណ្ឌិកសេដ្ឋីជាដើម កាលលោកទាំងនោះ បានស្តាប់ធម៌ ហើយបានព្រមទទួលថា ខ្លួនជាអ្នកដល់ព្រមដោយសទ្ធា និងសីលដូចពោល ក្នុងខណៈនោះ ព្រះសារីបុត្រ បានលើកសរសើរ អនាថបិណ្ឌិកសេដ្ឋីថា លោកបានព្យាករណ៍សោតាបត្តិផលរបស់ខ្លួន ក្រៅពីនេះលោកនៅមិនអាចយល់ដល់កិលេស ដែលស្ងប់ហើយ និងកិលេសដែលនៅសល់ តាមសាធក: ពីព្រះបាលី និងអដ្ឋកថា ដែលនាំមកពោលទុកហើយ ដោយហេតុនេះ ព្រះវិបស្សនាចារ្យ គួរអធិប្បាយលំដាប់ ញាណជាដើម ដល់អ្នកបដិបត្តិធម៌ ដែលសម្រេចធម៌ហើយ ចំណែកព្រះអរិយបុគ្គល ជាព្រះភិក្ខុគួរព្យាករណ៍ ភាពជាព្រះអរិយៈ ដោយមិនកន្លងល្មើស **ភូតារោចនសិក្ខាបទ**

[ ភូតារោចនសិក្ខាបទ ជាព្រះវិន័យ ដែលជាប់ទាក់ទងនឹងការនិយាយអួតឧត្តរិមនុស្សធម្ម ដល់អនុប្បសម្បន្ន គឺអ្នកដែលមិនមែនភិក្ខុ និងភិក្ខុនី ព្រះអរិយបុគ្គល ជាព្រះភិក្ខុ អាចប្រាប់ថា ខ្លួនជាព្រះអរិយៈ បានដល់ឧបសម្បន្ន គឺភិក្ខុ និងភិក្ខុនី តែប្រាប់ដល់អនុប្បសម្បន្នមិនបាន ត្រូវអាបត្តិបាចិត្តិយ ] ។

# ព្រះអរិយៈ មានសទ្ធាមិនកំរើកញាប់ញ័រ

ព្រះអរិយជាអ្នកមានសទ្ធាមាំទាំ មិនមានអ្នកណាទំលាយសេចក្ដីជ្រះថ្លា របស់ព្រះអរិយបានដោយការបញ្ឆោតចិត្ត សម្ដុតគម្រាម ឬបោកបញ្ឆោតដូចរឿងក្នុង សម័យពុទ្ធកាលដូចតទៅនេះ :-

**រឿងឧបាសក ឈ្មោះ សុប្បពុទ្ធ ( ត្រូវស្ដេចសក្កៈលឡងមើល )**

ឧបាសកឈ្មោះសុប្បពុទ្ធ មានរោគឃ្លង់ពេញខ្លួន រហូតត្រូវដេកថ្ងូរដោយទារុណកម្ម ជាមនុស្សអនាថា មិនមានទីស្នាក់អាស្រ័យ កាន់អម្បែងក្បឿងត្រាច់សូមទានតាំងពីតូច ថ្ងៃមួយអង្គុយស្ដាប់ធម៌ របស់ព្រះដ៏មានព្រះភាគនៅខាងចុងរបស់ពុទ្ធបរិស័យ ហើយបានសម្រេចធម៌ ជាព្រះសោតាបន្ន គេត្រិះរិះនឹងក្រាបទូលគុណធម៌ របស់ខ្លួនដល់ព្រះសោតាបន្ន តែមិនហ៊ានក្រាបទូលក្នុងកណ្ដាលបរិស័ទ ទើបត្រឡប់ចេញទៅជាមួយមនុស្សដទៃ ហើយវិលត្រឡប់ទៅគាល់ព្រះអង្គ ។

ក្នុងខណៈនោះ ព្រះឥន្ទត្រូវការនឹងសាកល្បងចិត្តរបស់លោក ទើបសម្ដែងខ្លួននៅកណ្ដាលអាកាស ហើយពោលសាកល្បង មានពាក្យធ្ងើយឆ្ងង ដូច្នេះថា:

( **ព្រះឥន្ទ** ) សុប្បពុទ្ធ.! អ្នកជាមនុស្សកំសត់ គ្មានទីពឹង យើងនឹងឲ្យទ្រព្យសម្បត្តិ ដ៏ច្រើនមហាសាលដល់អ្នក សូមអ្នកប្រកាសថា ព្រះពុទ្ធមិនមែនជាអ្នកត្រាស់ដឹងធម៌ទាំងពួងទេ..! ទាំងព្រះធម៌ ក៏មិនមែនជាធម៌ដែលដឹកនាំសត្វលោកឲ្យរួចផុតពីទុក្ខដែរ ព្រមទាំងព្រះសង្ឃ ក៏មិនមែនជា

*ព្រះសង្ឃអ្នកបដិបត្តិ ដោយប្រពៃដែរ យើងមិនត្រូវការព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃជាទីពឹងសម្រាប់យើងឡើយ ។*

***( សុប្បពុទ្ធ )*** *សួរថា: តើលោកជាអ្នកណា?*

***( ព្រះឥន្ទ )*** *យើងគឺជាព្រះឥន្ទ្រ*

***( សុប្បពុទ្ធ )*** *ព្រះឥន្ទល្ងង់ខ្លៅ*

*លោកនិយាយពាក្យ ដែលមិនគួរនិយាយ នឹងយើងទេ ហេតុអ្វីទើប លោកពោលថា យើងជាមនុស្សកំសត់ យើងជាបុត្ររបស់ព្រះសម្មាសម្ពុទ្ធ មិនមែនមនុស្សកំសត់ទេ យើងជាអ្នកមានទ្រព្យ ដោយអរិយទ្រព្យ ដ៏ប្រសើរ សុប្បពុទ្ធពោលដូច្នេះ ហើយបានពោលគាថាថា:*

សទ្ធាធនំ សីលធនំ ហិរិឱត្តប្បិយំ ធនំ
សុតធនញ្ច ចាគោ ច បញ្ញា វេ សត្តមំ ធនំ ។
យស្ស ឯតេ ធនា អត្ថិ ឥត្ថិយា បុរិសស្ស វា
អទលិទ្ទោតិ តំ អាហុ អមោឃំ តស្ស ជីវិតំ ។

*"ទ្រព្យ គឺ សទ្ធា សីល ហិរិ ឱត្តប្ប សុត ចាគ និង បញ្ញា ទ្រព្យ ទាំងនេះ បានដល់បុគ្គលណា អ្នកជាស្ត្រី ឬបុរស អ្នកមានបញ្ញាពោលថា បុគ្គលនោះមិនមែនមនុស្សកំសត់ ជីវិតរបស់គេ មិនឥតប្រយោជន៍" ។*

*[ គម្ពីរអដ្ឋកថាអធិប្បាយថា ការលះ ( ចាគ ) ក្នុងរឿងនេះ ជាការលះកិលេស និងខន្ធ ដែលទាក់ទង ដោយសោតាបត្តិមគ្គ ដូច្នោះ ព្រះអរិយបុគ្គល ទើបបានឈ្មោះថា មុត្តចាគ: គឺជាអ្នកបរិច្ចាគ ទានដោយមិនមានអាល័យហួងហែង ព្រោះលះកិលេស និង*

ខន្ធដូចពោលបានហើយ ការលះបង់ ជាធម៌ ដែលសម្រេចដោយមគ្គនេះ មានដល់ព្រះអរិយៈគ្រប់រូបរួមដល់សុប្បពុទ្ធផង ] ។

លំដាប់នោះ ព្រះឥន្ទប្រញាប់ចូលគាល់ព្រះមានព្រះភាគ ហើយក្រាបទូលរឿងនេះដល់ព្រះអង្គ ព្រះបរមសាស្ដាទ្រង់ត្រាស់ថា បុគ្គលដូចជាអ្នកមួយរយ ឬមួយពាន់រូប ក៏មិនអាចធ្វើឲ្យសុប្បពុទ្ធ ពោលបដិសេធព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃបាន កាលសុប្បពុទ្ធបានគាល់ព្រះមានព្រះភាគក្រាបទូលធម៌ ដែលខ្លួនបានសម្រេចហើយ ក្នុងចន្លោះផ្លូវ ត្រឡប់បានត្រូវយក្ខិនី ដែលប្រែក្រឡា ជាមេគោជល់ស្លាប់ទៅ គេទៅកើតជាទេវបុត្រអ្នកមានអានុភាពក្នុងឋាន សួគ៌ ជាន់តាវតឹង្ស ដោយអានុភាពសទ្ធា សីល ការស្ដាប់ ការលះបង់ និងបញ្ញា សូម្បីនឹងធ្លាប់ជាមនុស្សកំសត់ កាលជាមនុស្សក៏ក្លាយ ជាទេវតា អ្នកទ្រទ្រង់ឥទ្ធានុភាពច្រើន ជាងទេវតាអង្គខ្លះដោយផលរបស់មគ្គញាណដែលខ្លួនសម្រេច ធ្វើឲ្យទេវតាអង្គខ្លះ កើតការច្រណែន ព្រះឥន្ទបានឮ រឿងនោះហើយ ទើបពោលថា ពួកអ្នកកុំច្រណែនសុប្បពុទ្ធឡើយគេ ទ្រទ្រង់ឫទ្ធានុភាពច្រើន ក្នុងខណៈនោះ ព្រោះបានសន្សំ**សទ្ធា សីល សុត ចាគ** និង **បញ្ញា** ពីព្រះសាសនា របស់ព្រះពុទ្ធជាម្ចាស់ ក្នុងរឿងនេះ មានក្នុងគម្ពីរអដ្ឋកថា នៃ**ឧទាន** និង**ធម្មបទ** ។

ឧទាហរណ៍ខាងដើម បង្ហាញឲ្យឃើញថា អ្នកដែលសម្រេចធម៌ជាព្រះអរិយៈ យ៉ាងពិតប្រាកដ នឹងមិនអាចបោកបញ្ឆោត ដោយទ្រព្យសម្បត្តិណាៗ ដើម្បីឲ្យពោលបដិសេធ ព្រះរតនត្រ័យបាន ព្រោះគេ មិនអាច

លះបង់ព្រះរតនត្រ័យ ដើម្បីប្តូរយកទ្រព្យ ក្រោកាយ កាលពិចារណា មើល នឹងជួបថា ការជ្រះថ្លាក្នុងព្រះរតនត្រ័យ របស់គេមាំទាំរហូត មិនអាចប្តូរ ជាមួយវត្ថុណាៗ បានឡើយ ។

**រឿងឧបាសិកា ឈ្មោះ ធនញ្ជានី ( ដែលត្រូវគេគម្រាមកម្ហែង )**

នាង**ធនញ្ជានី** ជាព្រះសោតាបន្ន ដែលមានសទ្ធាមុតមាំ ក្នុងព្រះរតនត្រ័យ ប៉ុន្តែ ស្វាមីរបស់នាង ឈ្មោះ ភារទ្វាជ បែជារាប់អានព្រាហ្មណ៍ទៅវិញ ថ្ងៃមួយ ស្វាមីរបស់នាងប្រាថ្នានឹងជប់លៀងអាហារដល់ព្រាហ្មណ៍ ចំនួន ៥០០ នាក់ ទើបនិយាយជាមួយនាងថា :

( **ភារទ្វាជ** ) នែ៎..នាង ព្រឹកនេះ ខ្ញុំនឹងអញ្ជើញព្រាហ្មណ៍ ៥០០ នាក់ មកឆាន់ភត្តាហារនៅផ្ទះ, ខ្ញុំអង្វរនាងណា សូមនាង កុំស្វាធ្យាយថា ឆមោ ពុទ្ធស្ស ( ខ្ញុំសូមនមស្សការ ចំពោះព្រះពុទ្ធជាម្ចាស់ ) កុំធ្វើឲ្យអាចារ្យរបស់ ខ្ញុំយល់ខុសថា រាប់អានព្រះសមណគោតម ។

( **ធនញ្ជានី** ) អ្នកអើយ..! លោកនឹងជាយ៉ាងនោះ, ក៏ខ្ញុំជួយមិនបានទេ កាលខ្ញុំរឭក ដល់ព្រះពុទ្ធជាម្ចាស់ ក៏នឹងថា ឆមោពុទ្ធស្ស ដូចដើម ។

( **ភារទ្វាជ** ) នែ៎..នាង បើស្អែកនេះនាងថា ឆមោ ពុទ្ធស្ស ឲ្យព្រាហ្មណ៍ បានឮ ខ្ញុំនឹងអារនាងចេញជាចំណិតៗ ។

នាងធនញ្ជានីស្តាប់ពាក្យនោះហើយ បានពោលគាថា រហូតដល់ ៥០០ បទ មានជាដើមយ៉ាងនេះថា ។

សចេ មេ អង្គមង្គលានិ        កាមំ ឆេជ្ជសិ ព្រាហ្មណា
នេវាហំ វិរមិស្សាមិ         ពុទ្ធសេដ្ឋស្ស សាសនា ។

“បពិត្រព្រាហ្មណ៍ សូម្បីលោកនឹងកាប់ខ្ញុំជាចំណិតៗ តាមត្រូវការខ្ញុំក៏នឹងមិន ព្រមលះបង់ចោលពាក្យប្រៀនប្រដៅព្រះបរមសាស្ដា ជាអ្នកប្រសើរយ៉ាងពិតប្រាកដ”។

ក្នុងទីបំផុត ព្រាហ្មណ៍ជាស្វាមី ក៏បណ្ដោយចិត្តនាង ។

ក្នុងថ្ងៃទទួលភត្តាហារ នាងធនញ្ជានី បានដើរជំពប់ជើងដួលចុះ ធ្វើឲ្យនាងឈឺខ្លាំង ទើបរឭកដល់ព្រះសម្មាសម្ពុទ្ធ ហើយប្រណម្យដៃលើសិរសបែមុខទៅរកវត្ត ជេតពន បន្លឺឧទាន ៣ ដងថា នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (សូមនមស្ការដល់ព្រះដ៏មានព្រះភាគ ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹង ដោយប្រពៃ ចំពោះព្រះអង្គឯង ព្រះអង្គនោះ ) ។

លំដាប់នោះ ព្រាហ្មណ៍ ដែលឆាន់ភត្តាហារ ក្រោធខឹងមិនពេញចិត្តហើយក្រោកឡើង ត្រឡប់ទៅ ចំណែកព្រាហ្មណ៍ **ភារទ្វាជ** ក៏ក្រោធខឹងនឹងភរិយា និងគិតថា នឹងយកឈ្នះសាស្ដារបស់នាង ដោយការផ្ចាញ់ផ្ចាលទើបទៅគាល់ព្រះបរមសាស្ដា ហើយទូលសួរបញ្ហា កាលបានស្ដាប់ចម្លើយហើយក៏បានសម្រេចធម៌ ទើបក្រាបទូលសូមបព្វជ្ជា, ឧបសម្បទា ក្នុងសំណាក់ព្រះសម្មសម្ពុទ្ធ មិនយូរប៉ុន្មាន ក៏បានសម្រេចជាព្រះអរហន្ត រឿងនេះ មានសម្ដែងក្នុងព្រាហ្មណា សំយុត្ត ។

នឹងឃើញបានថា ព្រះអរិយ សូម្បីនឹងត្រូវគេសម្លុតគម្រាម ឲ្យលះបង់

ភាពជាពុទ្ធបរិស័ទ ដែលរាប់អានព្រះរតនត្រ័យ ក៏មិនព្រមលះបង់ ពីព្រោះមានសទ្ធាជមុតមាំ ដូចនាង **ធនញ្ជានី** ។

## ☞រឿងឧបាសក ឈ្មោះ សូរម្ពដ្ឋ ( ដែលត្រូវគេបោកបញ្ឆោត )

ឧបាសកឈ្មោះ សូរម្ពដ្ឋនេះ ក្នុងសម័យកាលមុន បានតាំងមនោបណិធាន ដើម្បីឲ្យបានជាតំណែង ឯតទគ្គៈ ក្នុងភាពជា អ្នកមានសទ្ធាមាំទាំ ( អវេច្ចប្បសន្ន ) តាំងពីសម័យកាលនៃព្រះសម្មាសម្ពុទ្ធ ព្រះនាមថា បទុមុត្តរ តមកក្នុងសម័យកាលរបស់ព្រះគោតម បរមគ្រូយើងនេះ លោកបានកើតជាបុត្រសេដ្ឋី ក្នុងក្រុងសាវត្ថី ថ្ងៃមួយ គេអារាធនានិមន្តព្រះអង្គ មកទទួលភត្តាហារ ព្រះអង្គទ្រង់សម្តែងធម៌ ដល់គេខាងក្រោយភត្តកិច្ច និងគេបានសម្រេចធម៌ ជាព្រះសោតាបន្ន កាលស្តាប់ធម៌ចប់ ។

កាលព្រះអង្គស្តេចត្រឡប់ហើយ មារត្រូវការនឹងបញ្ឆោតគេ ទើបនិមិត្តព្រះពុទ្ធ ស្តេចយាងមកប្រថាប់ឈរខាងមុខទ្វារផ្ទះ ក្នុងខណៈនោះគេចម្លែកចិត្ត ដែលព្រះអង្គ ទ្រង់យាងត្រឡប់មកទៀត និងគិតថា គង់នឹងមានហេតុពិសេស ទើបចូលទៅថ្វាយបង្គំ ដោយសម្គាល់ថា ជាព្រះពុទ្ធ ហើយទូលសួរហេតុការណ៍ ដែលស្តេចយាងត្រឡប់មកទៀត មារពោលថាៈ

“ម្នាលសូរម្ពដ្ឋ តថាគតសម្តែងធម៌ ដល់អ្នកខ្វះមួយៗ គឺតថាគតពោលថា ខន្ធ ៥ ទាំងអស់ មិនទៀង ជាទុក្ខ មិនមែនតួខ្លួន តែខន្ធ ៥ ទាំងអស់ មិនមែនវត្ថុ ដែលមិនទៀង ជាទុក្ខ មិនមែនតួខ្លួន តាមការពិតមានខន្ធ ៥ ខ្វះទៀងពិត ស្ថិតនៅជានិច្ចដែរ” ។

ក្នុងខណៈនោះ សូរម្ពដ្ឋត្រិះរិះថា ព្រះតម្រាស់របស់ព្រះសម្មាសម្ពុទ្ធ រមែងមិនផ្លាស់ប្តូរ យើងបានធ្លាប់ឮថា មារធ្វើខ្លួនជាសត្រូវជាមួយព្រះពុទ្ធ បុគ្គលនេះ នឹងជាមារយ៉ាងពិតប្រាកដ ទើបសួរថា អ្នកជាមារឬ?

( មារ ) មែនហើយ.! យើងជាមារ ។

( សូរម្ពដ្ឋ ) មារដូចអ្នក មួយរយ មួយពាន់ ក៏មិនអាចទំលាយសទ្ធារបស់យើងបានឡើយ ព្រះបរមសាស្តាត្រាស់ថា សង្ខារទាំងពួង មិនទៀង អ្នកកុំនៅត្រង់ទ្វារ របស់យើងឡើយ ចូរជៀសចេញទៅឥឡូវនេះ ។

ព្រះអង្គទ្រង់អាស្រ័យរឿងនេះ លើកសរសើរ**សូរម្ពដ្ឋ**ថា ជាឯតទគ្គ លើសក្នុងភាពជាអ្នកមានសទ្ធាមុតមាំ រឿងនេះ មានសម្តែងនៅក្នុងគម្ពីរអដ្ឋកថា អង្គុត្តរនិកាយ ។

សូម្បីឧបាសក និងឧបាសិកាដទៃ នឹងមិនបានទទួលតំណែងឯតទគ្គ ដូច**សូរម្ពដ្ឋ** តែក៏សទ្ធាមុតមាំក្នុងព្រះរតនត្រ័យទាំងអស់ សូម្បីអ្នកណានឹងបោកបញ្ឆោត ក៏មិនឃើញខុសតាមនោះ និងមិនជឿតាមពាក្យ ដែលពោលខុស ជាអាទិ៍ដូច្នេះ :

-សង្ខារខ្លះទៀត ទៀង ជាសុខ ជាតួខ្លួន ។

-មគ្គ ផល និងព្រះនិព្វាន មិនមានពិតទេ ។

-សូម្បីបុគ្គលនឹងព្យាយាមបដិបត្តិធម៌ ក៏មិនអាចបានសម្រេចធម៌រម្ងាប់កិលេស ឬ ឲ្យកិលេសថយចុះបានឡើយ ។

-ការមានចិត្តតាំងមាំ មិនមានពិតទេ ។

-ការឃើញច្បាស់នូវរូបនាមថា មិនទៀង ជាសុខ មិនមែនតួខ្លួន ក៏មិនមានពិតដែរ ។

-ព្រះអរិយអ្នកកំពុងបដិបត្តិ ឬបដិបត្តិហើយ ដើម្បីរម្ងាប់កិលេស ក៏មិនមានពិត ដូចគ្នា ។

# "ព្រះអរិយៈ មានសីលដ៏ផូរផង់"

*ក្នុងគម្ពីរអដ្ឋកថា ពោលដល់សីល របស់ព្រះអរិយថា :*

***[១]*** អរិយកន្តេហីតិ អរិយានំ កន្តេហិ បិយេហិ មនាបេហិ ។

***[២]*** បញ្ច សីលានិ ហិ អរិយសាវកានំ កន្តានិ ហោន្តិ ភវន្តរេបិ អវិជហិតព្វតោ ។ ***[៣]*** តានិ សន្ធាយេតំ វុត្តំ ។

*"១. ពាក្យថា អរិយកន្តេហិ ( សីល ដែលព្រះអរិយពេញចិត្តហើយ ) មានន័យថា សីល ដែលព្រះអរិយពេញចិត្តហើយ គឺចូលចិត្ត ពោលគឺ ជាទីស្រឡាញ់ ។*

*២. ព្រោះសីល ៥ ជាទីពេញចិត្ត នៃព្រះអរិយទាំងឡាយ ពីព្រោះលោកមិនគប្បីលះបង់សីល សូម្បីក្នុងភពដទៃៗ ឡើយ ។*

*៣. ពាក្យនេះ បញ្ជាក់ដល់សីល ៥ នោះឯង" ។*

***[១]*** សចេបិ ភវន្តរគតំ អរិយសាវកំ អត្តនោ អរិយភាវំ អជានន្តម្បិ កោចិ ឯវំ វទេយ្យ ឥមំ កុន្ថកិបិល្លិកំ ជីវិតា វោរោបេត្វា សកលចក្កវាឡគព្ភេ ចក្កវត្តិរជ្ជំ បដិបជ្ជាហី"តិ ។***[២]***នេវ សោ តំ ជីវិតា វោរោបេយ្យ ។***[៣]*** អថាបិ នំ ឯវំ វទេយ្យុំ សចេ ឥមំ ន ឃាតេស្សតិ, សីសំ តេ ឆិន្ទិស្សាមាតិ ។ ***[៤]*** សីសមេវស្ស ឆិន្ទេយ្យុំ ។ នេវ សោ តំ ឃាតេយ្យ ។

*"១. បើបុគ្គលណាមួយ គប្បីពោលនឹងព្រះអរិយសាវក ដែលនៅ*

កើតក្នុងភពដទៃ សូម្បីនឹងមិនដឹងថាខ្លួន ជាព្រះអរិយៈ ថាលោកចូរសម្លាប់ស្រមោច, កណ្ដៀរនេះ ហើយចូរសោយរាជ្យសម្បត្តិ ជាស្ដេចចក្រពត្តិក្នុងចក្រវាឡទាំងអស់ចុះ ។

២. គេនឹងមិនគប្បីសម្លាប់ស្រមោច កណ្ដៀរនោះទេ ។

៣. សូម្បីនឹងពោលជាមួយនឹងគេ ទៀតថា បើលោកមិនសម្លាប់វាទេ យើងនឹងកាត់ក្បាលរបស់លោក ។

៤. អ្នកឲ្យសម្លាប់ គប្បីកាត់ក្បាលរបស់គេ ៗ មិនគប្បីសម្លាប់ស្រមោច កណ្ដៀរនោះ ដោយពិត" ។

ក្រៅពីវៀរចាកការសម្លាប់សត្វហើយ ព្រះសោតាបន្ននឹងមិនធ្វើខុស ឬកន្លងល្មើសសីលណាមួយក្នុងសីលទាំង ៥ គឺ ការលួចទ្រព្យ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក និងផឹកសុរាមេរ័យ ដាច់ជាសមុច្ឆេទ លោកទទួលសីលរបស់ខ្លួន ក្រៃលែងជាងទ្រព្យសម្បត្តិ រាងកាយ ឬសូម្បីប្ដូរដោយជីវិត ដូច្នោះ កាលបើលោក ពិចារណា ដោយខ្លួនឯង ឬទទួលយកអារម្មណ៍ដែលនាំឲ្យកើតកិលេស ក៏នឹងយល់ច្បាស់លាស់ដល់ការមានសទ្ធាមាំទាំ និងសីលដែលផូរផង់ តាម**ធម្មាទាសសូត្រ**នេះ ព្រះអរិយៈសោតាបន្ន ទើបជាអ្នកមានសីល និងសទ្ធា ដែលមាំទាំក្នុងកាលទាំងពួង ( ដូចក្នុងកាលដែលប្រឈមជាមួយភាវៈដែលនឹងត្រូវកន្លងល្មើស ។ល។ ) ។

# "ព្រះអរិយៈ មិនដឹងថា ខ្លួនផុតពីអបាយឡើយ"

*ព្រះអរិយតាំងពីសោតាបន្នជាដើមទៅ សូម្បីនៅមានខន្ធសេសសល់ ក៏ជាអ្នករួចផុតពីអបាយភូមិហើយ ព្រះសោតាបន្ន និងព្រះសកទាគាមី នឹងបានកើតក្នុងកាមសុគតិភូមិ ( មនុស្សនិងទេវតា ) រូបភូមិ និងអរូបភូមិ ប្រសិនបើកើតក្នុងកាមសុគតិភូមិ ក៏នឹងកើតក្នុងត្រកូលខ្ពង់ខ្ពស់ មិនថោកទាប ចំណែកឯព្រះអនាគាមី ក៏នឹងទៅកើតក្នុងរូបភូមិ ឬអរូបភូមិប៉ុណ្ណោះ ។*

*យ៉ាងណាក៏ដោយ លំដាប់ព្រះអរិយៈនឹងមិនអាចពិចារណាដឹងថា ខ្លួនឯង បានផុតពីអបាយភូមិហើយ តែត្រូវស្តាប់ពាក្យត្រាស់សម្តែងអំពីព្រះពុទ្ធជាម្ចាស់ ទើបនឹងដឹងបាន ដូចសេចក្តីក្នុងអង្គុត្តរនិកាយថា :*

**[១]** តេន ខោ បន សមយេន តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ "យោ ហិ កោចិ អាវុសោ សឧបាទិសេសោ កាលំ ករោតិ, សព្វោ សោ អបរិមុត្តោ និរយា, អបរិមុត្តោ តិរច្ឆានយោនិយា, អបរិមុត្តោ បេត្តិវិសយា, អបរិមុត្តោ អបាយទុគ្គតិវិនិបាតា" តិ ។**[២]** អថ ខោ អហំ ភន្តេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទិំ នប្បដិក្កោសិំ ។**[៣]**អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កាមិំ "ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមី"តិ ។

*"១. [ព្រះសារីបុត្រក្រាបទូលថា] ក្នុងសម័យនោះឯង កាលបើ*

ពួកតិរ្ថិយ បរិព្វាជកទាំងនោះ កំពុងអង្គុយប្រជុំសន្ទនាគ្នា បានមានពាក្យនេះឡើងថា ម្នាលអាវុសោទាំងឡាយ អ្នកណាមួយ ដែលនៅមានខន្ធអស់ជីវិតទៅ អ្នកនោះ សុទ្ធតែ មិនផុតពីនរក មិនផុតពីកំណើតសត្វតិរច្ឆាន មិនផុតពីប្រេតវិស័យ មិនផុតពីអបាយ ទុគ្គតិ និងវិនិបាត ។

២. ខ្ញុំព្រះអង្គមិនត្រេកអរ មិនជំទាស់ពាក្យ ដែលតិរ្ថិយបរិព្វាជកទាំងនោះហើយ ។

៣. គ្រានោះ ទើបក្រោកពីអាសនៈជៀសចេញទៅ ដោយគិតថា យើងនឹង ដឹងច្បាស់សេចក្តីនៃភាសិតនេះ ក្នុងសំណាក់ព្រះមានព្រះភាគ" ។

**[១]** កេ ច សារីបុត្ត អញ្ញតិត្ថិយា បរិព្វាជកា ពាលា អព្យត្តា, កេ ច សឧបាទិសេសំ វា សឧបាទិសេសោតិ ជានិស្សន្តិ, អនុបាទិសេសំ វា អនុបាទិសេសោតិ ជានិស្សន្តិ ។ **[២]** នវយិមេ សារីបុត្ត បុគ្គលា សឧបាទិសេសា កាលំ កុរុមានា បរិមុត្តា និរយា, បរិមុត្តា តិរច្ឆានយោនិយា, អបរិមុត្តោ បេត្តិវិសយា, បរិមុត្តា អបាយទុគ្គតិវិនិបាតា ។

"១. [ព្រះដ៏មានព្រះភាគត្រាស់ថា] ម្នាលសារីបុត្រ អន្យតិរ្ថិយ បរិព្វាជកល្ងង់ខ្លៅ មិនឆ្លាត ធ្វើម្តេចនឹងដឹង អ្នកដែលនៅមានខន្ធសេសសល់ថាជា **សឧបាទិសេស** ឬ នឹងដឹងអ្នកដែលមិនមានខន្ធសេសសល់ថា ជា **អនុបាទិសេស** ។

២. ម្នាលសារីបុត្រ បុគ្គល ៩ ជំពូកនេះ ដែលមានខន្ធសេសសល់ អស់ជីវិត រមែងរួចពីនរក ផុតពីកំណើតសត្វតិរច្ឆាន ផុតពីប្រេតវិស័យ

ផុតពីអបាយ ទុគ្គតិ និង វិនិបាត" ។

កាលបើព្រះអង្គត្រាស់ដូច្នេះហើយ បានចែកព្រះអរិយ ៩ ជំពូក ទុកដូច្នេះ :-

១. អ្នកជាអន្តរាបរិនិព្វាយី សំដៅដល់ ព្រះអនាគាមី អ្នកទៅកើតក្នុងសុទ្ធាវាសភូមិ ភូមិណាមួយ បានសម្រេចជាព្រះអរហន្ត ហើយបរិនិព្វានក្នុងពាក់កណ្ដាលដំបូងអាយុរបស់សុទ្ធាវាសភូមិនោះ ។

២. អ្នកជា**ឧបហច្ចបរិនិព្វាយី** សំដៅដល់ ព្រះអនាគាមីអ្នកទៅកើតក្នុងសុទ្ធាវាសភូមិ ភូមិណាមួយ បានសម្រេចជាព្រះអរហន្តហើយបរិនិព្វានក្នុងពាក់កណ្ដាល ខាងក្រោយរបស់អាយុសុទ្ធាវាសភូមិនោះ ។

៣. អ្នកជា**អសង្ខារបរិនិព្វាយី** សំដៅដល់ ព្រះអនាគាមី អ្នកទៅកើតក្នុងសុទ្ធាវាសភូមិ ភូមិណាមួយ បានសម្រេចជាព្រះអរហន្តក្នុងភូមិនោះដោយស្រួលមិនចាំបាច់ ប្រើសេចក្ដីព្យាយាមច្រើន ហើយក៏រលត់ខន្ធបរិនិព្វាន ។

៤. អ្នកជា**សសង្ខារបរិនិព្វាយី** សំដៅដល់ ព្រះអនាគាមី អ្នកទៅកើតក្នុង សុទ្ធាវាសភូមិ ភូមិណាមួយ សម្រេចជាព្រះអរហន្ត ក្នុងភូមិនោះដោយសេចក្ដី ព្យាយាមយ៉ាងខ្លាំងក្លា ហើយក៏រលត់ខន្ធបរិនិព្វាន ។

៥. អ្នកជាឧទ្ធំសោតោអកនិដ្ឋគាមី សំដៅដល់ ព្រះអនាគាមី អ្នកទៅកើតក្នុងសុទ្ធាវាសភូមិ ថ្នាក់ទាប គឺ **អវិហាភូមិ** កាលចុតិហើយ ទៅកើតក្នុងសុទ្ធាវាសភូមិថ្នាក់ខ្ពស់ឡើងទៅ តាមលំដាប់ ពោលគឺ **អតប្បាភូមិ**

**អតប្បីភូមិ សុទស្សាភូមិ សុទស្សីភូមិ** និង **អកនិដ្ឋាភូមិ** ហើយទើបបាន សម្រេចជាព្រះអរហន្ត និងរលត់ខន្ធបរិនិព្វានក្នុងអកនិដ្ឋាភូមិនោះ ។

៦. សកទាគាមី សំដៅដល់ ព្រះសកទាគាមី អ្នកនឹងត្រឡប់មក កើតក្នុងមនុស្សលោកត្រឹមមួយជាតិទៀត ។

៧. **ឯកពីជី** សំដៅដល់ ព្រះសោតាបន្ន ដែលនឹងបដិសន្ធិតទៅខាង មុខមួយជាតិទៀត ក៏នឹងសម្រេចអរហត្តផល ហើយបរិនិព្វាន លោកជា អ្នកបំពេញបារមី ដោយការចម្រើនសមថភាវនាតិច តែចម្រើនវិបស្សនា ច្រើន ទើបមានបញ្ញាចាស់ក្លា ។

៨. **កោលំកោល** សំដៅដល់ ព្រះសោតាបន្ន ដែលនឹងបដិសន្ធិ តទៅ ២ ឬ ៦ ជាតិទៀត ជាយ៉ាងច្រើន លោកជាអ្នកបំពេញបារមីយ៉ាង កណ្ដាល មានសមាធិ និង បញ្ញាស្មើៗ គ្នា ។

៩. **សត្តក្ខត្តុបរម** សំដៅដល់ ព្រះសោតាបន្ន ដែលនឹងបដិសន្ធិ ក្នុងមនុស្សភូមិ និង ទេវភូមិត្រឹម ៧ ជាតិទៀត ក៏នឹងសម្រេចអរហត្តផល ហើយបរិនិព្វាន ។

លំដាប់តពីនោះ ព្រះបរមសាស្ដា បានមានព្រះតម្រាស់ ដែលជា សារៈសំខាន់ ក្នុងរឿងនេះថា :-

**[១]** ឆ តាវាយំ សារីបុត្ត ធម្មបរិយាយោ បដិភាសិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ ។**[២]** តំ កិស្ស ហេតុ ។ មាយិនំ ធម្មបរិយានំ សុត្វា បមាទំ អាហរិស្សតិ ។ **[៣]** អបិចាយំ មយា សារីបុត្ត

ធម្មបរិយាយោ បញ្ហាធិប្បាយេន ភសិតោតិ ។

"១. ម្នាលសារីបុត្រ ព្រះធម៌ទេសនា នៅមិនទាន់ជាក់ច្បាស់ដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាមុន ។

២. សេចក្ដីនោះ ព្រោះហេតុអ្វី? ព្រោះអ្នកស្ដាប់ធម៌ទេសនា ដែលតថាគត សម្ដែងនេះហើយ កុំដល់នូវសេចក្ដីប្រមាទ ។

៣. ដូច្នោះ ក៏ដោយ តថាគតសម្ដែងធម៌ទេសនានេះទុក ដោយលក្ខណៈ ដែលគួរឆ្លើយពាក្យសួរ" ។

ព្រះសូត្រនេះ ជាសាធកៈសម្ដែងថា ព្រះអង្គទ្រង់ស្វែងយល់ថា ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី អ្នកនៅជាឧបាទិសេស ជ្រាបថា ខ្លួនបានផុតពីអបាយហើយ អាចប្រមាទមិនព្យាយាមបដិបត្តិ ដើម្បីឲ្យសម្រេចអរហត្តផល ដូច្នោះ ទើបទ្រង់រង់ចាំឲ្យមានអ្នកសួរមុនសិន ដោយហេតុនេះ ព្រះអរិយៈទាំង ៣ ជំពូកខាងដើម ទើបមិនអាចដឹងបានថា ខ្លួនមានសុគតិភពពិតប្រាកដ ដោយព្រះតម្រាស់របស់ព្រះអង្គ មិនអាចដឹងច្បាស់ដោយខ្លួនឯងបាន ព្រះមហានាមទើបសង្ស័យក្នុងភព ដែលនឹងទៅកើតតទៅដូចសេចក្ដីក្នុងសំយុត្តនិកាយថា :

*[១]* តស្ស មយ្ហំ ភន្តេ សមយេ មុស្សតេវ ភគវន្តំ អារព្ភសតិ ។ មុស្សតិ ធម្មំ អារព្ភ សតិ ។ មុស្សតិ សង្ឃំ អារព្ភ សតិ ។ *[២]* តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ "ឥមម្ហិ ចាហំ សមយេ កាលំ ករេយ្យំ, កា មយ្ហំ គតិ ។ កោ អភិសម្បរាយោតិ ។ *[៣]* មា ភាយិ មហានាម មា

ភាយិ មហានាម ។ អចាបកំ តេ មរណំ ភវិស្សតិ។ អចាបិកា កាលំកិរិយា ។[៤] យស្ស កស្សចិ មហានាម ទីឃរត្តំ សទ្ធាបរិភាវិតំ ចិត្តំ, សីល ។បេ ។ សុត ។បេ។ ចាគ ។បេ។ បញ្ញា បរិភាវិតំ ចិត្តំ, តស្ស យោ ហិ ខ្វាយំ កាយោ រូបី ។បេ។ តំ ឥធេវ កាកា វា ខាទន្តិ ។ គិជ្ឈា កុសលា វា សុខុមា វា សិង្គាលា វា វិវិធា វា ចាណកជាតា ខាទន្តិ យញ្ច ខ្វស្ស ចិត្តំ ទីឃរត្តំ សទ្ធាបរិភាវិតំ, សីល ។បេ ។សុត។បេ ។ ចាគ ។បេ។ បញ្ញា បរិភាវិតំ, តំ ឧទ្ធំគាមិ ហោតិ វិសេសគាមិ ។

*“១. [ព្រះបាទមហានាមទូលសួរថា] សម័យនោះ ខ្ញុំព្រះអង្គភ្លេចសតិដែលប្រារព្ធដល់ព្រះដ៏មានព្រះភាគ ព្រះធម៌ និងព្រះសង្ឃ បពិត្រព្រះអង្គដ៏ចម្រើន :*

*២. ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះថា បើយើងគប្បីអស់ជីវិតក្នុងពេលនេះ គតិ របស់យើង នឹងជាយ៉ាងណា **សម្បរាយិកភព** នឹងទៅជាយ៉ាងណា?*

*៣. [ព្រះដ៏មានព្រះភាគត្រាស់ថា] សូមថ្វាយព្រះពរមហាបពិត្រ កុំខ្លាចឡើយៗ ការសុគតដ៏ល្អនឹងមានដល់មហាបពិត្រ ការអស់ជីវិតដ៏ល្អនឹងមានដល់មហាបពិត្រ ។*

*៤. មហាបពិត្រ ចិត្តរបស់អ្នកណាមួយដែលអប់រំហើយ ដោយ**សទ្ធា សីល សុត ចាគ** និង**បញ្ញា** រហូតអស់កាលយូរ កាយនេះរបស់អ្នកនោះមានរូបពួកក្អែក ត្មាត សត្វគម្រង់ សុនខ ឆ្កែចចក ឬជន្លួរផ្សេងៗ រមែង*

ចឹកស៊ីកាយនេះឯង ចំណែកចិត្តរបស់អ្នកនោះ ដែល**សទ្ធា សីល សុត ចាគ** និង**បញ្ញា** អប់រំហើយអស់កាលយូរ រមែងទៅកាន់ខាងលើ សម្រេចនូវគុណធម៌វិសេស" ។

ក្រោយពីនោះ ព្រះមានព្រះភាគត្រាស់ថា អរិយសាវក អ្នកដល់ព្រមដោយអង្គ ៤ គឺ មានសទ្ធាមាំក្នុងព្រះរតនត្រៃ និងមានសីលដ៏បរិសុទ្ធ រមែងបង្អោនចិត្តទៅកាន់ព្រះនិព្វាន ហើយត្រាស់ឧបមាប្រៀបចិត្ត ដែលបានអប់រំល្អហើយ ដោយសទ្ធាជាដើមថា កាលបុគ្គលមុជចុះក្នុងទឹកហើយ ធ្លាំងដាក់ទឹកដោះថ្លា ឬប្រេង អំបែងធ្លាំងរមែងបែកលិចចុះ តែទឹកដោះថ្លា និងប្រេងរមែងអណ្តែតលើទឹក យ៉ាងណា ចិត្តដែលអប់រំល្អហើយ ដោយសទ្ធាជាដើម រមែងកាន់តែខ្ពស់ឡើង តាមលំដាប់យ៉ាងនោះ ឬកាលបុគ្គលកាប់ដើមឈើ ដែលគ្រេតទៅទិសខាងកើត ដើមឈើ ដែលត្រូវកាប់រមែងគ្រេត ទៅទិសខាងកើត យ៉ាងណា ចិត្តដែលអប់រំល្អហើយ ដោយសទ្ធាជាដើម រមែងបង្អោនទៅកាន់ព្រះនិព្វាន ដូចដើមឈើដែរ ។

ព្រះសូត្រដែលនាំមកអាងនេះ សំដែងសាធកៈថា ព្រះសោតាបន្ន និងព្រះសកទាគាមី អ្នកខ្វះ នៅមានសេចក្តីសង្ស័យ ក្នុងកពខាងមុខ កិលេសដែលខ្ទនលះបានហើយ និងកិលេស ដែលនៅមិនទាន់បានលះ ។

ដូចពាក្យទូលសួររបស់ព្រះបាទមហានាម យ៉ាងណាក៏ដោយ សេចក្តីសង្ស័យដូចពោល មិនមែនវិចិកិច្ឆានីវរណៈ លះបានដោយសោតាបត្តិមគ្គ បានដល់សេចក្តីសង្ស័យ ៨ ឬ ១៦ យ៉ាង ដែលមានអត្តានុទិដ្ឋិជាទី

អាស្រ័យ ដូចពោលទុកក្នុងកង្ខាវិតរណវិសុទ្ធិ ដូច្នោះ ព្រះអរិយទាំងនោះ ទើបមិនមានវិចិកិច្ឆា ដែលចាត់ជាអកុសល គួរលះដោយមគ្គញាណ ។

# " មហាបច្ចវេក្ខណៈ ៧ យ៉ាង "

*មហាបច្ចវេក្ខណៈ គឺជាការពិនិត្យមើលដ៏ធំក្រៃលែង ៧ ប្រការ របស់ព្រះសោតាបន្ន ចេញពី**មជ្ឈិមនិកាយ មូលបណ្ណាសក កោសម្ពិយសូត្រ** មានសេចក្តីដូចតទៅនេះ :-*

កថញ្ច ភិក្ខវេ យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយ។

*"ម្នាលភិក្ខុទាំងឡាយ ការដឹងច្បាស់ [ សោតាបត្តិមគ្គញាណ ] ដ៏ប្រាសចាកទោស ជាធម៌នាំចេញនូវអ្នកដែលប្រព្រឹត្តតាមនោះ ដើម្បីសេចក្តីរលត់ទុក្ខ ដោយប្រពៃជាយ៉ាងណា" ។*

*[១]* ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញា-គតោ វា ឥធ បដិសញ្ចិក្ខតិ " អត្ថិ នុ ខោ បរិយុដ្ឋានំ អជ្ឈត្តំ អប្បហីនំ, យេនាហំ បរិយុដ្ឋានេន បរិយុដ្ឋិតចិត្តោ យថាភូតំ អប្បជានេយ្យំ ន បស្សេយ្យន្តិ " ។

សចេ ភិក្ខវេ ភិក្ខុ កាមរាគបរិយុដ្ឋិតោ ហោតិ បរិយុដ្ឋិតចិត្តោវ ហោតិ ។ សចេ ភិក្ខវេ ភិក្ខុ ព្យាបាទបរិយុដ្ឋិតោ ។ ថិនមិទ្ធបរិយុដ្ឋិតោ, ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតោ, វិចិកិច្ឆាបរិយុដ្ឋិតោ ឥធលោកចិន្តាយ បសុតោ, បរលោកចិន្តាយ បសុតោ ហោតិ, បរិយុដ្ឋិតចិត្តោវ ហោតិ ។ សចេ ភិក្ខវេ ភិក្ខុ ភណ្ឌនជាតោ វិវាទាបន្នោ អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តោ វិហរតិ, បរិយុដ្ឋិតចិត្តោវ ហោតិ ។

សោ ឯវំ បជានាតិ " នត្ថិ ខោ មេ តំ បរិយុដ្ឋានំ អជ្ឈត្តំ អប្បហីនំ, យេនាហំ បរិយុដ្ឋានេន បរិយុដ្ឋិតចិត្តោ យថាភូតំ នប្បជានេយ្យំ ន បស្សេយ្យំ ។ សុប្បណិហិតំ មេ មានសំ សច្ចានំ ពោធាយា" តិ ។ ឥទមស្ស បឋមំ ញាណំ អធិគតំ ហោតិ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ ។

"១. ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះទៅកាន់ព្រៃ គល់ឈើ ឬផ្ទះស្ងាត់ រមែងពិចារណាឃើញ ដូច្នេះថា យើងមានចិត្ត ដែលនៅមាន បរិយុដ្ឋានកិលេសណា រួបរឹតហើយ មិនគប្បីឃើញច្បាស់ តាមសេចក្ដីពិត បរិយុដ្ឋានកិលេសខាងក្នុងដែលយើង លះមិនទាន់បាននោះ មាននៅឬហ្ន៎ ។

ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមានចិត្តដោយកាមរាគៈតាំងឡើង ក៏ឈ្មោះថា មានចិត្តត្រូវតាំងឡើងហើយតែម្តង មានចិត្តដែលព្យាបាទ បានតាំងឡើងហើយ... មានចិត្ត ដែលថីនមិទ្ធតាំងឡើងហើយ... មានចិត្ត ដែលឧទ្ធច្ចកុក្កុច្ចតាំងឡើងហើយ... មានចិត្ត ដែលវិចិកិច្ឆាតាំងឡើងហើយ... ជាអ្នកខ្វល់ខ្វាយក្នុងការគិតរឿងលោកនេះ... ជាអ្នកខ្វល់ខ្វាយក្នុងការគិតរឿងលោកខាងមុខ... កើតទាស់ចិត្តឈ្លោះវិវាទទាស់ទែងគ្នា និងគ្នា ដោយលំពែងគឺមាត់ ក៏ឈ្មោះថា មានចិត្តតាំងឡើងជុំវិញហើយតែម្តង ។

ភិក្ខុនោះ រមែងដឹងច្បាស់ដូច្នេះថា យើងមានចិត្តដែលបរិយុដ្ឋាន-កិលេសណា តាំងឡើងហើយ មិនគប្បីឃើញច្បាស់ តាមសេចក្ដីពិត បរិយុដ្ឋានកិលេសខាងក្នុង ដែលយើងនៅលះមិនទាន់បាននោះ មិនបាន

កើតឡើង ចិត្តយើងតាំងទុកល្អហើយ ដើម្បីត្រាស់ដឹងសច្ចធម៌ លោកបាន សម្រេចបច្ចវេក្ខណញាណទី ១ នេះ ដែលកើតឡើងអាស្រ័យលោកុត្តរៈ មិនជាប់ដោយបុថុជ្ជន" ។

ព្រះអដ្ឋកថាទ្រង់ចែកបរិយុដ្ឋានកិលេស មានកាមរាគៈជាដើម ដើម្បី សម្តែងចំនួន កិលេសដូចពោលដែលមាននៅក្នុងចិត្តរបស់បុថុជ្ជន និង ព្រះសេក្ខៈ មិនបានសំដៅយក កិលេសគ្រប់យ៉ាង ត្រូវកើតឡើងក្នុង ចិត្តរបស់ព្រះអរិយៈ ។

បរិយុដ្ឋានកិលេស គឺនីវរណៈខ្ទះម៉្យាង ប្រាកដដល់ព្រះអរិយៈ ក្នុងខណៈ ចម្រើនវិបស្សនា តែកិលេសដូចពោល មិនអាចបិទបាំងការ កើតរលត់របស់រូបនាមបាន កាលលោកកំណត់ដឹងកិលេសទាំងនោះហើយ ក៏កំចាត់បានមួយរំពេចដោយមិន រវើរវាយជាពេលយូរ តមកកាលវិបស្សនា មានកម្លាំងច្រើនឡើង កិលេសដូចពោល ក៏នឹងមិនប្រាកដឡើងទៀត ដូច្នោះ បច្ចវេក្ខណញាណទី ១ ទើបកើតដល់អ្នកមិនជួប បរិយុដ្ឋានកិលេស ដែល បិទបាំងមិនឲ្យដឹងច្បាស់ការកើតរលត់ នឹងធ្វើឲ្យអ្នកសម្រេចទុកចិត្តបានថា ខ្លួនជាព្រះអរិយៈ ។

**[២]** បុន ច បរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ "ឥមំ នុ ខោ អហំ ទិដ្ឋឹ អាសេវន្តោ ភាវេន្តោ ពហុលីករោន្តោ លភាមិ បច្ចត្តំ សមថំ, លភាមិ បច្ចត្តំ និព្វុតិន្តិ" ។ សោ ឯវំ បជានាតិ "ឥមំ ខោ អហំ ទិដ្ឋឹ អាសេវន្តោ ភាវេន្តោ ពហុលីករោន្តោ លភាមិ បច្ចត្តំ សមថំ, លភាមិ បច្ចត្តំ និព្វុតិន្តិ"។ ឥទមស្ស

ទុតិយំ ឈានំ អធិគតំ ហោតិ អរិយំ

លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ។

"២. ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានទៀត អរិយសាវក រមែងពិចារណាឃើញដូច្នេះថា យើងសេពចម្រើន នឹងធ្វើសេចក្ដីឃើញច្បាស់នេះ ឲ្យច្រើន រមែងសម្រេចសេចក្ដីស្ងប់ខាងក្នុងចិត្តរបស់ខ្លួនឬហ្ន៎ អរិយសាវកនោះ រមែងឃើញ ច្បាស់យ៉ាងនេះថា យើងសេពចម្រើន និងធ្វើសេចក្ដីឃើញច្បាស់នេះឲ្យច្រើន រមែងសម្រេចការស្ងប់ចំពោះខ្លួន លោកបានសម្រេចបច្ចវេក្ខណញាណទី ២ នេះ ដែលកើតឡើងអាស្រ័យលោកុត្តរៈមិនជាប់ដោយបុថុជ្ជន" ។

ព្រះអរិយៈអ្នកសម្រេចមគ្គញាណ ហើយចម្រើនវិបស្សនា រមែងសេពបញ្ញា ដែលកើតអំពីមគ្គញាណរឿយៗ លោកជួបថា បរិយុដ្ឋាន-កិលេសស្ងប់ទៅពីចិត្តរបស់ខ្លួន និងកិលេសដែលជាប់ដោយអារម្មណ៍ ដែលខ្លួនកំណត់ដឹង ក៏មិនកើតឡើង ដូច្នោះ បច្ចវេក្ខណញាណទី ២ ទើបកើតដល់អ្នកឃើញច្បាស់សេចក្ដីស្ងប់ទៅរបស់កិលេស នឹងធ្វើឲ្យអ្នកសម្រេចទុកចិត្តបានថា ខ្លួនជាព្រះអរិយៈ ។

**[១]** បុន ច បរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ "យថារូ-បាយាហំ ទិដ្ឋិយា សមន្នាគតោ, អត្ថិ នុ ខោ ឥតោ ពហិទ្ធា អញ្ញោ សមណោ វា ព្រាហ្មណោ វា តថារូបាយ ទិដ្ឋិយា សមន្នាគតោ"តិ ។ សោ

ឃំ បជានាតិ "យថារូបាយាហំ ទិដ្ឋិយា សមន្នាគតោ, នត្ថិ ឥតោ ពហិទ្ធា អញ្ញោ សមណោ វា ព្រាហ្មណោ វា យថារូបាយាហំ ទិដ្ឋិយា សមន្នាគតោ"តិ ។ ឥទមស្ស តតិយំ ញាណំ អធិគតំ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ ។

*"៣. ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានទៀត អរិយសាវក រមែងពិចារណា ឃើញដូច្នេះថា យើងប្រកបដោយការឃើញច្បាស់ [ គឺ មគ្គញាណប្រភេទណា សមណៈ ឬ ព្រាហ្មណ៍ដទៃក្រៅធម្មវិន័យនេះ អ្នកប្រកបដោយការឃើញច្បាស់ ដូច្នោះ មាននៅឬហ្ន៎ អរិយសាវកនោះ រមែងឃើញច្បាស់យ៉ាងនេះថា យើងប្រកបដោយការឃើញច្បាស់យ៉ាងណា សមណៈ ឬ ព្រាហ្មណ៍ដទៃក្រៅធម្មវិន័យនេះ អ្នកប្រកបដោយការឃើញ ច្បាស់យ៉ាងនោះ មិនបានមាន លោកបានសម្រេចបច្ចវេក្ខណញាណទី ៣ នេះ ដែលកើតឡើងអាស្រ័យលោកុត្តរៈ មិនជាប់ដោយបុថុជ្ជន*

***[៤]*** បុន ច បរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យថារូ-បាយ ធម្មតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ, អហម្បិ តថារូបាយ ធម្មតាយ សមន្នាគតោ"តិ ។ កថំរូបាយ ច ភិក្ខវេ ធម្មតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ ។ ធម្មតា ឯសា ភិក្ខវេ ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស កិញ្ចាបិ តថារូបឹ អាបត្តឹ អាបជ្ជតិ, តថារូបាយ អបត្តិយា វុដ្ឋានំ បញ្ញាយតិ ។ អថ ខោ នំ ខិប្បមេវ សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ

ទេសេតិ វិវរតិ ឧត្តានីករោតិ, ទេសេត្វា វិវរិត្វា ឧត្តានីកត្វា អាយតឹ សំវរំ អាបជ្ជតិ ។ សេយ្យថាបិ ភិក្ខវេ ទហរោ កុមារោ មន្ទោ ឧត្តានសេយ្យកោ ហត្ថេន វា បាទេន វា អង្គារំ អក្កមិត្វា ខិប្បមេវ បដិសំហរតិ, ឯវមេវ ខោ ភិក្ខវេ ធម្មតា ឯសា ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស ។បេ។ សវរំ បជានាតិ ។ សោ ឯវំ បជានាតិ "យថារូបាយ ធម្មតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ, អហម្បិ យថារូបាយ ធម្មតាយ សមន្នាគតោ"តិ ។ ឥទមស្ស ចតុត្ថំ ញាណំ អធិគតំ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ។

"៤. ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានទៀត អរិយសាវក រមែង ពិចារណាឃើញដូច្នេះថា បុគ្គលអ្នកដល់ព្រមដោយការឃើញច្បាស់ [ គឺមគ្គញាណ ] ប្រកបដោយធម្មតាយ៉ាងណា ដល់យើង ក៏ប្រកបដោយធម្មតាយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកដល់ព្រមដោយសេចក្ដីឃើញច្បាស់ ប្រកបដោយធម្មតាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ធម្មតានេះ របស់បុគ្គល អ្នកដល់ព្រមដោយការឃើញច្បាស់ គឺការចេញពីអាបត្តិយ៉ាងណា រមែងប្រាកដ អរិយសាវក រមែងត្រូវអាបត្តិយ៉ាងនោះខ្លះ ដោយពិតដល់យ៉ាងនោះ អរិយសាវកនោះ ក៏ប្រញាប់សម្ដែង បើក បង្ហាញធ្វើអាបត្តិនោះ ឲ្យប្រាកដក្នុងសំណាក់ព្រះសាស្ដា ឬមិត្តសព្រហ្មចារី ដែលជាវិញ្ញូជន គ្រាសម្ដែងបើកបង្ហាញ ធ្វើឲ្យប្រាកដហើយ ក៏ដល់ការសង្រួមតទៅ ប្រៀបជាដូចក្មេងតូច ដែលដេកផ្ងារត្រូវរងើកភ្លើងដោយដៃ ឬជើងហើយ ក៏ត្រូវកន្ត្រាក់ចេញយ៉ាងឆាប់រហ័ស ដូច្នោះ ម្នាលភិក្ខុទាំងឡាយ

ធម្មតានេះ របស់បុគ្គលអ្នកដល់ព្រមដោយការ ឃើញច្បាស់... ក៏ដល់ការសង្រួមតទៅ អរិយសាវកនោះ រមែងឃើញច្បាស់យ៉ាងនេះថា បុគ្គលអ្នកដល់ព្រមដោយការឃើញច្បាស់ ប្រកបដោយធម្មតាយ៉ាងណា ដល់យើង ក៏ប្រកបដោយធម្មតា យ៉ាងនោះ លោកបានសម្រេច បច្ចវេក្ខណញាណទី ៤ នេះ ដែលកើតឡើងអាស្រ័យលោកុត្តរៈ មិនជាប់ដោយបុថុជ្ជន" ។

ភិក្ខុជាព្រះអរិយៈ រមែងត្រូវអាបត្តិ ដែលមិនមានចេតនា នឹងជាទោសផ្លូវលោក ដែលហៅថា **អចិត្តកៈ បណ្ណត្តិវជ្ជៈ** ដូចអាបត្តិធ្ងន់តាម **កុដិការសិក្ខាបទ** ( ពោលដោយការសាងកុដិធំហួសប្រមាណ ) និងអាបត្តិស្រាលតាម**សហសេយ្យសិក្ខាបទ** ( ពោលដោយការ ដេករួមជាមួយនឹង **អនុបសម្បន្ន** គឺអ្នកមិនមែនភិក្ខុ និងភិក្ខុនីលើស ៣ ថ្ងៃ ) លោកអាចត្រូវអាបត្តិដោយការភ្លាំងភ្លាត់ ដោយប្រាសចាកចេតនា និងកាលត្រូវអាបត្តិហើយ ក៏នឹងសម្តែងអាបត្តិប្រាប់ដល់ទោសរបស់ខ្លួនភ្លាម ចំណែកគ្រហស្ថអ្នក ជាព្រះអរិយៈ ក៏នឹងមិនបិទបាំងទោសរបស់ខ្លួន បើមានអ្នកប្រាថ្នាប្រយោជន៍ដើម្បីសួរ ក៏នឹងព្រមទទួលទោសរបស់ខ្លួនតាមសេចក្តីពិត ដូចមានសាធកៈ ពោលថា :

**[១]** អរិយសាវកោ ហិ អបត្តឹ អាបជ្ជន្តោ គរុកាបត្តីសុ កុដិ–ការសទិសំ លហុកាបត្តីសុ សហសេយ្យាទិសទិសំ អចិត្តកាបត្តឹយេវ អាបជ្ជតិ ។ **[២]** តមប្បិ អសញ្ចិច្ច, នោ សញ្ចិច្ច ។ អាបន្នំ ន បដិច្ឆាទេតិ ។

“១. មែនពិត អរិយសាវក ដែលត្រូវអាបត្តិ រមែងត្រូវអាបត្តិ ដែលមិនមានចេតនា ដូចកដិការអាបត្តិក្នុងអាបត្តិធ្ងន់ និងដូច**សហសេយ្យាបត្តិ** ក្នុងអាបត្តិស្រាល ។

២. លោកត្រូវអាបត្តិនោះ ដោយមិនតាំងចិត្ត មិនត្រូវអាបត្តិដោយតាំងចិត្ត នឹងមិនបិទបាំងអាបត្តិ ដែលត្រូវហើយ” ។

ទេសេតីតិ អបត្តិបដិគ្គាហកេ សភាគបុគ្គលេ សតិ ឯកំ ទិវសំ វា រត្តឹ វា អនធិវាសេត្វា រត្តឹ ចតុរង្គេបិ តមេ សភាគភិក្ខុនោ វសនដ្ឋានំ គន្ត្វា ទេសេតិយេវ ។

“ពាក្យពោលថា ទេសេតិ ( សម្តែង ) មានន័យថា កាលបើមានបុគ្គលដែលប្រាថ្នាប្រយោជន៍ ក៏មិនរង់ចាំមួយថ្ងៃ រមែងទៅកាន់ទីអាស្រ័យរបស់ភិក្ខុអ្នកប្រាថ្នាប្រយោជន៍ សូម្បីមានភាពងងិតដោយអង្គ ៤ [ ភាពងងឹតក្នុងពេលកណ្តាលអាធ្រាតរបស់ថ្ងៃ ១៥ រោច ខណៈនៅក្នុងព្រៃសណ្ឋះក្រាស់ និងមានពពកបាំង ] ហើយសម្តែងអាបត្តិតែម្តង” ។

**[៥]** បុន ច បរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ "យថារូ- ចាយ ធម្មតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ, អហម្បិ តថារូចាយ ធម្មតាយ សមន្នាគតោ"តិ ។ កថំរូចាយ ច ភិក្ខវេ ធម្មតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ ។ ធម្មតា ឯសា ភិក្ខវេ ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស កិញ្ចាបិ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ, តត្ថ

ឧស្សុក្កមាបន្នោ ហោតិ ។ អត្ថ ឆ្វស្ស តិព្វាបេក្ខា ហោតិ អធិសីលសិក្ខាយ អធិចិត្តសិក្ខាយ អធិបញ្ញាសិក្ខាយ ។

សេយ្យថាបិ ភិក្ខវេ គាវី តរុណវច្ឆា ថម្ភំ ច អាលុម្បតិ, វច្ឆកំ ច អបចិនតិ, ឯវមេវ ខោ ភិក្ខវេ ធម្មតា ឯសា ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស កិញ្ចាបិ ។ បេ ។ អធិបញ្ញាសិក្ខាយ ។ សោ ឯវំ បជានាតិ "យថារូបាយ ធម្មតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ, អហម្បិ យថារូបាយ ធម្មតាយ សមន្នាគតោ"តិ ។ ឥធមស្ស បញ្ចមំ ញាណំ អធិគតំ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ ។

*"៥. ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានទៀត អរិយសាវក រមែងពិចារណាឃើញដូច្នេះថា បុគ្គលអ្នកដល់ព្រមដោយការឃើញច្បាស់ ប្រកបដោយធម្មតាយ៉ាងណា ដល់យើងក៏ប្រកបដោយធម្មតាយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកដល់ព្រមដោយការឃើញច្បាស់ ប្រកប ដោយធម្មតា យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ធម្មតានេះ របស់បុគ្គល អ្នកដល់ព្រមដោយការឃើញច្បាស់ គឺអរិយសាវក ដល់សេចក្តីខ្វល់ខ្វាយ ក្នុងកិច្ចតូច-ធំ ដែលគួរធ្វើរបស់មិត្តសព្រហ្មចារីដោយពិត ដល់យ៉ាងនោះ សេចក្តីព្យាយាមក្រៃលែងរបស់*អធិសីលសិក្ខា អធិចិត្តសិក្ខា *និង* អធិបញ្ញាសិក្ខា*របស់លោកក៏នៅមាន ។*

*ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាមេគោកូនខ្ចី រមែងស៊ីស្មៅផង ក្រឡេកមើលកូនផង ដូច្នោះ អរិយសាវកនោះ រមែងដឹងច្បាស់យ៉ាង*

នេះថា បុគ្គលអ្នកដល់ព្រម ដោយការឃើញច្បាស់ប្រកបដោយធម្មតា យ៉ាងណា ដល់យើងក៏ប្រកបដោយធម្មតា យ៉ាងនោះ លោកបានសម្រេច បច្ចវេក្ខណញាណទី ៥ នេះ ដែលកើតឡើងអាស្រ័យលោកុត្តរៈមិនជាប់ដោយបុថុជ្ជន” ។

[៦] បុន ច បរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ “យថារូ–ចាយ ពលតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ, អហម្បិ តថារូចាយ ពលតាយ សមន្នាគតោ” តិ ។ កថំរូចាយ ច ភិក្ខវេ ពលតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ ។ ពលតា ឯសា ភិក្ខវេ ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស, យំ តថាគតប្បវេទិតេ ធម្មវិនយេ ទេសិយមានេ អត្ថិកត្វា មនសិកត្វា សព្វចេតសា សមន្នាហរិត្វា ឱហិតសោតោ ធម្មំ សុណាតិ ។ សោ ឯវំ បជានាតិ “យថារូចាយ ពលតាយ ។បេ។ សមន្នាគតោ” តិ ។ ឥទមស្ស ចដ្ឋំ ឈាណំ អធិគតំ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ ។

“៦. ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានទៀត អរិយសាវក រមែងពិចារណា ឃើញដូច្នេះថា បុគ្គលអ្នកដល់ព្រមដោយការឃើញច្បាស់ប្រកបដោយពលៈយ៉ាងណា ដល់យើង ក៏ប្រកបដោយពលៈយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកដល់ព្រមដោយការឃើញច្បាស់ ប្រកបដោយពលៈយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ពលៈនេះ របស់បុគ្គលអ្នកដល់ព្រមដោយការឃើញច្បាស់ គឺកាលបុគ្គលអ្នកសម្តែងធម្មវិន័យ ដែល

*ព្រះតថាគតប្រកាស អរិយសាវកនោះ យកចិត្តទុកដាក់ធ្វើឲ្យកើត ប្រយោជន៍ កំណត់ដោយចិត្តទាំងអស់ផ្ទៀងសោតៈស្តាប់ធម៌ អរិយសាវកនោះ ដឹងច្បាស់យ៉ាងនេះថា បុគ្គលអ្នកដល់ព្រមដោយការឃើញច្បាស់ ប្រកបដោយពលៈយ៉ាងណា ដល់យើងក៏ប្រកបដោយពលៈយ៉ាងនោះ លោកបានសម្រេចបច្ចវេក្ខណញាណទី ៦ នេះ ដែលកើតឡើង អាស្រ័យលោកុត្តរៈ មិនជាប់ដោយបុថុជ្ជន" ។*

**[៧]** បុន ច បរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ "យថារូ-បាយ ពលតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ, អហម្បិ តថារូបាយ ពលតាយ សមន្នាគតោ"តិ ។ កថំរូបាយ ច ភិក្ខវេ ពលតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ ។ ពលតា ឯសា ភិក្ខវេ ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស, យំ តថាគតប្បវេទិតេ ធម្មវិនយេ ទេសិយមនេ លភតិ អត្ថវេទំ ។ លភតិ ធម្មវេទំ ។ លភតិ ធម្មូបសំហិតំ បាមុជ្ជំ ។ សោ ឯវំ បជានាតិ "យថារូបាយ ពលតាយ ។បេ។ សមន្នាគតោ"តិ ។ ឥទមស្ស សត្តមំ ញាណំ អធិគតំ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ ។

*"៧. ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានទៀត អរិយសាវករមែងពិចារណា ឃើញដូច្នេះថា បុគ្គលអ្នកដល់ព្រមដោយការឃើញច្បាស់ ប្រកបដោយពលៈយ៉ាងណា ដល់យើង ក៏ប្រកបដោយពលៈយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកដល់ព្រមដោយការឃើញច្បាស់ ប្រកបដោយពលៈយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ពលៈនេះ របស់បុគ្គល*

អ្នកដល់ព្រមដោយការឃើញច្បាស់ គឺកាលបុគ្គលសម្តែងធម្មវិន័យ ដែលព្រះតថាគតប្រកាស់ទុក អរិយសាវកនោះ រមែងយល់សេចក្តី យល់គោលធម៌ បានទទួលបាមោជ្ជ ប្រកបដោយធម៌ អរិយសាវកនោះ ដឹងច្បាស់យ៉ាងនេះថា បុគ្គល អ្នកដល់ព្រមដោយការឃើញច្បាស់ ប្រកបដោយពលៈយ៉ាងណា ដល់យើងក៏ប្រកប ដោយពលៈយ៉ាងនោះ លោកបានសម្រេចបច្ចវេក្ខណញាណទី ៧ នេះ ដែលកើតឡើងអាស្រ័យលោកុត្តរៈ មិនជាប់ដោយបុថុជ្ជន” ។

ឯវំ សត្តង្គសមន្នាគតស្ស ខោ ភិក្ខវេ អរិយសាវកស្ស ធម្មតា សុសមឆិដ្ឋា ហោតិ សោតាបត្តិផល សច្ចិកិរិយាយ ។ ឯវំ សត្តង្គសមន្នា-គតោ ខោ ភិក្ខវេ អរិយសាវកោ សោតាបត្តិផលសមន្នាគតោ ហោតិ ។

“ម្នាលភិក្ខុទាំងឡាយ ធម៌ណា [ គឺប្រក្រតីរបស់ព្រះអរិយ ] ដែលអរិយសាវក អ្នកប្រកបដោយអង្គ ៧ ប្រការយ៉ាងនេះ ពិនិត្យមើលល្អហើយ ដោយញាណដែលឃើញច្បាស់ សោតាបត្តិផល ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកប្រកបដោយអង្គ ៧ ប្រការនេះ រមែងជាអ្នកដល់ព្រមដោយសោតាបត្តិផល” ។

-.-.-.-.

# "ការចូលផលសមាបត្តិ "

ផលសមាបត្តិ គឺការកើតឡើងរបស់ផលចិត្តនៃព្រះអរិយៈ ដូចជាមួយការចូល កាន់ការរលត់រូបនាមទាំងអស់ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា:

កា ផលសមាបត្តីតិ ។

យា អរិយផលស្ស និរោធេ អប្បនា ។

សួរថា : ផលសមាបត្តិ គឺអ្វី?

ឆ្លើយថា : គឺការចូលទៅក្នុងសេចក្តីរលត់ [ រូបនាម ] របស់ផលចិត្តនៃព្រះអរិយៈ ។

បុថុជ្ជនមិនអាចចូលផលសមាបត្តិបាន ព្រោះនៅមិនបានសម្រេចផល មិនអាច ត្រឡប់ចូលផលសមាបត្តិ ក្នុងលំដាប់ផល ដែលសម្រេចកន្លងមកហើយ ផលថ្នាក់ខ្ពស់ ក្នុងគម្ពីរវិសុទ្ធិមគ្គ ពោលដល់ការយល់របស់អ្នកខ្លះ ( **កេចិវាទ** ) ថា អ្នកខ្លះ ពោលថា "ព្រះអនាគាមិ និងព្រះអរហន្តប៉ុណ្ណោះ អាចចូលផលសមាបត្តិបាន ព្រោះបំពេញ**សមាធិសិក្ខា**បរិបូណ៌ តែព្រះសោតាបន្ន និងព្រះសកទាគាមី មិនអាចចូលផលសមាបត្តិបាន ព្រោះមិនបានបំពេញ**សមាធិសិក្ខា**បរិបូណ៌" ហើយពោលជំទាស់ថា បុថុជ្ជនអាចចូលឈានសមាបត្តិ ដែលខ្លួនធ្លាប់សម្រេចមកហើយបាន ព្រះអរិយៈទើបគួរចូលផលសមាបត្តិ ដែលធ្លាប់សម្រេចមកហើយបានដូចគ្នា សូម្បីក្នុងគម្ពីរបដិសម្ភិទាមគ្គក៏ដល់រឿងនេះថា :

សោតាបត្តិផលសមាបត្តត្ថាយ ឧប្បាទំ និមិត្តំ អយូហានំ បដិសន្ធិ ។ បេ ។ អភិភុយ្យតីតិ គោត្រភុ ។

*“ញាណឈ្មោះថា គោត្រភូ ព្រោះគ្របសង្កត់ការកើតឡើង ការប្រព្រឹត្តទៅ និមិត្ត ( វត្ថុដែលប្រាកដដូចមានពិត ) សេចក្តីខ្វល់ខ្វាយ បដិសន្ធិ... ដើម្បីត្រូវការចូល សោតាបត្តិផលសមាបត្តិ” ។*

សកទាគាមិផលសមាបត្តត្ថាយ ឧប្បាទំ ។ល។ អភិភុយ្យតីតិ គោត្រភុ ។

*“ញាណឈ្មោះថា គោត្រភូ ព្រោះគ្របសង្កត់ការកើតឡើង.......... ដើម្បីត្រូវការ ចូលសកទាគាមិផលសមាបត្តិ” ។*

*សរុបសេចក្តីថា ព្រះអរិយអាចចូលផលសមាបត្តិ ដែលខ្លួនសម្រេចបានដោយពិត យ៉ាងណាក៏ដោយ លោកមិនអាចចូលផលសមាបត្តិបានក្នុងខណៈឥន្ទ្រិយ៍ ៥ នៅមិនទាន់ចាស់ក្លា ទើបគួរចម្រើនវិបស្សនាដដែលហើយដដែលទៀត ដើម្បីឲ្យសមាធិន្ទ្រិយ៍ជាដើមចាស់ក្លា កាលឥន្ទ្រិយ៍ ៥ ចាស់ក្លាបរិបូណ៌ហើយ លោកក៏នឹងសម្រេចផលសមាបត្តិ កាលចូលផលសមាបត្តិបានរឿយៗ ទើបនឹងប្រាកដចិត្តថា ខ្លួន ជាព្រះអរិយបុគ្គល ដូចសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គថា :*

វិបស្សនា បនេសា តិវិធា ហោតិ សង្ខារបរិគ្គណ្ហនកវិបស្សនា ផលសមាបត្តិវិបស្សនា និរោធសមាបត្តិវិបស្សនាតិ ។ តត្ថ សង្ខារបរិគ្គ-ណ្ហនកវិបស្សនា មន្ទា វា ហោតុ តិក្ខា វា, មគ្គស្ស បទដ្ឋានំ

ហោតិយេវ ។ ផលសមាបត្តិវិបស្សនា តិក្ខា វដ្ដតិ មគ្គភាវនាសទិសា ។ និរោធសមាបត្តិវិបស្សនាតិ បន នា តិមន្ទនាតិតិក្ខា វដ្ដតិ ។

*“ម្យ៉ាងទៀត វិបស្សនា ៣ យ៉ាងគឺ :*

*១. សង្ខារបរិគ្គណ្ហនកវិបស្សនា ( វិបស្សនា ដែលកំណត់ដឹងសង្ខារ ) នឹងជាយ៉ាងទន់ខ្សោយ ឬចាស់ក្លាក៏ដោយ ជាហេតុជិតដល់មគ្គបានដូចគ្នា ។*

*២. ផលសមាបត្តិវិបស្សនា ( វិបស្សនាដើម្បីចូលផលសមាបត្តិ ) ត្រូវជាយ៉ាង ចាស់ក្លាពិតៗ ដូចគ្នានឹងមគ្គភាវនា ទើបប្រើបាន ។*

*៣. និរោធសមាបត្តិវិបស្សនា ( វិបស្សនា ដើម្បីចូលនិរោធសមាបត្តិ ) ត្រូវមិនទន់ខ្សោយ ឬចាស់ក្លាពេក ទើបប្រើបាន” ។*

*សេចក្ដីថា “**សង្ខារបរិគ្គណ្ហកវិបស្សនា** ( វិបស្សនា ដែលកំណត់ដឹងសង្ខារ ) នឹង ជាយ៉ាងទន់ខ្សោយ ឬចាស់ក្លា ក៏ដោយ ជាហេតុជិតដល់មគ្គបានដូចគ្នា” មានន័យថា វិបស្សនាយ៉ាងទន់ខ្សោយ រមែងញ៉ាំងឲ្យកើត **ទន្ធាភិញ្ញាមគ្គ** គឺមគ្គដែលសម្រេចយឺត ចំណែកវិបស្សនាលំដាប់ចាស់ក្លា រមែងញ៉ាំងឲ្យកើត**ខិប្បាភិញ្ញាមគ្គ** គឺ មគ្គដែលសម្រេចឆាប់ វិបស្សនា ទើបមានលំដាប់ទន់ខ្សោយ ឬចាស់ក្លា របស់វិបស្សនា តែមិនថា ជាលំដាប់ណា កាលវិបស្សនានោះបរិបូណ៌ ដោយលក្ខណៈរបស់**វុដ្ឋានគាមិនី** គឺនាំទៅកាន់មគ្គបាន ក៏ជាហេតុជិតរបស់មគ្គដូចគ្នា ។*

*សេចក្ដីថា “ដូចជាមួយមគ្គភាវនា” មានន័យថា ដូចជាមួយមគ្គភាវនា ព្រោះសូម្បីនឹងទទួលយកសង្ខារជាអារម្មណ៍ ក៏ប្រព្រឹត្តទៅដោយលក្ខណៈ*

*ចេញពីសង្ខារទាំងពួង និងព្រោះជាបច្ច័យដល់ផល ដែលទទួលយកព្រះនិព្វាន ជាអារម្មណ៍ ដូចមគ្គដែលជាបច្ច័យដល់ផលក្នុងមគ្គវីថិ ។*

*ការពោលថា វិបស្សនាដើម្បីចូលផលសមាបត្តិ ត្រូវចាស់ក្លាពិតៗ ទើបទើងប្រើបាន សំដៅដល់ វិបស្សនា របស់អ្នកផ្តើមព្យាយាមដើម្បីចូលផលសមាបត្តិ កាលអាចចូលផលសមាបត្តិរហូតស្ទាត់ជំនាញហើយ ក៏អាចចូលផលសមាបត្តិបានសូម្បី **សង្ខារុបេក្ខាញាណ**នឹងមិនចាស់ក្លាក៏ដោយ ដូចសេចក្តីក្នុងគម្ពីរអដ្ឋកថា **បដិសម្ភិទាមគ្គ**ថា :*

***[១]*** សង្ខារុបេក្ខាយ តិក្ខាយ សតិ កិលេសប្បហានេ សមត្ថស្ស មគ្គស្ស សម្ភវតោ តស្សា តិក្ខាការទស្សនត្ថំ ឯវចនបទេហិ សហ ទឡ្ហីកត្វា មូលបទានិ វុត្តានិ ។ ***[២]*** ផលស្ស និរុស្សាហភាវេន សន្តសភាវត្តា មគ្គាយត្តត្តា ច មន្ទភូតាបិ សង្ខារុបេក្ខា ផលស្ស បច្ចយោ ហោតីតិ ទស្សនត្ថំ មូលបទេនេវ វុត្តានីតិ វេទិតព្វានិ ។

*“១. ព្រះសារីបុត្រ ពោលដល់មូលបទ ( បទគោល ) [ ៥ បទថា **ឧប្បាទំ** ( ការកើតឡើង ) ជាដើម ] ដោយពោលបញ្ចប់ជាមួយពាក្យវេវចនៈ [ ១០ បទថា **គតី** ( គតិ ) ជាដើមទុកក្នុងមគ្គវារៈ ] ដើម្បីសម្តែងសេចក្តីចាស់ក្លារបស់**សង្ខារុបេក្ខាញាណ**នោះ ព្រោះការកើតឡើងរបស់មគ្គ ដែលអាចលះបង់កិលេសបាន កាលសង្ខារុបេក្ខាញាណចាស់ក្លាហើយ ។*

*២. គប្បីជ្រាបថា លោកពោលដល់មូលបទ [ ៥ បទទុកក្នុង*

ផលសមាបត្តិវារៈ ] ដើម្បីសម្តែងថា សូម្បីសង្ខារុបេក្ខា នឹងជាយ៉ាងទន់ខ្លី ក៏ជាបច្ច័យដល់ផលបាន ព្រោះផលមានសភាពស្ងប់ ដោយប្រាសចាក សេចក្តីឧស្សាហៈ [ ក្នុងការកម្ចាត់កិលេស ] និងកើតជាប់ដោយមគ្គ [ ដែលខ្លួនសម្រេចហើយ ]” ។

## ☞ “អានិសង្សរបស់ផលសមាបត្តិ”

ព្រះអរិយៈគួរអធិដ្ឋាន ជាលំដាប់ដំបូងថា សូមឲ្យផលចិត្តកើតតែម្យ៉ាង ជារៀងរហូតតាំងពីពេលនេះ ហើយចូលផលសមាបត្តិស្មើរដែលត្រូវការដើម្បីសោយ លោកុត្តរសុខ គឺសុខក្នុងផលនិងសុខក្នុងនិព្វាន ដូចព្រះរាជាសោយសុខក្នុងរាជសម្បត្តិ និងទេវតាសោយសុខក្នុងទិព្វសម្បត្តិ ក្នុងខណៈចូលផលសមាបត្តិ ព្រះអរិយៈ នឹងសម្រេចការរលត់សង្ខារទុក្ខទាំងអស់នៅយ៉ាងស្ងប់សុខ ក្រៅពីនោះ អ្នកដែលផ្តើម សម្រេចមគ្គផលហើយរមែងចូលផលសមាបត្តិរឿយៗ ឬស្ថិតនៅក្នុងផលសមាបត្តិ អស់កាលយូរ ដើម្បីឲ្យព្រះវិបស្សនាចារ្យ ឬដើម្បីមិត្តសព្រហ្មចារីទុកចិត្តថាខ្លួនជាព្រះអរិយៈ ។

# ☞ លក្ខណៈនៃការចូលផលសមាបត្តិ

*ព្រះអរិយកំណត់ដឹងអារម្មណ៍ដែលជាសង្ខារ គឺរូប វេទនា សញ្ញា សង្ខារ និង វិញ្ញាណ ហើយលះបង់អារម្មណ៍ ដូចពោល សម្រេចសេចក្ដីស្ងប់ដែលមិនមានសង្ខារ ដោយមិនមានសេសសល់ ការលះសង្ខារ ហើយសម្រេចការរលត់សង្ខារនេះ គឺការចូលផលសមាបត្តិ ដូចព្រះសារីបុត្រ ពោលទុកក្នុង**មហាវេទល្លសូត្រ**ថា :*

**[១]** ទ្វេ ខោ អាវុសោ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា សមាបត្តិយា ។ **[២]** សព្វនិមិត្តានញ្ច អមនសិការោ, អនិមិត្តាយ ច ធាតុយា មនសិការោ ។

*"១. អ្នកមានអាយុ បច្ច័យរបស់ការចូលចេតោវិមុត្តិ ដែលមិនមាននិមិត្ត ( ផលសមាបត្តិ ) មាន ២ ប្រការ គឺ ៗ*

*២. ការមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងអស់ និងការធ្វើទុកក្នុងចិត្ត [ និព្វាន ] ធាតុដែលមិនមាននិមិត្ត" ។*

*លំដាប់ការចូលផលសមាបត្តិ គប្បីជ្រាបតាមន័យនៃគម្ពីរវិសុទ្ធិមគ្គ ដូចតទៅនេះ :-*

**[១]** ផលសមាបត្តត្ថិកេន ហិ អរិយសាវកេន រហោគតេន បដិសល្លីនេន ឧទយព្វយាទិវសេន សង្ខារា វិបស្សិតព្វា ។ **[២]** តស្ស បវត្តានុបុព្វវិបស្សនស្ស សង្ខារារម្មណគោត្រភុញាណានន្តរា ផលសមា-

បត្តិវសេន និរោធេ ចិត្តំ អប្បេតិ ។ [៣] ផលសមាបត្តិដ្ឋិតាយ ចេត្ត សេក្ខស្សាបិ ផលមេវ ឧប្បជ្ជតិ, ន មគ្គោ ។

*“១. ដោយពិតហើយ អរិយសាវកអ្នកត្រូវការនឹងចូលផលសមាបត្តិ ត្រូវគេចចេញ នៅក្នុងទីស្ងាត់ កំណត់ឃើញសង្ខារដោយវិបស្សនាញាណ មានឧទយព្វយ ញាណជាដើម ។*

*២. ចិត្តរបស់អ្នកចម្រើនវិបស្សនា តាមលំដាប់ហើយ រមែងចូលទៅក្នុងការរលត់ ដោយអំណាចផលសមាបត្តិ ក្នុងលំដាប់**តពីអនុលោម-ញាណ** ដែលមានសង្ខារ ជាអារម្មណ៍ ។*

*៣. ម៉្យាងទៀត ផលចិត្តប៉ុណ្ណោះ បង្កើតឡើងសូម្បីដល់ព្រះសេក្ខៈ ព្រោះបង្អោនចិត្តទៅកាន់ផលសមាបត្តិ មគ្គចិត្តមិនកើត” ។*

*ព្រះអរិយបុគ្គល អ្នកចម្រើនវិបស្សនា រមែងច្បាស់ការកើតរលត់ គឺ **ឧទយព្វយញាណ** ជាលំដាប់ដំបូង បន្ទាប់ពីនោះ វិបស្សនាញាណផ្សេងៗ ទើបរៀងមកប្រាកដ រហូតដល់សង្ខារុបេក្ខាញាណ ដោយហេតុនេះ ព្រះអរិយៈ អ្នកចម្រើនវិបស្សនា ដើម្បីចូលផលសមាបត្តិ ទើបសម្រេចនូវឧទយព្វយញាណជាដើមទៅ រហូតដល់សង្ខារុបេក្ខាញាណ កាលបើសង្ខារុបេក្ខាញាណចាស់ក្លាហើយ អនុលោមញាណរមែងកើតឡើង និងកាលបើលះអារម្មណ៍ ដែលជាសង្ខាររូបនាមបានទាំងអស់ហើយ ទើបចូលកាន់សភាពរលត់សង្ខារ គឺព្រះនិព្វាន ការកើតឡើងរបស់ចិត្ត ក្នុងខណៈនោះ នឹងដូចក្នុងខណៈ ដែលសម្រេចមគ្គផលចិត្ត ដែលជាផលរបស់មគ្គ*

*ដែលកើត ( ដែលកើតឡើងមុន ) រមែងប្រាកដតែម្យ៉ាង ព្រោះជាការចម្រើនវិបស្សនាដោយប្រាថ្នាសម្រេចផលចិត្ត ដែលធ្លាប់កើតមកហើយ មិនកើតមគ្គចិត្តថ្នាក់ខ្ពស់ ដែលមិនបានប៉ងប្រាថ្នាទុក ។*

*បើព្រះអរិយៈប្រាថ្នានឹងសម្រេចមគ្គថ្នាក់ខ្ពស់ ហើយចម្រើនវិបស្សនានោះ ក៏នឹងផ្សេងគ្នាពីវិបស្សនា ដែលបដិបត្តិដើម្បីចូលផលសមាបត្តិ ព្រោះត្រូវធ្វើនាទីរបស់**សម្មប្បធាន ៤** យ៉ាង ទើបមិនអាចសម្រេចវិបស្សនាញាណថ្នាក់ខ្ពស់បានងាយ ដូចវិបស្សនា ដែលបដិបត្តិដើម្បីចូលផលសមាបត្តិ ដូចគម្ពីរមហាដីការបស់វិសុទ្ធិមគ្គ ពោលថា :*

អញ្ញាយេវ វិបស្សនាចារោ អរិយមគ្គាវហោ, អញ្ញោ ផលសមាបត្តិអាវហោ ។

*"ការបដិបត្តិវិបស្សនា ដែលនាំមគ្គញាណដ៏ប្រសើរមកឲ្យ ផ្សេងពីការបដិបត្តិវិបស្សនា ដែលនាំផលសមាបត្តិមកឲ្យ" ។*

*ព្រះអរិយៈអ្នកចម្រើនវិបស្សនា ដើម្បីសម្រេចមគ្គថ្នាក់ខ្ពស់ នឹងសម្រេចវិបស្សនាថ្នាក់ផ្សេងៗ មុនហើយ សម្រេចមគ្គថ្នាក់ខ្ពស់ កាលបើសង្ខារុបេក្ខាញាណចាស់ក្លាហើយ តែមិនអាចចូលផលសមាបត្តិបាន ព្រោះប្រាថ្នាក្នុងមគ្គ និងបើវិបស្សនាញាណ របស់លោកនៅមិនទាន់ចាស់ក្លាក៏នឹងកើតសង្ខារុបេក្ខាញាណដដែលៗហើយ ដដែលទៀត អ្នកខ្លះ ដែលនៅត្រេកអរក្នុងការចូលផលសមាបត្តិ ក៏អាចបង្អោនចិត្តទៅ ក្នុងផលសមាបត្តិនោះ ធ្វើឲ្យមានផលចិត្តតភ្ជាប់ នឹងតាំងនៅបានយូរ ដូច្នោះ អ្នកដែលត្រូវ*

ការនឹងសម្រេចមគ្គថ្នាក់ខ្ពស់ ទើបគួរអធិដ្ឋានសូមមិនឲ្យចូលផលសមាបត្តិ រហូតឃ្លាងចន្លោះពេលនេះ សូម្បីក្នុងពេលបដិបត្តិធម៌ ក៏ត្រូវរវាំងប្រយ័ត្ន មិនឲ្យបង្អោនចិត្តទៅ ក្នុងផលសមាបត្តិ ។

## ការតាំងនៅរបស់ផលសមាបត្តិ

ព្រះសារីបុត្រពោលដល់អង្គ ៣ ក្នុងការតាំងនៅរបស់ផលសមាបត្តិ ទុកក្នុង**មហាវេទល្លសូត្រ**ថា :

[១] តយោ ខោ អាវុសោ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា ឋិតិយា ។ [២] សព្វនិមិត្តានញ្ច អមនសិការោ, អនិមិត្តាយ ច ធាតុយា មនសិការោ, បុព្វេ ច អភិសង្ខារោ ។

“១. អ្នកមានអាយុ បច្ច័យនៃការតាំងនៅនៃចេតោវិមុត្តិ ដែលមិនមាននិមិត្ត មាន ៣ ប្រការ ។

២. គឺការមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងអស់ ការធ្វើទុកក្នុងចិត្ត [ និព្វាន ] ធាតុ ដែលមិនមាននិមិត្ត និងការកំណត់ពេលទុកមុន” ។

ព្រះអរិយៈអ្នកត្រូវការនឹងតាំងនៅក្នុងផលសមាបត្តិជាវេលា ៥ នាទី ១០ នាទី ៣០ នាទី ១ ម៉ោង ឬ ច្រើនតិចជាងនេះ គប្បីអធិដ្ឋានសូមឲ្យផលសមាបត្តិតាំងនៅ រហូតកាលត្រឹមនោះ ហើយចម្រើនវិបស្សនាតទៅ ដោយឲ្យកំណត់ដឹងរូបនាម តាមប្រក្រតី មិនត្រូវកង្វល់ដល់ផលសមាបត្តិ កាលបើសង្ខារុបេក្ខាញាណចាស់ក្លាឡើង តាមលំដាប់វិបស្សនាញាណហើយ ចិត្តនឹងលះពីអារម្មណ៍រូបនាមទាំងអស់ ហើយចូល

កាន់ការរលត់រូបនាម គឺព្រះនិព្វានក្នុងទីបំផុត យ៉ាងណាក៏ដោយ ការតាំងនៅនៃផល សមាបត្តិបានយូរ តាមពេលវេលាដែលអធិដ្ឋាន រមែងប្រាកដដល់អ្នកមានវិបស្សនាញាណចាស់ក្លា ចំណែកក្នុងអ្នកមានវិបស្សនាញាណមិនទាន់ចាស់ក្លា អាចតាំងនៅ បានមិនយូរតាមពាក្យអធិដ្ឋាន និងបើមិនអធិដ្ឋានទុកមុន ក៏រមែងតាំងនៅក្នុងផល សមាបត្តិបានត្រឹមមួយខណៈ ។

## ការរលត់របស់រូបនាមក្នុងផលសមាបត្តិ

ព្រះអរិយៈ រមែងដឹងច្បាស់ការរលត់រូបនាម ជាអារម្មណ៍ម៉្យាង ក្នុងខណៈចូល ផលសមាបត្តិ ដូចសេចក្តីដែលពោលដល់ការតាំងមាំ របស់ផលចិត្តក្នុង**អង្គុត្តរនិកាយ**ថា :

[១] ឥធានន្ទ ភិក្ខុ ឯវំ សញ្ញី ហោតិ "ឯតំ សន្តំ ឯតំ បណីតំ, យទិទំ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ"។ [២] ឯវំ ខោ អានន្ទ សិយា ភិក្ខុនោ តថារូបោ សមាធិបដិលាភោ, យថា នេវ យថវិយំ បថវិសញ្ញី អស្ស, ន វាយស្មិំ អាបោសញ្ញី អស្ស , ន តេជស្មិំ តេជោសញ្ញី អស្ស , ន វាយស្មិំ វាយោសញ្ញី អស្ស , ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស , ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស , ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស, ន នេវសញ្ញានាសញ្ញា–នាសញ្ញាយតនសញ្ញី អស្ស, ន ឥធលោកេ ឥធលោកស្មិំ អស្ស , ន

បរលោកេ បរលោកសញ្ញី អស្ស, យម្បិ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា, តត្រាបិ ន សញ្ញី អស្ស, សញ្ញី ចន អស្សាតិ ។

*"ម្នាលអានន្ទ ភិក្ខុក្នុងធម្មវិន័យនេះ សម្គាល់យ៉ាងនេះថា ការរលត់នេះស្ងប់ ប្រណីត ដែលជាទីស្ងប់នៃសង្ខារទាំងឡាយ លះ**ឧបធិ**ទាំងអស់ [ គឺ ខន្ធូបធិ កិលេសូបធិ អភិសង្ខារូបធិ ដែលជាបុណ្យបាប និងកាមគុណ] អស់តណ្ហា ប្រាសចាកតម្រេក រលត់ទុក្ខ ។*

*២. ម្នាលអានន្ទ ការសម្រេចសមាធិ ដូច្នោះ របស់ភិក្ខុ [ អ្នកចូលផលសមាបត្តិ ] ជាការធ្វើទុកក្នុងចិត្តយ៉ាងនេះថា ភិក្ខុនោះមិនគប្បីសម្គាល់**បឋវីកសិណ**ថា ជា**បឋវីកសិណ** មិនគប្បីសម្គាល់**អាបោកសិណ**ថា ជា**អាបោកសិណ** មិនគប្បីសម្គាល់**តេជោកសិណ**ថា ជាតេជោកសិណ មិនគប្បីសម្គាល់**វាយោកសិណ**ថា ជា**វាយោកសិណ** មិនគប្បីសម្គាល់**អាកាសានញ្ចាយតនឈាន**ថា ជា**អាកាសានញ្ចាយតនឈាន** មិនគប្បីសម្គាល់នូវ**វិញ្ញាណញ្ចាយតនឈាន**ថា ជា**វិញ្ញាណញ្ចាយតនឈាន** មិនគប្បីសម្គាល់**អាកិញ្ចញ្ញាយតនឈាន**ថា ជា**អាកិញ្ចញ្ញាយតនឈាន** មិនគប្បីសម្គាល់នូវ **នេវសញ្ញានាសញ្ញាយតនឈាន**ថា ជា**នេវសញ្ញានាស-ញ្ញាយតនឈាន** មិនគប្បីសម្គាល់លោកនេះថា ជាលោកនេះ មិនគប្បីសម្គាល់លោកខាងមុខថា ជាលោកខាងមុខ មិនគប្បីសម្គាល់រូប ដែលបានឃើញ សម្លេងដែលបានឮ អារម្មណ៍ ដែលបានទទួល អារម្មណ៍*

ដែលដឹងច្បាស់ ដែលខ្លួនដល់ហើយដោយចិត្ត ស្វែងរកហើយ ត្រាច់គិតហើយ តែលោកនៅមានសញ្ញា ការសម្រេចសមាធិដូច្នោះ គប្បីមានដល់ភិក្ខុបាន យ៉ាងនេះ” ។

សេចក្តីថា “ភិក្ខុនោះ មិនគប្បី**បឋវីកសិណ**ថា ជា**បឋវីកសិណ**” ជាដើម មានន័យថា សូម្បីភិក្ខុនោះ នឹងសម្រេចរូបឈានហើយ ក៏មិនទទួលដឹងអារម្មណ៍របស់រូប ឈានក្នុងខណៈចូលផលសមាបត្តិ ។

សេចក្តីថា “មិនគប្បីសម្គាល់នូវ**អាកាសានញ្ចាយតនឈាន**ថា ជា**អាកាសានញ្ចាយតនឈាន**” ជាដើម មានន័យថា សូម្បីភិក្ខុនោះនឹងសម្រេចអរូបឈានហើយ ក៏មិនទទួលយកអារម្មណ៍ របស់អរូបឈានក្នុងខណៈចូលផលសមាបត្តិ ។

សេចក្តីថា “មិនគប្បីសម្គាល់លោកនេះថា ជាលោកនេះ មិនគប្បីសម្គាល់លោកខាងមុខថា ជាលោកខាងមុខ” ជាដើម មានន័យថា ភិក្ខុនោះមិនដឹងរឿងរបស់លោកនេះ ចាប់ផ្តើមតាំងពីចិត្តរបស់ខ្លួន ជាដើមទៅ សូម្បីដឹងរឿងរបស់លោកខាងមុខ ដែលមានទេវលោកជាដើម ដោយ**អភិញ្ញាចិត្ត** ឬ ដោយចិត្តប្រក្រតី ។

សេចក្តីថា “មិនគប្បីសម្គាល់រូប ដែលបានឃើញ” ជាដើម សំដៅដល់មិនគិត ដល់អារម្មណ៍ ដែលជាបញ្ញត្តិ ឬបរមត្ថ គ្រប់យ៉ាងដូចក្នុងពេលមុននឹងសម្រេចមគ្គផល សេចក្តីថា “តែលោកនៅមានសញ្ញា” សំដៅដល់ភិក្ខុនោះ នឹងបានឃើញច្បាស់ព្រះនិព្វាន ដែលរលត់សង្ខារ រូបនាម

ទាំងអស់ ។

គម្ពីរអដ្ឋកថា អធិប្បាយរឿងនេះថា :

[១] ឯតំ សន្តំ ឯតំ បណីតន្តិ សន្តំ សន្តន្តិ អប្បេត្វា និសិន្នស្ស ទិវសំបិ ចិត្តុប្បាទោ សន្តំ សន្តន្តេវ បវត្តតិ ។ បណីតំ បណីតន្តិ អប្បេត្វា និសិន្នស្ស ទិវសំបិ ចិត្តុប្បាទោ បណីតំ បណីតន្តេវ បវត្តតិ ។ [២] និព្វានំ និព្វានន្តិ អប្បេត្វា និសិន្នស្ស ទិវសំបិ ចិត្តុប្បាទោ និព្វានំ និព្វានន្តេវ បវត្តតិ បវត្តតីតិ សព្វំបេតំ ផលសមាបត្តិសមាធី សន្ធាយ វុត្តំ ។

“១. ព្រះតម្រាស់ថា ឯតំ សន្តំ ឯតំ បណីតំ ( សភាពនោះស្ងប់ ប្រណិត ) មានន័យថា ចិត្តុប្បាទរបស់អ្នកអង្គុយចូលផលសមាបត្តិ ដោយធ្វើទុកក្នុងចិត្តថា ស្ងប់ៗ រមែងប្រព្រឹត្តទៅថា ស្ងប់ៗ សូម្បីពេញមួយថ្ងៃ ។

២. ចិត្តុប្បាទរបស់អ្នកអង្គុយចូលផលសមាបត្តិ ដោយធ្វើទុកក្នុងចិត្តថា ប្រណិតៗ រមែងប្រព្រឹត្តទៅថា ប្រណិតៗ សូម្បីពេញមួយថ្ងៃ ។

៣. ចិត្តុប្បាទរបស់អ្នកអង្គុយចូលផលសមាបត្តិ ដោយធ្វើទុកក្នុងចិត្តថា រលត់ទុក្ខៗ រមែងប្រព្រឹត្តទៅថា រលត់ទុក្ខ សូម្បីពេញមួយថ្ងៃ ដោយប្រការដូច្នេះ ពាក្យទាំងអស់នោះ បញ្ជាក់ដល់សមាធិ នៅក្នុងផលសមាបត្តិ” ។

សេចក្តីថា “ចិត្តុប្បាទរបស់អ្នកអង្គុយចូលផលសមាបត្តិ ដោយធ្វើទុកក្នុងចិត្តថា ស្ងប់ៗ រមែងប្រព្រឹត្តទៅថា ស្ងប់ៗ” សំដៅដល់ការប្រព្រឹត្តទៅរបស់ផលចិត្ត ដែលទទួលយកការស្ងប់ជាអារម្មណ៍ មិនមែនសំដៅ

ដល់ការបរិកម្មក្នុងចិត្ត ដូចដែល បានពោលទុកហើយក្នុងរឿងមគ្គចិត្ត ។

## ☞ ការចេញអំពីផលសមាបត្តិ

ការលះអារម្មណ៍ គឺព្រះនិព្វាន ដែលរលត់សង្ខារ ហើយត្រឡប់មកទទួលដឹងអារម្មណ៍ ដែលជាសង្ខារ គឺ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ យ៉ាងណាមួយ គឺ ការចេញពីផលសមាបត្តិ ដូចព្រះសារីបុត្រពោលទុកក្នុង**មហាវេទល្លសូត្រ**ថា :

ទ្វេ ខោ អាវុសោ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា វុដ្ឋានាយ, សព្វនិមិត្តានញ្ច មនសិការោ, អនិមិត្តាយ ច ធាតុយា អមនសិការោ ។

“អ្នកមានអាយុ បច្ច័យនៃការចេញរបស់**ចេតោវិមុត្តិ** ដែលមិនមាននិមិត្ត ( ផលសមាបត្តិ ) មាន ២ ប្រការគឺ ការធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងអស់ និងការមិនធ្វើទុកក្នុងចិត្ត ( និព្វាន ) ធាតុ ដែលមិនមាននិមិត្ត” ។

មានសេចក្តីទាក់ទងរឿងនេះ ក្នុងគម្ពីរវិសុទ្ធិមគ្គថា :

សព្វនិមិត្តានន្តិ រូបនិមិត្តវេទនាសញ្ញាសង្ខារវិញ្ញាណនិមិត្តានំ កាមញ្ច ន សព្វានេវេតានិ ឯកតោ មនសិករោតិ, សព្វសង្គាហិកវសេន បនេតំ វុត្តំ ។ តស្មា យំ ភវង្គស្ស អារម្មណំ ហោតិ តំ មនសិករោតោ ផលសមាបត្តិវុដ្ឋានំ ហោតិ ។

“ពាក្យថា សព្វនិមិត្តានំ ( និមិត្តទាំងអស់ ) គឺនិមិត្តដែលបានដល់រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ សូម្បីបុគ្គលមិនអាចធ្វើទុកក្នុង

ចិត្តនូវនិមិត្តទាំងអស់នោះ ព្រមគ្នាបាន តែពាក្យនេះ ពោលទុក ដោយជាប់ ដោយការប្រមូលនិមិត្តទាំងអស់ [ ដែលគួរជាអារម្មណ៍ របស់ចិត្ត ដែល ចេញពីសមាបត្តិ ] ដូច្នោះ និមិត្តណាជាអារម្មណ៍ របស់ភវង្គណា កាល ព្រះអរិយៈធ្វើទុកក្នុងចិត្តនូវនិមិត្តនោះ ការចេញពីផលសមាបត្តិ រមែង កើតឡើង” ។

កាលបើភវង្គចិត្តកើតឡើង ព្រះអរិយៈរមែងចេញពីផលសមាបត្តិ តែព្រះអរិយៈ ទូទៅលំបាកនឹងទទួលដឹងភវង្គចិត្តបាន លោករមែងទទួល ដឹងភាវៈ ដែលកើតបន្ទាប់ពីភវង្គ ដូចការពិចារណាផល និងនិព្វាន ( **បច្ចវេក្ខណញ្ញាណ** ) ការធ្វើទុកក្នុងចិត្តនូវអារម្មណ៍យ៉ាងណាមួយ ឬ ការកំណត់ដឹងរូបនាមបច្ចុប្បន្ន ចិត្តដែលពិចារណាធ្វើទុកក្នុងចិត្ត ឬ កំណត់ដឹងអារម្មណ៍ទាំងនេះ រមែងប្រាកដច្បាស់ដល់លោក ដូច្នោះ កាល ចិត្តដូចពោលប្រាកដឡើង ក៏គួរដឹងថា ខ្លួនចេញផលសមាបត្តិហើយ ។

សេចក្តីថា “ពាក្យនេះ ពោលទុក ជាប់ទាក់ទងដោយការប្រមូល និមិត្តទាំងអស់” មានន័យថា ភវង្គចិត្តដួងណាមួយ ដែលកើតបន្ទាប់អំពី ផលជវនចិត្តដួងចុងក្រោយ រមែងទទួលយកសង្ខារ យ៉ាងណាមួយជា អារម្មណ៍ តែមិនអាចទទួលដឹងសង្ខារទាំង ៥ យ៉ាងព្រមគ្នាបានយ៉ាងណា-ក៏ដោយ សេចក្តីនេះ សំដៅដល់សង្ខារទាំងអស់ ដែលជា អារម្មណ៍របស់ ភវង្គផ្សេងៗ ដែលប្រាកដដល់ព្រះអរិយៈ អ្នកចេញពីសមាបត្តិ សេចក្តីនេះ ដូចវិបស្សនា ដែលឃើញច្បាស់រូបនាម ម្តងមួយក្នុងបច្ចុប្បន្នខណៈតាម

ដែលពោលទុកក្នុងព្រះបាលី និងអដ្ឋកថាថា ឃើញច្បាស់សង្ខារ ដែលមានក្នុងភូមិ ៣ ទាំងអស់ ( **តេភូមិកសង្ខារ** ) ឬអ្នកឃើញច្បាស់ខន្ធទាំង ៥ ដែលពិតហើយ ក្នុងខណៈមួយៗ ចិត្តរមែងទទួលអារម្មណ៍ បានតែមួយ នឹងទទួលអារម្មណ៍ច្រើនជាងមួយមិនបាន ។

អ្នកខ្លះ អាចចូលផលសមាបត្តិបានឆាប់ ដោយកើតផលចិត្ត និងចិត្ត ដែលពិចារណា ធ្វើទុកក្នុងចិត្ត ឬកំណត់ដឹងផ្លាស់គ្នាទៅច្រើនគ្រា ធ្វើឲ្យ មិនអាចចូលផល សមាបត្តិបានយូរ ដោយចំពោះ អ្នកខ្លះ ដែលស្តាប់ គោលធម៌មកតិច អាចពិចារណា នឹកគិតក្នុងខណៈចូលផលសមាបត្តិ ធ្វើឲ្យ ត្រូវចេញពីផលសមាបត្តិនោះ ដូចរឿងព្រះ មហាមោគ្គល្លានដែលនឹង ពោលតទៅក្នុងថ្ងៃមួយ ព្រះថេរៈប្រាប់ពួកភិក្ខុថា "យើងអានេញ្ជសមាធិ នៅជិតច្រាំងស្ទឹងសិប្បិនិតា បានឮសម្លេងបន្ទើ ដ៏ពិរោះសោតៈ របស់ហ្វូងដំរី ដែលចុះទៅលេងទឹកហើយ ឡើងច្រាំង" អានេញ្ជសមាធិ គឺសមាធិ ដែល មិនកម្រើក ជាអរហត្តផលសមាធិ ដែលបុគ្គលសម្រេចអាស្រ័យនូវ រូបាវចរចតុត្ថជ្ឈាន ឬអរូបាវចរចតុត្ថជ្ឈានយ៉ាងណាមួយ ជាបាទ ដូចដែល អធិប្បាយទុកក្នុងគម្ពីរអដ្ឋកថា របស់ឧទានសមាធិ ដូចពោលមាន ការតាំង មាំមិនកម្រើកដោយវត្ថុណាមួយ ធ្វើឲ្យមិនបានឮសម្លេងគ្រប់យ៉ាង សូម្បី ទាំងសម្លេងរន្ទះបាញ់ ក្នុងខណៈចូលផលសមាបត្តិ ដូច្នោះ ភិក្ខុទាំងឡាយ ទើបមិនជឿ ព្រះមោគ្គល្លានហើយទៅក្រាបទូលព្រះមានព្រះភាគ ព្រះអង្គ ត្រាស់ឆ្លើយថា :

អត្ថេសោ ភិក្ខវេ សមាធិ, សោ ច ខោ អបរិសុទ្ធោ ។

“ម្នាលភិក្ខុទាំងឡាយ សមាធិនោះមានពិត តែនៅមិនទាន់ផូរផង់” ។ ការដែលព្រះថេរៈបានឮសម្លេងដំរី ក៏ព្រោះថា លោកចូលអានេញ្ជសមាធិ ហើយចេញពីសមាធិ ដូចពោល នឹងកើតចិត្តប្រក្រតីផ្លាស់គ្នាទៅ ម៉្យាងទៀត ក្នុងអដ្ឋកថាព្រះវិន័យ អធិប្បាយបន្ថែមថា លោកសម្រេចធម៌ជាព្រះអរហន្ត កាលចេញបួសហើយ ៧ ថ្ងៃ នៅមិនទាន់ស្ទាត់ជំនាញ ក្នុងសមាបត្តិ ដោយវសីការៈ ៥ យ៉ាង ហើយចូលចតុត្ថជ្ឈាន និងបានឮសម្លេងដំរី កាលចេញពីចតុត្ថជ្ឈាន តែលោកសម្គាល់ថា បានឮ ក្នុងខណៈចូលសមាបត្តិ ទើបពោលដូច្នោះ សូម្បីព្រះអដ្ឋកថាចារ្យនឹងពោលថា ជាចតុត្ថជ្ឈាន ក៏គួរ ជាចតុត្ថជ្ឈានរបស់អរហត្តផលតែម៉្យាង ព្រោះចូលឈានកាលចាប់ផ្តើមសម្រេចជាព្រះអរហន្ត ។

ការពោលថា ព្រះមហាមោគ្គល្លានបានឮ សម្លេងដំរីក្នុងខណៈចេញពីឈាន នឹងសម្គាល់ថា ការបានឮនោះ កើតក្នុងខណៈចូលសមាបត្តិ តាមសាធកៈក្នុងព្រះបាលី និងអដ្ឋកថា ធ្វើឲ្យជ្រាបថា ការទទួលដឹង ឬការធ្វើទុកក្នុងអារម្មណ៍យ៉ាងណាមួយ អាចកើតឡើងមុន បច្ចវេក្ខណញាណ ក្នុងពេលចេញពីសមាបត្តិ សូម្បីព្រះអរិយៈ នឹងនៅក្នុងលំដាប់ជាមួយគ្នា ក៏អាចផ្សេងគ្នា ដោយការចូល ផលសមាបត្តិ តាមពេលដែលខ្លួនត្រូវការ ដូចសេចក្តីក្នុងគម្ពីរអដ្ឋកថា របស់**ឧបរិបណ្ណាសកៈ**ថា :

ទ្វេ ហិ ឧីណាសវា សតតវិហារី នោសតតវិហារី ច ។

តត្ថ សតតវិហារី យំ កិញ្ចិ កម្មំ កត្វាបិ ផលសមាបត្តឹ សមាបជ្ជិតុំ សក្កោតិ ។ នោសតតវិហារី បន អប្បមត្តកេបិ កិច្ចេ កិច្ចប្បសុតោ ហុត្វា ផលសមាបត្តឹ អបេតុំ ន សក្កោតិ ។

*“ព្រះខីណាស្រព មាន ២ ប្រភេទ គឺៈ*

*១. **សស្សតវិហារី** ព្រះខីណាស្រពអ្នកនៅដោយសមថៈ និងវិបស្សនារឿយៗ ។*

*២. **នោសស្សតវិហារី** ព្រះខីណាស្រព អ្នកមិនបាននៅ ដោយសមថៈ និង វិបស្សនារឿយៗ ។*

*ក្នុងព្រះខីណាស្រពទាំងនោះ ព្រះខីណាស្រពអ្នកជា**សស្សតវិហារី** សូម្បីធ្វើ ការងារយ៉ាងណាមួយ ក៏អាចចូលនូវសមាបត្តិបាន ចំណែក ព្រះខីណាស្រព អ្នកជា**នោសស្សតវិហារី** ជាអ្នកខ្វល់ខ្វាយមុខនាទី ក្នុងកិច្ចត្រឹមបន្តិចបន្តួច ក៏មិនអាចចូលផលសមាបត្តិបាន” ។*

*ក្នុងគម្ពីរអដ្ឋកថា ខាងដើមលើកសាធកៈថា មានព្រះថេរៈ និងសិស្សសាមណេរទៅនៅក្នុងវត្តព្រៃមួយកន្លែង ព្រះថេរៈបានទីស្នាក់នៅអាស្រ័យជៀសវាង ខ្យល់ភ្លៀងបាន តែសាមណេរមិនបានទីស្នាក់អាស្រ័យ ព្រះថេរៈរវល់រកទីសម្រាក ឲ្យសាមណេរ ទើបមិនអាចចូលផលសមាបត្តិបាន របូតមួយវស្សា តែសាមណេរ ញ៉ាំងពេលឲ្យកន្លងទៅ ដោយសុខក្នុងផលសមាបត្តិ គ្រាចេញព្រះវស្សាហើយ សាមណេរសួរ ព្រះថេរៈថា លោកម្ចាស់ទៅក្នុងវត្តព្រៃរីករាយឬទេ? លោកឆ្លើយថា មិនសប្បាយ រឿងនេះ*

សាមណេរជាសាធកៈរបស់ព្រះអរហន្ត ប្រភេទដំបូង ទើបអាចចូលផលសមាបត្តិសោយនិព្វានសុខបាន សូម្បីនឹងមិនមានទីអាស្រ័យ តែព្រះថេរៈជាព្រះអរហន្តប្រភេទក្រោយ ដែលមិនអាចចូលផលសមាបត្តិ ព្រោះរវល់រកទីស្នាក់ឲ្យសាមណេរ ។

ដោយហេតុនេះ អ្នកចម្រើនវិបស្សនា ទើបគួរព្យាយាមបដិបត្តិធម៌ ដើម្បីឲ្យសម្រេចភាពជាព្រះអរិយៈ អ្នកអាចចូលផលសមាបត្តិ បានជានិច្ច ក្នុងពេលដែលត្រូវការ ។

# និព្វានកថា

តទៅនេះ នឹងពោលដល់ព្រះនិព្វាន ដែលជាអារម្មណ៍របស់មគ្គផល ដោយសង្ខេបព្រះនិព្វាននោះ មិនមែនប្រាសាទ មហានគរ ពន្លឺ ឬ សេចក្តីស្ងប់ត្រជាក់ ព្រោះវត្ថុទាំងនោះ ជាបញ្ញត្តិ គឺវត្ថុដែលសន្មតិគ្នា និងជាសង្ខតធម៌ គឺធម៌ដែលកើតតាមហេតុបច្ច័យ គឺ **កម្ម ចិត្ត ឧតុ** និង**អាហារ** តែព្រះនិព្វានជាបរមត្ថធម៌ គឺ ធម៌ ដែលជាសភាវៈ ដ៏ខ្ពង់ខ្ពស់ មិនប្រែប្រួល និងជាអសង្ខតធម៌ គឺ ធម៌ ដែលមិនមានហេតុបច្ច័យតាក់តែង ព្រះនិព្វាននេះមានលក្ខណៈស្ងប់ចាកកិលេស និងទុក្ខក្នុង**វដ្ត** គឺរូបនាម ( សន្តិលក្ខណៈ ) និងមិនមានសង្ខាររូបនាម ដែលកើតរលត់ជានិច្ច ( វិសង្ខារ ) ពិតហើយព្រះនិព្វានបាន ឈ្មោះថា **វិសង្ខារ** ព្រោះជាសភាពផ្ទុយគ្នា នឹងសង្ខារដែលសត្វលោកទទួលដឹងថា ជាបុគ្គល ជាយើង របស់យើង ។

គម្ពីរបដិសម្ភិទាមគ្គ សំដែងលក្ខណៈរបស់ព្រះនិព្វានថា :

[១] ឧប្បាទោ សង្ខារា ។ អនុប្បាទោ និព្វានំ [២] បវត្តំ សង្ខារា ។ អប្បវត្តំ និព្វានំ ។ [៣] និមិត្តំ សង្ខារា ។ អនិមិត្តំ និព្វានំ ។[៤] អាយូហនា សង្ខារា ។ អាយូហនា និព្វានំ ។ [៥] បដិសន្ធិ សង្ខារា ។ អបដិសន្ធិ និព្វានំ ។

“១. ការកើតឡើង [របស់រូបនាម] ជាសង្ខារ ការមិនកើតឡើង ជាព្រះនិព្វាន ។

២. ការប្រព្រឹត្តទៅ [របស់រូបនាម] ជាសង្ខារ ការមិនប្រព្រឹត្ត ទៅជាព្រះនិព្វាន ។

៣. និមិត្ត [គឺសង្ខាររូបនាម] ជាសង្ខារ ការមិនមាននិមិត្ត ជាព្រះនិព្វាន ។

៤. សេចក្តីខ្វល់ខ្វាយ [គឺ កុសល និងអកុសល] ជាសង្ខារ សេចក្តីមិនខ្វល់ខ្វាយជាព្រះនិព្វាន ។

៥. ការកើតថ្មីជាសង្ខារ ការមិនកើតថ្មី ជាព្រះនិព្វាន" ។

សេចក្តីខាងដើមសម្តែងថា ព្រះនិព្វាន គឺ សភាពរលត់សង្ខាររូបនាមទាំងអស់ ដែលជាការមិនកើតឡើងមុនរបស់រូបនាម ការមិនប្រព្រឹត្តទៅយ៉ាងតភ្ជាប់ ក្រោយពីកើតឡើងហើយ ការមិនមាននិមិត្ត គឺសង្ខារដែលប្រាកដដូចមានពិត ការមិនខ្វល់ខ្វាយធ្វើកុសល និងអកុសល ដើម្បីឲ្យខ្លួននៅជាសុខ និងការមិនកើតថ្មី ក្រៅពីនេះ នៅមានពាក្យស័ព្ទ សម្តែងដល់ព្រះនិព្វាន ដែលប្រកបដោយរូបស័ព្ទមកពីធាតុ (**ធាតុសិទ្ធ**) ក្នុងព្រះបាលី និងអដ្ឋកថា ជាដើមដូចជា :

-និព្វន្តិ ធីរា ( អ្នកមានបញ្ញា រមែងរលត់ )

-និព្វាបេន្តិ រាគគ្គិ( ញុំាងភ្លើងរាគៈឲ្យរលត់ )

-បរិនិព្វាយតិ ( រមែងបរិនិព្វាន )

-បរិនិព្វាតុ សុគតោ ( សូមព្រះសុគតមេត្តាបរិនិព្វាន )

-បរិនិព្វាបេយ្យ( គប្បីបរិនិព្វាន )

-បរិនិព្វាយិស្សតិ( នឹងបរិនិព្វាន )

-អន្តរាបរិនិព្វាយី ( អ្នកបរិនិព្វានក្នុងចន្លោះ )

-បរិនិព្វុតោ ( បរិនិព្វានហើយ )

ដូច្នោះ ទើបតាំងរូបវិគ្រោះ គឺពាក្យកំណត់សេចក្តីរបស់ពាក្យនិព្វាន ដូច្នេះ :-

[១] និព្វាតិ វដ្តទុក្ខំ ឯត្ថាតិ និព្វានំ ។

[២] និព្វាតិ វដ្តទុក្ខំ ឯតស្មឹ អធិគតេតិ និព្វានំ ។

[៣] និព្វាយតេ និព្វានំ។

“១. ទុក្ខក្នុងវដ្ត រមែងរលត់ទៅក្នុងសភាវៈនេះ ហេតុនោះ សភាវៈនោះ ឈ្មោះថា និព្វាន ( សភាវៈជាទីរលត់ទុក្ខ ) ។

២. ទុក្ខក្នុងវដ្ត រមែងរលត់ទៅ កាលបុគ្គលសម្រេចសភាវៈនេះ ហេតុនោះ សភាវៈនោះ ឈ្មោះថា និព្វាន ( សភាវៈធ្វើឲ្យរលត់ទុក្ខ ) ។

៣. ការរលត់ ឈ្មោះថា និព្វាន ( សភាវៈរលត់ទុក្ខ )” ។

**និព្វាន** ដែលជាសភាវៈរលត់រូបនាម ដូចពោល ត្រាស់ទុកក្នុងព្រះបាលីថា :

-អតក្កាវចរោ ( ស្ទាបស្ទង់ចុះមិនបាន ដោយទស្សនៈ ) គឺ មិនមែនសម្មតិបញ្ញត្តិ ដែលដឹងបាន ដោយការត្រិះរិះគិត ។

-គម្ភីរោ ( ជ្រាលជ្រៅ ) គឺ មិនប្រាកដច្បាស់ ដូចសម្មតិបញ្ញត្តិ ។

-ទុទ្ទសោ ( *ឃើញបាន ដោយលំបាក* ) គឺ មិនអាចឃើញច្បាស់បាន ដោយបញ្ញាប្រក្រតី ដែលកើតពីការសិក្សា ( សុតមយបញ្ញា ) ឬ កើតពីការគិតដឹង ( ចិន្តាមយបញ្ញា ) ។

-បណ្ឌិតវេទនីយោ ( *ជាវិស័យ ដែលបណ្ឌិតនឹងគប្បីដឹងច្បាស់* ) គឺ ជាវត្ថុ ដែលបណ្ឌិតអ្នកចម្រើនវិបស្សនា សម្រេចដោយមគ្គញាណ និងផលញាណហើយ នឹងអាចគប្បីឃើញដោយជាក់ច្បាស់បាន ។

ម្យ៉ាងទៀត និព្វាននេះ មិនមែនអារម្មណ៍របស់តណ្ហា ដែលជាប់ដោយកាមគុណ ទើបជាសភាវៈដែលរួចផុតពីតណ្ហា ឬជាសភាវៈប្រាសចាកតណ្ហា ពិតមែនហើយ អ្នកដែលឃើញច្បាស់និព្វាន ដោយមគ្គញាណរមែងរលត់តណ្ហាទៅពីចិត្តរបស់ខ្លួន ដូចសេចក្តីក្នុងព្រះបាលីថា :

**[១]** និព្វានំ ឥតិ នំ ព្រូមិ វានំ វុច្ចតិ តណ្ហា ។ **[២]** យោ រាគាស អភិជ្ឈា លោភោ អកុសលមូលំ **[៣]** វានប្បហានំ វានវូបមំ វានប្បដិនិស្សគ្គំ វានប្បដិបស្សទ្ធិ អមតំ និព្វានំ ។

"១.ក្នុងបាទគាថាថា និព្វានំ ឥតិ នំ ព្រូមិ ( *តថាគត ពោលសភាវៈនោះថាជានិព្វាន* ) តណ្ហាបានឈ្មោះថា វានៈ ( *សភាវៈចងភពនោះៗ ចូលនឹងភពដទៃ ឬចងកម្មចូលនឹងផលកម្ម* ) ។

២. រាគៈណាៗនៅមាន រាគៈនោះ ជាអភិជ្ឈាជាអកុសលមូល គឺ លោភៈ ។

៣. ព្រះតថាគត ពោលការលះតណ្ហា ការស្ងប់នៃតណ្ហា ការលះ

តណ្ហា ការរម្ងាប់តណ្ហាថា ជានិព្វាន ដែលមិនស្ងាប់" ។

នន្ទិសំយោជនោ លោកោ វិតក្កស្ស វិចារណំ
តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតិ ។

"លោកមានសេចក្តីរីករាយប្រកបទុក ការត្រិះរិះទៅ [ក្នុងអារម្មណ៍ផ្សេងៗ] ជាគ្រឿងសញ្ចររបស់លោកនោះ តថាគត ពោលថា **និព្វាន** ព្រោះលះតណ្ហា បានដាច់ស្រឡះ" ។

តាមសាធកៈ ដែលពោលមកនេះ ទើបតាំងរូបវិគ្គហៈរបស់និព្វានស័ព្ទមួយន័យទៀតថា :

[១] វានតោ និក្ខន្តំ និព្វានំ ។ [២] នត្ថិ វានំ ឯត្ថាតិ និព្វានំ ។

[៣] នត្ថិ វានំ ឯតស្មឹ អធិគតេតិ និព្វានំ ។

"១. សភាវៈរួចផុតពីតណ្ហា ឈ្មោះថា និព្វាន ។

២. តណ្ហា រមែងមិនមានក្នុងសភាវៈនេះ ហេតុនោះ សភាវៈនោះ ឈ្មោះថា និព្វាន ( សភាវៈជាទីប្រាសចាកតណ្ហា ) ។

៣. តណ្ហា រមែងមិនមាន កាលបើបុគ្គលបានសម្រេចសភាវៈនេះ ដោយហេតុនោះ សភាវៈនោះ ឈ្មោះថា និព្វាន ( សភាវៈធ្វើឲ្យតណ្ហាប្រាសចាកទៅ )" ។

តាមរូបវិគ្គហៈខាងដើម និព្វានជាសភាវៈ ដែលរួចផុតពីតណ្ហា ដោយអត្ថធម៌ គឺការស្ងប់នៃរូបនាម និងទុក្ខក្នុងវដ្តៈទាំងអស់ ។

និព្វាននោះ មានការមិនមាននិមិត្តជាគ្រឿងប្រាកដ ( អនិមិត្តបច្ចុប្បដ្ឋានំ )

*គឺ ប្រាកដក្នុងបញ្ញារបស់ព្រះអរិយៈ ដោយប្រាសចាកនិមិត្ត គឺរូបរាងសណ្ឋាន អ្នកដែលឃើញច្បាស់និព្វានហើយ ទើបមិនអាចពោលថា និព្វានមាន រូបរាងយ៉ាងណា ឬដូចនឹងវត្ថុណា លោកដឹងថា និព្វានជាការរលត់មិន កើតឡើងទៀត របស់រូបនាម ដែលកើតរលត់រឿយៗ និងពោលដល់ សភាវៈរលត់នោះ ដោយប្រាសចាករូបរាងសណ្ឋាន ដូចគម្ពីរមិលិន្ទបញ្ហា ពោលថា:*

អប្បដិភាគំ មហារាជ និព្វានំ ។ ន សក្កា និព្វានស្ស រូបំ វា សណ្ឋានំ វា វយំ វា បមាណំ វា ឱបម្មេន វា ការណេន វា ហេតុនា វា នយេន វា ឧបទស្សយិតុំ ។

*“បពិត្រមហារាជ និព្វានមិនមានវត្ថុណា ប្រៀបបានបុគ្គលមិនអាច សម្ដែងពណ៌ រូបរាង ខ្នាត ឬចំនួនរបស់ព្រះនិព្វាន ដោយការប្រៀបធៀប ដោយហេតុជួយ ដោយហេតុគោល ឬដោយន័យ [ដែលអនុមានដឹង]” ។*

# ✍ និព្វានមិនមែនជាសភាវបញ្ញត្តិ 📖

អ្នកខ្លះ អាចយល់ថា និព្វានជាការសូន្យទទេ មិនមានអ្វីឡើយ ព្រោះពោលទុក ខាងដើមថា **និព្វាន** ជាការរលត់រូបនាម ការមិនកើតឡើងរបស់រូបនាម ដោយសំគាល់ថា និព្វានជាអភាវបញ្ញត្តិ គឺបញ្ញត្តិដែលពោលដល់វត្ថុ ដែលមិនមាន តែនិព្វាន មិនមែនការសូន្យទទេ ព្រោះប្រាកដដោយសភាវៈរលត់រូបនាម ដូច្នោះ ព្រះអរិយៈ ទើបឃើញច្បាស់ព្រះនិព្វានដោយមគ្គញាណ និងផលញាណ ទាំងក្រសែរូបនាម របស់ព្រះអរហន្តនឹងរលត់ស៊ប់ មិនកើតឡើងទៀត ក្រោយបរិនិព្វានហើយ ការប្រាកដដោយសភាវៈរបស់និព្វាន ត្រាស់ទុកក្នុងគម្ពីរឧទាន និងឥតិវុត្តកថា :

*[១]* អត្ថិ ភិក្ខវេ អជាតំ អភូតំ អកតំ អសង្ខតំ ។ *[២]* នោ ចេ តំ ភិក្ខវេ អភវិស្ស អជាតំ អភូតំ អកតំ អសង្ខតំ, *[៣]* អយិធ ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយេថ ។ *[៤]* យស្មា ច ខោ ភិក្ខវេ អត្ថិ អជាតំ អភូតំ អកតំ អសង្ខតំ,*[៥]* តស្មា ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយតិ ។

“១. ម្នាលភិក្ខុទាំងឡាយ ធម្មជាត មិនកើតឡើង មិនមានឡើង មិនត្រូវហេតុ បច្ច័យធ្វើមិនត្រូវតាក់តែង នៅមាន ។

២. បើធម្មជាតិដែលមិនកើតឡើង មិនមានឡើង មិនមានហេតុ បច្ច័យធ្វើ មិនត្រូវតាក់តែង នឹងមិនមាន ។

៣. ការរួចផុតពីធម្មជាតិដែលកើតឡើង មានឡើង ត្រូវហេតុបច្ច័យធ្វើត្រូវតាក់តែងនេះ នឹងមិនគប្បីប្រាកដ ។

៤. ម្នាលភិក្ខុទាំងឡាយ ក៏ព្រោះធម្មជាត ដែលមិនកើតឡើង មិនមានឡើង មិន តូវហេតុបច្ច័យធ្វើ មិនត្រូវតាក់តែង នៅមាន ។

៥. ដូច្នោះ ការរួចផុតពីធម្មជាតិ ដែលកើតឡើង មានឡើង ត្រូវហេតុបច្ច័យ ធ្វើ ត្រូវតាក់តែង ទើបប្រាកដ" ។

ព្រះតម្រាស់នេះ មានន័យថា និព្វាន ជាការរលត់មិនកើតឡើងរបស់រូបនាម មានលក្ខណៈ ដូច្នេះ គឺ :

-មិនកើតឡើង គឺ ប្រាសចាកការកើតឡើងរបស់រូបនាម ។

-មិនមានឡើង គឺមានការប្រាកដរបស់រូបនាម ។

-មិនត្រូវហេតុបច្ច័យ គឺ កម្មចិត្តឧតុ និង អាហារធ្វើឲ្យកើតឡើង ។

-មិនត្រូវហេតុបច្ច័យ ដូចពោលតាក់តែងឲ្យមានលក្ខណៈផ្សេងគ្នា ។

បើនិព្វានមិនមាន ការដាច់សូន្យនៃក្រសែរូបនាម ដែលកើតរលត់រឿយៗ ក៏មិនមាន និព្វាន ជាសភាវៈ ដែលមានពិត ដោយបរមត្ថ ព្រោះជាអារម្មណ៍របស់មគ្គញាណ និងផលញាណ មិនមែនសភាព ដែលមិនមានពិត ដូចអភាវបញ្ញត្តិ និងដោយហេតុ ដែលជាសភាវៈដែលមានពិតក្រសែរូបនាម ដែលកើតឡើងដល់ព្រះអរិយៈ ទើបរលត់សូន្យ មិនប្រព្រឹត្តទៅ ក្នុងកពតទៅក្រោយពីលោកបរិនិព្វានហើយ ។

[១] អត្ថិ ភិក្ខវេ តទាយតនំ, [២] យត្ថ នេវ បឋវី ន អាបោ ន តេជោ ន វាយោ ន អាកាសានញ្ចាយតនំ ន វិញ្ញាណញ្ចាយតនំ ន អាកិញ្ចញ្ញាយតនំ ន នេវសញ្ញានាសញ្ញាយតនំ នាយំ លោកោ ន បរលោកោ ន ឧភោ ចន្ទិមសុរិយា [៣] តត្រាបាហំ ភិក្ខវេ នេវ អាគតឹ វទាមិ ន គតឹ ន ចុតឹ ន ឧប្បត្តឹ អប្បតិដ្ឋំ អប្បវត្តំ អនារម្មណមេវេតំ ។ [៤] ឯសេវន្តោ ទុក្ខស្ស ។

"១. បច្ច័យ [ដែលជាអារម្មណ៍ គឺនិព្វាន] នោះ នៅមាន ។

២. ដី ទឹក ភ្លើង ខ្យល់ អាកាសានញ្ចាយតន វិញ្ញាណញ្ចាយតន អាកិញ្ចញ្ញាយតន នេវសញ្ញានាសញ្ញាយតន លោកនេះ លោកខាងមុខ ព្រះច័ន្ទ និងព្រះអាទិត្យ ទាំងពីរ រមែងមិនមានក្នុងបច្ច័យនោះ ។

៣. ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលបច្ច័យ នោះថា ជាការមក ការទៅ ការតាំងនៅ ការចុតិ ការកើតឡើង បច្ច័យនោះ រកទីតាំងអាស្រ័យមិនបាន មិនមាន ការប្រព្រឹត្តទៅយ៉ាងតក្លាប់ [របស់រូបធម៌ និងនាមធម៌] រកអារម្មណ៍មិនបាន ។

៤. បច្ច័យនេះឯង ជាទីបំផុតនៃទុក្ខ ។

សេចក្តីថា "ដី ទឹក ភ្លើង ខ្យល់ រមែងមិនមានក្នុងបច្ច័យនោះ" មានន័យថា ព្រះនិព្វាន ដែលជាអារម្មណបច្ច័យរបស់មគ្គញាណ និងផលញាណ មិនមានធាតុ ទាំង ៤ និងមានឧបាទាយរូប ដែលអាស្រ័យធាតុទាំង ៤ ព្រមទាំងមិនមាននាមធម៌ ដែលទាក់ទងជាមួយកាមភព និង

រូបភព ដែលកើតឡើងអាស្រ័យរូប ។សេចក្តីថា "អាកាសានញ្ចាយតន វិញ្ញាណញ្ចាយតន អាកិញ្ចញ្ញាយតន នេវសញ្ញានាសញ្ញាយតន មិនមានក្នុងបច្ច័យនោះ" មានន័យថា ក្នុងនិព្វាន មិនមានអារម្មណ៍ និងនាមធម៌ដែលដឹងអារម្មណ៍ជាប់ទាក់ទងនឹងអរូបភព ។

សេចក្តីថា "លោកនេះ លោកខាងមុខ រមែងមិនមានក្នុងបច្ច័យនោះ" មានន័យថា ក្នុងនិព្វានមិនមានធម៌ ដែលទាក់ទងជាមួយលោកនេះ និង លោកខាងមុខទាំងអស់ ដូច្នោះ ក្នុងខណៈកើតមគ្គផល ដែលទទួលនិព្វាន ជាអារម្មណ៍ អ្នកសម្រេចនិព្វាន រមែងមិនទទួលដឹងរឿងរបស់លោកនេះ ផ្តើមតាំងពីចិត្តរបស់ខ្លួនជាដើមទៅ មិនទទួលដឹងរឿងរបស់លោកខាងមុខ ដែលទេវលោកជាដើម គឺមិនមានការដឹងរបស់លោក ។

សេចក្តីថា "ព្រះច័ន្ទ និងព្រះអាទិត្យ ទាំងពីរ រមែងមិនមានក្នុង បច្ច័យនោះ" មានន័យថា ក្នុងនិព្វាន មិនមានព្រះច័ន្ទ និងព្រះអាទិត្យ រួម ទៅដល់ផ្កាយផ្សេងៗ ព្រោះមិនចាំបាច់ត្រូវមាន ពន្លឺដើម្បីកម្ចាត់ភាពងងឹត ពីព្រោះមិនមានភាពងងឹត ព្រោះប្រាសចាករូប ដោយឥតសេសសល់ ទាំងពន្លឺ និងភាពងងឹត ជារូបបរមត្ថ សូម្បីក្នុងព្រះសូត្រខ្លះ បានបញ្ជាក់ ដល់ការមិនមានភាពងងឹតក្នុងនិព្វានថា តមោ តត្ថ ន វិជ្ជតិ ( ភាពងងឹត មិនមានក្នុងនិព្វាននោះ ) ។

សេចក្តីថា "យើងមិនពោលបច្ច័យនោះ ថា ជាការមក ការទៅ ការតាំងនៅ ការផ្លាស់ប្តូរ ការកើតឡើង" មានន័យថា ក្នុងនិព្វាន មិនមាន

ការមក ដូចការផ្លាស់មក កាន់មនុស្សភូមិ ឬ ទេវភូមិ អំពីភូមិដទៃ មិនមាន ការផ្លាស់ពីនិព្វានទៅកាន់ភូមិដទៃ មិនមាន ការតាំងនៅ របស់បុគ្គល ដូចក្នុងមនុស្សភូមិ ឬទេវភូមិ មិនមានចុតិ គឺការស្លាប់ មិនមាន ការកើតឡើងថ្មី ក្រោយអំពីចុតិ មានត្រឹមតែជាអារម្មណ៍របស់មគ្គញាណ ផលញាណ និង បច្ចវេក្ខណញាណ ប៉ុណ្ណោះ ។

សេចក្តីថា "បច្ច័យនោះ រកទីតាំងអាស្រ័យមិនបាន" មានន័យថា និព្វាន មិនមែនរូបធម៌ ទើបមិនបានតាំងនៅក្នុងទីណាៗ ឬអាស្រ័យវត្ថុណានីងសូម្បីជានាមធម៌ ក៏មិនបានអាស្រ័យធម៌ ដែលជាបច្ច័យ ព្រោះមិនមែនជាធម៌ ដែលជាផល ( **បច្ចុប្បន្ន** ) ។

សេចក្តីថា "បច្ច័យនេះឯង ជាទីបំផុតនៃទុក្ខ" មានន័យថា និព្វាន អាស្រ័យអារម្មណ៍របស់មគ្គផលនេះ ជាទីបំផុតនៃទុក្ខក្នុង**វដ្តៈ** គឺ រូបនាម ព្រោះកាលបុគ្គល សម្រេចនិព្វានហើយ ទុក្ខទាំងអស់ក៏អស់ទៅ ។

## និព្វានផ្ទុយគ្នាជាមួយនឹងសង្ខារ

[១] យស្មា និព្វានំ សព្វសង្ខារវិធុរសភាវំ, ។ [២] តស្មា យថា សង្ខតធម្មេសុ កត្ថចិ នត្ថិ, តថា តត្ថបិ សព្វេ សង្ខតធម្មា ។ [៣] ន ហិ សង្ខតាសង្ខតធម្មានំ សមោធានំ សម្ភវតិ ។

"១. ដោយហេតុដែលនិព្វាន មានសភាវៈឆ្ងាយពីសង្ខារទាំងពួង ។

២. ដូច្នោះ សង្ខតធម៌ទាំងពួង ទើបមិនមានក្នុងនិព្វាន ដូចនិព្វាន មិនមានក្នុង សង្ខតធម៌យ៉ាងណានិមួយ ។

៣. ព្រោះការប្រជុំរួមគ្នារបស់ធម៌ ដែលជាសង្ខត និងអសង្ខត មិនមាន" ។

កាលបើសង្ខារ ដែលកើតរលត់កំពុងប្រាកដ បុគ្គលរមែងសម្រេចព្រះនិព្វាន ដែលរលត់សង្ខារមិនបាន និងសង្ខារក៏មិនប្រាកដ ក្នុងខណៈដែលព្រះអរិយៈឃើញច្បាស់និព្វាន លោកជ្រាបថា សង្ខារយ៉ាងណានិមួយ មិនកើតឡើងទៀត កាលបរិនិព្វានហើយ ។

ព្រះអរិយៈ អ្នកឃើញច្បាស់និព្វាន ដែលជាសភាវៈរលត់សង្ខារគ្រប់យ៉ាង ដោយមគ្គញាណ នឹងមិនកើតតណ្ហាទាំងនេះ គឺ :

-អបាយគាមិនីតណ្ហា គឺ តណ្ហាដែលនាំទៅកាន់អបាយភូមិ ។

-ឱឡារិកកាមតណ្ហា គឺ កាមតណ្ហាយ៉ាងគ្រោតគ្រាត ។

-សុខុមកាមតណ្ហា គឺ កាមតណ្ហាយ៉ាងល្អិត ។

-រូបតណ្ហា គឺ តណ្ហា ក្នុងរូបឈាន និង រូបភព ។

-អរូបតណ្ហា គឺ តណ្ហា ក្នុងអរូបឈាន និង អរូបភព លោកលះ តណ្ហាចេញ ធ្វើឲ្យមិនកើតទៀត បានស្រាយគ្រឿងចងគឺតណ្ហា ប្រាសចាកសេចក្តីពាក់ព័ន្ធក្នុងតណ្ហា ដូច្នោះ និព្វានដែលរលត់សង្ខារ ដែលជា អារម្មណ៍របស់មគ្គញាណ ៤ ទើបជាសភាវៈដែលរលត់តណ្ហា លះតណ្ហា កំណាត់តណ្ហា ផុតពីតណ្ហា នឹងមិនមានការពាក់ព័ន្ធក្នុងតណ្ហា ដូចព្រះ តម្រាស់ថា :

[១] កតមញ្ច ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ។

[២] យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ។

“១. ម្នាលភិក្ខុទាំងឡាយ អរិយសច្ច គឺ ការរលត់ទុក្ខយ៉ាងម៉េច ។

២. បានដល់ ការរលត់ស៊ប់ដោយឥតសេសសល់ ការលះ ការកំណត់ ការរួចផុត និងការមិនពាក់ព័ន្ធក្នុងតណ្ហានោះ” ។

ក្រៅពីនោះ កាលបុគ្គលឃើញច្បាស់និព្វាន ដោយមគ្គញាណ ៤ សង្ខារទាំងអស់ រមែងរលត់ទៅមិនប្រាកដក្នុងខណៈនោះ ព្រមទាំងមិនកើតកិលេស និងខន្ធ ដែលគួរកើតឡើងមុននឹងឃើញច្បាស់និព្វាន ដូច្នោះ និព្វាន ទើបពោលថា :

-ទីស្ងប់នៃសង្ខារទាំងពួង

-លះឧបធិទាំងអស់ [គឺខន្ធ កិលេស អភិសង្ខារ ដែលជាបុណ្យ បាប និងកាមគុណ]

-អស់តណ្ហា

-ប្រាសចាកតម្រេក

-រលត់ទុក្ខ

☞មានសេចក្ដីទាក់ទងរឿងនេះ ក្នុងព្រះសូត្រថា :

ឥទម្បិ ខោ ឋានំ ទុទ្ទសំ, យទិទំ សព្វសង្ខារ សមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ។

“សូម្បីឋានៈនេះ គឺ និព្វានដែលជាទីស្ងប់នៃសង្ខារទាំងពួង លះឧបធិ

ទាំងអស់, អស់តណ្ហា ប្រាសចាកតម្រេក រលត់ទុក្ខ ក៏ឃើញច្បាស់បាន លំបាក" ។!

# និព្វាន ២ ប្រភេទ

និព្វានមានតែមួយ ដោយសភាវលក្ខណៈ ( សន្តិលក្ខណៈ ) ស្ងប់នៃ**វដ្តទុក្ខ** គឺ រូបនាម បែកជា ២ ប្រភេទ តាមការនៅមាន ឬមិនមាន នៃខន្ធ ដូច្នេះ :-

១. សឧបាទិសេសនិព្វាន ការរលត់កិលេសរបស់ព្រះអរហន្ត អ្នកនៅមានជីវិត ដែលមានខន្ធនៅសេសសល់ ។

២. អនុបាទិសេសនិព្វាន ការរលត់កិលេសរបស់ព្រះអរហន្ត អ្នកបរិនិព្វានហើយ ដែលមិនមានខន្ធសេសសល់ ។

អនុបាទិសេសនិព្វាន ជាការរលត់ខន្ធ ដែលហៅថា ខន្ធបរិនិព្វាន គឺ ខន្ធក្នុងភពថ្មី ដែលអាចកើតឡើង កាលមិនបានអប់រំមគ្គ តែរលត់អស់ មិនកើតទៀត ក្រោយពីបរិនិព្វាន ចុតិចិត្តរបស់ព្រះអរហន្ត ព្រោះបានអប់រំមគ្គហើយ ដូច្នោះ ការរលត់ខន្ធ ដូចពោល ទើបប្រាកដក្នុងខណៈសម្រេចអរហត្តមគ្គ តែមិនមែនសភាវៈដែលកើតឡើងពិតៗ ទើបពោលមិនបានថា កើតឡើងក្នុងកាលណា ពិតមែនកិលេស និងខន្ធ ក្នុងភពថ្មី រមែងកើតឡើងរឿយៗ ក្នុងគ្រប់ៗខណៈ ដែលមានហេតុ បច្ច័យព្រមមូលកាលនៅមិនបានអប់រំមគ្គ កិលេស និងខន្ធដែលគួរកើតឡើងនោះ នៅមិនបានកើត

ឡើងហើយ ទើបមិនមែនអតីត មិនបានកើតឡើងនៅក្នុងបច្ចុប្បន្ន ទើបមិនមែនបច្ចុប្បន្ន និងមិនបានកើតឡើងតទៅ យ៉ាងពិតប្រាកដ ទើបមិនមែនអនាគត ទើបជាធម៌ ដែលផុតពីកាលទាំង ៣ ដែលហៅថា **កាលវិមុត្តិ** សូម្បីការរលត់អស់ មិនកើតទៀត របស់កិលេស និងខន្ធទាំងនោះក៏មិនមែនអតីត បច្ចុប្បន្ន និង អនាគត ទើបជាកាលវិមុត្តិដូចគ្នា ។

ដោយហេតុនេះ និព្វានទាំង ២ គឺ សឧបាទិសេសនិព្វាន ដែលជាការរលត់ កិលេស និងអនុបាទិសេសនិព្វាន ដែលជាការរលត់ខន្ធ ទើបមិនអាចពោលថា កើតឡើងក្នុងកាលណា ព្រោះជាកាលវិមុត្តិ និងព្រោះជាសភាវៈរលត់អស់ មិនកើតទៀត របស់កិលេស និងខន្ធ ដែលជា **កាលវិមុត្តិ** ដោយហេតុ ដែលនិព្វាន **ជាកាលវិមុត្តិ** ដូច្នោះ ទើបមិនគួរសង្ស័យថា ព្រះអរិយៈទទួលដឹងការរលត់កិលេសអនាគត ក្នុងខណៈសម្រេចគោត្រភូញាណ ទទួលដឹងការរលត់កិលេសបច្ចុប្បន្ន ឬទទួលដឹងការរលត់ ខន្ធអនាគតក្នុងខណៈសម្រេចមគ្គញាណ ។

ក្នុងគម្ពីរឥតិវុត្តកៈ ពោលដល់រឿងនិព្វានថា :

**[១]** ទ្វេមា ភិក្ខវេ និព្វានធាតុយោ ។ កតមេ ទ្វេ ។ សឧបាទិសេសា ច និព្វានធាតុ, អនុបាទិសេសា ច និព្វានធាតុ, **[២]** កតមា ច ភិក្ខវេ សឧបាទិសេសា ច និព្វានធាតុ ។ ឥធ ភិក្ខវេ ភិក្ខុ អរហំ ហោតិ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ

បរិខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោ ។ តស្សេវ បញ្ចិន្ទ្រិយានិ, យេសំ អវិឃាតត្តា មនាបាមនាបំ បច្ចនុភោតិ ។ សុខទុក្ខំ បដិសំវេទេតិ តស្ស យោ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ, អយំ វុច្ចតិ ភិក្ខវេ សឧបាទិសេសា និព្វានធាតុ ។ **[៣]** កតមា ច ភិក្ខវេ អនុបា–ទិសេសា និព្វានធាតុ, ឥធ ភិក្ខវេ ភិក្ខុ អរហំ ហោតិ ។បេ។ សម្មទញ្ញា វិមុត្តោ ។ តស្ស ឥធេវ ភិក្ខវេ សព្វវេទិតានិ អនភិនន្ទិតានិ សីតិ ភវិស្សន្តិ ។ អយំ វុច្ចតិ ភិក្ខវេ អនុបាទិសេសា និព្វានធាតុ ។

*“១. ម្នាលភិក្ខុទាំងឡាយ និព្វានធាតុ មាន ២ ប្រភេទ ទាំងនេះ និព្វានធាតុ ២ ប្រភេទ ដូចម្តេច គឺ សឧបាទិសេសនិព្វានធាតុ និង អនុបាទិសេសនិព្វានធាតុ ។*

*២. ម្នាលភិក្ខុទាំងឡាយ សឧបាទិសេសនិព្វានធាតុ ដូចម្តេច ភិក្ខុក្នុងធម្មវិន័យនេះជាអ្នកឆ្ងាយចាកកិលេស អស់អាសវៈហើយ ព្រហ្មចរិយៈ នៅចប់ហើយ ធ្វើកិច្ចដែលគួរធ្វើស្រេចហើយ ដាក់ភារៈចុះ បានហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ អស់សំយោជនៈ ក្នុងភពនេះហើយ រួចផុតហើយ ព្រោះត្រាស់ដឹងដោយប្រពៃ ភិក្ខុនោះ រមែងសោយអារម្មណ៍ ទាំងដែលពេញចិត្ត និងមិនពេញចិត្ត នៅសោយសុខ និង ទុក្ខ ព្រោះ ឥន្ទ្រីយ៍ ៥ នៅមិនទាន់រលត់ទៅ ឥន្ទ្រីយ៍ ៥ ទាំងនោះ របស់លោក នៅតាំងនៅមួយគ្រា ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃរាគៈ ទោសៈ និង មោហៈ របស់លោកនេះបាន ឈ្មោះថា* ***សឧបាទិសេសនិព្វានធាតុ*** *។*

៣. ម្នាលភិក្ខុទាំងឡាយ អនុបាទិសេសនិព្វានធាតុនោះយ៉ាងណា? ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកឆ្ងាយចាកកិលេស អស់អាសវៈហើយ មានមគ្គព្រហ្មចរិយៈចប់បរិបូណ៌ហើយ ធ្វើកិច្ចដែលគួរធ្វើស្រេចហើយ ដាក់ចុះភារៈបានហើយ មានប្រយោជន៍របស់ខ្លួនបានចាក់ធ្លុះហើយ លះបង់សំយោជនៈក្នុងភពនេះហើយ រួចផុតហើយ ព្រោះដឹងដោយប្រពៃ វេទនាទាំងពួងរបស់លោកក្នុងអត្តភាពនេះឯង មិនបានភ្លើតភ្លើន ( ដោយតណ្ហា មានៈ និងទិដ្ឋិ ) និងស្ងប់ត្រជាក់ ម្នាលភិក្ខុទាំងឡាយ សេចក្តីស្ងប់ត្រជាក់នេះឯង ឈ្មោះថា **អនុបាទិសេសនិព្វានធាតុ** ។

ទុវេ ឥមា ចក្ខុមតា បកាសិតា និព្វានធាតូ អនិស្សិតេន តាទិនា
ឯកា ហិ ធាតុ ឥធ ទិដ្ឋធម្មិកា សឧបាទិសេសា ភវនេត្តិសង្ខយា ។
អនុបាទិសេសា បន សម្បរាយិកា យម្ហិ និរុជ្ឈន្តិ ភវានិ សព្វសោ
យេ ឯតទញ្ញាយ បទំ អសង្ខតំ វិមុត្តចិត្តា ភវនេត្តិសង្ខយា
តេ ធម្មសារា ធិគមា ខយេ រតា បហំសុ តេ សព្វភវានិ តាទិនោ ។

“និព្វានធាតុ ២ ប្រភេទពួកនេះ ព្រះតថាគតមានចក្ខុ មិនត្រូវតណ្ហា និងទិដ្ឋិចូលទៅអាស្រ័យ ជាតាទិបុគ្គល បានប្រកាសទុក និព្វានធាតុ ១ មានក្នុងបច្ចុប្បន្ននេះ ឈ្មោះថា **សឧបាទិសេសនិព្វាន** ព្រោះអស់តណ្ហា ។ ចំណែកនិព្វាន មួយប្រការទៀត ដែលមានមកក្នុងពេលដែលរំលត់ខន្ធនិងភពទាំងឡាយដោយគ្មានសេសសល់ នោះថា **អនុបាទិសេសនិព្វាន** ។

ជនពួកណា បានដឹងនិព្វានធាតុដែលគប្បីបន្ទុះ ដោយមគ្គញាណ និងផលញាណ មិនមានបច្ច័យតាក់តែង មានចិត្តរួចផុតហើយ ព្រោះអស់តណ្ហាដែលនាំទៅក្នុងភព ជនពួកនោះ ត្រេកអរហើយក្នុងនិព្វាន ជាទីអស់កិលេស ព្រោះបន្ទុះធម៌ដែលជាសារៈ ជាអ្នកមាំទាំ លះភពទាំងអស់បាន” ។

*ក្នុងគាថាខាងដើម គុណបទរបស់ព្រះនិព្វានធាតុ គឺ :*

*-**អសង្ខត:** ( សភាវៈដែលមិនមានបច្ច័យគឺ **កម្ម ចិត្ត ឧតុ** និង**អាហារ** ឬ**អវិជ្ជា សង្ខារ**។ល។ តាក់តែង ។ ម្យ៉ាងទៀត ជាសភាវៈផ្ទុយគ្នាជាមួយសង្ខតធម៌ ប្រៀប ដូចទឹកជាមួយភ្លើង ក្ដៅជាមួយត្រជាក់ ។ល....។*

*-**បទ** ( ដែលព្រះអរិយគប្បីចាក់ធ្លុះ ដោយមគ្គញាណ និងផលញាណ ) ។*

*ក្រៅពីនោះ និព្វានដែលចែកជា ២ ប្រភេទខាងដើម ចែកចេញតាមហេតុដែល ផ្សេងគ្នា គឺមាន ខន្ធ ឬមិនមានខន្ធ , និព្វានដែលជាអារម្មណ៍របស់មគ្គញាណ និង ផលញាណនោះមានលក្ខណៈតែមួយ គឺ **សន្តិលក្ខណៈ** ទើបមិអាចបែងចែកជា ប្រភេទនិព្វានថា មានលក្ខណៈ ឬមិនស្ងប់ ដូច្នេះ ទើបមិនគួរ បែងចែកព្រះនិព្វាន ដោយភាវៈជាហេតុនិងផលថា និព្វានជាអារម្មណ៍របស់មគ្គញាណ និងផលញាណ ជាហេតុ ផ្សេងគ្នាអំពីនិព្វានដែលមានខន្ធនៅសល់ ឬរលត់ខន្ធជាផល បើដូច្នោះ នឹងជំទាស់គ្នាជាមួយបាលីដែលនាំមកពោលទុកខាងដើម ហើយនឹងយល់ខុសថា និព្វានដែលជាហេតុជាបរមត្ថ ចំណែកនិព្វានដែលជាផល ជាបញ្ញត្តិ ដែលមិនមាន លក្ខណៈ ។ ម្យ៉ាងទៀត ជំទាស់ជាមួយសេចក្ដីក្នុងគម្ពីរ**អភិធម្មត្ថសង្គហ**ថា :*

តទេតំ សភាវតោ ឯកវិធម្បិ សឧបាទិនិព្វានធាតុ អនុបាទិសេសនិ-ព្វានធាតុ ចេតិ ទុវិធំ ហោតិ ការណបរិយាយេន។

*“និព្វាននោះ សូម្បីមានសភាវៈតែម្យ៉ាង តែក៏ចែកជា ២ យ៉ាង តាមបរិយា នៃហេតុ គឺ **សឧបាទិសេសនិព្វានធាតុ** (និព្វានដែលមានខន្ធសេសសល់នៅ )និង **អនុបាទិសេសនិព្វានធាតុ** ( និព្វានដែលមិនមានខន្ធសេសសល់នៅ)” ។*

*អ្នកខ្លះយល់ថា និព្វានជាបញ្ញត្តិ ដែលពោលដល់វត្ថុមិនមាន ទើបហៅថា **អភាវបញ្ញត្តិ** បើនិព្វានជាអភាវបញ្ញត្តិ ក៏មិនមែនសភាវៈដែលមានពិតដោយបរមត្ថ*

ប៉ុន្តែ នេះត្រឹមតែជាការនឹកគិត ដែលជាអារម្មណ៍របស់មនោវិញ្ញាណតែប៉ុណ្ណោះ បើសិនជាដូច្នោះ ការរលត់កិលេសដោយ**សឧបាទិសេសនិព្វានធាតុ** ឬការរលត់ដោយអនុ**បាទិសេសនិព្វានធាតុ** ក៏មិនមានពិត ព្រោះព្រះអរហន្តក៏នៅមានកិលេសនឹងកាលលោកបរិនិព្វានហើយក៏ត្រូវទៅកើតទៀត មិនអាចមានអ្នកណាអាចរួចផុតទៅអំពី**វដ្តសំសារ**បានឡើយ ។

# និព្វានជាអារម្មណ៍របស់មគ្គផល

និព្វានជាអារម្មណ៍របស់មគ្គផល ជានិព្វានដោយទូទៅ សូម្បីនិព្វាន ២ ប្រភេទដែលពោលនោះ ក៏រាប់ចូលនិព្វាននេះដូចគ្នា ដូច្នោះព្រះអរិយៈដែលទទួលយកការរលត់នាមរូបជាអារម្មណ៍ ក្នុងខណៈដែលចាក់ធ្លុះមគ្គផល ទើបប្រកបដោយការរលត់កិលេសដោយ**សឧបាទិសេសនិព្វានធាតុ** និង**អនុបាទិសេសនិព្វានធាតុ** ព្រោះរលត់រូបនាមទាំងអស់ក្នុងសភាវៈអារម្មណ៍ដែលខ្លួនទទួលដឹង ។

លោកមិនបានដឹងការរលត់រូបនាម ដោយចំណែកថា មានខន្ធសេសសល់ ឬមិនមានខន្ធសេសសល់ មិនបានដឹងអារម្មណ៍ដែលលះដោយចំណែក ជាការរលត់រាគៈ រលត់ទោសៈ រលត់មោហៈ រលត់រូប រលត់វេទនា ។ល។ មិនបានដឹងអារម្មណ៍ដោយចំណែកក្នុងកាលជាអនាគត និងមិនបានដឹងអារម្មណ៍ព្រមជាមួយពាក្យបញ្ញត្តិថានិព្វានរលត់រូបនាម មិនមានកិលេស មិនមានខន្ធ មិនមានសង្ខារ ដូច្នោះ និព្វានដែលព្រះអរិយៈឃើញជាក់ច្បាស់ទើបមិនមែនអការបញ្ញត្តិ ដែលកើតអំពីការនឹកគិតអ្នកបដិបត្តិធម៌ ចាក់ធ្លុះព្រះនិព្វានហើយ ទើបដឹងថាកិលេសរលត់ទៅអំពីចិត្តរបស់ខ្លួន និងខន្ធក្នុងភពថ្មីក៏មិនកើតឡើងយ៉ាងពិតប្រាដក ហើយ

នឹងយល់ចូលថា សភាវៈល្អិតសុខុម ឃើញបានដោយលំបាក ហើយមិនមែនជាស័យនៃការនឹកគិតត្រិះរិះនោះឡើយ ។

**មានសេចក្តីជាប់ទាក់ទងជាមួយព្រះនិព្វានក្នុងគម្ពីរសំយុត្តនិកាយថា :**

**(១)** តស្មាតិហ ភិក្ខវេ សេ អាយតនេ វេទិតព្វេ ។ **(២)** យត្ថ ចក្ខុ ច និរុជ្ឈតិ រូបសញ្ញា ច និរុជ្ឈតិ, សេ អាយតនេ វេទិតព្វេ ។ **(៣)** យត្ថ សោតញ្ច និរុជ្ឈតិ, សទ្ទសញ្ញា ច និរុជ្ឈតិ, សេ អាយតនេ វេទិតព្វេ ។ **(៤)** យត្ថ ឃានញ្ច និរុជ្ឈតិ, គន្ធសញ្ញា ច និរុជ្ឈតិ, សេ អាយតនេ វេទិតព្វេ ។ **(៥)** យត្ថ ជិវ្ហា ច និរុជ្ឈតិ, រសសញ្ញា ច និរុជ្ឈតិ, សេ អាយតនេ វេទិតព្វេ ។ **(៦)** យត្ថ កាយោ ច និរុជ្ឈតិ, ផោដ្ឋព្វសញ្ញា ច និរុជ្ឈតិ, សេ អាយតនេ វេទិតព្វេ ។ **(៧)** យត្ថ មនោ ច និរុជ្ឈតិ, ធម្មសញ្ញា ច និរុជ្ឈតិ, សេ អាយតនេ វេទិតព្វេ ។

*“ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះឯង បុគ្គលគប្បីដឹងបច្ច័យនោះ ( គឺនិព្វាន ) ។*

*២. ចក្ខុនិងសញ្ញា ក្នុងរូបរលត់ទៅក្នុងទីណា បុគ្គលគប្បីដឹងបច្ច័យនោះ ( គឺទីដែលរលត់របស់ចក្ខុនិងសញ្ញាក្នុងរូប ) ។*

*៣.ត្រចៀកនិងសញ្ញា ក្នុងសំលេងរលត់ទៅក្នុងទីណា បុគ្គលគប្បីដឹងបច្ច័យ នោះ ( គឺទីដែលរលត់របស់ត្រចៀកនិងសញ្ញាក្នុងសំលេង ) ។*

*៤. ច្រមុះនិងសញ្ញា ក្នុងក្លិនរលត់ទៅក្នុងទីណា បុគ្គលគប្បីដឹងបច្ច័យនោះ ( គឺទីដែលរលត់របស់ច្រមុះនិងសញ្ញាក្នុងរូប ) ។*

*៥. អណ្តាតនិងសញ្ញា ក្នុងរសរលត់ទៅក្នុងទីណា បុគ្គលគប្បីដឹងបច្ច័យនោះ ( គឺទីដែលរលត់របសអណ្តាតនិងសញ្ញាក្នុងរស ) ។*

៦. កាយនិងសញ្ញា ក្នុងផោដ្ឋព្វៈរលត់ទៅក្នុងទីណា បុគ្គលគប្បីដឹងបច្ច័យនោះ( គឺទីដែលរលត់របស់កាយនិងសញ្ញាក្នុងផោដ្ឋព្វៈ ) ។

៧. ចិត្តនិងសញ្ញាក្នុងធម៌រលត់ទៅក្នុងទីណា បុគ្គលគប្បីដឹងបច្ច័យនោះ ( គឺទីដែលរលត់របស់ចិត្តនិងសញ្ញាក្នុងធម៌ )” ។

សេចក្តីថា “បុគ្គលគប្បីដឹងបច្ច័យនោះ (គឺនិព្វាន )” មានន័យថា គប្បីព្យាយាមបដិបត្តិដើម្បីឲ្យឃើញព្រះនិព្វាន ដែលជាអារម្មណបច្ច័យ ដោយមគ្គ-ញាណ ៤ ។

សេចក្តីថា“ចក្ខុនិងសញ្ញា ក្នុងរូបរលត់ទៅក្នុងទីណា បុគ្គលគប្បីដឹងបច្ច័យនោះ ( គឺទីដែលរលត់របស់ចក្ខុនិងសញ្ញាក្នុងរូប ) មានន័យថា កាលបុគ្គលកំណត់ដឹងរូបនាមក្នុងខណៈឃើញប្រច័ក្សព្រះនិព្វាន ការរលត់របស់ចក្ខុនិងសញ្ញាក្នុងរូបទុកក្នុងរឿងនេះ ដូចគម្ពីរអដ្ឋកថាអធិប្បាយថា :

” យត្ថ ចក្ខុ ច និរុជ្ឈតិ រូបសញ្ញា ច និរុជ្ឈតិ, សេ អាយតនេ វេទិតព្វេ”តិ ឯត្ថ ទ្វិន្នំ អាយតនំ បដិក្ខេបេន និព្វានំ ទស្សិតំ ។

“ ព្រះមានព្រះភាគទ្រង់សម្តែងព្រះនិព្វាន ដោយការបដិសេធន៍អាយតនៈ ២ ក្នុងព្រះតម្រាស់នោះថា យត្ថ ចក្ខុ ច និរុជ្ឈតិ រូបសញ្ញា ច និរុជ្ឈតិ ។ សេ អាយតនេ វេទិតព្វេ (ចក្ខុនិងសញ្ញាក្នុងរូបរលត់ទៅក្នុងទីណា បុគ្គលគប្បីដឹងបច្ច័យនោះ )” ។

ម្យ៉ាងទៀ ក្នុងខណៈដែលចក្ខុនិងសញ្ញាក្នុងរូបរលត់ កាលបើសេចក្តីរលត់របស់ចក្ខុប្រាដកច្បាស់ សេចក្តីរលត់របស់រូបដែលកើតរួមជាមួយចក្ខុក៏ប្រាដកច្បាស់ និងកាលសេចក្តីរលត់សញ្ញាក្នុងរូបប្រាដកច្បាស់ សេចក្តីរលត់របស់ចិត្តនិងចេតសិក ដែលកើតរួមជាមួយសញ្ញា ក្នុងរូបព្រមទាំងរូប ដែលជា

អារម្មណ៍របស់សញ្ញាក៏ប្រាកដច្បាស់ កាលបើសេចក្តីលត់របស់ចក្ខុនិងសញ្ញាក្នុងរូបប្រាកដច្បាស់ សេចក្តីរលត់របស់វិបស្សនា ដែលកំណត់ដឹងរូបនាមក្នុងខណៈឃើញក៏ប្រាកដច្បាស់ ។

សរុបសេចក្តីថា រូបនាមគ្រប់យ៉ាងរបស់ព្រះអរិយៈដែលប្រច័ក្សព្រះនិព្វានក្នុងខណៈឃើញរមែងរលត់ទៅ លោកបន្ទុះធម៌ទើបមិនបានឃើញរូបនាមគ្រប់យ៉ាង ក្នុងខណៈបន្ទុះមគ្គផលដោយទទួលយកសេចក្តីរលត់ជាអារម្មណ៍ទេ ។

ក្នុងព្រះសូត្រខាងដើមនោះ ព្រះអង្គទ្រង់បញ្ជាក់ការរលត់របស់អាយតនៈជាគូៗទៅថា គឺនិព្វាន ។ ខ្លឹមសារសង្ខេប ត្រាស់ដល់សេចក្តីរលត់របស់អាយតនៈខាងក្នុង ៦ និងខាងក្រៅ ៦ ទាំងអស់ ដូច្នោះ ព្រះអានន្ទទើបពោលសរុបសេចក្តីក្នុងព្រះសូត្រនេះថា :

សឡាយតននិរោធំ នោ ឯតំ អាវុសោ ភគវតា សន្ធាយ ភាសិតំ ។

“ម្នាលអាវុសោទាំងឡាយ ព្រះពុទ្ធវចនៈនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ភាសិត សំដៅយកសេចក្តីរលត់របស់អាយតនៈ ( អាយតនៈខាងក្នុងនិងខាងក្រៅ ) ៦” ។

សូម្បីក្នុងគម្ពីរអដ្ឋកថានៃព្រះសូត្រនោះ ក៏អធិប្បាយរឿងនេះដែរថា :

(១) សឡាយតននិរោធោ វុច្ចតិ និព្វានំ ។ (២) តំ សន្ធាយ ភាសិតន្តិ អត្ថោ ។ (៣) និព្វានស្មិញ្ហិ ចក្ខុអាទីនិ ចេវ និរុជ្ឈន្តិ រូបសញ្ញាទយោ ច និរុជ្ឈន្តីតិ ។

“ ១. និព្វាន ពោលដល់ការរលត់អាយតនៈ ( ខាងក្នុង និងខាងក្រៅ) ៦ ។

២. ព្រះសូត្រនេះត្រាស់ទុកបញ្ជាក់ដល់និព្វាននោះ ។

៣. ព្រោះចក្ខុជាដើម និងសញ្ញាក្នុងរូបជាដើម រមែងរលត់ក្នុងនិព្វាន” ។

រួមទាំងមតិរបស់អាចារ្យពួកខ្លះ ដែលជួបក្នុងអដ្ឋកថានៃគម្ពីរឧទានក៏ស្រប គ្នាជាមួយសេចក្តីខាងដើមថា :

(១) អញ្ញោ ឥជាតិ អជ្ឈត្តិកាយតនានិ ។ (២) ហុរន្តិ ពាហិរាយតនានិ ។ (៣) ឧភយមន្តរេនាតិ ចិត្តចេតសិកាតិ ។

“១. អាចារ្យពួកដ៏ទៃពោលថា ពាក្យថា **ឥធ** (ក្នុងអាយតនខាងក្នុងនេះ) គឺ អាយតនៈខាងក្នុង ៦ ។

២. ពាក្យថា **ហុរំ** ( ក្នុងអាយតនៈខាងក្រៅដ៏ទៃ ) គឺអាយតនៈខាងក្រៅ ៦ ។

៣. ពាក្យថា **ឧភយមន្តរេន** ( ក្នុងធម៌គឺចិត្តនិងចេតសិក ដែលជាវិញ្ញាណ ៦ ដែលក្រៅអំពីអាយតនៈខាងក្នុងនិងអាយតនៈខាងក្រៅ) គឺចិត្ត និងចេតសិក” ។

អ្នកចំរើនវិបស្សនា គប្បីកំណត់ដឹងរូបនាមយ៉ាងណានិមួយ ដែលប្រាកដ ច្បាស់ ក្នុងទ្វារ ៦ កាលមគ្គផលប្រាកដឡើង គេដឹងថារូបនាមគ្រប់យ៉ាងរលត់ ទៅដោយមិនមានទ្វារ អារម្មណ៍ ចិត្ត ឬ ចេតសិកយ៉ាងណានិមួយប្រាកដក្នុង ខណៈនោះសេចក្តីរលត់រូបនាមយ៉ាងនេះ ជាការរលត់គ្រប់យ៉ាង ដែលលោក ហៅថាជា ព្រះនិព្វាន ។

កាលអាយតនៈទាំងអស់រលត់ សង្ខារធម៌ទាំងអស់ក៏រលត់ទៅដូចគ្នា ព្រះសម្មាសម្ពុទ្ធ ទើបពោលដល់ព្រះនិព្វាន ថាជាសភាវៈផុយគ្នាជាមួយសង្ខារ ដោយបដិសេធន៍សង្ខារគ្រប់យ៉ាងថា :

យត្ថ អាបោ ច បឋវី តេជោ វាយោ ន គាធតិ ។
អតោ សរា និវត្តន្តិ ឯត្ថ វដ្តំ ន វត្តតិ ។
ឯត្ថ នាមញ្ច រូបញ្ច អសេសំ ឧបរុជ្ឈតិ ។

“ បឋវីធាតុ អាបោធាតុ តេជោធាតុ និងវាយោធាតុ មិនតាំងនៅក្នុង

និព្វានណា ក្រសែខន្ធរមែងមិនមានក្នុងនិព្វាននេះ ការវិលវល់( កម, កិលេស, និងវិបាក) មិនប្រព្រឹត្តទៅក្នុងនិព្វាននេះ រូបនិងនាមរមែងរលត់ដោយគ្មានសេសសល់ក្នុងនិព្វាននេះ" ។

វិញ្ញាណំ អនិទស្សនំ អនន្តំ សព្វតោបភំ
ឯត្ថ អាបោ ច បឋវី តេជោ វាយោ ន គាធតិ ។
ឯត្ថ ទីឃញ្ច រស្សញ្ច អណុំ ថូលំ សុភាសុភំ ។
ឯត្ថ នាមញ្ច រូបញ្ច អសេសំ ឧបរុជ្ឈតិ
វិញ្ញាណស្ស និរោធេន ឯត្ថេតំ ឧបរុជ្ឈតិ ។

"និព្វានដែលបុគ្គលគប្បីដឹងដោយប្រច័ក្ស មិនមាននរណាឃើញបាន មិនមានទីបំផុត ផូរផង់មិនកករល្អក់ បឋវីធាតុ អាបោធាតុ តេជោធាតុ និងវាយោ-ធាតុ រមែងតាំងនៅក្នុងព្រះនិព្វាននេះមិនបាន ។

រូបវែងក្តី, ខ្លីក្តី, ល្អិតក្តី, គ្រោតគ្រាតក្តី, ស្អាតនិងមិនស្អាតក្តី រមែងតាំងនៅមិនបានក្នុងព្រះនិព្វាននេះ រូបនាមរមែងរលត់ទៅ មិនមានសេសសល់ក្នុងព្រះនិព្វាននេះ ព្រោះវិញ្ញាណរលត់ រូបនាមទើបរលត់ទៅមិនមានសេសសល់ក្នុងព្រះនិព្វាននេះ" ។

សេចក្តីថា "ព្រោះវិញ្ញាណរលត់ រូបនាមនោះ ទើបរលត់មិនមានសេសសល់ក្នុងនិព្វាននេះ" មានន័យថា ព្រោះវិញ្ញាណគឺ ចុតិចិត្តរបស់ព្រះអរហន្តនិងអភិសង្ខារវិញ្ញាណគឺចិត្តដែលតាក់តែងរូបនាម ទើបរលត់ដោយគ្មានសេសសល់ក្នុងព្រះនិព្វាន ។ សេចក្តីថា ព្រោះចុតិរលត់ រូបនាមក្នុងបច្ចុប្បន្នទើបរលត់អស់ និងព្រោះអភិសង្ខារវិញ្ញាណដែលឲ្យផលតទៅរលត់ រូបនាមក្នុងអនាគតទើបមិនមិនកើតឡើងទៀត ដូច្នោះ រូបនាមទាំងអស់ទើបរលត់ទៅមិនកើតទៀត ដូចជា

ពន្លឺភ្លើងទៀន ដែលរលត់ទៅហើយដូច្នោះឯង ។

សេចក្តីថា "និព្វានដែលបុគ្គលគប្បីដឹងជាក់ច្បាស់ " មានន័យថា គប្បីដឹងជាក់ច្បាស់ដោយមគ្គញាណ ។

សេចក្តីថា " មិនមានទីបំផុត" មានន័យថា មិនមានទីបំផុតគឺ ការកើត ការតាំងនៅ និងការរលត់ទៅ ។

ព្រះបាលីថា **សព្វតោបភំ** មានន័យ ៣ ប្រការ មានក្នុងគម្ពីរអដ្ឋកថាថា :

-មានកំពង់ទឹកមិនកករល្អក់ គឺ មានកំពង់ទឹកដូចមហាសមុទ្រដែលមានកំពង់ទឹកមិនកករល្អក់ មានន័យថា មានផ្លូវបន្ទុះព្រះនិព្វានដោយកម្មដ្ឋាន ៣៨ យ៉ាងណានិមួយ ( កម្មដ្ឋាន ៣៨ គឺ កម្មដ្ឋាន ៤០ បានដល់ **កសិណ ១០, អសុភ ១០, អនុស្សតិ ១០, ព្រហ្មវិហារ ៤, អរូបជ្ឈាន ៤, អាហារេបដិកូលសញ្ញា ១, ចតុធាតុវវត្ថា ១** ដោយរួម**អាលោកកសិណ** គឺកសិណចន្លោះក្នុង**អនន្តាកាស-កសិណ** គឺកសិណអាកាសរកទីបំផុតមិនមាន (អាកាសានញ្ចាយតនឈាន) ។

-ប្រាកដក្នុងទិសទាំងទិសទាំងអស់ គឺនិព្វានជាធម៌ដែលបុគ្គលអ្នកបដិបត្តិអាចបន្ទុះបានក្នុងទិសទាំងអស់ដោយមិនមានខេត្តកំណត់ ។

-ផូរផង់ គឺមិនមានធម្មជាតិដទៃ ដែលភ្លឺស្វាងស្វែត្រចះត្រចង់បរិសុទ្ធិផូរផង់ក្រៃលែងជាងព្រះនិព្វានមិនបាន ព្រោះមិនប្រកបដោយកិលេសដែលធ្វើឲ្យសៅហ្មង ដូចគ្នាជាមួយការដែលពោលដល់បញ្ញាថា ដូចជាពន្លឺស្វរសែង និងពោលដល់ចិត្តដែលមិនប្រកបដោយកិលេសថាផូរផង់ សមដូចព្រះពុទ្ធវចនៈថា :

បញ្ញាអាលោកោ បញ្ញាអាភាសោ បញ្ញាបជ្ជោតោ ។

"ពន្លឺ គឺបញ្ញា, ឱភាស គឺបញ្ញា, ដួងប្រទីប គឺបញ្ញា" ។

បភស្សរមិទំ ភិក្ខវេ ចិត្តំ ។

"ម្នាលភិក្ខុទាំងឡាយ ចិត្តនេះផូរផង់" ។

ន័យម្យ៉ាងទៀត ពាក្យថា "ផូរផង់" មានន័យថា ផូរផង់មិនកករល្អក់ ព្រោះមិនត្រូវកិលេសរួបរិតហ៊ុមព័ទ្ធឲ្យសៅហ្មង ពោលគឺ បញ្ញានិងចិត្តដែលត្រូវកិលេសនឹងកើតរួម ឬកើតក្នុងកាលមុន និងកើតក្នុងកាលជាខាងក្រោយ ក៏អាចធ្វើឲ្យមិនផូរផង់ តែនិព្វានជាការរលត់កិលេសនិងសង្ខារគ្រប់យ៉ាង ទើបមិនប្រកបដោយកិលេសដោយប្រការទាំងពួង ។ ដូច្នោះ ទើបមិនត្រូវកិលេសហ៊ុមព័ទ្ធឲ្យសៅហ្មងដូចជាលាបពណ៌នៅលើអាកាសមិនបាន ពាក្យអធិប្បាយនេះពោលទុកក្នុងគម្ពីរដីការបស់សីលក្ខន្ធវគ្គ ។

ការពោលនិព្វានផូរផង់មិនមានកករល្អក់ មិនមែនបញ្ជាក់ថាជាពន្លឺ ដូចជាពន្លឺព្រះច័ន្ទ និងពន្លឺព្រះអាទិត្យ ឬពន្លឺផ្កាយនោះទេ ប្រសិនបើពោលថាជាពន្លឺ គួរពោលទុកក្នុងព្រះបាលីនិងអដ្ឋកថាសុទ្ធៗ បើជាយ៉ាងនោះ ។ ម្យ៉ាងទៀត ទាំងមិនគួរពោលទុកក្នុងលក្ខណៈផុយគ្នាពីកិលេសនិងសង្ខារថា ការអស់រាគៈ ( **រាគក្ខយោ** ) (សេចក្តីស្ងប់នៃសង្ខារទាំងពួង) **សព្វសង្ខារសមថោ** ( ការមិនកើតឡើង ) **អនុប្បាទោ** ជាដើម ។ ក្រៅអំពីនោះ ការប្រកាន់ថា និព្វានជាពន្លឺដ៏ត្រចះត្រចង់នៅជំទាស់ជាមួយពាក្យថា **អនិទស្សនំ** ( ឃើញមិនបាន ) **អនិមិត្តបច្ចុប្បដ្ឋានំ** ( មិនមាននិមិត្តជាគ្រឿងសម្គាល់ជាអាការប្រាកដ ) និងសេចក្តីថា ក្នុងព្រះបាលីនិងអដ្ឋកថា ទាំងអស់ដែលពោលថា មិនមានរូបនាមក្នុងព្រះនិព្វាន ។

សរុបសេចក្តីរបស់ព្រះនិព្វានដោយគាថាព័ន្ធថា :

និស្សេសសង្ខារវិវេកលក្ខណំ
សកលសង្ខតវិធុរសភាវំ
និព្វានមេតំ សុគតេន ទេសិតំ

ជានេយ្យ សង្ខារនិរោធមគ្គកំ ។

“អ្នកមានបញ្ញាគប្បីឃើញព្រះនិព្វាន ដែលព្រះសុគតទ្រង់សម្តែងទុក ដែលមានលក្ខណៈស្ងាត់ចាក់សង្ខារទាំងពួង មានសភាពឆ្ងាយចាក់សង្ខតធម៌ទាំងអស់ ជាត្រឹមតែជាសភាវៈរលត់សង្ខារ” ។

# បរិច្ឆេទទី៧

# [ មហាវិបស្សនា ១៨ ]

អតីតំ នាន្វាគមេយ្យ នប្បដិកង្ខេ អនាគតំ យទតីតម្បហីនន្តំ អប្បត្តញ្ច អនាគតំ បច្ចុប្បន្នញ្ច យោ ធម្មំ តត្ថ តត្ថ វិបស្សតិ អសំហិរំ អសង្កុប្បំ តំ វិទ្វា អនុព្រូហយេ ។

*( ម..១៤.២៧២.២៤១/ បិដកខ្មែរ ២៨.២ )*

*បុគ្គលមិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ដែលកន្លងទៅហើយ មិនគប្បីប្រាថ្នា បញ្ចក្ខន្ធ ដែលមិនទាន់មកដល់ទេ ព្រោះបញ្ចក្ខន្ធណាជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់មួយទៀត បុគ្គលណា ឃើញច្បាស់នូវធម៌ជាបច្ចុប្បន្ន ក្នុងទីនោះ ៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម និងមិនបានកម្រើក (ដោយពួកកិលេស)គប្បីចម្រើនរឿយៗ នូវផលសមាបត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ ៗ*

# មហាវិបស្សនា ១៨

អដ្ឋារស មហាវិបស្សនា នាម អនិច្ចានុបស្សនាទិកា បញ្ញា ។ យាសុ–

*[១]* អនិច្ចានុបស្សនំ ភាវេន្តោ និច្ចសញ្ញំ បជហាតិ ។ *[២]* ទុក្ខានុបស្សនំ ភាវេន្តោ សុខសញ្ញំ បជហាតិ ។ *[៣]* អនត្តានុបស្សនំ ភាវេន្តោ អនត្តាសញ្ញំ បជហាតិ ។ *[៤]* និព្វិទានុបស្សនំ ភាវេន្តោ នន្ទឹ បជហាតិ ។ *[៥]* វិរាគានុបស្សនំ ភាវេន្តោ រាគំ បជហាតិ ។ *[៦]* និរោធានុបស្សនំ ភាវេន្តោ សមុទយំ បជហាតិ ។ *[៧]* បដិនិស្សគ្គា–នុបស្សនំ ភាវេន្តោ អាទានំ បជហាតិ ។ *[៨]* ខយានុបស្សនំ ភាវេន្តោ ឃនសញ្ញំ បជហាតិ ។ *[៩]* វយានុបស្សនំ ភាវេន្តោ អាយូហនំ បជហាតិ ។ *[១០]* វិបរិណាមានុបស្សនំ ភាវេន្តោ ធុវសញ្ញំ បជហាតិ ។ *[១១]* អនិមិត្តានុបស្សនំ ភាវេន្តោ និមិត្តំ បជហាតិ ។ *[១២]* អប្បណិហិតានុបស្សនំ ភាវេន្តោ បណិធឹ បជហាតិ ។ *[១៣]* សុញ្ញតានុបស្សនំ ភាវេន្តោ អភិនិវេសំ បជហាតិ ។ *[១៤]* អធិបញ្ញាធម្មនុបស្សនំ ភាវេន្តោ សារាទានាភិនិវេសំ បជហាតិ ។ *[១៥]* យថាភូតញ្ញាណទស្សនំ ភាវេន្តោ សម្មោហាភិនិវេសំ បជហាតិ ។ *[១៦]* អាទីនវានុបស្សនំ ភាវេន្តោ អាលយាភិនិវេសំ បជហាតិ ។ *[១៧]* បដិសង្ខានុបស្សនំ ភាវេន្តោ អប្បដិសង្ខំ បជហាតិ ។

[១៨] វិវដ្ដានុបស្សនំ ភាវេន្ដោ សំយោគាភិនិវេសំ បជហាតិ ។

**មហាវិបស្សនា** គឺបញ្ញាឃើញច្បាស់រូបនាម ដោយសភាពមិនទៀង ជាដើម មាន ១៨ យ៉ាងគឺ ៖

១ អ្នកចម្រើនបញ្ញាដឹងច្បាស់ថាមិនទៀង ( អនិច្ចានុបស្សនា ) រមែងលះការសម្គាល់ថាទៀង ( និច្ចានុបស្សនា ) ។

២ អ្នកចម្រើនបញ្ញាដឹងច្បាស់ថាជាទុក្ខ ( ទុក្ខានុបស្សនា ) រមែងលះការសម្គាល់ថាសុខ ( សុខសញ្ញា ) ។

៣ អ្នកចម្រើនបញ្ញាដឹងច្បាស់ថាមិនមែនតួខ្លួន ( អនត្តានុបស្សនា ) រមែងលះការសម្គាល់ថាជាតួខ្លួន ( អនត្តសញ្ញា) ។

៤ អ្នកចម្រើនបញ្ញាដឹងច្បាស់សេចក្ដីនឿយណា ( និព្វិទានុបស្សនា ) រមែងលះការត្រេកត្រអាល ( នន្ទិ ) ។

៥ អ្នកចម្រើនបញ្ញាដឹងច្បាស់សេចក្ដីប្រាសចាកតម្រេក ( វិរាគានុបស្សនា) រមែងលះសេចក្ដីតម្រេក (រាគៈ) ។

៦ អ្នកចម្រើនបញ្ញាដឹងច្បាស់ការរលត់ ( និរោធានុបស្សនា ) រមែងលះការកើតឡើង (សមុទយៈ) ។

៧ អ្នកចម្រើនបញ្ញាដឹងច្បាស់ការបោះបង់ កិលេស ដែលសម្គាល់ថាទៀង ជាសុខ ជាតួខ្លួន ( បដិនិស្សគ្គានុបស្សនា ) រមែងលះការប្រកាន់ខ្ជាប់ ( កិលេសនិងសង្ខារ) ( អាទានៈ ) ។

៨ អ្នកចម្រើនបញ្ញាដឹងច្បាស់ការអស់ទៅ ( ខយានុបស្សនា ) រមែងលះការសម្គាល់ថាជាក្រុម ( ឃនបញ្ញា ) ។

៩ អ្នកចម្រើនបញ្ញា ដឹងច្បាស់ការអស់ទៅ របស់សង្ខារ ដែលជា អតីត និង អនាគត ដែលមិនបានឃើញច្បាស់ ដោយតាំងចិត្តទុក ជារឿយៗ ជាមួយនឹងការសូន្យទៅរបស់សង្ខារបច្ចុប្បន្ន ដែលឃើញច្បាស់ ( វយានុបស្សនា ) រមែងលះសេចក្ដីខ្វល់ខ្វាយ ដើម្បីលះការរស់ នៅល្អបានសុខ ( អាយូហានៈ ) ។

១០ អ្នកចម្រើនបញ្ញា ដឹងច្បាស់ការប្រែប្រួលទៅ ( វិបរិណាមានុបស្សនា) រមែងលះការសម្គាល់ ថាទៀង ( ធុវសញ្ញា) ។

១១ អ្នកចម្រើនបញ្ញា ដឹងច្បាស់ថាមិនមាននិមិត្តរូបរាង ( អនិមិត្តានុបស្សនា) រមែងលះនិមិត្តរូបរាង ( និមិត្តៈ) ។

១២ អ្នកចម្រើនបញ្ញា ដឹងច្បាស់ថា មិនគួរប្រាថ្នា ( អប្បណិហិតានុបស្សនា) រមែងលះការប្រាថ្នា សុខ ( បណិធិ) ។

១៣ អ្នកចម្រើនបញ្ញា ដឹងច្បាស់ថាសូន្យទទេ ( សុញ្ញតានុបស្សនា) រមែងលះការប្រកាន់មាំថា ជាតួខ្លួន ( អភិនិវេសៈ) ។

១៤ អ្នកចម្រើនបញ្ញា ដ៏ក្រៃលែង ដែលដឹងច្បាស់សភាវធម៌ថា សង្ខាររលត់ទៅ ព្រោះដឹងច្បាស់ ការរលត់ទៅរបស់សង្ខារ ដែលជា

អារម្មណ៍ និងសភាវដឹងអារម្មណ៍ ( អធិបញ្ញាធម្មវិបស្សនា) រមែងលះការប្រកាន់មាំដោយប្រកាន់ខ្ជាប់ថា ជាខ្លឹមសារ ដែលទៀងនិងជាតួខ្លួន ( សារាទានាភិនិវេស:) ។

១៥ អ្នកចម្រើនបញ្ញា ដឹងច្បាស់តាមសេចក្ដីពិត ក្នុងរូបនាមព្រមដោយហេតុបច្ច័យ ( យថាភូតញ្ញាណទស្សនៈ ) រមែងលះការនូវប្រកាន់មាំ គឺសេចក្ដីវង្វេង ដោយទិដ្ឋិ និងវិចិកិច្ឆា ( អភិនិវេស:) ។

១៧ អ្នកចម្រើនបញ្ញា ដឹងច្បាស់នូវទោស ( អាទីនវានុបស្សនា) រមែងលះការប្រកាន់មាំ ដោយបលិពោធ ( អាលយាភិនិវេស:) ។

១៧ អ្នកចម្រើនបញ្ញា កំណត់ដឹងទៀត ដើម្បីលះសង្ខារ ( បដិ-សង្ខានុបស្សនា) រមែងលះការ មិនកំណត់ដឹងទៀត ក្នុងសង្ខារ ដែលមិនទៀងជាទុក្ខ មិនមែនតួខ្លួន ( អប្បដិសង្ខារ) ។

១៨ អ្នកចម្រើនបញ្ញា ដឹងច្បាស់ការថយត្រឡប់ អំពីសង្ខារទាំងអស់ សង្ខារុបេក្ខាញាណ និង អនុលោមញាណ (វិវដ្ដានុបស្សនា) រមែងលះការប្រកាន់មាំដោយប្រកប ក្នុងសង្ខារ ( សំយោគាភិនិវេស: ) ។

# ១. អនិច្ចានុបស្សនា

អ្នកប្រាថ្នាសេចក្ដីព្យាយាម ដែលកំណត់ដឹងរូបនាម ដោយលក្ខណៈពិសេសតាមសមគួរ រមែងដឹងច្បាស់ ការកើតឡើង និងរលត់ទៅបញ្ញាដែលដឹងច្បាស់ថាមិនទៀងនេះ ឈ្មោះថា អនិច្ចនុបស្សនា ក្នុងរឿងនេះទាក់ទងនឹងសេចក្ដី ៣ ប្រការ គឺៈ

១. អនិច្ចៈ សភាពមិនទៀង គឺរូបនាមខន្ធ ៥ ដែលកើតរលត់តាមទ្វារទាំង ៦ ព្រោះប្រកបដោយសភាវៈ កើតឡើងនិងរលត់ទៅ ឬព្រោះកើតឡើងហើយរលត់ទៅវិញមួយរំពេច ។

២. អនិច្ចលក្ខណៈ លក្ខណៈមិនទៀង គឺការកើតឡើង តាំងនៅនិង រលត់ទៅ ឬការកើតឡើងហើយរលត់ទៅវិញមួយរំពេច ។

៣. អនិច្ចានុបស្សនា ញាណដឹងច្បាស់ថាមិនទៀង ដោយឃើញច្បាស់ការមិនទៀងរបស់រូបនាមបច្ចុប្បន្ន ។

មានសេចក្ដីទាក់ទងជាមួយនឹងរឿងនេះក្នុងគម្ពីរវិសុទ្ធិមគ្គថា :

១ **អនិច្ចន្តិ ។ល។ អាការវិការោ** (ទំព័រ ៥១១)

“១. ខន្ធ៥ ឈ្មោះថា **សភាពមិនទៀង** ព្រោះកើតឡើង រលត់ទៅនិងប្រែត្រឡប់ អំពីសភាពទាំងពីរ ឬ ព្រោះកើតឡើងហើយរលត់ទៅ ។

២. ការកើតឡើង រលត់ទៅ និងប្រែត្រឡប់ទៅ ឬលក្ខណៈប្រែប្រួលដែលហៅថា ការកើតឡើងហើយរលត់ទៅ ឈ្មោះថា លក្ខណៈមិន

ទៀង” ។

[១] អនិច្ចតាតិ តេសំយេវ ឧប្បាទវយញ្ញថត្តំ ហុត្វា អភាវោ វា ។ [២] និព្វត្តានំ ឯតេនេវាការេន អដ្ឋត្វា ខណភង្គេន ភេទោតិ អត្ថោ។ [៣] អនិច្ចានុបស្សនាតិ តស្សា អនិច្ចតាយ វសេន រូបាទីសុ អនិច្ចន្តិ អនុបស្សនា ។

“១. ពាក្យថា អនិច្ចតា (ការមិនទៀង) គឺការកើតឡើងរលត់ទៅ និងប្រែប្រួលទៅ របស់ខន្ធ៥ទាំង នោះ ។

២. ការសម្គាល់ ក៏គឺការមិនតាំងនៅ ដោយលក្ខណៈនោះឯង ដោយការរលត់ទៅមួយខណៈ ។

៣. ពាក្យថា អនិច្ចានុបស្សនា ( ញាណដឹងច្បាស់ថាមិនទៀង ) គឺការដឹងច្បាស់ក្នុងរូបជាដើម ថា មិនទៀង ដោយជាប់ដោយការមិនទៀងនោះ“ ។

ក្នុងសេចក្តីសម្គាល់របស់លក្ខណៈមិនទៀង ២ ប្រការនោះ ប្រការក្រោយ គឺការកើតឡើង ហើយរលត់ទៅ ប្រាកដច្បាស់ក្នុង វិបស្សនាញាណលំដាប់ខ្ពស់ តាំងអំពីភង្គញាណជាដើមទៅ ដូច្នោះ ទើបជាលក្ខណៈ ដែលសំខាន់ជាងប្រការដំបូង អ្នកដែលឃើញលក្ខណៈ ដូចពោលនេះ ទើបឈ្មោះថា បានសម្រេចនូវ**អនិច្ចានុបស្សនាញាណ** យ៉ាងច្បាស់ក្លា ដូចគម្ពីរមូលដីការពោលថា:

ហុត្វា អភាវដ្ឋេនាតិ ឥធំ ឥតរេសំ ចតុន្នំ អាការានំ សង្គហកត្ថា វិសុំ វុត្តំ ។

“ពាក្យថា ហុត្វា អភាវដ្ឋេន ( ព្រោះជាសភាពកើតឡើង ហើយ រលត់ទៅ ) នេះពោលទុកដោយចំពោះ ព្រោះរួមលក្ខណៈដទៃ ៤ យ៉ាង ទុកក្នុងលក្ខណៈដំបូង” ។

ខនេះសំដៅសេចក្តីថា ក្នុងគម្ពីរសម្មោវិនោទនី បានពោលដល់ លក្ខណៈ ដំបូងថាមិនទៀង ព្រោះជាសភាពកើតឡើងហើយរលត់ទៅហើយ ពោល ថាមិនទៀង ព្រោះហេតុ ៤ ប្រការដទៃ ការពោលបំបែកចេញ អំពីគ្នា និងគ្នា ដោយមិនពោលរួមជាលក្ខណៈ ៥ យ៉ាង មានបំណងដើម្បីរួម លក្ខណៈ ៤ យ៉ាងក្រោយទុកក្នុងលក្ខណៈដំបូង ដើម្បីបញ្ជាក់ការសម្គាល់ របស់លក្ខណៈដំបូងថា អ្នកដែលចម្រើនវិបស្សនា ឃើញច្បាស់ថា រូបនាម កើតរលត់ ក៏នឹងឃើញលក្ខណៈ ៤ យ៉ាងទៀតគឺ :

-មានការកើតឡើង និងរលត់ទៅ (ឧប្បាទវយវន្តតា)

-ប្រែប្រួលមិនស្ថិតស្ថេរ (វិបរិណាម)

-ស្ថិតនៅមួយខណៈ (តាវកាលិក)

-បដិសេធសេចក្តីទៀង (និច្ចបដិក្ខេប)

ក្រៅអំពីនេះ មានពាក្យអធិប្បាយ ក្នុងគម្ពីរមហាដីកា របស់គម្ពីរ វិសុទ្ធិមគ្គថា:

កិញ្ចាបិ ឧប្បាទាទិ តិវិធម្បិ សង្ខតលក្ខណាតាយ អនិច្ចលក្ខណំ, តថាបិ ជាតិជរាទីសុ ធិដ្ឋាសុ ន តថា អនិច្ចលក្ខណំ ចាកដំ ហុត្វា ឧបដ្ឋាតិ យថា វយក្ខណោតិ អាហា ភង្គោ ឆាម អនិច្ចតាយ បរមា កោដីតិ ។

*"ខណៈទាំង ៣ មានការកើតឡើងជាដើម សូម្បីមានលក្ខណៈមិនទៀង ព្រោះជាលក្ខណៈរបស់សង្ខតធម៌ តែលក្ខណៈមិនទៀង រមែងមិនប្រាកដដោយជាក់ច្បាស់ ក្នុងកាលបុគ្គល ដឹងច្បាស់ក្នុងខណៈកើតឡើង និង ខណៈប្រែប្រួល ដូចខណៈរលត់ទៅ ដូច្នោះ ទើបពោលថា* ភង្គោ ឆាម អនិច្ចតាយ បរមា កោដិ *( ទីបំផុតរបស់ការមិនទៀង ឈ្មោះថា ការរលត់ )" ។*

*ម្យ៉ាងទៀត សភាវៈដែលត្រូវតាក់តែងដោយហេតុបច្ច័យ ប្រជុំរួមគ្នា ឈ្មោះថា **សង្ខារ ឬសង្ខតធម៌** គឺរូបនាម ឬខន្ធ ៥ នោះឯង សង្ខតធម៌ ដូចពោល ប្រកបដោយខណៈ ៣ គឺ **ឧប្បាទ** ( ខណៈកើតឡើង ) **ជរា** ( ការប្រែប្រួល ) និង **មរណៈ** ( ការបែកធ្លាយ ) ខណៈទាំង ៣ ពួកនោះបាន ឈ្មោះថា **សង្ខតលក្ខណៈ** គឺលក្ខណៈរបស់សង្ខតធម៌ នឹងសង្ខតធម៌ ក៏គឺសភាពមិនទៀង ( អនិច្ចៈ ) នោះឯង សង្ខតលក្ខណៈទាំង ៣ គឺ ការកើតឡើង តាំងនៅ និងរលត់ទៅ ទើបបានឈ្មោះថា អនិច្ចលក្ខណៈ ទៀតផង ។*

យ៉ាងណាក៏ដោយ ការមិនទៀងរបស់សង្ខតធម៌ នឹងនៅមិនប្រាកដដោយការឃើញច្បាស់ការកើតឡើង និង តាំងនៅប៉ុណ្ណោះ ព្រោះបុគ្គលអាចអនុមានដឹងបានថា កាលមានការកើតឡើង និងតាំងនៅ ក៏ត្រូវមានការរលត់ទៅ បន្ទាប់ពីកាលបុគ្គលបានឃើញច្បាស់នូវការរលត់ទៅហើយទើបមិនយល់សេចក្ដីមិនទៀងយ៉ាងជាក់ច្បាស់ ដូច្នោះ សេចក្ដីមិនទៀងទើបប្រាកដច្បាស់ក្នុងខណៈរលត់ទៅ ដោយហេតុនេះ ក្នុងគម្ពីរវិសុទ្ធិមគ្គទើបពោលថា ភង្គោ នាម អនិច្ចតាយ បរមាកោដិ ( ទីបំផុតរបស់សេចក្ដីមិនទៀង ឈ្មោះថាការរលត់ ) ពិតហើយ វិបស្សនាញាណ ជាការឃើញជាក់ច្បាស់អំពីលោកទស្សនៈខាងក្នុង រហូតទាំងឃើញច្បាស់នូវការរលត់ទៅយ៉ាងជាក់ច្បាស់ មិនមែនការបរិកម្ម ឬពិចារណាថា សព្វេ សង្ខារា អនិច្ចា ( សង្ខារទាំងពួងមិនទៀង ជាដើម ) ។

សូម្បីសភាវៈមិនទៀង គឺអរូបនាម នឹងជាអ្នកម្យ៉ាងជាមួយនឹងលក្ខណៈមិនទៀង ដោយមិនបានកំណត់ដឹងសភាវៈ ដែលពិតប្រាកដរបស់រូបនាមក៏នឹងជាការទទួលដឹងសម្មតិបញ្ញត្តិ មិនមែនអនិច្ចានុបស្សនា បន្ទាប់ពីការកំណត់ដឹងសភាវៈ ដែលមិនប្រាកដរបស់រូបនាម ទើបនឹងជា អនិច្ចានុប-ស្សនាញាណ ដូចគម្ពីរអដ្ឋសាលិនី ពោលថាៈ

**[១]** វុដ្ឋានគាមិនី បន វិបស្សនា កិមារម្មណាតិ ។ លក្ខណា-រម្មណាតិ ។ **[២]** លក្ខណំ នាម បញ្ញត្តិគតិកំ នវត្តព្វធម្មភូតំ ។

*[៣]* យោ បន អនិច្ចំ ទុក្ខំ អនត្តាតិ តីណិ លក្ខណានិ សល្លក្ខេតិ, តស្ស បញ្ចក្ខន្ធា កណ្ឋេ ពទ្ធកុណបំ វិយ ហោន្តិ ។ សង្ខារារម្មណមេវ ញាណំ សង្ខារតោ វុដ្ឋាតិ ។ *[៤]* យថា ហិ ឯកោ ភិក្ខុ បត្តំ កិណិតុកាមោ បត្តវាណិជេន បត្តំ អាភតំ ទិស្វា ហដ្ឋបហដ្ឋោ គណ្ហិស្សាមីតិ ចិន្តេត្វា វីមំសមានោ តីណិ ឆិទ្ទានិ បស្សេយ្យ ។ សោ ន ឆិទ្ទេសុ និរាលយោ ហោតិ ។ បត្តេ បន និរាលយោ ហោតិ ។ *[៥]* ឯវមេវ តីណិ លក្ខណានិ សល្លក្ខេត្វា សង្ខារេសុ និរាលយោ ហោតិ ។ សង្ខារារម្មណនេវ ញាណេន សង្ខារតោ វុដ្ឋាតីតិ វេទិតព្វំ ។

*[៦]* ទុស្សោបមេបិ ឯសេវ នយោ ។

*“១.សួរថា : **វុដ្ឋានគាមិនីវិបស្សនា** មានអ្វីជាអារម្មណ៍ ព្រោះមានសេចក្តីសង្ស័យថា វុដ្ឋានគាមិនីវិបស្សនានោះ មានសង្ខារជាអារម្មណ៍ ឬមានលក្ខណៈ ៣ ជាអារម្មណ៍ បើមានសង្ខារជាអារម្មណ៍ ហើយលក្ខណៈ ៣ ក៏ជាអារម្មណ៍មិនបាន បើមានលក្ខណៈ ៣ ជាអារម្មណ៍ ក៏មិនគួរពោលថា គោត្រភូ និង មគ្គនេះផុតទៅអំពីអារម្មណ៍ ។*

*ឆ្លើយថា : **វុដ្ឋានគាមិនីវិបស្សនា** មានត្រៃលក្ខណ៍ជាអារម្មណ៍ ។*

*២. តាមធម្មតា ត្រៃលក្ខណ៍នោះ មានសភាពបញ្ញត្តិ មិនមែនហៅថាជា**កាមធម៌ មហគ្គតធម៌ លោកុត្តរធម៌** ណាមួយទេ ។*

*៣. បុគ្គលណា ឃើញច្បាស់ត្រៃលក្ខណ៍ថា មិនទៀងជាទុក្ខ មិន*

មែនត្លួខន ខន្ធ ៥ រមែងប្រាកដដល់គេ ដូចជាសាកសពសត្វល្អួយ ចងព្យួរសំយុងត្រង់ក ដោយការឈ្លាសវៃ ដែលមានសង្ខារធម៌ជាអារម្មណ៍ ក៏ផុតទៅអំពីសង្ខារ ។

៤.ឧបមាថា ភិក្ខុមួយរូបត្រូវការទិញបាត្រ បានហើយបាត្រ ដែលអ្នកលក់បាត្រនាំមកសរសើរ ដឹងត្រឹមលើកសរសើរ មានគំនិតគិតថា នឹងទិញបាត្រនេះ ហើយពិនិត្យមើល ទើបឃើញប្រហោងធ្លុះ ៣ ប្រហោង លោកមិនមែនអស់សេចក្តីពេញចិត្តក្នុងប្រហោងធ្លុះ តែអស់សេចក្តីពេញចិត្តក្នុងបាត្រយ៉ាងណា ។

៥. សូម្បី សេចក្តីឧបមាសំពត់ ដែលមានស្នាមដាច់ ៣ កន្លែង ក៏មានន័យដូចគ្នា ” ។

វុដ្ឋានគាមិនីវិបស្សនា គឺសង្ខារុបេក្ខាញាណខាងចុង និងអនុលោមញាណ កំណត់ដឹងសង្ខារ ដោយសភាវៈ ដែលមានពីតរបស់រូបនាម ដូចការរឹង ឬទន់របស់ធាតុដី ការប៉ះខ្ទប់សម្ផស្សរបស់ផស្សៈ ការដឹងអារម្មណ៍របស់ចិត្តជាដើម ហើយឃើញច្បាស់ការរលត់ទៅរបស់សង្ខារ ទើបនឹងឃើញច្បាស់ត្រៃលក្ខណ៍យ៉ាងណា ម្យ៉ាងកាលនោះ សង្ខាររមែងប្រាកដដល់អ្នកបដិបត្តិធម៌ថា ដូចសាកសពល្អួយដែលគួររង្កៀស ដូចសាកសពពស់ សាកសពសុនខ ល្អួយចងសំយុងក រមែងបង្ករកើតការរង្កៀស កាលអ្នកបដិបត្តិធម៌ កំណត់ដឹងសង្ខារយ៉ាងនេះ គោត្រភូញាណ ដែលកើតបន្ទាប់អំពីអនុលោមញាណ ដែលឃើញច្បាស់សង្ខារថា មិនទៀង

ជាដើម រមែងផុតទៅអំពីសង្ខារ គឺរតទៅរកនិព្វាន ដែលរលត់សង្ខារ ដោយមិនទទួលយកសង្ខារជាអារម្មណ៍ ។

ការដែលអ្នកបដិបត្តិធម៌ ឃើញច្បាស់ត្រៃលក្ខណ៍ហើយ ត្រូវការនឹងលះសង្ខារ ដែលជាប់ដោយត្រៃលក្ខ ណ៍នោះ មានឧបមាថា ភិក្ខុមួយអង្គត្រូវការទិញបាត្រ តែឃើញបាត្រមានរន្ធធ្លុះ ៣ ប្រហោង ទើបផ្លាស់ចិត្ត ភិក្ខុអង្គនោះ ចង់នឹងទិញបាត្រមុន នឹងឃើញប្រហោងធ្លុះ កាលបើឃើញហើយ ទើបអស់សេចក្តីត្រូវការទាំងដែលសេចក្តីត្រូវការ ដូចពោលជាប់ដោយបាត្រ មិនទាក់ទងប្រហោងធ្លុះ ព្រោះមិនត្រូវការប្រហោងធ្លុះតាំងពីដើម ក្នុងករណីជាមួយគ្នា អ្នកបដិបត្តិធម៌ មានការពាក់ព័ន្ធអាល័យក្នុងសង្ខារមុននឹងដឹងច្បាស់ត្រៃលក្ខណ៍ មិនមែន ពាក់ព័ន្ធក្នុងត្រៃលក្ខណ៍ ដូចនោះ ទើបត្រូវការលះសង្ខារដែលប្រកបដោយត្រៃលក្ខណ៍ មិនត្រូវការនឹងលះត្រៃលក្ខណ៍ ដោយហេតុនេះគោត្រភូញាណ និងមគ្គញាណ ដែលឃើញច្បាស់នូវការរលត់សង្ខារជាអារម្មណ៍ ទើបផុតទៅអំពីសង្ខារ មិន មែនផុតទៅអំពីត្រៃលក្ខណ៍តែម្យ៉ាង ប៉ុន្តែជាបញ្ញត្តិ ដូចគម្ពីរមូលដីកាអធិប្បាយថា :

[១] អនិច្ចន្តិអាទិនា សង្ខារេសុ បវត្តមានេន ញាណេន លក្ខណានិបិ បដិវិទ្ធានិ ហោន្តិ តទាការសង្ខារគ្គហណតោតិ អាហ លក្ខណារម្មណាតិ ។ សង្ខារារម្មណា ឯវ យថាវុត្តាធិប្បាយេន លក្ខណារម្មណាតិ វុត្តាតិ ទស្សេន្តោ លក្ខណំ នាមាតិអាទិមាហ ។

*[២]* អនិច្ចតា ទុក្ខតា អនត្តតាតិ ហិ វិសុំ គយ្ហមានំ លក្ខណំ បញ្ញត្តិគតិកំ បរមត្ថតោ អវិជ្ជមានំ ។ អវិជ្ជមានត្តតា ឯវ បរិត្តាទិវសេន នវត្តព្វធម្មភូតំ ។ *[៣]* តស្មា វិសុំ គហេតព្វស្ស លក្ខណស្ស បរមត្ថតោ អភាវា អនិច្ចំ ទុក្ខំ អនត្តតាតិ សង្ខារេ សភាវតោ សល្លក្ខេន្តោវ លក្ខណានិ សល្លក្ខេតិ នាមាតិ អាហ" យោ បន អនិច្ចំ ទុក្ខំ អនត្តាតិ តីណិ លក្ខណានិ សល្លក្ខេតី"តិ។

*[៤]* យស្មា ច អនិច្ចន្តិអាទិនា សង្ខារាវ ទិស្សមានា, តស្មា តេ កណ្ឋេ ពទ្ធកុណបំ វិយ បដិសជ្ជនីយា ហោន្តិ ។

*"សូម្បីត្រៃលក្ខណ៍ ក៏ជាបុគ្គលចាក់ធ្លុះ បានដោយវិបស្សនាញាណ ដែលដំណើរទៅក្នុងសង្ខារ ដោយន័យថា មិនទៀងជាដើម ព្រោះបាន កំណត់សង្ខារដោយលក្ខណៈនោះដូច្នោះ ទើបពោលថា លក្ខណារម្មណា* ( វុដ្ឋានគាមិនីវិបស្សនា *មានត្រៃលក្ខណ៍ជាអារម្មណ៍) ព្រះអដ្ឋកថាចារ្យ ទើងសម្ដែងថា វិបស្សនា ដែលមានសង្ខារជាអារម្មណ៍នោះឯង ដែល ពោលថា មានត្រៃលក្ខណ៍ជាអារម្មណ៍តាមសេចក្ដីប្រាថ្នា ដូចដែលបាន ពោលទុកហើយ ទើបពោលថា* លក្ខណំ នាម *( តាមធម្មតានៃត្រៃលក្ខណ៍ នោះមានសភាពជាបញ្ញត្តិមិនមែន ហៅថា* ***ជាកាមធម៌ មហគ្គតធម៌ លោកុត្តរធម៌*** *ដោយប្រការណាទេ ) ជាដើម ។*

*២. ដោយពិតហើយ ត្រៃលក្ខណ៍ដែលបុគ្គល ឃើញច្បាស់ ដោយចំពោះ មិនបានកំណត់ដឹងសង្ខារថាជា ការមិនទៀង ភាពជាទុក្ខ*

ភាពមិនមែនតួខ្លួន ជាបញ្ញត្តិដែលមិនមានពិតដោយបរមត្ថ ទើបជាធម៌ដែលពោល មិនបានថា ជាការមធម៌ជាដើម ព្រោះមិនមានពិតនោះឯង ។

៣. អ្នកដែលកំណត់ដឹងសង្ខារ ដោយសភាព ដែលមិនមានពិតថា មិនទៀង ជាទុក្ខ មិនមែនតួខ្លួន រមែងបានឈ្មោះថា ឃើញច្បាស់ត្រៃលក្ខណ៍ ព្រោះមិនមានត្រៃលក្ខណ៍ ដែលគួរកាន់យក ដោយចំពោះមិនបាន កំណត់ដឹងសង្ខារ ដោយបរមត្ថ ដូច្នោះ ទើបពោលថា យោ បន អនិច្ចំ ទុក្ខំ អនត្តាតិ តីណិ លក្ខណានិ សល្លក្ខេតិ ( បុគ្គលណាឃើញច្បាស់ត្រៃលក្ខណ៍ថា មិនទៀងជាទុក្ខ មិនមែនតួខ្លួន ) ។

៤. ដោយហេតុ ដែលសង្ខារប្រាកដ ដោយលក្ខណ៍ មិនទៀងជាដើម ដូចនោះសង្ខារទាំងនោះ ទើបជាវត្ថុ ដែលគួរលះទៅ ដូចសាកសពសត្វរលួយចងព្យួរត្រង់ក" ។

សរុបសេចក្តីថា អ្នកប្រារព្ធសេចក្តីព្យាយាម ដែលកំណត់ដឹងសភាវៈដែលមានពិតរបស់រូបនាម ក្នុងបច្ចុប្បន្នខណៈ ហើយឃើញច្បាស់ការមិនទៀង បញ្ញាដែលឃើញច្បាស់នូវការមិនទៀង នោះឈ្មោះថា អនិច្ចានុបស្សនា បញ្ញាដូចពោលនេះ នៅមិនប្រាកដក្នុងលំដាប់ ញាតបរិញ្ញា គឺបញ្ញាដឹងច្បាស់ដោយការកំណត់ដឹង ដែលជានាម **រូបបរិច្ឆេទញាណ** និង **បច្ចយបរិគ្គហញាណ** ព្រោះញាណទាំងពីរ ដឹងច្បាស់លក្ខពិសេស ( សភាវលក្ខណៈ ) របស់រូបនាម តមកសម្រេចនូវសម្មសនញាណជាដើមហើយ ឃើញច្បាស់ការមិនទៀង ជាទុក្ខមិនមែនតួខ្លួន ទើបបាន

ឈ្មោះថា **អនិច្ចានុបស្សនា** ជាដើម បញ្ញាដែលឃើញច្បាស់នូវការមិនទៀង ឈ្មោះថា **អនិច្ចានុបស្សនា** មិនមែនឈ្មោះថា **ទុក្ខានុបស្សនា** ឬ **អនត្តានុបស្សនា** បញ្ញាដែលឃើញច្បាស់ថា បញ្ញាដែលឃើញច្បាស់ថា ជាទុក្ខ ឈ្មោះថា **ទុក្ខានុបស្សនា** បញ្ញាដែលឃើញច្បាស់ថាមិនមែនតួខ្លួន ឈ្មោះថា **អនត្តានុបស្សនា** ដូចគម្ពីរវិភង្គមូលដីកាពោលថា:

**[១]** អនិច្ចាទីហិ អនិច្ចលក្ខណាទីនំ អញ្ញត្តវចនំ រុប្បនាទិវសេន បវត្តរូទិគ្គហណតោ វិសិដ្ឋស្ស អនិច្ចាទិគ្គហណស្ស សព្ភាវា ។ **[២]** ន ហិ នាមរូបបរិច្ឆេទមត្តេន កិច្ចសិទ្ធិ ហោតិ ។ អនិច្ចានុយោ ច រូចាទីនំ អាការា ឧដ្ឋព្វា ។ **[៣]** អនិច្ចន្តិ ច គណ្ហន្តោ ទុក្ខំ អនត្តាតិ ន គណ្ហាតិ ។ តថា ទុក្ខាទិគ្គហណោ ឥតរស្សាគ្គហណំ ។

“១. ការសម្តែងសេចក្តីផ្សេងគ្នា រវាងអនិច្ចលក្ខណ៍ជាដើម ជាមួយ ខន្ធដែលមិនទៀងជាដើម រមែងមានបាន ព្រោះមានការឃើញច្បាស់នូវ សេចក្តីមិនទៀងជាដើម ដែលពិសេសទៅអំពីការឃើញច្បាស់រូបជាដើម ដែលដំណើរទៅដោយលក្ខណ៍ប្រែប្រួលជាដើម ។

២. ដោយពិតហើយ ការសម្រេចរបស់នាទី គឺ **អនិច្ចានុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា** រមែងមិនមាន ដោយកំណត់ដឹងរូបនាម តែម្យ៉ាង តែគប្បីដឹងច្បាស់លក្ខណៈមិនទៀងរបស់ រូបជាដើម ។

៣. ក្រៅពីនោះ អ្នកដែលឃើញច្បាស់ថាមិនទៀង រមែងឃើញ ច្បាស់ថាជាទុក្ខ មិនមែនតួខ្លួន ការមិនឃើញច្បាស់នូវអនិច្ចលក្ខណៈ

ជាដើមដទៃក្នុងខណៈឃើញច្បាស់ទុក្ខលក្ខណៈជាដើម ក៏ដូចគ្នានេះ" ។

ខខាងដើមសំដៅសេចក្តីថា បញ្ញាដែលឃើញច្បាស់សភាវៈ ដែលមានពិតរបស់រូបនាមខន្ធ ៥ ជាមួយៗ ផ្សេង ជាមួយនឹងញាណ ដែលឃើញច្បាស់ត្រៃលក្ខណ៍របស់ខន្ធ ៥ ទាំងនោះ ដូច្នោះ ព្រះអដ្ឋកថាចារ្យទើបញែកត្រៃលក្ខណ៍ចេញអំពីខន្ធ មិនទៀងជាទុក្ខ មិនមែនតួខ្លួន បើលោកមិនញែកសភាវៈទាំងពីរចេញពីគ្នាហើយ ការឃើញច្បាស់រូបនាមក៏ជាការឃើញច្បាស់ត្រៃលក្ខណ៍ទៅព្រមគ្នា តែសេចក្តី ពិតមិនមែនយ៉ាងនោះ ដូច្នោះ ទើបមានការឃើញច្បាស់លក្ខណៈ មិនទៀងជាដើម ដោយសម្មសនញាណជាដើមដែលចាត់ជា តីរណបរិញ្ញា ( ការដឹងច្បាស់ដោយការពិចារណានូវសាមញ្ញលក្ខណៈ ) ដូចគម្ពីរអនុដីកាអធិប្បាយថា

ឥទានិ តមេវ ភេទំ ញាតតីរណបរិញ្ញាវិសយតាយ ទាកដំកាតុំ ន ហីតិ អាទិមាហ ។

"ឥឡូវនេះ ព្រះដីកាចារ្យពោលថា នហិ ( ដោយពិតហើយ ការសម្រេចរបស់នាទី គឺ **អនិច្ចានុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា** រមែងមិនមាន ដោយការកំណត់ដឹងរូបនាមតែម្យ៉ាង តែគប្បីដឹងច្បាសនូវលក្ខណៈមិនទៀង របស់រូបជាដើម) ដើម្បីសម្តែងសេចក្តីផ្សេងគ្នានោះប្រាកដច្បាស់ សេចក្តីជាវិស័យរបស់ញាតបរិញ្ញា និងតីរណបរិញ្ញា " ។

សេចក្តីថា "ដើម្បីសម្តែងការផ្សេងគ្នានោះ ប្រាកដច្បាស់នូវសេចក្តីជាវិស័យរបស់ញាតបរិញ្ញា និង តីរណបរិញ្ញា" សំដៅសេចក្តីថា ខន្ធ ៥

ដែលបានឈ្មោះថា មិនទៀង ជាទុក្ខ មិនមែនតួខ្លួន ជាវិស័យរបស់ញាតបរិញ្ញា គឺកំណត់ដឹងដោយញាតបរិញ្ញា ចំណែកត្រៃលក្ខណ៍ជាវិស័យរបស់តីរណបរិញ្ញា គឺកំណត់ដឹងដោយតីរណបរិញ្ញា ។

# ពេលប្រាកដនៃអនិច្ចានុបស្សនា

អ្នកបដិបត្តិធម៌ ដែលកំណត់ដឹងរូបនាមបច្ចុប្បន្ន តាមសភាវៈដែលជាពិត រមែងកើតបញ្ញា ដែលហ្មត់ចត់ ទំលាយសន្តិបញ្ញត្តិ គឺការកើតឡើងបន្តមិនដាច់ក្រសែនៃអារម្មណ៍ ដូចជាក្រមសំណុំ ពោលគឺ អ្នកដែល មិនបាន កំណត់ដឹងរូបនាមដែលកើតឡើង ក្នុងបច្ចុប្បន្នខណៈ រមែងមិនអាចឃើញច្បាស់សភាវៈ ដែលមានពិតរបស់រូប នាមបាន ទាំងមិនអាចឃើញច្បាស់នូវការកើត រលត់របស់រូបនាម បានយ៉ាងពិតប្រាកដទៀត ដូច្នោះ អ្នកដែលមិនឃើញច្បាស់ការកើតរលត់របស់រូបនាម ទើបយល់ខុសថា រូបដែលឃើញមកមុន ជាម្យ៉ាង ជាមួយការឃើញដែលកើតក្នុងខាងក្រោយ ដូចនេះជាដើម ក្រសែរូបនាម ដែលតភ្ជាប់ មិនដាច់ក្រសែ រហូតធ្វើយល់ខុសថា ជាវត្ថុតែមួយ គឺសន្តតិបញ្ញត្តិនេះជាគ្រឿងបិទបាំងអនិច្ចលក្ខណៈ គឺការកើតឡើងហើយរលត់ទៅ ទើបធ្វើ **អនិច្ចលក្ខណៈ** ដូចពោល មិនប្រាកដដល់មនុស្សទូទៅ ដែលមិនបានកំណត់ដឹងរូបនាម តែអ្នកដែលកំណត់ដឹងរូបនាម រហូចអាចឃើញច្បាស់ការកើតឡើងដែលជាខាងដើម និងការរលតទៅ ដែលជាទីបំផុតរបស់ រូបនាមបានហើយ រមែងយល់ថា សភាវៈកើតឡើង របស់រូបនាម

មួយៗ ជាម្យ៉ាងៗផ្សេងជាមួយនឹងសភាវៈ រលត់ទៅ រូបដែលកើតឡើង មុនជាម្យ៉ាងៗ ផ្សេងជាមួយនឹងរូបដែលកើតឡើង ក្នុងខាងក្រោយនាម ដែលកើត ឡើងមុន ក៏ជាម្យ៉ាងៗ ផ្សេងជាមួយនឹងនាម ដែលកើតឡើង ក្នុងខាងក្រោយ រូបនិងនាមទាំងពីរនោះកើតឡើង និងរលត់ទៅជាចំណែក ៗ មិនបានតាំងនៅយឺនយូរ បុគ្គលនោះអាចទំលាយ សន្តតិបញ្ញត្តិ ដូចពោល ដោយការឃើញច្បាស់នូវការកើត និងការរលត់របស់រូបនាម លំដាប់នោះ អនិច្ចលក្ខណៈរបស់រូបនាមរមែងប្រាកដ ព្រោះសន្តតិ បញ្ញត្តិមិនអាច បិទបាំងបាន ដោយប្រការដូចនេះ អនិច្ចានុបស្សនារមែងប្រាកដ តាំងពី ពេលឃើញអនិច្ចលក្ខណៈ ដែលកើតឡើងឯង កាលទំលាយសន្តតិ-បញ្ញត្តិ បានហើយ ។

កាលបើអនិច្ចលក្ខណៈ ប្រាកដជាក់ច្បាស់ហើយ អ្នកបដិបត្តិធម៌ អាចកំណត់តាមសភាវៈនោះៗថា“មិនទៀងៗ” “ជាទុក្ខៗ” “មិនមែនតួខ្លួនៗ” តែការកំណត់ ដោយបរិកម្មក្នុងចិត្ត មិនមែនគោលសំខាន់ នឹងបរិកម្ម ឬ មិនបរិកម្មក៏បាន សេចក្តីយល់ដែលឃើញដែលឃើញ ជាក់ច្បាស់ ដែល មិនទៀង ជាទុក្ខ មិនមែនតួខ្លួន ទើបជាគោលសំខាន់ ព្រោះ អនិច្ចានុបស្សនាជាដើម រមែងមាន បានដោយការឃើញច្បាស់ត្រៃលក្ខណ៍ យ៉ាងពិតប្រាកដ ក្រៅពីនោះ បើតាំងចិត្តបរិកម្មថាមិនទៀង ជាទុក្ខ មិន មែនតួខ្លួនក្នុងខណៈដែលត្រៃលក្ខណ៍មិនបានប្រាកដពិតៗ ក៏នឹងត្រឹមតែជា ការចាំបានសម្គាល់ដឹង គឺសញ្ញាប៉ុណ្ណោះ មិនមែងបញ្ញាឃើញច្បាស់

*យ៉ាងពិតប្រាកដ ដូចដែលពោលហើយក្នុងបរិច្ឆេទទី ៥ ។*

*ក្នុងគម្ពីរវិសុទ្ធិមគ្គ និងមហាដីកា ពោលដល់រឿងអនិច្ចលក្ខណៈថា:*

***[១]*** អនិច្ចលក្ខណំ តាវ ឧទយព្វយានំ អមនសិការា សន្តតិយា បដិច្ឆន្នត្តា ន ឧបដ្ឋាតិ ។ ***[២]*** ឧទយព្វយំ បន បរិគ្គហេត្វា សន្តតិយា វិកោបិតាយ អនិច្ចលក្ខណំ យាថាវសរសតោ ឧបដ្ឋាតិ ។

*"១. **អនិច្ចលក្ខណៈ** ដែលព្រះអង្គទ្រង់សម្ដែង ទុកជាលំដាប់ដំបូង មែងមិនប្រាកដព្រោះសន្តតិបិទបាំងទុក បន្ទាប់ពីមិនបានដឹងច្បាស់នូវការកើតរលត់ ។*

*២. តែកាលដឹងច្បាស់ការកើតរលត់ហើយ ទំលាយសន្តតិបញ្ញត្តិ **អនិច្ចលក្ខណៈ** ក៏ប្រាកដតាមសភាពរបស់ខ្លួនយ៉ាងពិតប្រាកដ" ។*

***[១]*** សន្តតិយា ហិស្ស បដិច្ឆន្នត្តា អនិច្ចលក្ខណំ ន ឧបដ្ឋាតិ ។ សា ច សន្តតិ ឧទយព្វយាមនសិការេន បដិច្ឆាទិកា ជាតា ។ ***[២]*** ឧទយព្វយំ បស្សតោ ន ឧទយាវត្ថា វយាវត្ថំ ចាបុណាតិ វយាវត្ថា វា ឧទយាវត្ថំ អញ្ញោវ ឧទយក្ខណោ ។ អញ្ញោវ វយក្ខណោតិ ឯកោបិ ធម្មោ ខណវសេន ភេទតោ ឧបដ្ឋាតិ ។ បគេវ អតីតាទិកោតិ អាហ "ឧទយព្វយំ បន ។បេ។ ឧបដ្ឋាតី"តិ ។ ***[៣]*** តត្ថ សន្តតិយា វិកោបិតាយាតិ បុព្វាបរិយេន បវត្តមានានំ ធម្មានំ អញ្ញោញ្ញភាវលក្ខណេន សន្តតិយា ឧគ្ឃាដិតាយ ។ ន ហិ

សម្មទេវ ឧទយព្វយំ សល្លក្ខេន្តស្ស ធម្មា សម្ពន្ធភាវេន ឧបដ្ឋហន្តិ។ អថ ខោ អយោសលាកា វិយ អសម្ពន្ធភាវេនាតិ សុដ្ឋុតរំ អនិច្ចលក្ខណំ ចាកដំ ហោតិ ។

"១. អនិច្ចលក្ខណៈ រមែងមិនប្រាកដដល់ អ្នកដែលមិនបានកំណត់ដឹងនោះ ព្រោះត្រូវសន្តតិបិទបាំងទុក្ខ ម្យ៉ាងទៀត សន្តតិនោះ ជាសភាពបិទបាំងបានដោយការមិនឃើញច្បាស់នូវការកើតរលត់ ។

២. កាលបុគ្គលឃើញច្បាស់ការកើតរលត់ ខណៈកើត រមែងមិនដល់ខណៈរលត់ ឬ ខណៈរលត់មិនដល់ ខណៈកើតប្រាកដ ជាម្យ៉ាង ខណៈរលត់ប្រាដកជាម្យ៉ាង មិនលាយឡំគ្នា សូម្បីសភាវៈធម៌ម្យ៉ាង ក៏ប្រាកដជាម្យ៉ាងៗផ្សេង ក្នុងខណៈកើតនិងក្នុងខណៈរលត់ ដូចពោលមកនេះ រូបនាមដែលជាអតីតជាដើម មិន មានសេចក្តីគួរសង្ស័យឡើយ ដូច្នេះព្រះអដ្ឋកថាចារ្យ ទើបពោលថា ឧយព្វយំ បន ។បេ។ បដ្ឋាតិ ( តែកាលដឹងច្បាស់នូវការកើតរលត់ហើយទំលាយសន្តតិបញ្ញត្តិ អនិច្ចលក្ខណៈក៏ប្រាកដតាមសភាពរបស់ខ្លួនយ៉ាង ពិតប្រាកដ ) ។

៣. ក្នុងរឿងនោះ ពាក្យថា សន្តតិយា វិកោបិតាយ ( ទំលាយសន្តតិបញ្ញត្តិ ) សំដៅសេចក្តីថា ទំលាយការបន្តគ្នា មិនដាច់ក្រសែដោយការកំណត់ដឹងសេចក្តីជារបស់សភាវៈធម៌ ដែលដំណើរ ទៅមុននិងក្រោយ ដោយពិតហើយ កាលបុគ្គលកំណត់ដឹង ការកើតរលត់យ៉ាងត្រឹមត្រូវ សភាវៈធម៌ទាំងឡាយរមែងមិនប្រាកដ ដោយការបន្តគ្នា ដូច

ដែកល្អសមួយបាច់ ដែលរៀបទុកម្តងមួយសសៃ ប្រាកដ ដោយការមិនលាយឡំគ្នា" ។

តាមពាក្យអធិប្បាយក្នុងគម្ពីរអដ្ឋកថា និងដីកាដូចពោល អ្នកដែលកំណត់ដឹងរូបនាមតាមដែលប្រាកដ រមែងឃើញច្បាស់ការកើតរលត់របស់រូបនាមម្តងមួយថា រូបនាមដែលកើតឡើងមុនជាម្យ៉ាងៗផ្សេង ជាមួយនឹងរូបនាមដែលកើតឡើងតមក មិនមែនសភាវៈម្យ៉ាងជាមួយគ្នា ការឃើញច្បាស់នូវការកើតរលត់នេះឈ្មោះថា ទំលាយសន្តតិបញ្ញត្តិ ដែលខនសម្គាល់ថា ជាវត្ថុជាមួយគ្នា ដែលបន្តមិនដាច់ក្រសែ អ្នកដែលទំលាយសន្តតិបញ្ញត្តិបាន រមែងឃើញច្បាស់អនិច្ចលក្ខណៈរបស់រូបនាម ដែលជាសភាបកើតឡើង ប្រែប្រួល និងរលត់ទៅ ឬ ជាសភាពកើតឡើងហើយរលត់ទៅ ក្នុងខណៈនោះ បញ្ញាដែលឃើញច្បាស់ថា រូបនាមមិនទៀងរមែងកើត ឡើងដោយមានឈ្មោះថា **អនិច្ចានុបស្សនា** រមែងទំលាយ **និច្ចសញ្ញា** គឺការសម្គាល់ថារូបនាមទៀង ទាំងទំលាយវដ្តទុក្ខ ដែលបានដល់កិលេសកម្ម និងវិបាកខន្ធដែលនឹងកើតតទៅ ដែលជាប់ទាក់ទងដោយបញ្ញា ដូចពោល ដូចគម្ពីរបដិសម្ភិទាមគ្គពោលថា:

អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហាតិ ។

"អ្នកដែលឃើញច្បាស់ការមិនទៀង រមែងកម្ចាត់ ការសម្គាល់ថាទៀង" ។

ខសេចក្តីថា "រមែងកំចាត់ការសម្គាល់ថាទៀង" ជាសំនួនភាសា

ដែលពោលដល់វត្ថុដែលជាគោលសំខាន់ ដូចពោលថា រាជា អាគច្ឆតិ ( ព្រះរាជាស្ដេចមក) ដែលពោលរួមទៅដល់បរិវាររបស់ព្រះអង្គទៀតផង ដូចនោះ ទើបសំដៅសេចក្ដីដល់អកុសលគ្រប់យ៉ាងដែលកើតតាមសញ្ញា ដូចការឃើញខុស ដែលហៅថា ទិដ្ឋិវិបល្លាស, ការគិតខុស ដែលហៅថា ចិត្តវិបល្លាស ជាដើម ដូចគម្ពីរមហាដីការបស់វិសុទ្ធិមគ្គ អធិប្បាយថា :

**[១] និច្ចសញ្ញាន្តិ និច្ចគាហំ ។ សញ្ញាសីសេន និទ្ទេសោ ។ [២] សុខសញ្ញំ អត្តសញ្ញន្តិ ឯត្ថាបិ ឯសេវ នយោ ។**

“១. ពាក្យថា **និច្ចសញ្ញា** ( ការសម្គាល់ថាទៀង ) គឺការប្រកាន់មាំថា ទៀង ពាក្យនេះសម្ដែងទុក ដោយប្រាប្ធ ពោលដល់សញ្ញាជាគោល ។

២. សូម្បីពាក្យពោលថា **សុខសញ្ញា** ( ការសម្គាល់ថាជាសុខ ) **អត្តសញ្ញា** ( ការសម្គាល់ថាជាតួខ្លួន ) ក៏មានន័យជាមួយគ្នានេះនោះឯង” ។

**[១] និច្ចសញ្ញាយាតិ សង្ខតធម្មា និច្ចា សស្សតាតិ ឯវំ បវត្តាយ មិច្ឆាសញ្ញាយ ។**

**[២] សញ្ញាគ្គហណេនេវ ទិដ្ឋិចិត្តានម្បិ គហណំ ទដ្ឋព្វំ [៣] ឯស នយោ សេសេ បទេសុបិ ។**

“១.ពាក្យថា **និច្ចសញ្ញាយ** (សេចក្ដីសម្គាល់ថាទៀង) មានន័យថា ការសម្គាល់ខុសដែលប្រព្រឹត្តទៅយ៉ាងនេះថា សង្ខតធម៌ ទៀងយឺនយូរ ។

*២. គប្បីជ្រាបការកាន់យកទិដ្ឋិ និងចិត្តដោយការកាន់យកសញ្ញាទៀតផង ។*

*៣. សូម្បីអនុបស្សនាដទៃអំពីនេះ* **ទុក្ខានុបស្សនា** *និង* **អនត្តានុបស្សនា** *ក៏មានន័យដូចគ្នា" ។*

*សេចក្តីនេះសំដៅសេចក្តីថា ការសំគាល់ថាទៀង ដែលលះបានដោយអនិច្ចានុបស្សនានោះ ជាមិច្ឆាសញ្ញាដែលសំគាល់ខុសថា សង្ខារដែលជាការឃើញ បានឮ ។ល។ ជារបស់ទៀង ស្ថិតនៅជានិច្ច មិនប្រែប្រួល កាលសញ្ញាវិបល្លាសដូចពោល ត្រូវលះបាន ក៏ជាការលះទិដ្ឋិវិបល្លាស និងចិត្តវិបល្លាសបាន ការដែលទុក្ខានុបស្សនាលះសុខសញ្ញា និងអនត្តានុបស្សនានេះអត្តសញ្ញាក៏ដូចគ្នា ។*

## ការលះបង់កិលេសដោយវិបស្សនាញាណ និងមគ្គញាណ

***សួរថា:*** *និច្ចសញ្ញាជាដើមដែលត្រូវលះដោយ អនិច្ចានុបស្សនានោះ តើជាអតីត អនាគត ឬបច្ចុប្បន្នឬ? ។*

***ឆ្លើយថា:*** *កិលេសដែលជាអតីត ជាវត្ថុដែលកើតឡើងហើយរលត់ទៅ ទើបត្រូវលះមិនបាន កិលេសដែលជាអនាគត នៅមិនប្រាកដក្នុងខណៈចម្រើនវិបស្សនា តែនឹងកើតឡើងប្រាកដដល់អ្នកដែលមិនបានចម្រើនវិបស្សនា ទើបត្រូវលះមិនបាន ក្រៅពីនោះ ក្នុងបច្ចុប្បន្នខណៈដែលបុគ្គលឃើញច្បាស់ថា មិនទៀង ក៏កើតកុសលវិបល្លាសតែម្យ៉ាង*

មិនមានកិលេសដែលគួរលះក្នុងខណៈនោះ ទើបលះកិលេសបច្ចុប្បន្ន មិនបាន ជាការពិតហើយកិលេសដែលត្រូវលះនោះជាវត្ថុដែលនឹងប្រាកដ កាលមានហេតុបច្ច័យព្រមគ្នា ដោយកើតឡើងដល់អ្នកដែល មិនឃើញ ច្បាស់ដល់ការមិនទៀងរបស់រូបនាម ដែលប្រាកដផ្លូវទ្វារទាំង ៦ ។

# អនុស័យកិលេសដែលដេកសម្ងំ

កិលេសដែលព្រមគ្នានឹងកើតឡើង កាលមានហេតុបច្ច័យដល់ព្រម មិនមែនអតីត ព្រោះមិនមែនវត្ថុដែលកើតឡើងហើយ មិនមែនជាអនាគត ព្រោះនៅមិនប្រាកដជាកើតឡើង និងមិនមែន បច្ចុប្បន្ន ព្រោះមិនមែនកំពុងកើតឡើង ចាត់ជាអនុស័យ គឺកិលេសដេកសម្ងំ ដែលផុតទៅពីកាលទាំង ៣ បែងចេញជាពីរប្រភេទគឺ :

១. **សន្តានុស័យ** កិលេសដែលដេកសម្ងំ ក្នុងក្រសែចិត្តជាវត្ថុដែលអាចកើតឡើងកាលបើមានហេតុបច្ច័យព្រមគ្នាដល់បុថុជ្ជន និងព្រះសេក្ខៈ ព្រោះនៅលះកិលេសដោយមគ្គមិនបាន ។

២. **អារម្មណានុស័យ** កិលេសដែលដេកសម្ងំ ក្នុងអារម្មណ៍ដែលមិនបានកំណត់ដឹងដោយ វិបស្សនាថា មិនទៀង ជាទុក្ខ មិនមែនជាតួខ្លួន ជាវត្ថុដែលអាចកើតឡើងដល់បុថុជ្ជន និងព្រះសេក្ខៈគិតថា ទៀង ជាសុខ ជាតួខ្លួន ក្នុងកន្លែងខ្លះហៅថា **អារម្មណាធិគ្គហិតុប្បន្នៈ** គឺកិលេសដែលកើតឡើង ព្រោះប្រកាន់មាំអារម្មណ៍ ។

# អារម្មណានុស័យ

*វិបស្សនាញាណអាចលះកិលេស ដែលជាអារម្មណានុស័យ ចំណែកមគ្គញាណ លះកិលេស ដែលជាសន្តានុស័យ ចំណែកមគ្គញាណ លះកិលេសដែលជាសន្តានុស័យ ដូចសេចក្តីក្នុងគម្ពីរវិភង្គថា*

***[១] សត្តានុសយា កាមរាគានុសយោ បដិឃានុសយោ មានានុសយោ, ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ, ភវរាគានុសយោ អវិជ្ជានុសយោ ។ [២] យំ លោកេ អនុបិយរូបំ អសាតរូបំ, ឯត្ថ សត្តានំ រាគានុសយោ អនុសេតិ ។ [៣] យំ លោកេ អនុបិយរូបំ អសាតរូបំ, ឯត្ថ សត្តានំ បដិឃានុសយោ អនុសេតិ ។ [៤] ឥតិ ឥមេសុ អវិជ្ជា អនុបតិតា ។ [៥] តទេកដ្ឋា មានោ ច ទិដ្ឋិ ច វិចិកិច្ឆា ច ទដ្ឋព្វា ។***

*“១. អនុស័យ ៧ គឺ **កាមរាគានុស័យ** ( អនុស័យ ដែលត្រេកអរកាមគុណ ) **បដិឃានុស័យ** ( អនុស័យដែលក្រោធខឹង ) **មានានុស័យ** ( អនុស័យដែលប្រកាន់តួខ្លួន ) **ទិដ្ឋានុស័យ** ( អនុស័យដែលឃើញខុស ) **វិចិកិច្ឆានុស័យ** ( អនុស័យដែលសង្ស័យ ) **ភវរាគានុស័យ** ( អនុស័យដែលត្រេកអរក្នុងភព ) និងអវិជ្ជានុស័យ ( អនុស័យដែលមិនដឹងតាមសេចក្តីពិត ) ។*

*២. រាគានុស័យរបស់ពួកសត្វ រមែងដេកសម្ងំក្នុងសភាព*

ដែលគួរស្រលាញ់គួរត្រេកអរ ក្នុងលោក គឺសង្ខារនេះ ។

៣. បដិឃានុស័យរបស់ពួកសត្វ រមែងដេកសម្ងំក្នុងសភាព ដែលមិនគួរស្រលាញ់មិនគួរត្រេកអរក្នុងលោកនេះ ។

៤. កាលជាដូចនេះ អវិជ្ជានុស័យក៏ដេកសម្ងំក្នុងរាគៈ និង បដិឃៈទាំងពីរពួកនេះ ។

៥. គប្បីជ្រាបថា មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ តាំងនៅក្នុងចិត្ត ១ ដួង ជាមួយ ចិត្តដែលប្រកបជាមួយនឹងអវិជ្ជានោះ ”។

សេចក្តីនេះ អធិប្បាយថា អារម្មណ៍ចែកជាពីរប្រភេទ គឺៈ

១. សភាវឥដ្ឋារម្មណ៍ អារម្មណ៍ដែលគួរត្រេកអរ ពេញចិត្ត តាមធម្មជាតិ ដូចរូបល្អ សម្លេងពីរោះ ក្លិនក្រអូបជាដើម ។

២. បរិកប្បឥដ្ឋារម្មណ៍ អារម្មណ៍ដែលគួរត្រេកអរពេញចិត្ត ដោយការគិតនឹក ដូចវត្ថុបដិកូល ឧច្ចារៈ សាកសពជាដើម ជាអារម្មណ៍ ដែលបុគ្គលទូទៅមិនគប្បីប្រាថ្នា តែសត្វប្រភេទខ្លះមានសុនក សុករៈ ឬ សត្វត្មាតជាដើម ។ ពេញចិត្តអារម្មណ៍ទាំងនោះ ដោយអំណាចនៃចិត្ត របស់ខ្លួន ។

អារម្មណ៍ទាំងពីរប្រភេទពួកនេះ ជាសភាពដែលគួរស្រលាញ់គួរ ត្រេកអរក្នុងលោកគឺសង្ខារ ឈ្មោះថា **បិយរូប** ( សភាពដែលគួរឲ្យ ស្រលាញ់ ) **សាតរូប** ( សភាពដែលគួរឲ្យស្រលាញ់ ) កាមរាគានុស័យ និងភវរាគានុស័យ រមែងដេកសម្ងំនៅក្នុងឥដ្ឋារម្មណ៍ ដែលជាធម៌ផ្នែក

លោកិយៈនោះ ។

ដោយទំនងជាមួយគ្នា អនិដ្ឋារម្មណ៍ចែកចេញជាពីរប្រភេទគឺៈ

១ សភាវអនិដ្ឋារម្មណ៍ អារម្មណ៍ដែលមិនគួរត្រេកអរ ពេញចិត្តតាមធម្មជាតិ ដូចរូបមិនល្អសម្លេងមិនពីរោះ ក្លិនស្អុយជាដើម ។

២ បរិកប្បអនិដ្ឋារម្មណ៍ អារម្មណ៍ដែលមិនគួរត្រេកអរពេញចិត្តដោយការនឹកគិតដូចការបាន ជួបព្រះពុទ្ធជាម្ចាស់ ដែលតិរ្ថិយសំគាល់ថាជាអពមង្គលជាដើម ។

អារម្មណ៍ទាំងពីរប្រភេទនេះ ជាសភាពដែលមិនគួរស្រលាញ់ មិនគួរត្រេកអរក្នុងលោក គឺសង្ខារ ឈ្មោះថា **អប្បិយរូប** ( តាមសភាពដែលមិនគួរស្រលាញ់ ) **អសាតរូប** ( សភាពដែលមិនគួរត្រេកអរ ) បដិឃានុស័យ រមែងដេកសម្ងំនៅក្នុងអនិដ្ឋារម្មណ៍ ដែលជាធម៌ផ្នែកលោកិយៈនោះ ។

ក្រៅពីនោះ ក្នុងគ្រប់ខណៈដែលកាមរាគានុស័យ ដេកសម្ងំក្នុងឥដ្ឋារម្មណ៍ និងបដិឃានុស័យ ដេកសម្ងំក្នុងអនិដ្ឋារម្មណ៍ សូម្បីតែអវិជ្ជានុស័យ ក៏ដេកសម្ងំក្នុងអារម្មណ៍ទាំងនោះទៀតផង កាលអវិជ្ជានុស័យដេកសម្ងំយ៉ាងនេះ មានៈ ទិដ្ឋិ និង វិចិកិច្ឆា ដែលរមែងកើតរួមជាមួយនឹងអវិជ្ជាក្នុងចិត្ត ១ដួងជាមួយគ្នា ក៏ដេកសម្ងំដូចគ្នា។

ម្យ៉ាងទៀត ការដេកសម្ងំ មិនមែនការលាក់ទុកនៅខាងក្នុង តែជាសភាពព្រម ដែលកើតឡើង បានតាមអំណាចរបស់អារម្មណ៍ កាល

*មានហេតុបច្ច័យ ព្រោះនៅលះមិនទាន់បាន ដោយវិបស្សនាញាណ ដោយតទង្គបហាន និងមគ្គញាណ ដោយសមុច្ឆេទបហាន ដូចពាក្យអធិប្បាយក្នុងគម្ពីរអដ្ឋកថា និងដីកាថា*

ឯត្ថ សត្តានំ រាគានុសយោ អនុសេតីតិ ឯតស្មិំ ឥដ្ឋារម្មណេ សត្តានំ អប្បហីនដ្ឋេន រាគានុសយោ អនុសេតិ ។

*"ព្រះតម្រាស់ថា* **ឯត្ថ សត្តានំ រាគានុសយោ អនុសេតិ** *( រាគានុស័យរបស់ពួកសត្វ រមែងដេកសម្ងំក្នុងសភាពដែល គួរស្រលាញ់ គួរត្រេកអរក្នុងលោកនេះ ) សំដៅយក រាគានុស័យរបស់ ពួកសត្វ រមែងដេកសម្ងំក្នុងឥដ្ឋារម្មណ៍នេះ ដោយសភាព ដែលនៅលះមិនបាន ដោយវិបស្សនាញាណ និង មគ្គញាណ" ។*

អារម្មណសន្តានានុសយនេសុ ឥដ្ឋារម្មណេ អារម្មណានុសយនេន អនុសេតិ។

*"ក្នុងបណ្ដាការដេកសម្ងំ ក្នុងអារម្មណ៍ និងការដេកសម្ងំក្នុងក្រសែចិត្ត កិលេសរមែងដេកសម្ងំក្នុងឥដ្ឋារម្មណ៍ ដោយដេកសម្ងំក្នុងអារម្មណ៍ ។*

***[១]*** អារម្មណសន្តានានុសយនេសូតិ អារម្មណានុសយនំ សន្តានានុសយនន្តិ ទ្វីសុ អនុសយនេសុ ។ ***[២]*** តថា ហិ មគ្គេន អសមុច្ឆិន្នោ រាគោ ការណលាភេ ឧប្បជ្ជនារហោ ថាមគតដ្ឋេន សន្តានេ អនុសេតីតិ វុច្ចតិ, ***[៣]*** ឯវំ ឥដ្ឋារម្មណម្បីតិ តស្ស

អារម្មណានុសយំ ឧទ្ធតំ ។

“១. ពាក្យពោលថា អារម្មណសន្តានានុសយនេសុ (ក្នុងបណ្តាការដេកសម្ងំក្នុងអារម្មណ៍ និងការដេកសម្ងំក្នុងក្រស៊ៃចិត្ត ) មានន័យថា ការដេកសម្ងំ ២ ប្រការគឺ ការដេកសម្ងំក្នុងអារម្មណ៍ និងការដេកសម្ងំក្នុងក្រស៊ៃចិត្ត ។

ឧបមាថា រាគៈដែលលះមិនបានដាច់ខាតដោយមគ្គ គួរកើតឡើងកាលមានហេតុបច្ច័យ រមែងពោលថា **សន្តានេ អនុសេតិ** ( រមែងដេកសម្ងំក្នុងក្រស៊ៃចិត្ត ) ដោយសេចក្តីជាសភាព ដែលមានកម្លាំងយ៉ាងណា ។

១. សូម្បីឥដ្ឋារម្មណ៍ ដែលនៅមិនទាន់លះបង់ដោយវិបស្សនា និងមគ្គបាន គួរកើតឡើងកាលមានហេតុបច្ច័យ រមែងពោលថា **អារម្មណេ អនុសេតិ** ( រមែងដេកសម្ងំក្នុងអារម្មណ៍ ) ដោយសេចក្តីជា សភាពដែលមានកម្លាំងយ៉ាងនោះ គប្បីជ្រាបការដេកសម្ងំក្នុងអារម្មណ៍ របស់រាគៈនោះយ៉ាងនេះ” ។

សរុបសេចក្តីថា ការដែលកិលេសដេកសម្ងំក្នុងអារម្មណ៍ គឺការកើតកិលេសបាន ក្នុងអារម្មណ៍ដែលមិនបានឃើញច្បាស់តាមសេចក្តីពិតដោយវិបស្សនាញាណ និងមគ្គញាណ ទើបហៅថា **អារម្មណានុស័យ** គឺអនុស័យ ដែលដេកសម្ងំនៅក្នុងអារម្មណ៍ ព្រះដ៏មានព្រះភាគត្រាស់ដល់ការលះបង់អនុស័យប្រភេទនេះថា :

**[១]** សុខាយ ភិក្ខវេ វេទនាយ រាគានុសយោ បហាតព្វោ ។

[២] ទុក្ខាយ វេទនាយ បដិឃានុសយោ បហាតព្វោ ។

[៣] អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយោ បហាតព្វោ ។

*"១. ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរលះរាគានុស័យក្នុងការសោយសុខ ( សុខវេទនា ) ។*

*២. គួរលះបង់បដិឃានុស័យ ក្នុងការសោយទុក្ខ ( ទុក្ខវេទនា ) ។*

*៣. គួរលះអវិជ្ជានុស័យ ក្នុងការសោយអារម្មណ៍ មិនមែនសុខ មិនមែនទុក្ខ ( ឧបេក្ខាវេទនា )" ។*

*ក្នុងគម្ពីរអដ្ឋកថាអធិប្បាយរឿងនេះថា :*

ឥមស្មិំ សុត្តេ អារម្មណានុសយោ កថិតោ ។

*"ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងអារម្មណានុស័យ ទុកក្នុងព្រះសូត្រនេះ" ។*

*អារម្មណានុស័យនេះ មានឈ្មោះដទៃថា* ***អារម្មណាធិគ្គហិតុប្បន្នៈ*** *គឺ កិលេសដែលកើតឡើង ព្រោះប្រកាន់មាំអារម្មណ៍ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :*

ចក្ខាទីនំ បន អាបាថគតេ អារម្មណេ បុព្វភាគេ អនុប្បជ្ជមានម្បិ កិលេសជាតំ អារម្មណស្ស អធិគ្គហិតត្តា ឯកំ អបរភាគេ ឯកន្តេន ឧប្បត្តិតោ អារម្មណាធិគ្គហិតុប្បន្នន្តិ វុច្ចតិ ។

*"ម្យ៉ាងទៀត កាលអារម្មណ៍ មកប្រាកដដល់ចក្ខុជាដើម កិលេសទាំងឡាយ ដែលសូម្បីនៅមិនទាន់កើតឡើង ក្នុងខាងដើម ខណៈបាន*

ទទួលអារម្មណ៍ ឲនឈ្មោះថា អារម្មណាធិគ្គហិតុប្បន្នៈ ព្រោះកើតឡើង ប្រាកដក្នុងខាងក្រោយ បន្ទាប់ពីប្រកាន់មាំអារម្មណ៍ដោយពិត” ។

សេចក្តីខាងដើមមានន័យថា កាលអារម្មណ៍ ៦ដែលគួរពេញចិត្ត ឬមិនគួរពេញចិត្តដែលបាន ដល់ រូប សម្លេង ក្លិន រស សម្ផស្ស ឬ ធម្មារម្មណ៍ មកប្រាកដផ្លូវទ្វារ៦ ជាការឃើញ បានឮ ធំក្លិន ភ្លក្សរស ប៉ះខ្ទប់សម្ផស្ស ឬនឹកគិតក្នុងខណៈនោះកិលេសដែលជាសេចក្តីលោភ ឬសេចក្តីក្រោធកើតឡើង ឬមិនក៏បាន បើកិលេសកើតឡើង ក្នុងខណៈនោះ ក៏នឹងកើតទៀតក្នុងខាងក្រោយយ៉ាងពិតប្រាកដ ឬសូម្បី នឹងមិនកើតឡើង ក្នុងខណៈនោះព្រោះយោនិសោមនសិការជាដើម កិលេសក៏អាចប្រាកដ បាន ក្នុងខាងក្រោយ កាលមានហេតុបច្ច័យដល់ព្រម ដូចការអាឡោះ អាល័យ ការជួបជាមួយអារម្មណ៍ដែលប្រហាក់ ប្រហែលគ្នា ឬការជួប ជាមួយអារម្មណ៍ដែលផ្ទុយគ្នា ការជំរុញបបែបួលអំពីអ្នកដទៃ ព្រោះបុគ្គល ប្រកាន់មាំ នៅក្នុងអារម្មណ៍តែបើមិនមានការប្រកាន់មាំអារម្មណ៍ កិលេស ក៏នឹងប្រាកដមិនបានកិលេស ដែលព្រមនឹងប្រាកដ ព្រោះប្រកាន់មាំ អារម្មណ៍ទើបបានឈ្មោះថា អារម្មណាធិគ្គហិតុប្បន្នៈ ។

ព្រះអរិយៈ អ្នកកំចាត់កិលេសបាន ដាច់ជាសមុច្ឆេទ ដោយមគ្គញាណ ហើយ រមែងអាចលះកិលេស ដែលជាអារម្មណានុស័យ ដែលឈ្មោះថា អារម្មណាធិគ្គហិតៈបានយ៉ាងពិតប្រាកដ ។ ចំណែកវិបស្សនាលះបង់ អារម្មណានុស័យបានដូចគ្នា ពោលគឺ អ្នកបដិបត្តិធម៌ ដែលឃើញច្បាស់

*ថា អារម្មណ៍មាន រូប ការឃើញ ឮសម្លេង ការបានឮជាដើម ដែល ប្រាកដផ្លូវទ្វារ ៦ នោះ មិនទៀង ជាទុក្ខ មិនមែនតួខ្លួន រមែងបានឈ្មោះថា លះបង់កិលេស ដែលប្រកាន់មាំខុសថា ទៀង ជាសុខ ជាតួខ្លួន ទើប ពោលបានថា កិលេសមិនដេកសម្ងំក្នុង អារម្មណ៍ដែលកំណត់ដឹង កាល មានអារម្មណានុស័យស្ងប់ទៅដូចនោះ កិលេសដែលជាបរិយុដ្ឋាន ឬ វិតិក្កមៈរួមដល់កុសលធម៌ អកុសលធម៌និងវិបាកខន្ធ អាចកើតឡើង កាលមានអនុស័យក៏ផ្លាស់ប្តូរ ស្ងប់ទៅព្រមគ្នា ដូចគម្ពីរមហាដីកា ពោលដល់សេចក្តីស្ងប់ទៅ របស់កិលេសកម្មនិងវិបាកទាំងនោះ ដោយ វិបស្សនាថា :*

**[១] អនិច្ចានុបស្សនា តាវ តទង្គប្បហានវសេន និច្ចសញ្ញំ បរិច្ចន្តិ ។ [២] បរិច្ចជន្តី ច តថា អប្បវត្តិយំ យេ និច្ចន្តិ គហណវសេន កិលេសា, តម្មូលកា អភិសង្ខារា, តទុភយមូលកា ច វិបាកា ខន្ធា អនាគតេ ឧប្បជ្ជេយ្យុំ, តេ សព្វេបិ អប្បវត្តិករណវសេន បរិច្ចជតិ ។ [៣] តថា ទុក្ខានុបស្សនាទយោ ។[៤] តេនាហ វិបស្សនា តទង្គវសេន សទ្ធិំ ខន្ធាភិសង្ខារេហិ កិលេសេ បរិច្ចជតីតិ ។**

*“១.អនិច្ចានុបស្សនា ដែលសម្តែងលំដាប់ដំបូង រមែងលះបង់ និច្ចសញ្ញា ដោយ តទង្គបហានជាដើម ។*

*២. ម្យ៉ាងទៀត អនិច្ចានុបស្សនា លះនិច្ចសញ្ញារមែងលះកិលេស ដែលប្រកាន់ថា ទៀង អភិសង្ខារ គឺបុណ្យបាប ដែលមានកិលេសនោះ*

ជាហេតុនិងវិបាកខន្ធដែលមានកិលេស និងអភិសង្ខារ ទាំងពីរនោះ ជាហេតុទាំងអស់ ដែលអាចកើតក្នុងអនាគត ដោយធ្វើមិនកើតទៀត ។

៣. ទុក្ខានុបស្សនាជាដើមក៏លះ សុខសញ្ញាជាដើម បានដូចគ្នា ។

១ ដូច្នោះ ព្រះអដ្ឋកថាចារ្យទើបពោលថា

**វិបស្សនា តទង្គវសេន សទ្ធិំ ខន្ធាភិសង្ខារេហិ កិលេសេ បរិច្ចជតិ ។**

( វិបស្សនារមែងលះកិលេសព្រមដោយខន្ធ និងអភិសង្ខារ ដោយតទង្គបហាន )" ។

អធិប្បាយដោយសង្ខេបថា កាលបុគ្គលមិនដឹងច្បាស់ថា អារម្មណ៍ដែលប្រាកដផ្លូវទ្វារទាំង ៦ នោះ មិនទៀង កិលេស ដែលប្រកាន់មាំថាទៀង រមែងមានឱកាសកើតឡើង ដូចនោះ កិលេសទើបដេកសម្ងំក្នុងអារម្មណ៍ ដែលមិនយល់ឃើញថាមិនទៀង តមកបុគ្គលនោះ អាចគិតដល់អារម្មណ៍ដូចពោលថា ទៀង តាមហេតុបច្ច័យ ដែលហេតុបច្ច័យដែលប្រាកដព្រមគ្នា ការគិតដល់នេះជាបរិយុដ្ឋានខាងក្រោយមក គេនឹងព្យាយាម ដើម្បីបានទទួលអារម្មណ៍ ដែលពេញចិត្ត ដើម្បីនៅដោយល្អមានសេចក្ដីសុខ ឬដើម្បីទំលាយវត្ថុ ដែលមិនពេញចិត្ត តាមហេតុបច្ច័យដែលខ្លួនបានទទួល សេចក្ដីព្យាយាមនេះជាអភិសង្ខារ ដែលមានកិលេសជាហេតុកើត ព្រោះកើតបន្ទាប់ពីកិលេសដែលសម្គាល់ថាទៀង ក្រោយពីនោះ វិបាកខន្ធ ក្នុងភពថ្មី គឺបដិសន្ធិចិត្ត ជាដើមរមែងកើត តមកតាមហេតុបច្ច័យព្រោះអភិសង្ខារគឺបុណ្យនិងបាប ។

ដោយប្រការដូចនេះ វិបាកខន្ធក្នុងភពថ្មី រមែងកើតឡើង កាលមានកម្មជាហេតុ បើមិនមានកម្ម វិបាកខន្ធ ក៏កើតឡើង មិនបានទិង កម្មក៏មិនកើតឡើង បើមិនមានកិលេស ដែលសម្គាល់ខុសថា ទៀង សូម្បីកិលេស ក៏នឹងកើតឡើងមិនបាន កាលមិនមានការប្រកាន់ខុសថា ទៀង នឹងឃើញបានថា បើបុគ្គលដឹងច្បាស់តាមសេចក្តីពិត អារម្មណ៍ដែលប្រាកដ ផ្លូវទ្វារ ៦ មិនទៀង ការប្រកាន់ខុសថា ទៀង រមែងមិនកើតឡើង អនិច្ចានុបស្សនា ទើបធ្វើសភាវៈទាំងនោះស្ងប់ទៅ គឺ :

-អនុស័យ ដែលប្រកាន់មាំថា ទៀង ។

-បរិយុដ្ឋាន ដែលគិតដល់អារម្មណ៍ ដែលធ្លាប់ជួបថា ទៀង ។

-វីតិក្កមៈ គឺការកន្លងល្មើសផ្លូវកាយ និង វាចា ដោយជាប់ដោយអារម្មណ៍ ដែលគិតថា ទៀង ។

-សេចក្តីព្យាយាម ធ្វើបុណ្យ និងបាប គឺអភិសង្ខារ ដើម្បីបានទទួលវត្ថុដែលខ្លួនត្រូវការនឹងបដិសេធវត្ថុ ដែលខ្លួនមិនត្រូវការ ។

-វិបាកខន្ធក្នុងភពថ្មី ដែលជាហេតុរបស់បុណ្យ និងបាប ។

ដោយហេតុនេះ ទើបពោលបានថា អនិច្ចានុបស្សនា រមែងលះកិលេស កម្ម និងវិបាកខន្ធព្រោះ ធ្វើអនុស័យ ជាដើមទៅរហូតដល់ខន្ធក្នុងភពថ្មីស្ងប់ចុះ ដោយទំនងជាមួយគ្នា ទុក្ខានុបស្សនា រមែងលះសុខសញ្ញា និងអនត្តានុបស្សនា រមែងលះអត្តសញ្ញា រួមទៅដល់កិលេសជាដើម ដូចនោះ ក្នុងគម្ពីរវិសុទ្ធិមគ្គ ទើបពោលថា “វិបស្សនារមែងលះ

*កិលេសព្រមដោយខន្ធ និងអភិសង្ខារដោយតទង្គបហាន" ។*

# សន្តានានុស័យ

*កិលេសដែលកើតឡើងបាន កាលមានហេតុបច្ច័យ ដល់ព្រមក្នុងក្រសែចិត្តរបស់បុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី ព្រោះលះមិនទាន់បាន ដោយមគ្គ ឈ្មោះថា **សន្តានានុស័យ** គឺ កិលេសដេកសម្ងំក្នុងក្រសែចិត្ត សំដៅសេចក្តីថា កិលេសដែលព្រមនឹងកើតឡើងក្នុងក្រសែចិត្តរបស់បុគ្គលទាំងនោះ តួយ៉ាងដូចមនុស្សមានជំងឺ ដែលនៅមិនទាន់ជាបាត់ កាលមានមនុស្សសួរថា: សុខសប្បាយជាទេ ក៏ត្រូវឆ្លើយថា: មិនសប្បាយ ព្រោះកាលមុនបានធ្លាប់មានជំងឺ ហើយនឹងមានជំងឺតទៅទៀត ក្នុងទំនងដូចគ្នា កិលេសទាំងនេះគឺ :*

***-អនុស័យ*** *៧ ក្នុងបុថុជ្ជន ។*

***-អនុស័យ ៥*** *( វៀរទិដ្ឋិ និង វិចិកិច្ឆា ) កើតមានសម្រាប់ព្រះសោតាបន្ន និងព្រះសកទាគាមី ) ។*

***-អនុស័យ ៣*** *គឺកវរាគៈ មានៈ និងអវិជ្ជា កើតមានសម្រាប់ព្រះអនាគាមី ។*

*កិលេសដូចពោល សូម្បីនឹងមិនមានកម្លាំង កើតឡើង ដោយខណៈទាំង ៣ គឺឧប្បាទខណៈ ឋិតិខណៈ និងភង្គខណៈ ក៏មានសភាពនឹងកើតឡើង កាលមានហេតុបច្ច័យដល់ព្រម ទើបជាអនុស័យ ដែលព្រមនឹងកើតឡើងរឿយៗ ។*

*ក្នុងគម្ពីរយមកពោលដល់រឿងនេះថា :*

**[១] អនាគាមិស្ស អវិជ្ជានុសយោ ច មានានុសយោ ច ភវរាគានុសយោ ច អនុសេន្តិ ។បេ។ [២] ទ្វិន្នំ បុគ្គលានំ អវិជ្ជានុសយោ ច កាមរាគានុសយោ ច បដិឃានុយោ ច មានានុសយោ ច ភវរាគានុសយោ ច អនុសេន្តិ ។ តោ ច តេសំ ទិដ្ឋានុយោ ច វិចិកិច្ឆានុសយោ ច អនុសេន្តិ ។ [៣] បុថុជ្ជនស្ស អវិជ្ជានុសយោ ច អនុសេតិ, កាមរាគានុសយោ ច បដិឃានុសយោ មានានុសយោ ច ទិដ្ឋានុយោ ច វិចិកិច្ឆានុសយោ ច ភវរាគានុយោ ច អនុសេន្តិ ។**

*“១. អវិជ្ជានុស័យ មានានុស័យ និងភវរាគានុស័យ រមែងដេក សម្ងំដល់ព្រះអនាគាមី ។ល។*

*២. អវិជ្ជានុស័យ កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងភវរាគានុស័យរមែងដេក សម្ងំដល់បុគ្គលពីរជំពូក ព្រះសោតាបន្ន និងព្រះសកទាគាមី តែទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យរមែងដេក សម្ងំដល់បុគ្គលទាំងនោះ ។*

*៣. **អវិជ្ជានុស័យ** កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ រមែងដេកសម្ងំដល់បុថុជ្ជន” ។*

*ក្នុងបណ្តាអនុស័យ អនុស័យដែលមិនកើតរួមគ្នា ដោយខណៈ*

កើតឡើង ( ឧប្បាទខណៈ ) គឺៈ

-កាមរាគៈ ជាមួយភវរាគៈ ។

-រាគៈ ជាមួយបដិឃៈ និងវិចិកិច្ឆា ។

-បដិឃៈ ជាមួយនឹងមានៈ ទិដ្ឋិ វិចិកិច្ឆា និងរាគៈ ។

-មានៈ ជាមួយនឹងទិដ្ឋិ វិចិកិច្ឆា និងបដិឃៈ ។

-ទិដ្ឋិ ជាមួយនឹងវិចិកិច្ឆា ភវរាគៈ និងមានៈកិលេស ដែលមិនបានកើតឡើងរួមគ្នាត្រូវហៅថា ជាកិលេសដេកសម្ងំរួមគ្នា នៅក្នុងក្រសែចិត្តដោយឈ្មោះថា **អនុស័យ** កិលេសដូចពោល មិនមែនកំពុងកើតឡើងពិតៗ ដោយសេចក្តីជាខណៈកើតឡើង តាំងនៅ និងរលត់ទៅ ដូចបរិយុដ្ឋាន និងវីតិក្កមៈ តែជាកិលេសដល់ព្រមនឹងកើតឡើង កាលបានទទួលហេតុបច្ច័យ ដែលសមគួរព្រោះនៅមិនទាន់ លះបានដាច់ស្រេះដោយមគ្គ ។

រឿងដែលកាមរាគៈ និងបដិឃៈដេកសម្ងំនៅរួមគ្នា ក្នុងបុគ្គលប្រាកដក្នុងគម្ពីរយមកៈ និងអដ្ឋកថាថា :

**[១] យស្ស កាមរាគានុសយោ អនុសេតិ តស្ស បដិឃានុសយោ អនុសេតីតិ ។ អាមន្តា ។ [២] យស្ស កាមរាគានុសយោ ឧប្បជ្ជតិ តស្ស បដិឃានុសយោ ឧប្បជ្ជតីតិ ។ អាមន្តា។**

“១. បុច្ឆាថា កាមរាគានុស័យ ដេកសម្ងំដល់បុគ្គលណា?

បដិឃានុស័យ ក៏ដេកសម្ងំដល់បុគ្គលនោះ មែនឬ ?

**វិសជ្ជនា :** ( **អាមន្តា** ) មែន ។

២.**បុច្ឆាថា :** កាមរាគានុស័យនោះ កំពុងកើតដល់បុគ្គលណា បដិឃានុស័យ ក៏កំពុងកើតដល់ បុគ្គលនោះ មែនឬ ?

**វិសជ្ជនា :** ( **អាមន្តា** ) មែន កំពុងកើត ។

**[១] យស្មិំ សន្តានេ អនុសយា អប្បហីនា, យស្មិំ វា បន នេសំ សន្តានេ ឧប្បត្តិបច្ចយេ សតិ ឧប្បត្តិ អនិវារិតា ។ [២] តត្ថ អនុប្បជ្ជនក្ខណេបិ អនុប្បន្នបុព្វេ្វោវ កាលន្តរេ ឧប្បជ្ជមានកញ្ញ ឧចានាយ យស្ស កាមរាគានុសយោ ឧប្បជ្ជតិ, តស្ស បដិឃានុសយោ ឧប្បជ្ជតិយេវ នាម ។**

“១.អនុស័យ នៅមិនទាន់បានលះក្នុងក្រសែខន្ធណា ឬថាកាលមានហេតុកើតរបស់អនុស័យ ទាំងនោះក្នុងក្រសែខន្ធ ការកើតឡើងរបស់អនុស័យមិនបានត្រូវហាមទុក ។

២. កាមរាគានុស័យកំពុងកើតដល់បុគ្គលណា សូម្បីក្នុងខណៈមិនមែនកំពុងកើតឡើងបដិឃានុស័យ ក៏ឈ្មោះថា កំពុងកើតដល់បុគ្គលនោះ ព្រោះអាស្រ័យអនុស័យ ដែលធ្លាប់កើតឡើងហើយ នឹងកើតឡើងក្នុងកាលដទៃក្នុងក្រសែខន្ធដែលនៅលះ និងហាមអនុស័យមិនបាន” ។

ក្នុងគម្ពីរមូលដីកា អធិប្បាយបន្ថែមឡើងថា កិលេសដែលមាន

កំពុងនឹងកើតឡើងកាលមាន ហេតុបច្ច័យគ្រប់គ្រាន់ ជាកិលេសដេកសម្ងំដែលឈ្មោះថាអនុស័យ សំដៅដល់កាមរាគៈជាដើម ៧ យ៉ាង ប៉ុណ្ណោះ មិនជាប់ទាក់ទងជាមួយនឹងកិលេស ដទៃដែលសូម្បីនឹងមិនត្រូវលះដោយមគ្គ ចំណែកគម្ពីរវិសុទ្ធមគ្គ ពោលថា កិលេសដែលអាចកើតឡើងបាន ដោយមិនបានគ្រប់គ្រងទុក ដោយសមថៈ និងវិបស្សនាក៏ឈ្មោះថា **អនុស័យ** ដូចកិលេស ដែលមិនទាន់បានលះដោយមគ្គ ។

តាមសេចក្តី ដែលពោលទុកខាងដើម អនុស័យ ៧ យ៉ាង ៥ យ៉ាង ឬ ៣ យ៉ាង រមែងដេកសម្ងំក្នុង ក្រសែខន្ធរបស់បុថុជ្ជន និងព្រះសេក្ខៈរឿយៗ ក្នុងវេលាទាំងនេះ គឺ

-ខណៈកើតអកុសលចិត្ត ។

-ខណៈកើតកុសលចិត្ត ។

-ខណៈកើតវិបាកចិត្តធ្វើនាទីបដិសន្ធិ ភវង្គនិងចុតិ ។

អនុស័យទាំងនេះ នៅដេកសម្ងំក្នុងក្រសែខន្ធ គឺរូបម្យ៉ាង របស់អសញ្ញសត្វព្រហ្ម ទៀតផង ដូចនោះ អនុស័យដូចពោល ដែលដេកសម្ងំក្នុងក្រសែខន្ធរបស់បុថុជ្ជន និងព្រះសេក្ខៈ ដែលអាចកើតឡើង តាមហេតុបច្ច័យ ទើបបានឈ្មោះថា សន្តានុស័យ រមែងត្រូវលះបានដាច់ស្រឡះ ដោយមគ្គប៉ុណ្ណោះ មិនអាចត្រូវលះបាន ដាច់ស្រឡះ ដោយវិបស្សនា វិបស្សនានោះ រមែងលះកិលេស ដែលកំពុងកើតឡើង ដោយតទង្គបហាន នឹងគ្រប់គ្រងកិលេស ដទៃដែលមិនបាន កើតឡើង

ដោយវិក្ខម្ភនបហាន ។

សរុបសេចក្តីថា សេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គថា “ អនិច្ចានុបស្សនា លះសេចក្តីសម្គាល់ថាទៀង” គឺអនិច្ចានុបស្សនា លះអារម្មណានុស័យ កិលេសដែលជាបរិយុដ្ឋាន និងវីតិក្កមៈព្រមទាំងកម្ម និងវិបាកខន្ធ តាមន័យដែលពោលហើយ ក្នុងខាងដើម ។

**២.កាលបុគ្គលឃើញច្បាស់នូវការមិនទៀងហើយ ក៏ត្រូវឃើញសេចក្តីទុក្ខ និងភាពមិនមែនតួខ្លួន**

អ្នកដែលឃើញច្បាស់អារម្មណ៍ថា មិនទៀងរមែងប្រាសចាក ការប្រកាន់មាំថា ទៀង ទាំងនៅមិនសម្គាល់ថា អារម្មណ៍ ដែលកើតរលត់នោះ ជាសុខ ឬជាតួខ្លួនទៀត គេយល់ថា សភាវធម៌ ដែលកើតឡើងហើយរលត់ទៅនោះ ជាទុក្ខ ដែលមិនគួរប្រាថ្នា ពេញចិត្ត ព្រោះនៅមានការកើតរលត់ និងយល់ថា មិននៅក្នុងអំណាចរបស់ខ្លួន មិនអាចបង្គាប់បញ្ជាបាន ដូចនោះបញ្ញា ដែលឃើញច្បាស់សេចក្តីទុក្ខ និងសភាពមិនមែនតួខ្លួន ទើបកើតឡើង ដោយស្របតាមបញ្ញាឃើញច្បាស់សេចក្តីមិនទៀង ដូចសេចក្តីក្នុងអង្គុត្តរនិកាយថា :

**[១] អនិច្ចសញ្ញា ភាវេតព្វា អស្មិមានសមុគ្ឃាតាយ ។ [២] អនិច្ចសញ្ញិនោ ភិក្ខវេ អនត្តសញ្ញា សណ្ឋាតិ ។ [៣] អនត្តសញ្ញី អស្មិមានសមុគ្ឃាតំ បាបុណាតិ ទិដ្ឋេវ ធម្មេ និព្វានំ ។**

“១. គប្បីចម្រើនសំគាល់ថា មិនទៀង ដើម្បីដកចេញអស្មិមានៈ

( ការប្រកាន់ខ្លួន ) ។

២. ម្នាលភិក្ខុទាំងឡាយ ការសម្គាល់ថាមិនមែនតួខ្លួន រមែងកើតឡើងដល់បុគ្គល អ្នកសម្គាល់ថា មិនទៀង ។

៣. អ្នកសម្គាល់ថា មិនមែនតួខ្លួន រមែងដល់ការដកចេញនូវអស្មិមានៈ និងសម្រេចនិព្វាន ក្នុងបច្ចុប្បន្នភព” ។

អស្មិមានៈ គឺការប្រកាន់ខ្លួន ជាសេចក្ដីប្រកាន់ខ្លួន ក្នុងគុណធម៌ដែលមានពិត ដែលសម្គាល់ថា ល្អជាងបុគ្គលដទៃ កើតឡើងដល់ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី ដែលពិតហើយ សូម្បីព្រះអរិយៈ នឹងមិនមានការប្រកាន់មាំក្នុងតួខ្លួន ដូចបុថុជ្ជន ព្រោះលះសក្កាយទិដ្ឋិបាន ដាច់ស្រឡះហើយ តែលោកនៅគិតដល់អំពើ ឬ និយាយចចារ ដោយមានការប្រកាន់ខ្លួនដោយអស្មិមានៈ អស្មិមានៈ ដែលដល់ព្រះអរិយៈនេះ ក្នុងកន្លែងខ្លះហៅថា ទិដ្ឋិមានៈ ព្រោះមានលក្ខណៈចំណែកខ្លះ ស្រដៀង នឹងសក្កាយទិដ្ឋិ ក្នុងខ្លះក៏ហៅថាមិច្ឆាទិដ្ឋិ ក្នុងករណី ដែលពោលថា សម្មាទិដ្ឋិ គឺមគ្គខាងលើនេះសម្មាទិដ្ឋិ ។

សេចក្ដីថា “ការសម្គាល់ថា មិនមែនតួខ្លួន រមែងកើតឡើងដល់បុគ្គល អ្នកសម្គាល់ថាមិនទៀង “ជាអត្ថន័យក្នុងរឿងនេះ សំដៅសេចក្ដីថា កាលបុគ្គលឃើញច្បាស់ថា មិនទៀង ក៏ជាការឃើញច្បាស់ថា មិនមែនតួខ្លួន និងកាលឃើញច្បាស់ថា មិនមែនតួខ្លួន ក៏ជាការលះអស្មិមានៈ ដោយអរហត្តមគ្គបាន ដូចនោះ ព្រះអង្គទើបត្រាស់ថា គប្បី

ចម្រើនអនិច្ចសញ្ញា ដើម្បីដកចេញនូវអស្មិមានះ ក្នុងគម្ពីរអដ្ឋកថា បាន អធិប្បាយថា :

**[១] អនិច្ចលក្ខណេ ទិដ្ឋេ អនត្តលក្ខណំ ទិដ្ឋមេវ ហោតិ ។ [២] តេសុ ហិ តីសុ លក្ខណេសុ ឯកស្មិំ ទិដ្ឋេ ឥតរទ្វយំ ទិដ្ឋមេវ ហោតិ ។ [៣] តេន វុត្តំ អនិច្ចសញ្ញិនោ ភិក្ខវេ អនត្តសញ្ញា សណ្ឋាតីតិ"។**

"១. កាលបុគ្គលដឹងច្បាស់អនិច្ចលក្ខណៈ ក៏ជាការដឹងច្បាស់ អនត្តលក្ខណៈ ។

២. ដោយពិតហើយ កាលបុគ្គលឃើញច្បាស់ លក្ខណៈមួយ ក្នុងខណៈ ៣ ទាំងនោះ ក៏ជាការឃើញច្បាស់លក្ខណៈលក្ខណៈដទៃបាន ។

៣. ដូច្នោះ ព្រះអង្គទើបត្រាស់ថា **អនិច្ចសញ្ញិនោ ភិក្ខវេ អនត្តសញ្ញា សណ្ឋាតិ** ( ម្នាលភិក្ខុទាំងឡាយ ការសំគាល់ថា មិនមែន តួខ្លួន រមែងកើតឡើងដល់បុគ្គល អ្នកសម្គាល់ថា មិនទៀង )" ។

សរុបសេចក្តីថា អ្នកប្រារព្ធសេចក្តីព្យាយាម ដែលឃើញច្បាស់ ការមិនទៀងហើយ រមែងឃើញច្បាស់សភាពជាទុក្ខ និងសភាពមិនមែន តួខ្លួន ដោយជាក់ច្បាស់បាន ពោលគឺ កាលគេគិតពិចារណាអារម្មណ៍ ដែលខ្លួនឃើញច្បាស់ថាមិនទៀង រមែងជួបលក្ខណៈដែលជាទុក្ខ និង មិនមែនតួខ្លួន មិនជួបលក្ខណៈដែល ជាសុខ និងជាតួខ្លួន ដូចនោះ មិន ត្រឹមកិលេសដែលប្រកាន់មាំថាទៀង និងស្ងប់ទៅក្នុងខណៈនោះ សូម្បី

កកិលេសដែលប្រកាន់មាំថាជាសុខ និងជាតួខ្លួន ក៏ស្ងប់ទៅដូចគ្នា ។

ក្នុងគម្ពីរសម្មោហវិនោទនី ពោលថាការមិនទៀង និងសភាពជាទុក្ខ ដោយសម្មតិរមែងប្រាកដ ដល់អ្នកស្រុកទូទៅ កាលគេឃើញថ្នាំង ឬកែវ ឬវត្ថុណាមួយ ជ្រុះពីដៃបែកទៅ ក៏និយាយថា មិនទៀង ឬ កាលមានរបួសកើតឡើងក្នុងរាងកាយ ឬត្រូវបន្ទាមុត ក៏និយាយថាជាទុក្ខ តែសភាពមិនមែនតួខ្លួនមិន ប្រាកដជាក់ច្បាស់ ដូចសេចក្តីងងឹត ដែលដឹងបានលំបាក សេចក្តីមិនទៀង និងសភាពជាទុក្ខអាចប្រាកដទាំង ក្នុងសម័យដែលមាន ឬមិនមានព្រះពុទ្ធត្រាស់ដឹង ឬមិនមានក៏បាន តែសភាពមិនមែនតួខ្លួនប្រាកដបាន កាលមានព្រះពុទ្ធជាម្ចាស់មកត្រាស់ដឹងប៉ុណ្ណោះ សូម្បីតាបស អ្នកមានឫទ្ធិច្រើនដែលជាព្រះពោធិសត្វ ឈ្មោះ**សរភង្គៈ** ជាដើម ក៏សម្តែងធម៌រឿងការមិនទៀង និងសភាពជាទុក្ខ តែមិនអាចសម្តែងដល់រឿងការ មិនមែនតួខ្លួនបាន ព្រោះបើលោកសម្តែងរឿងអនត្តាបាន អ្នកស្តាប់ក៏គួរនឹងសម្រេចធម៌ដូចគ្នា ។ ការសម្តែងរឿងអនត្តានោះ ជាវិស័យរបស់ព្រះសព្វញ្ញូប៉ុណ្ណោះ ដូចនោះ ព្រះអង្គទើបសម្តែងរឿងអនត្តា ផ្គួបជាគូទៅជាមួយ នឹងលក្ខណៈមិនទៀងខ្លះ លក្ខណៈជាទុក្ខខ្លះ ឬលក្ខណៈទាំងពីរយ៉ាងខ្លះ ។

ជាការពិតហើយ លក្ខណៈមិនទៀង និងជាទុក្ខ ដែលតាបសក្រៅព្រះពុទ្ធសាសនា ពោលដល់នោះ ជាត្រឹមតែមិនទៀង និងជាទុក្ខ ដែលសាយដោយសម្មតិបញ្ញត្តិ មិនមែនលក្ខណៈមិនទៀង និងជាទុក្ខ

យ៉ាងពិតប្រាកដ ព្រោះលក្ខណៈមិនទៀង ដែលដឹងថាផ្ទាំង បែកជាប់ដោយសម្មតិបញ្ញត្តិ គឺផ្ទាំង មិនមែនសភាព ដែលដឹងច្បាស់ដោយវិបស្សនាញាណ ព្រោះផ្ទាំងជាវត្ថុដែលមិនមានពិតដោយសភាវៈ សូម្បីការដឹងច្បាស់នូវសេចក្ដីស្លាប់ថា មិនទៀង ក៏ជាការមិនទៀង ដែលលាយដោយសម្មតិបញ្ញត្តិដូចគ្នា ក្រៅពីនោះ សេចក្ដីជាទុក្ខ ដែលឈឺចុកចាប់តាមរាងកាយរបស់មនុស្សទូទៅ ក៏មិនមែនជាសេចក្ដីទុក្ខ ដែលជាទុក្ខលក្ខណៈ ព្រោះជាប់ដោយសម្មតិបញ្ញត្តិគឺយើងឈឺ យើងចុក តាបសមាន**សរភង្គៈ**ជាដើម ដែលមិនដឹងច្បាស់អនិច្ចលក្ខណៈ និងទុក្ខលក្ខណៈយ៉ាងច្បាស់លាស់ ដូចនេះរមែងមិនអាចសម្ដែងដល់ អនត្តលក្ខណៈដែលពិតប្រាកដបាន ។

អនិច្ចលក្ខណៈ និងទុក្ខលក្ខណៈ ដោយបរមត្ថនោះ ជាវត្ថុដែលដឹងច្បាស់បានលំបាក និងបញ្ជូន ផលអ្នកចម្រើនវិបស្សនា អាចឃើញច្បាស់អនត្តលក្ខណៈបានក្នុងពេលមុនមក សូម្បីលក្ខណៈទាំងពីរនោះ ក៏ជាវិស័យរបស់ព្រះសម្មាសម្ពុទ្ធមួយព្រះអង្គប៉ុណ្ណោះ ដូចគម្ពីរមូលដីកាពោលថាៈ

**[១] អនត្តលក្ខណបញ្ញាបនស្ស អញ្ញេសំ អវិសយត្តា អនត្តលក្ខណទីបកានំ អនិច្ចទុក្ខលក្ខណានញ្ច បញ្ញាបនម្បិ អវិសយតា ទស្សិតា ហោតិ ។ [២] ឯវំ បនទុប្បញ្ញាបនតា ឯតេសំ ទុរូបដ្ឋានតាយ ហោតិ ។**

“១. ព្រះអដ្ឋកថាចារ្យ សម្ដែងថា ការណែនាំអនិច្ចលក្ខណៈ និង

ទុក្ខលក្ខណៈ ពិតប្រាកដ ដែលសម្តែងដល់អនត្តលក្ខណៈ មិនមែនជាវិស័យ ព្រោះការណែនាំ អនត្តលក្ខណៈ មិនមែនវិស័យរបស់អ្នកដទៃ ។

២. មយ៉ាងទៀត ការណែនាំបានលំបាកយ៉ាងនេះ រមែងមានបាន ព្រោះលក្ខណៈទាំង ៣ នោះ ប្រាកដបានលំបាក" ។

សេចក្តីនេះ មានន័យថា តាបសក្រៅព្រះពុទ្ធសាសនា និងមិន យល់អនិច្ចលក្ខណៈ និងទុក្ខលក្ខណៈ ដោយបរមត្ថ ទើបមិនអាចណែនាំ អនត្តលក្ខណៈបាន និងក្រៅពីព្រះសម្មាសម្ពុទ្ធហើយ ក៏មិនមាននរណា យល់ត្រៃលក្ខណៈ ដែលពិតប្រាកដ ដោយបរមត្ថបាន ទើបមិនមាន នរណាអាចណែនាំបាន វៀរព្រះពុទ្ធប៉ុណ្ណោះ ការដែលបុគ្គលដទៃពោល ណែនាំត្រៃលក្ខណ៍បានលំបាក ក៏ព្រោះថា ជាសភាវធម៌ ដែលដឹងបាន លំបាកនោះឯង ព្រោះត្រូវឃើញច្បាស់សភាវៈ ដែលមានពិត ឬ លក្ខណៈ ពិសេស ( សភាវលក្ខណៈ ) របស់រូបនាមយ៉ាង ជាក់ច្បាស់មុនទើបនឹង ដឹងច្បាស់ត្រៃលក្ខណ៍បាន ។

អនិច្ចលក្ខណៈ និងទុក្ខលក្ខណៈដែលសម្តែងដល់អនត្តលក្ខណៈ បាននោះ ត្រូវជាលក្ខណៈពិតប្រាកដ ដែលបុគ្គលឃើញច្បាស់ ដោយ វិបស្សនា មិនមែនលក្ខណៈដោយសម្មតិបញ្ញត្តិដែលជាការ បែកធ្លាយ របស់ឆ្នាំង ឬការឈឺចុកចាប់ដោយទូទៅ លក្ខណៈដោយសម្មតិបញ្ញត្តិ ដូចពោលមិនអាចសម្តែង ដល់អនត្តលក្ខណៈបាន ព្រោះមិនមែនបញ្ញា ឃើញជាក់ច្បាស់យ៉ាងពិតប្រាកដ ដូចគម្ពីរអនុដីកាអធិប្បាយថា :

[១] ន ហិ យថាភូតកណ្ណកវេធាទិវសេន លព្ភមានា អនិច្ចទុក្ខតា សត្តានំ ឯកន្តតោ អនត្តតាធិគមហេតុ ហោន្តិ ។ [២] បច្ចយប្បដិពទ្ធអភិណ្ហសម្បដិបីឡនាទិវសេន បន លព្ភមានា ហោន្តិ ។ [៣] តថា ហិ ចក្ខាទីនិ កម្មាទិមហាភូតាទិបច្ចយប្បដិពទ្ធ-វុត្តីនិ [៤] តតោ ឯវ អហុត្វា សម្ភវន្តិ, ហុត្វា បដិវេន្តីតិ អនិច្ចានិ, អភិណ្ហសម្បដិបីឡិតត្តា ទុក្ខានិ ។ ឯវំ ភូតានិ ច អវសវត្តនតោ អនត្តកានីតិ បរិគ្គហោ ឋិតេហិ សមុបចិតញាណសម្ភារេហិ បស្សិតុំ សក្កា ។

“១. ដោយពិតហើយ អនិច្ចលក្ខណៈ និងទុក្ខលក្ខណៈ ដែលប្រាកដ ដោយជាប់ដោយការបែកធ្លាយរបស់ថ្នាំង ឬការចាក់ដោតរបស់បន្ទាជាដើម មិនមែនហេតុ ដែលធ្វើពួកសត្វសម្រេចអនត្តលក្ខណៈបានយ៉ាងពិតប្រាកដ ។

២. តែអនិច្ចលក្ខណៈ និងទុក្ខលក្ខណៈ ដែលប្រាកដជាប់ ដោយហេតុបច្ច័យនិងការកៀប សង្កត់រឿយៗទើបជាហេតុដូចពោល ។

៣. ដូចនឹងឃើញបានថាចក្ខុជាដើម ដំណើរទៅជាប់ក្នុង អតីតមានកម្មជាដើម និងបច្ច័យក្នុងបច្ចុប្បន្នមានមហាភូតរូបជាដើម ។

៤. ដោយហេតុនោះឯង ទើបមិនទៀងព្រោះមិនធ្លាបកើតហើយកើតឡើង កើតឡើងហើយរលត់ទៅ និងជាទុក្ខព្រោះត្រូវបៀតបៀនរឿយៗ ដោយការកើតរលត់ម្យ៉ាង ទៀតអាយតនៈដែលជាយ៉ាងនោះ

មិនមែនខ្លួន ព្រោះមិនទៅក្នុងអំណាច ដូចនោះអ្នកដែលបានសន្សំបញ្ញាត្តមុកស្ថិតនៅក្នុងការកំណត់ដឹងទើបអាចឃើញបាន" ។

សរុបសេចក្តីថា អនិច្ចានុបស្សនាបែងចេញជា២ប្រភេទគឺ

១. បច្ចក្ខញាណ បញ្ញាឃើញច្បាស់ថារូបនាមមិន ទៀងដោយឃើញច្បាស់ការកើតរលត់ ឬការរលត់ទៅប៉ុណ្ណោះក្នុងខណៈ រលឹកដឹងទាន់សភាវធម៌ ដែលប្រាកដផ្លូវទ្វារ ៦ ។

២. អនុមាណញាណ បញ្ញាដែលអនុមានដឹងច្បាស់រូបនាមក្នុងអតីត ឬ អនាគតដែលជាខាងក្រៅ ឬដែលនៅក្នុងលោកទាំងអស់ មានសភាពមិនទៀង ដោយយល់តាមបញ្ញា ដែលឃើញច្បាស់ពីការជំនាញរបស់ខ្លួនហើយ ក្នុងកន្លែងខ្លះ ហៅថា **អន្វយញាណ** គឺបញ្ញាស្របតាមបញ្ញា ឃើញច្បាស់ ។

អនិច្ចានុបស្សនា ទាំង ២ ប្រភេទដោយការឃើញច្បាស់ និងដោយការអនុមានដឹងរមែងផ្តើម កើតឡើងតាំងពីសម្មសនញាណជាដើមទៅ និងមានកម្លាំងចាស់ក្លា បរិបូរណ៍ក្នុងលំដាប់កន្លញាណជាដើម ទៅដោយលះកិលេសដែលប្រកាន់មាំថា ទៀង ដូចប្រាកដ សេចក្តីថា

**អនិច្ចានុបស្សនំ ភាវេន្តោ និច្ចសញ្ញំ បជហតិ ។**

"អ្នកចម្រើនអនិច្ចានុបស្សនា រមែងលះនិច្ចសញ្ញាបាន"

**អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហតិ ។**

"អ្នកដែលឃើញច្បាស់ថា មិនទៀង រមែងកំចាត់សេចក្តីថាទៀង" ។

# ២.ទុក្ខានុបស្សនា

ការអធិប្បាយសេចក្ដីដ៏សេស ក្នុងមហាវិបស្សនាដែលមានទូវ ទុក្ខានុបស្សនាជាដើម នឹងសម្ដែងចំពោះ សេចក្ដីពិសេស ដែលនៅមិនបានពោលទុកក្នុងអនិច្ចាបស្សនា ចំណែកសេចក្ដីដែលមានដោយត្រង់ នឹងមិន ពោលដដែលទៀត ។

អ្នកចម្រើនវិបស្សនា ដែលកំណត់ដឹងសភាវធម៌ ដែលពិតប្រាកដរបស់រូបនាមហើយ ឃើញច្បាស់ថា រូបនាមមានការកើតរលត់បៀតបៀនរឿយៗ បញ្ញាដែលដឹងច្បាស់ថាជា ទុក្ខក្នុងលក្ខណៈនេះ ឈ្មោះថាទុក្ខានុបស្សនាក្នុងរឿងនេះ គប្បីជ្រាបសេចក្ដីដែលទាក់ទងរបស់ ៣ ប្រការ គឺ

**ទុក្ខ** សភាពត្រូវបៀតបៀន គឺ រូបនាមខន្ធ ៥ ដែលកើតរលត់តាមទ្វារ ៦ ដែលត្រូវបៀតបៀន ដោយការកើតរលត់រឿយ ៗ ។

**ទុក្ខលក្ខលក្ខណៈ** លក្ខណៈជាទុក្ខ គឺ ការបៀតបៀន ។

**ទុក្ខានុបស្សនា** ញាណដឹងច្បាស់ថាជាទុក្ខដោយឃើញច្បាស់ការត្រូវបៀតបៀនរបស់រូបនាម ដែលកើតរលត់ ឬ ឃើញច្បាស់ថា គួរខ្លាចជាភ័យគួរខ្ពើមមិនល្អស្អាត ។

មានសេចក្ដីជាប់ទាក់ទងរឿងនេះក្នុងគម្ពីរវិសុទ្ធិមគ្គថា :

**[១] យទនិច្ចំ តំ ទុក្ខន្តិ វចនតោ បន តទេវ ខន្ធបញ្ចកំ ទុក្ខំ ។ តស្មា ។ អភិណ្ហប្បដិបីឡនា។ [២] អភិណ្ហប្បដិបីឡនាការោ ទុក្ខលក្ខណំ ។**

“១. ខន្ធ៥នោះនុ៎ះឯង ឈ្មោះថា សភាពជាទុក្ខ ដូចព្រះពុទ្ធតម្រាស់ថា **យទនិច្ចំ តំ ទុក្ខំ** ( សភាវណាមិនទៀង សភាវនោះជាទុក្ខ ) ព្រោះត្រូវបៀតបៀនរឿយៗ ។

២.លក្ខណៈដែលត្រូវបៀតបៀនរឿយៗ ឈ្មោះថា លក្ខណៈជាទុក្ខ” ។

លក្ខណៈជាទុក្ខបែកចេញជា ៣ ប្រភេទគឺ :

១ ទុក្ខទុក្ខ ទុក្ខពិត គឺលក្ខណៈដែលអត់ធន់បាន ដោយលំបាករបស់ទុក្ខវេទនា ដែលមាននៅខាង ក្នុងកាយនិងចិត្ត សំដៅដល់អាការដែលអត់ធន់បាន ដោយលំបាក មាននៅខាងក្នុងកាយនិងចិត្តក្នុងខណៈដែលសោយអារម្មណ៍ ។

១. វិបរិណាមទុក្ខ ទុក្ខប្រែប្រួល គឺសុខវេទនា ដែលដឹងត្រឹមជាសុខផ្លូវកាយនិងចិត្ត ជាសភាវៈ ដែលប្រែប្រួល មិនតាំងនៅជានិច្ច ។

២. សង្ខារទុក្ខ ទុក្ខប្រចាំសង្ខារ គឺលក្ខណៈដែលត្រូវកើត រលត់បៀតបៀនជានិច្ច ដែលមាននៅ ក្នុងគ្រប់រូបនាម ។

គ្រប់លក្ខណៈ ដែលចាត់ជាត្រៃលក្ខណ៍នោះ ជាលក្ខណៈរបស់សង្ខារដែលមានក្នុងភូមិ ៣ ទាំងអស់ ។

ដូចគម្ពីរមហាដីការបស់វិសុទ្ធិមគ្គពោលថា:

**តីសុ ទុក្ខតាសុ សង្ខារទុក្ខតាវ ព្យាបិនី។**

“ក្នុងបណ្ដាទុក្ខលក្ខណៈទាំង ៣ លក្ខណៈរបស់សង្ខារ ទុក្ខប៉ុណ្ណោះ

គ្របដណ្ដប់នៅក្នុងសង្ខារទាំងអស់”។

អ្នកដែលមិនបានកំណត់ដឹងរូបនាម ដែលកើតរលត់តាមទ្វារទាំង ៦ រមែងមិនឃើញច្បាស់ថា ការកើតរលត់បៀតបៀនរូបនាមជានិច្ចកាលទុក្ខវេទនាកើតឡើង ព្រោះនៅក្នុងឥរិយាបថយ៉ាងណាមួយ៉ាង ដ៏យូរក៏រមែងមិនបានកំណត់ដឹងតាមសេចក្ដីពិតថា ត្រឹមជាសភាវៈអត់ធន់បានដោយលំបាក តែរមែងផ្លាស់ ឥរិយាបថដើម្បីជៀសវាងវេទនាដូចពោលទុក្ខវេទនា ទើបមិនប្រាកដច្បាស់ដល់មនុស្សទូទៅ ព្រោះឥរិយាបថបិតបាំងទុក្ខកាលបុគ្គល មិនបានដឹងច្បាស់លក្ខណៈ ចរបស់ទុក្ខទុក្ខដែលគ្រោតគ្រាតក៏មិនអាចឃើញច្បាស់ លក្ខណៈរបស់វិបរិណាមទុក្ខ និងសង្ខារទុក្ខបាន ។

ចំណែកអ្នកដែលកំណត់ដឹងរូបនាម ដែលកើតរលត់តាទ្វារ ទាំង ៦ រមែងដឹងច្បាស់ថា ការកើតរលត់បៀតបៀនរូបនាមរឿយៗ ដូចនោះគេទើបអាចដឹងច្បាស់ការប្រែប្រួលបាត់ ទៅរបស់សុខ វេទនា ដែលកើតឡើង ក្នុងឥរិយាបថ ដែលសប្បាយ និងដឹងច្បាស់ទុក្ខវេទនាដែលអត់ធន់បានដោយលំបាក ដូចការឈឺចុកចាប់ អស់កម្លាំង ដែលប្រាកដឡើង ដោយសេចក្ដីជាសភាវៈរបស់សង្ខារ ក្នុងខណៈខ្លះអាចកំណត់ដឹង ចិត្តដែលត្រូវការនឹងផ្លាស់ប្ដូរឥរិយាបថ ព្រោះអត់ធន់អង្គុយតទៅមិនបាន និងកំណត់ដឹងអាកប្បកិរិយា ផ្លាស់ប្ដូរឥរិយាបថរួមទៅដល់ការប្រាកដរបស់សុខវេទនា កាលទុក្ខវេទនាស្បើយបាត់ទៅ អ្នក

ដែលដឹងច្បាស់ថារូបនាម ត្រូវការកើតរលត់បៀតបៀនហើយ បដិបត្តិយ៉ាងនេះឈ្មោះថា អ្នកដកចេញនូវឥរិយាបថ ដែលបិទបាំងទុក្ខ និងយល់ទុក្ខលក្ខណៈ យ៉ាងពិតប្រាកដ ព្រោះបានឃើញច្បាស់លក្ខណៈរបស់សង្ខារទុក្ខ ដូចគម្ពីរវិសុទ្ធិមគ្គពោលថាៈ

**ទុក្ខលក្ខណំ អភិណ្ហសម្បដិបីឡនស្ស អមនសិការា ឥរិយាបថេហិ បដិច្ឆន្នត្តា ន ឧបដ្ឋាតិ។**

“ទុក្ខលក្ខណៈ មិនប្រាកដព្រោះឥរិយាបថបិទបាំងទុក្ខ បន្ទាប់ពីមិនបានធ្វើទុកក្នុងចិត្តនូវការបៀត បៀនរឿយៗ” ។

**អភិណ្ហសម្បដិបីឡនំ មនសិកត្វា ឥរិយាបថេ ឧគ្ឃាដិតេ ទុក្ខលក្ខណំ យថាវសរសតោ ឧបដ្ឋាតិ។**

“កាលអ្នកបដិបត្តិធម៌ ធ្វើទុក្ខក្នុងចិត្តនូវការត្រូវបៀតបៀន រឿយៗ ហើយដកចេញនូវឥរិយាបថ ទុក្ខលក្ខណៈ រមែងប្រាកដដោយភាពរបស់ខ្លួនតាមសេចក្តីពិត” ។

ពាក្យពោលក្នុងគម្ពីរអដ្ឋកថាថា “ដកចេញនូវឥរិយាបថ” អាចធ្វើយល់ថាលោកសម្តែងសេចក្តីប្រាកដរបស់ទុក្ខទុកត្រឹមតែម៉្យាង តែលោកសម្តែងសេចក្តីប្រាកដ របស់វិបរិណាមទុក្ខ និងសង្ខារទុក្ខដោយពាក្យពោលថា“ធ្វើទុកក្នុងចិត្តនូវការត្រូវបៀតបៀនរឿយៗ” ទៀតផង ដូចនោះប្រយោគខាងដើម ទើបសម្តែងដល់ការប្រាកដរបស់ទុក្ខទាំង ៣ ប្រភេទ ។

ទុក្ខានុបស្សនា ដោយបរមត្ថ ដែលដឹងច្បាស់ទុក្ខលក្ខណៈ យ៉ាងពិតប្រាកដ រមែងលះកិលេស ដែលប្រកាន់មាំថា ជាសុខ ពោលគឺ អ្នកដែលមិនដឹងច្បាស់រូបនាមថា ជាទុក្ខ រមែងសម្គាល់ខុសថា ជាសុខ ដោយសញ្ញាវិបល្លាស ទិដ្ឋិវិបល្លាស និងចិត្តវិបល្លាស ក្រៅពីនោះ នៅកើតកិលេសដទៃ កុសលកម្ម ឬអកុសលកម្ម និងវិបាកខន្ធ ដែលជាផលកម្ម តែអ្នកដែលឃើញថាជាទុក្ខ រមែងមិនកើតការ សម្គាល់ខុស ជាដើម ក្នុងអារម្មណ៍នោះ ព្រោះទុក្ខានុបស្សនា លះកិលេសដែលប្រកាន់មាំថាជាសុខ ដូចប្រាកដសេចក្តីថា :

**ទុក្ខានុបស្សនំ ភាវេន្តោ សុខសញ្ញំ បជហាតិ ។**

“អ្នកចម្រើនទុក្ខានុបស្សនា រមែងលះសុខសញ្ញាបាន” ។

**ទុក្ខតោ អនុបស្សន្តោ សុខសញ្ញំ បជហាតិ ។**

“អ្នកដែលឃើញច្បាស់ថាជាទុក្ខ រមែងលះសុខសញ្ញាបាន” ។

សរុបសេចក្តីថា ទុក្ខានុបស្សនាចែកចេញជា ២ប្រភេទគឺ

១. បច្ចក្ខញាណ បញ្ញាឃើញច្បាស់ថារូបនាមជាទុក្ខ ដោយដឹងច្បាស់ថាត្រូវបៀតបៀនដោយ ការកើតរលត់ ឬប្រែប្រួលបែកធ្លាយទៅ ឬត្រូវបៀតបៀន ។

២.អនុមាណញាណ បញ្ញាដែលអនុមានដឹងថា រូបនាមក្នុងអតីត ឬអនាគត ដែលជាខាងក្រៅ ឬដែលនៅក្នុងលោកទាំង អស់មានសភាពជាទុក្ខ ដោយយល់តាមបញ្ញា ដែលឃើញច្បាស់ពីការជំនាញ

របស់ខ្លួនហើយ ក្នុងកន្លែងខ្លះហៅថា **អន្វយញាណ** គឺបញ្ញាស្រុបតាមបញ្ញា ឃើញច្បាស់ ។

ទុក្ខានុបស្សនា ទាំង ២ ប្រភេទ ដោយការឃើញច្បាស់ និងដោយការអនុមានដឹង រមែងចាប់ផ្តើមកើតឡើង តាំងតែ**សម្មសនញាណ** ជាដើមទៅ ។

# ៣. អនត្តានុបស្សនា

កាលអ្នកបដិបត្តិធម៌ កំណត់ដឹងរូបនាម ដោយសភាវលក្ខណៈ ហើយ រមែងដឹងច្បាស់ថា រូបនាមមិនប្រព្រឹត្តតាម ដែលខ្លួនត្រូវការ បញ្ញាដែលដឹងច្បាស់ថា ត្រឹមតែជាសភាវធម៌ ដែលកើតរលត់ទៅតាម ហេតុបច្ច័យ មិនមែនតួខ្លួនឈ្មោះថា **អនត្តានុបស្សនា** ។

អត្តាដែលផ្ទុយគ្នាជាមួយនឹងអនត្តា មិនមែនសំដៅដល់តួខ្លួន គឺ រាងកាយដែលជាទីប្រជុំគ្នារបស់ ពួករូបនាមដែលជាបញ្ញត្តិ តែសំដៅដល់ អាត្ម័ន ឬ វិញ្ញាណដែលមនុស្សទូទៅយល់ខុសថា ជាម្ចាស់នៃខន្ធ ( **សាមិ** ) វត្ថុដែលតាំងនៅរហូតកាល ( **និវាសី** ) វត្ថុដែលធ្វើកម្ម ( **ការក** ) វត្ថុ ដែលសោយផលកម្ម ( **វេទនា** ) វត្ថុដែលញ៉ាំងរាងកាយទាំងអស់ និង ចំណែកខ្លះ គឺឥន្ទ្រីយ៍ជាដើម ដំណើរទៅតាមសេចក្តីត្រូវការរបស់ខ្លួន ( **សយំវសី** ) វត្ថុដែលត្រួតត្រារាងកាយឲ្យប្រព្រឹត្តទៅតាមដែលត្រូវការ ( **អធិដ្ឋាយក** ) ដូចពោលទុកហើយក្នុងខាងដើម ។

អត្តាមិនមែនខន្ធ ៥ មិនមាននៅក្នុងខន្ធ ៥ ត្រឹមតែជាបញ្ញត្តិ ដែល មនុស្សទូទៅអ្នកនៅមានទិដ្ឋិ ប្រកាន់មាំថាមានពិត ដូច្នេះខន្ធ ៥ ទើបជា អនត្តាតាមរូបវិគ្រោះថា **ន អត្តា អនត្តា** ( **អនត្តា** គឺ សភាវៈមិនមែន ជាអត្តា ) ឬ មានវិគ្គហៈថា **នត្ថិ អត្តា ឯតេសន្តិ អនត្តា** ( សភាវៈ មិនមែនអត្តា ) ពិតហើយ កាលបើខន្ធ ៥ ជាអត្តា ក៏គួរប្រព្រឹត្តទៅតាម ដែលខ្លួនត្រូវការ នៅក្នុងបង្គាប់បញ្ជា តែមិនបាន ជាយ៉ាងនោះ ទើបជា

អត្តា ចំណែកលក្ខណៈ ដែលមិនប្រព្រឹត្តទៅតាមតម្រូវការ ឈ្មោះថា អត្តលក្ខណៈ ។

អ្នកដែលឃើញច្បាស់ការកើតរលត់របស់ខន្ធ ៥ តាមសេចក្តីពិត រមែងមិនជួបអត្តាដែលជាតួខ្លួន នៅក្នុងសេចក្តីត្រូវការ ទើបដឹងច្បាស់ថា រូបនាម ត្រឹមតែជាសភាវធម៌ មិនមែនអត្តាយ៉ាងណា ញាណដឹងច្បាស់ថា ជាអត្តានេះ ឈ្មោះថា **អនត្តានុបស្សនា** ដូចគម្ពីរវិសុទ្ធិមគ្គពោលថា៖

**[១] យំ ទុក្ខំ តទនត្តាតិ បន វចនតោ តទេវ ខន្ធបញ្ចកំ អនត្តា ។ តស្មា ។ អវសវត្តនតោ ។**

**[២] អវសវត្តនាការោ អនត្តលក្ខណំ ។**

“១. ខន្ធ ៥ នុ៎ះ ពិតណាស់ជាអនត្តា ដូចព្រះតម្រាស់ថា **យំ ទុក្ខំ តទនត្តា** ( សភាវធម៌ណាជាទុក្ខ សភាវធម៌នោះ មិនមែនជាតួខ្លួន ) ព្រោះមិនប្រព្រឹត្តទៅតាមសេចក្តីត្រូវការបាន ។

២. លក្ខណៈដែលមិនប្រព្រឹត្តទៅតាមត្រូវការ ជាលក្ខណៈរបស់អនត្តា ”។

មនុស្សទូទៅ ដែលមិនបានកំណត់ដឹងសភាវធម៌ ដែលប្រាកដតាមទ្វារទាំង ៦ រមែងមិនអាចវែកញែកសភាវធម៌ ដោយខណៈ សភាវៈ នាទី និង អារម្មណ៍បាន តែនិងដឹងច្បាស់ក្នុងលក្ខណៈ ដែលជាក្រុមទាំងមូលជាមួយគ្នា ដូចក្នុងខណៈឃើញរូប គេសម្គាល់ថា ការចង់មើល ការមើលគ្រាដំបូង ការមើលគ្រាតមក និងការពិចារណាកើតឡើងព្រមគ្នា ជំនួស

ពេលដែលនឹងដឹងចំពោះនូវសភាវៈឃើញតែម្យ៉ាង ខណៈនោះចាត់ថាជាឃនបញ្ញត្តិ គឺបញ្ញត្តិអស្រ័យក្រុមបានបិទបាំងសភាវធម៌ ដែលពិតប្រាកដអ្នកដែលមិនបានកំណត់ដឹងយ៉ាងនេះ រមែងមិនអាចយល់អនត្តលក្ខណៈ និង **អនត្តានុបស្សនា** ក៏នឹងមិនប្រាកដដល់គេ ។

ក្នុងករណីផ្ទុយគ្នាអ្នកដែលកំណត់ដឹងសភាវធម៌ ដែលប្រាកដតាមទ្វារទាំង ៦ រមែងអាចវែក ញែកសភាវធម៌នោះ ដោយខណៈ សភាវៈនាទី និង អារម្មណ៍ក្នុងខណៈដែលសតិ សមាធិ និង បញ្ញាមានកម្លាំងចាស់ក្លាឡើង គេមិនដឹងច្បាស់ក្នុងលក្ខណៈដែលជាក្រុមទាំងមូល ដូចក្នុងខណៈឃើញរូប រមែងដឹងច្បាស់ថាមានត្រឹមសភាវៈឃើញប្រាកដហើយរលត់ទៅដោយមិននៅក្នុងអំណាចរបស់ខ្លួន ខណៈនោះ អាចចាត់ថាអាចទម្លាយនូវឃនបញ្ញត្តិ ដែលបិទបាំងសភាវធម៌ អ្នកដែលកំណត់ដឹងយ៉ាងនេះ រមែងយល់អនត្តលក្ខណៈ និង អត្តានុបស្សនាក៏នឹងប្រាកដដល់គេ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :

**អនត្តលក្ខណំ នានាធាតុវិនិព្ភោគស្ស អមនសិការា**

**ឃនេន បដិច្ឆន្នត្តា នបដ្ឋាតិ ។**

“អនត្តលក្ខណៈ មិនប្រាកដព្រោះត្រូវសំណុំបិទបាំងទុក បន្ទាប់ពីមិនបានដឹងច្បាស់ការបែកខ្ចាយ ចេញទៅរបស់ធាតុផ្សេងៗ ដែលរូបធាតុនិងនាមធាតុ” **នានាធាតុយោ វិនិព្ភុជិត្វា ឃនវិនិព្ភោគេ កតេ អនត្តលក្ខណំ អនត្តលក្ខណំ យថាវសរសតោ បដ្ឋាតិ ។**

“កាលបំបែកធាតុផ្សេងៗចេញទៅ ហើយធ្វើការបំបែក សេចក្ដីជាសំណុំ អនត្តលក្ខណៈរមែង ប្រាកដដោយសភាពរបស់ខ្លួន តាមសេចក្ដីពិត” ។

សេចក្ដីជាសំណុំ ដែលបិទបាំងអនត្តលក្ខណៈ ចែកជា ៤ ប្រភេទ គឺ:

១. **សន្តតិឃនៈ** សេចក្ដីជាក្រុមដោយការតភ្ជាប់ សំដៅសេចក្ដីថា រូបនាមជាសភាពកើតឡើង យ៉ាងតភ្ជាប់ មនុស្សទូទៅ ទើបមិនអាចចែកនូវរូប ចែកនាមក្នុងខណៈៗ ចេញពីគ្នា ធ្វើប្រកាន់ខុសជាតួខ្លួន ដែលប្រព្រឹត្តទៅតាមដែលខ្លួនត្រូវការ ព្រោះត្រូវសេចក្ដីជាក្រុម ដូចពោលបិទបាំង សភាវធម៌ទុក ដូចក្នុងខណៈឃើញរូបមនុស្សទូទៅ រមែងសម្គាល់ថា ការចង់មើល ការមើលគ្រាដំបូង ការមើលគ្រាតមក និងការពិចារណាកើតឡើងព្រមគ្នា ទើបធ្វើយល់ខុសថាយើងឃើញបាន មើលបាន តាមសេចក្ដីត្រូវការរបស់ខ្លួន សូម្បីក្នុងខណៈបានឮ ។ល។ រួមទៅដល់ខណៈបត់ លា ដើរ ឈរ អង្គុយ ដេក ជាដើម មនុស្សទូទៅក៏មិនអាចចែករូបចែកនាម ក្នុងមួយខណៈៗចេញពីគ្នាបាន ទើបធ្វើប្រកាន់ខុសថា ជាតួខ្លួនដែលប្រព្រឹត្តទៅតាមដែលខ្លួនត្រូវការ ។

ចំណែកអ្នកដែលឃើញច្បាស់ដោយបញ្ញា សភាវធម៌រមែងយល់យ៉ាង ត្រឹមត្រូវដោយមិនត្រូវបិទបាំងថា អាកប្បកិរិយា ផ្លូវកាយ វាចា និង ចិត្ត សុទ្ធតែជាសភាវធម៌ ដែលកើតតាមហេតុបច្ច័យ មិនមាន

តួខ្លួនយ៉ាងណា ដូចការចង់មើល ជាសភាវៈម្យ៉ាង ការមើលជាម្យ៉ាងទៀត ដូចនេះជាដើម ការយល់ដូចនេះ ជាការដឹងច្បាស់អន្តលក្ខណៈ របស់រូបនាម ដែលប្រាសចាកការតភ្ជាប់ ។

២. **សមូហឃនៈ** សេចក្ដីជាក្រុមដោយកងរូបនាម សំដៅសេចក្ដីមនុស្សទូទៅ រមែងសំគាល់ថា រូបនាមជាក្រុមជាមួយគ្នា មិនអាចវែកញែករូបនាមចេញពីគ្នាបាន ព្រោះត្រូវសេចក្ដីជាក្រុម ដូចពោលបិទបាំងទុក ធ្វើយល់ខុសថា មានតួខ្លួន ដូចក្នុងខណៈបន្ទាបខ្លួនក៏សំគាល់ថា សេចក្ដីចង់នឹងបន្ទាប់ខ្លួន សភាវៈបន្ទាប់ខ្លួនជាមួយគ្នា ក្រៅពីនោះនៅសំគាល់ថា ចក្ខុបសាទជាមួយនឹងរូប ដែលឃើញ សោតបសាទជាមួយនឹងសម្លេងដែលបានឮ ជាយ៉ាងជាមួយគ្នា កាលឃើញដៃរបស់ខ្លួនហើយប៉ះខ្ទប់ ឬប៉ះខ្ទប់ហើយឃើញដៃ ក៏សម្គាល់ថា រូបដៃដែលឃើញ និងរូបដៃ ដែលឃើញ និងរូបដៃក៏ប៉ះខ្ទប់ជាយ៉ាងជាមួយគ្នា ទាំងនៅសម្គាល់ថា ចក្ខុបសាទរូប ដែលជាទីតាំង សភាវឃើញ និងកាយបសាទរូប ដែលជាទីតាំងរបស់សភាវៈប៉ះខ្ទប់ ជាយ៉ាងជាមួយគ្នា ដូចនេះជាដើម សេចក្ដីជាក្រុមដោយកងរូប កងនាម ឬទាំងកងរូបនាម ដែលបុគ្គលសម្គាល់ថា ជាយ៉ាងជាមួយគ្នានេះ ឈ្មោះថា សមូហឃនៈ ជាវត្ថុដែលបិទបាំងអនត្តលក្ខណៈ របស់រូបនាមដល់បុគ្គល អ្នកមិនបាន ចម្រើនវិបស្សនា ។

ចំណែកអ្នកដែលកើតបញ្ញាឃើញច្បាស់សភាវធម៌ រមែងយល់ថា

រូបនិងនាមកើតខណៈនីមួយៗ បំបែកចេញពីគ្នា ដោយជានីមួយៗសុទ្ធ ដូចចិត្តដែលត្រូវការទឹងបន្ទាបខ្លួន ឬសណ្តូកកើតឡើង មុនសភាវបន្ទាបខ្លួន ឬ សណ្តូក ទាំងពីរយ៉ាងជាខណៈនីមួយៗ បំបែកចេញពីគ្នា បើមិនមានចិត្តដែលត្រូវការ នឹងបន្ទាបខ្លួន ឬសណ្តូក សភាវៈបន្ទាបខ្លួន ឬសណ្តូករមែងកើតឡើងមិនបាន កាលកំណត់ដឹងថា ឡើងប៉ោងហ្ន៎...សភាវៈឡើងប៉ោងជាយ៉ាងនីមួយៗ ជាមួយនឹងចិត្ត ដែលកំពុងកំណត់ដឹង បើមិនមានសភាវៈឡើងប៉ោង ចិត្តដែលកំណត់ដឹង ក៏កើតឡើងមិនបាន ក្រៅពីនោះក្នុងខណៈកំណត់សភាវៈឃើញ បានឮ និងប៉ះខ្ទប់ យ៉ាងតភ្ជាប់ រមែងយល់ថា រូបដែលឃើញ សម្លេងដែលបានឮ ការប៉ះខ្ទប់សម្ផស្សដែលទទួលដឹង ជាយ៉ាង នីមួយៗបំបែកចេញពីគ្នា ទាំងនៅយល់ថាចក្ខុបសាទរូបដែលជាទីតាំងសភាវៈឃើញ និងកាយបសាទរូបដែលជាទីតាំងរបស់សភាវៈប៉ះខ្ទប់ ជាយ៉ាងនីមួយៗ បំបែកចេញពីគ្នា សភាវៈឃើញ ( **ចក្ខុវិញ្ញាណ** ) ការប៉ះ ខ្ទប់រវាងរូប និងការឃើញ ( **ផស្សៈ** ) និងការយល់ថាល្អ ឬមិនល្អដែលកើតពីការឃើញ ( **វេទនា** ) ក៏ជាយ៉ាងនីមួយៗ បំបែកចេញពីគ្នា ដូចនេះជាដើម គេរមែងយល់ថា អាកប្បកិរិយាផ្លូវកាយ វាចា និងចិត្តសុទ្ធតែជាសភាវធម៌ ដែលកើតតាមហេតុបច្ច័យ មិនមានតួខ្លួនយ៉ាងណា ការយល់ដូចនេះ ជាការឃើញច្បាស់នូវអនត្តលក្ខណៈ របស់រូបនាម ដែលប្រាសចាកសេចក្តីជាក្រុម ។

៣. **កិច្ចឃនៈ** សេចក្តីជាក្រុមដោយនាទី មានន័យថា រូបនាម

និមួយៗ មាននាទីផ្សេងគ្នា តាមសភាវៈនោះៗ តែមនុស្សទូទៅ រមែង សំគាល់ថា រូបនាមជាប្រភេទតែមួយ ដែលមាននាទីដូចគ្នា ព្រោះត្រូវ សេចក្តីជាក្រុមដូចពោលបិទបាំងទុក្ខ ធ្វើយល់ខុសថាមានតួខ្លួន ដូចក្នុង ខណៈឃើញ ចក្ខុបសាទធ្វើនាទីប៉ះខ្ទប់រូប ចក្ខុវិញ្ញាណធ្វើនាទីឃើញ រូបធ្វើនាទីត្រូវឃើញដូចនេះជាដើម តែអ្នកដែលមិនបានចម្រើនវិបស្សនា រមែងយល់ឃើញថារូបនាមជាប្រភេទតែមួយ ទើបមានតួខ្លួនដែលឃើញ បានឮ ។ល។ ពិតហើយ នាទីរបស់រូបនាមជាច្បាប់ធម្មជាតិ ដែលដំណើរទៅតាមគន្លងប្រក្រតី ដូច :

-**ចក្ខុវិញ្ញាណ** ធ្វើនាទីឃើញ ។

-**សោតវិញ្ញាណ** ធ្វើនាទីបានឮ ។

-**ឃានវិញ្ញាណ** ធ្វើនាទីដឹងក្លិន ។

-**ជិវ្ហាវិញ្ញាណ** ធ្វើនាទីភ្លក្សរស់ ។

-**កាយវិញ្ញាណ** ធ្វើនាទីប៉ះខ្ទប់សម្ផស្ស ។

-**មនោវិញ្ញាណ** ធ្វើនាទីនឹកគិតរឿងរ៉ាវផ្សេងៗ ។

-**សុខវេទនា** ធ្វើនាទីញ៉ាំងចិត្តរីករាយ ។

-**ទុក្ខវេទនា** ធ្វើនាទីញ៉ាំងចិត្តសៅហ្មង ។

-**ឧបេក្ខាវេទនា** ធ្វើនាទីញ៉ាំងចិត្តព្រងើយ គឺមិនសុខមិនទុក្ខ ។

-ចិត្តដែលត្រូវការនឹងបន្ទាបខ្លួន ធ្វើនាទីបង្កឲ្យកើតរូប ដែលកម្រើកដោយសភាវៈបន្ទាបខ្លួន ។

-រូបដែលបន្ទាបខ្លួន ធ្វើនាទីកម្រើកចូលរកវាផកាយ ។

ចំណែកអ្នកដែលកើតបញ្ញាដឹងច្បាស់សភាវៈធម៌ រមែងយល់យ៉ាង ត្រឹមត្រូវដោយមិនត្រូវបិទបាំងថា រូបនាមម្យ៉ាងៗ មាននាទីផ្សេងគ្នា ការយល់ដូចនេះ ជាការឃើញច្បាស់អនត្តលក្ខណៈ របស់រូបនាម ដែលជាយ៉ាងនីមួយៗ បំបែកចេញពីគ្នា ដោយនាទីថា សភាវធម៌ម្យ៉ាងមិនអាចធ្វើនាទីម្យ៉ាងទៀតបាន ។

**៤.អារម្មណាយនៈ** សេចក្តីជាក្រុមដោយអារម្មណ៍ មានន័យថា នាមធម៌មួយៗ មានអារម្មណ៍ផ្សេងគ្នា តាមសភាវៈធម៌នោះៗ តែមនុស្សទូទៅ រមែងសំគាល់ថា នាមធម៌មានអារម្មណ៍ដូចគ្នា ព្រោះត្រូវសេចក្តីជាក្រុមដូចពោលបិទបាំងទុក្ខ ធ្វើយល់ខុសថា មានតួខ្លួនដែលមានអារម្មណ៍ដូចគ្នាជា យើងម្នាក់ដែលឃើញ បានឮ ។ល។ ដូចចក្ខុវិញ្ញាណទទួលរូបជាអារម្មណ៍ ចិត្តដែលឃើញទើបមិនមែនចិត្ត ដែលបានឮ ឬ ចិត្តដែលឃើញពណ៌ស មិនមែនចិត្តដែលឃើញពណ៌ខ្មៅ ចិត្តដែលឃើញពណ៌ខ្មៅមិនមែនចិត្ត ដែលឃើញពណ៌ស ឬចិត្តដួងដំបូងដែលឃើញមិនមែនចិត្តដួងតមកដែលឃើញ ។

ចំណែកអ្នកដែលកើតបញ្ញាដឹងច្បាស់សភាវធម៌ រមែងយល់យ៉ាងត្រឹមត្រូវដោយមិនត្រូវបិទ បាំងថា នាមធម៌នីមួយៗមានអារម្មណ៍ផ្សេងគ្នា ការយល់ដូចនេះ ជាការដឹងច្បាស់អនត្តលក្ខណៈរបស់នាម ថាមានអារម្មណ៍ផ្សេងគ្នា ដូចចិត្តដែលត្រូវការនឹងមើល ចិត្តដែលកំណត់ដឹងថា

“ចង់មើលហ្ន” ចិត្តដែលឃើញនឹងចិត្តដែលកំណត់ដឹងថា “ឃើញហ្ន៎” យ៉ាងណានីមួយ បំបែកចេញពីគ្នា ការយល់ដូចនេះ ជាការដឹងច្បាស់អនត្តលក្ខណៈរបស់នាម ដែលជាយ៉ាងនីមួយ បំបែកចេញអំពីគ្នាបាន ដោយអារម្មណ៍ ។

ពាក្យអធិប្បាយខាងដើម ពោលតាមសេចក្តីក្នុងគម្ពីរមហាដីកា របស់វិសុទ្ធិមគ្គថា :

[១] យា ហោសា អញ្ញមញ្ញបត្ថទ្ធេសុ សម្ពន្ធិតេសុ រូបារូបធម្មេសុ ឯកត្តាភិនិវេសវសេន អបរិមទ្ទិតសង្ខារេហិ គយ្ហមានា សមូហឃនតា, តថា តេសំ តេសំ ធម្មានំ កិច្ចភេទស្ស សតិបិ បដិនិយតភាវេ ឯកតោ គយ្ហមានា កិច្ចឃនតា, តថា សារម្មណធម្មានំ សតិបិ អារម្មណករណភេទេ ឯកតោ គយ្ហមានា អារម្មណឃនតា ច, [២] តា ធាតូសុ ញាណេន វិនិព្ភុជិត្វា ទិស្សមានាសុ ហត្ថេន បរិមជ្ជិយមានោ ផេណបិណ្ឌោ វិយ វិលយំ គច្ឆន្តិ, [៣] យថាបច្ចយំ បវត្តមានា សុញ្ញា ឯតេ ធម្មា ធម្មមត្តាតិ អនត្តលក្ខណំ ចាកដតរំ ហោតិ ។

“១.ដោយពិតហើយ បញ្ញាពួកណា គឺ :

-សេចក្តីជាសំណុំ ដោយក្រុមរូបនាម ( សមូហឃនបញ្ញត្តិ ) ដែលបុគ្គលអ្នកនៅមិនបានដឹងច្បាស់នូវសង្ខារ ទទួលដឹងដោយយល់ថា តែម្យ៉ាងដូចគ្នាក្នុងរូបធម៌ និងនាមធម៌ដែលកើតរួមគ្នា និងបត្ថម្ភគ្នា និងគ្នា ។

-សេចក្តីជាក្រុមដោយនាទី ( **កិច្ចឃនបញ្ញត្តិ** ) ដែលបុគ្គលទទួលដឹងដោយយល់ថាជាយ៉ាងជាមួយគ្នា សូម្បីសភាវធម៌នោះៗ នឹងមាននាទីផ្សេងគ្នាយ៉ាងពិតប្រាកដ ។

-សេចក្តីជាក្រុមដោយអារម្មណ៍ ( **អារម្មណឃនបញ្ញត្តិ** ) ដែលបុគ្គលទទួលដឹងដោយយល់ថា ជាយ៉ាងជាមួយគ្នា សូម្បីសភាវធម៌ដែលទទួលអារម្មណ៍នោះៗ និងមានការទទួលអារម្មណ៍ផ្សេងគ្នា ។

២. បញ្ញត្តិទាំងនោះរមែងសូន្យទៅ កាលបុគ្គលដឹងច្បាស់ធាតុដោយបំបែកចេញដោយបញ្ញាដូច ពពុះទឹកដែលប៉ះខ្ទប់ដៃ ។

១. លក្ខណៈរបស់អនត្តារ មែងប្រាកដច្បាស់ថាធម៌ គឺរូបនាមទាំងនេះ ត្រឹមតែជាសភាវធម៌ ដែលសូន្យចាកតួខ្លួន ដែលដំណើរទៅតាមហេតុបច្ច័យ” ។

***អនត្តានុបស្សនា*** ដែលលះសេចក្តីជាក្រុម ដោយសេចក្តីតភ្ជាប់ ( ដោយខណៈ ) ក្រុមរូបនាម ( ដោយសភាព ) នាទី និងអារម្មណ៍ដូចនេះ រមែងយល់ថា មានត្រឹមតែសភាវធម៌ ដែលបែកជារូបនាម មិនមានតួខ្លួន យើង របស់យើង និងអាចលះអត្តសញ្ញាជាដើមបាន ពោលគឺអ្នកដែលមិនដឹងច្បាស់រូបនាម តាមសេចក្តីពិត រមែងកើតសញ្ញាវិបល្លាសដែលសម្គាល់ខុសថា មានតួខ្លួនរួមដល់ទិដ្ឋិវិបល្លាស និងចិត្តវិបល្លាសគេរមែងធ្វើកម្ម ដែលជាបុណ្យ ឬបាប ដោយអំណាចរបស់វិបល្លាសហើយនឹងកើតវិបាក ខន្ធដែលជាផលកម្មតមក ក្នុងករណីដូយគ្នា អ្នក

ដែលឃើញថាជាអនត្តា រមែងមិនកើតការសម្គាល់ខុសថា ដើមក្នុងអារម្មណ៍ ព្រោះអនត្តានុបស្សនាលះសញ្ញាវិបល្លាសជាដើម ទៅរហូតដល់ទុក្ខសង្សារវដ្ត ដែលមាន ខន្ធប្ចាំក្នុងកពតទៅ ដូចប្រាកដសេចក្តីថា:

**អនត្តានុបស្សនំ ភាវេន្តោ អត្តសញ្ញំ បជហាតិ។**

"អ្នកចម្រើន អនត្តានុបស្សនា រមែងលះអត្តសញ្ញាបាន" ។

**អនត្តតោ អនុបស្សន្តោ អត្តសញ្ញំ បជហាតិ ។**

"អ្នកដែលឃើញច្បាស់ថា ជាអត្តា រមែងលះអត្តសញ្ញាបាន" ។

សរុបសេចក្តីថា អនត្តានុបស្សនាបែងចេញជា២ ប្រភេទគឺ:

**១. បច្ចក្ខញាណ** បញ្ញាឃើញច្បាស់ថារូបនាម ត្រឹមតែជាសភាវធម៌ មិនមែនអត្តាតួខ្លួន ក្រោយ ពីយល់ថា រូបនាមដែលប្រាកដតាមទ្វារ ទាំង ៦ មិនទៀង ជាទុក្ខ ឬបង្គាប់បញ្ជាមិនបាន ។

**២. អនុមានញាណ** បញ្ញាដែលអនុមានដឹងថា រូបនាមក្នុងអតីត ឬអនាគត ដែលជាខាងក្រៅ ឬដែលនៅក្នុងលោកទាំងអស់មានសភាព មិនមែនតួខ្លួនដោយយល់តាមបញ្ញាដែលឃើញច្បាស់ពីការជំនាញរបស់ខ្លួនហើយ ក្នុងកន្លែងខ្លះហៅថា **អន្វយញាណ** គឺបញ្ញាដែលស្របតាម បញ្ញាឃើញច្បាស់ ។

អនត្តានុបស្សនា ទាំង ២ ប្រភេទដោយការឃើញច្បាស់ និង ដោយការអនុមានដឹង រមែងចាប់ផ្តើមកើតឡើងតាំងពី សម្មសនញាណ ជាដើមទៅ នឹងមានកម្លាំងចាស់ក្លាបរិបូណ៌ក្នុងខណៈភង្គញាណជាដើមទៅ ។

ម្យ៉ាងទៀត អនិច្ចានុបស្សនាដែលដឹងច្បាស់ការ មិនទៀងនោះ ចែកជា ២ លក្ខណៈគឺ :

១.ការដឹងច្បាស់សភាវៈកើតឡើង តាំងនៅ និងរលត់ទៅ ក្នុងពេលតែខណៈមួយៗ ។

២. ការដឹងច្បាស់សភាវៈកើតឡើងនិងរលត់ទៅ មានសេចក្តីទាក់ទងរឿងនេះ ក្នុងគម្ពីរមហាដីការបស់វិសុទ្ធិមគ្គពោលថា:

**វិសេសតោ ធម្មានំ ខណិកនិរោធេ អនិច្ចតា វោហារោតិ ឧស្សន្នោ ហុត្វា អភាវោ វាតិ អាទិមាហំ។**

“ព្រះអដ្ឋកថាចារ្យទឹងសម្តែងថា ឈ្មោះថាអនិច្ចលក្ខណៈ រមែងមានក្នុងការរលត់ទៅមួយខណៈ របស់សភាវធម៌ដោយចំពោះ ទើបពោលថា ***ហុត្វា អភាវោ វា*** ( ឬលក្ខណៈប្រែប្រួលដែលហៅថា ការកើតឡើងហើយរលត់ទៅ ) ជាដើម” ។

**អនិច្ចតោ តាវ អនុបស្សន្តោ ភង្គានុបស្សកស្ស យុត្តា ភង្គោ ឆាម អនិច្ចតាយ បរមា កោដីតិ ។**

“ធម្មតាថា ការរលត់ជាទីបំផុតរបស់សេចក្តីមិនទៀងដូចនោះ ការដឹងច្បាស់ថាមិនទៀងទើបគួរសមដល់អ្នកឃើញច្បាស់ការរលត់” ។

ក្នុងអនិច្ចលក្ខណៈទាំងពីរនេះ លក្ខណៈក្រោយជាការ រលត់ទៅរបស់រូបនាមក្នុងបច្ចុប្បន្នដែល ហៅថា ភង្គខណៈ ចាត់ជាអនិច្ចលក្ខណៈដែលប្រាកដច្បាស់បំផុតដូនោះ អនិច្ចានុបស្សនា ទើបកើតឡើង ដល់អ្នក

ដែលសម្រេចកន្ត្ដញាណជាដើមហើយ ដោយការឃើញ ការរលត់ទៅរបស់រូបនាមដែលកើតរលត់រឿយៗ ក្រៅពីនោះ ទុក្ខានុបស្សនាក៏ប្រាកដដល់គេ ដែលយល់ថារូបនាមជាទុក្ខ ដែលមិនគួរពេញចិត្ត ព្រោះត្រូវសេចក្ដីកើតរលត់បៀតបៀន ឬជាទុក្ខព្រោះសាបសូន្យបែកធ្លាយទៅមិនមែនជាសុខដែលគួរ ពេញចិត្ត និងអនត្តានុបស្សនារមែងប្រាកដក្នុងខណៈយល់ថាមិនអាចឃុំឃាំង រូបនាមទៀង និងជាសុខ ដែលជាថាវរៈបាន ។

តាមដែលពោលមកហើយនេះ អនុបស្សនា ៣ ប្រការ រមែងប្រាកដតាមសមគួរដល់ អ្នកឃើញច្បាស់ការរលត់ទៅ របស់រូបនាមក្នុងបច្ចុប្បន្ន ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :

**[១] តត្ថ យស្មា ភង្គោ នាម អនិច្ចតាយ បរមា កោដិ, [២] តស្មា សោ ភង្គានុបស្សកោ យោគាវចរោ សព្វំ សង្ខារគតំ អនិច្ចតោ អនុបស្សតិ, នោ និច្ចតោ ។ [៣] តតោ អនិច្ចស្ស ទុក្ខត្តា, ទុក្ខស្ស អនត្តត្តា តទេវ ទុក្ខតោ អនុបស្សតិ, នោ សុខតោ ។ អនត្តតោ អនុបស្សតិ, នោ អត្តតោ ។**

“១.ក្នុងរឿងនោះ

អ្នកប្រាជ្ញសេចក្ដីព្យាយាមដែលដឹងច្បាស់ការរលត់ទៅ ទើបដឹងច្បាស់សង្ខារទាំងពួងថាមិនទៀង មិនមែនឃើញថាទៀង ។

៣. ក្រោយពីនោះ រមែងឃើញច្បាស់ជាទុក្ខ មិនមែនឃើញថាជាសុខ និងឃើញច្បាស់ថា មិនមែនតួខ្លួន មិនមែនឃើញថាជាតួខ្លួន ព្រោះសភាពមិនទៀងជាទុក្ខ និងទុក្ខក៏ជាអនត្តា” ។

# ៤. និព្វិទានុបស្សនា

និព្វិទានុបស្សនា ក៏គឺនិព្វិទាញាណដែលពោលទុកបន្ទាប់អំពីអាទីនវញាណ ក្នុងបរិច្ឆេទទី៦ រមែងប្រាកដដល់អ្នកដែលឃើញច្បាស់ការរលត់ទៅរបស់រូបនាមក្នុងបច្ចុប្បន្ន ខណៈនោះៗឃើញដឹងត្រឹម ថា រូបនាម គួរខ្លាច និងមានទោសទើបកើតការនឿយណាយ រូបនាមដែលខ្លួនឃើញច្បាស់ការរលត់ទៅនោះ ។

អ្នកដែលឃើញច្បាស់តាមសេចក្តីពិត ដោយអនុបស្សនានេះ រមែងសម្គាល់ថា រូបនាមគួរត្រេកត្រអាល ទើបកើតការត្រេកត្រអាល ដែលហៅថាតណ្ហាដែលកើតរួមជាមួយបីតិ ( **សប្បីតិកតណ្ហា** ) បញ្ចូនផលឲ្យកើតកិលេសកម្មនិងវិបាកខន្ធ ដែលជាផលកម្មតមក ដោយអាស្រ័យការត្រេកត្រអាលជាហេតុ តែការត្រេកត្រអាលជាដើមនោះ រមែងត្រូវកំចាត់បានដោយអនុបស្សនានេះ ក្នុងខណៈឃើញសង្ខារថា គួរនឿយណាយ ដូចគម្ពីរវិសុទ្ធិមគ្គ និងមហាដីកាពោលថា :

និព្វិទានុបស្សនំ ភាវេន្តោ នន្ទឹ បជហាតិ ។

“អ្នកចម្រើននិព្វិទានុបស្សនា រមែងលះការត្រេកត្រអាលបាន”។

[១] និព្វិទានុបស្សនា យាតិ សង្ខារេសុ និព្វិន្ទនាការេន

បវត្តាយ អនុបស្សនាយ ។ [២] នន្ទិតោតិ សប្បីតិកតណ្ហាតោ ។

"១.ពាក្យថា **និព្វិទានុបស្សនាយ** ( ដោយនិព្វិទានុបស្សនា ) មានន័យថា ដោយអនុបស្សនា ដែលដំណើរទៅ ដោយលក្ខណៈនឿយណាយ ក្នុងសង្ខារទាំងឡាយ ។

២. ពាក្យថា **នន្ទិតោ** ( ពីការត្រេកត្រអាល ) មានន័យថា ( ដោះចិត្តចេញ ) ពីតណ្ហាដែលកើតរួមជាមួយបីតិ" ។

# ៥.វិរាគានុបស្សនា

អ្នកចម្រើនវិបស្សនា ដែលនឿយណាយរូបនាម ដោយនិព្វិទាញាណហើយ រមែងប្រាសចាកតម្រេក ក្នុងរូបនាម ដែលឃើញច្បាស់ ការរលត់ទៅនោះចិត្តរបស់គេ រមែងបង្អោនចិត្តទៅកាន់ព្រះនិព្វាន ដែលរលត់រូបនាម ដូចគម្ពីរវិសុទ្ធិមគ្គនិងមហាដីកាអធិប្បាយថា :

**[១] ខយវិរាគោតិ សង្ខារានំ ខណភង្គោ ។ [២] អច្ចន្តវិរាគោតិ និព្វានំ ។ [៣] វិរាគានុបស្សនាតិ តទុភយទស្សនវសេន បវត្តា វិបស្សនា ច មគ្គោ ច ។**

"១. ពាក្យថា **ខយវិរាគោ** ( ការសូន្យអស់ទៅ ) អធិប្បាយបានថា ការរលត់ទៅក្នុងគ្រប់ខណៈ របស់សង្ខារទាំងឡាយ ។

២. **អច្ចន្តវិរាគោ** ( ការអស់ទៅយ៉ាងក្រៃលែង ) គឺព្រះនិព្វាន ។

៣. ពាក្យថា **វិរាគានុបស្សនា** ( ការឃើញច្បាស់ សេចក្តីប្រាសចាកតម្រេក ) គឺ វិបស្សនា និងមគ្គ ដែលប្រព្រឹត្តទៅដោយការឃើញវិរាគៈទាំងពីរនោះ" ។

**វិរាគានុបស្សនាយាតិ តថា វិរជ្ជនាការេន បវត្តាយ អនុបស្សនាយ ។**

"ពាក្យថាវិរាគានុបស្សនា ( អនុបស្សនា ដែលឃើញច្បាសនូវសេចក្តីប្រាសចាកតម្រេក ) អធិប្បាយបានថា **អនុបស្សនា** ដែលប្រព្រឹត្តទៅដោយលក្ខណៈ ប្រាសចាកតម្រេកដូចយ៉ាងនោះ" ។

សេចក្តីខាងដើមមានន័យថា ការអស់ទៅសូន្យទៅ របស់កងសង្ខារ ដែលកំណត់ដឹងឈ្មោះថា **ខយវិរាគៈ** វិបស្សនាដែលកំណត់ដឹងឈ្មោះថា ទទួលយកការអស់ទៅជាអារម្មណ៍ ចំណែកព្រះនិព្វាន ដែលរលត់សង្ខារទាំងអស់ឈ្មោះថា **អច្ចន្តវិរាគៈ** តែវិបស្សនា មិនអាចទទួលដឹងព្រះនិព្វានជាអារម្មណ៍បាន ដោយត្រង់យ៉ាងណាក៏ដោយ **មុញ្ចិតុកម្យតាញាណ** មានសភាពត្រូវការនឹងផុតទៅអំពីសង្ខារ និងបង្អោនទៅកាន់ព្រះនិព្វាន ដូច្នោះ ទើបឈ្មោះថា ឃើញព្រះនិព្វាន ដោយអម ជាការបង្អោនទៅកាន់ព្រះនិព្វាន ដោយហេតុនេះ **មុញ្ចិកម្យតាញាណ** ទើបបានឈ្មោះថា **វិរាគានុបស្សនា** ព្រោះឃើញច្បាស់វិរាគៈទាំងពីរយ៉ាងនោះ សូម្បីមគ្គញាណ ក៏បានឈ្មោះថា **វិរាគានុបស្សនា** ព្រោះទទួលដឹងព្រះនិព្វានជាអារម្មណ៍ ដោយត្រង់ នឹងឃើញច្បាស់ការអស់ទៅសូន្យទៅ

របស់សង្ខារ ដោយនាទី ដែលមិនសង្ស័យ ក្នុងទីនេះសំដៅយកមុញ្ចិតុកម្យ-តាញាណថា ជាវិរាគានុបស្សនា ព្រោះនៅក្នុងរឿងការចែកវិបស្សនាផ្នែកលោកិយ: ។

អ្នកដែលសម្រេចកង្គញាណទៅហើយ អាចដឹងច្បាស់ការរលត់ទៅរបស់សង្ខារបានជាក់ច្បាស់ រមែងយល់ថា សង្ខារមិនទៀង ជាទុក្ខ មិនមែនតួខ្លួន បញ្ញាដែលកើតឡើងក្នុងខណៈនោះ ដែលមានលក្ខណៈនឿយណាយឈ្មោះថា **និព្វិទានុបស្សនា** ចំណែកបញ្ញា ដែលមានលក្ខណៈប្រាសចាកតម្រេកឈ្មោះថា **វិរាគានុបស្សនា** ដូចនោះ អ្នកបដិបត្តិធម៌ ទើបមិនគួរបរិកម្មក្នុងចិត្តថាគួរនឿយណាយៗ ឬប្រាសចាកតម្រេកៗ តែដឹងត្រឹមតែដល់សភាវៈនឿយណាយ ឬប្រាសចាកតម្រេក ក្នុងសង្ខារដែលប្រាសចាកត្រៃលក្ខណ៍យ៉ាងពិតប្រាកដ ។

## ៦. និរោធានុបស្សនា

និរោធានុបស្សនា គឺបញ្ញាដឹងច្បាស់ការរលត់ទៅ ជាមុញ្ចិតុកម្យ-តាញាណ ដែលមានកម្លាំងចាស់ ក្លាដែលត្រូវការនឹងកំណត់សង្ខារ ដែលបានឃើញច្បាស់ការរលត់ទៅ មនុស្សទូទៅ ដែលមិនបានឃើញច្បាស់ការរលត់ទៅ ព្រមដោយការកំណត់សង្ខារ រមែងនឹងកើតសង្ខារក្នុងភពថ្មីតទៅដោយជាប់ដោយសង្ខារ ដែលខ្លួនមិនបានឃើញច្បាស់ តាមសេចក្តីពិត តែកាលឃើញច្បាស់ការរលត់ទៅ ដោយ**និរោធានុបស្សនា**ហើយ សង្ខារក្នុងភពថ្មី ក៏មិនកើតឡើងការកំណត់ដឹងដើម្បីមិនសង្ខារកើតឡើង

ក្នុងភពថ្មីនេះ ជាការធ្វើសង្ខាររលត់ទៅ ដូចពាក្យអធិប្បាយ ក្នុងគម្ពីរមហាដីកាវិសុទ្ធិមគ្គថា:

**[១] និរោធានុបស្សនាយាតិ សង្ខារានំ និរោធស្ស អនុបស្សនាយ ។ [២] យថា សង្ខារា និរុជ្ឈន្តិយេវ, អាយតឹ បុនព្ភវវសេន ឧប្បជ្ជន្តិ, ឯវំ វា អនុបស្សនា និរោធានុបស្សនា ។ [៣] មុញ្ចិតុកម្យតា ហិ អយំ ពលប្បត្តា ។**

"១.ពាក្យថា **និរោធានុបស្សនា** ( បញ្ញាឃើញច្បាស់ការរលត់ទៅ ) គឺបញ្ញាឃើញច្បាស់ការរលត់ ទៅរបស់សង្ខារទាំងឡាយ ។

២. ន័យម្យ៉ាងទៀត គឺបញ្ញាឃើញច្បាស់ដោយសង្ខារ រលត់ទៅ មិនកើតឡើងទៀតដោយសេចក្ដីជាភពថ្មី ។

៣. ពិតហើយ អនុបស្សនានេះ ក៏គឺជា**មុញ្ចិតុកម្យតាញាណ** ដែលសម្រេចការចាស់ក្លា" ។

ពាក្យថា **និរោធានុបស្សនា** មានន័យ ២ ប្រការគឺ :

-បញ្ញាឃើញច្បាស់ការរលត់ទៅ ឬបញ្ញាឃើញច្បាស់ការរលត់ទៅ ⇨=និរោធស្ស អនុបស្សនា និរោធានុបស្សនា (កម្មឆដ្ឋីតប្បុរិសសមាស) ឬ និរោធតោ អនុបស្សនា និរោធានុបស្សនា ( បញ្ចមីតប្បុរិសសមាស) ។

បញ្ញាឃើញច្បាស់ ដើម្បីឲ្យសង្ខាររលត់ទៅ ឬបញ្ញាឃើញច្បាស់ដែលញុំាងសង្ខាររលត់ទៅ = និរោធាយ អនុបស្សនា និរោធានុបស្សនា (ចតុត្ថីតប្បុរិសសមាស)ឬ និរោធេតីតិ និរោធោ និរោធោ ច សោ អនុបស្សនា

**ជាតិ និរោធានុបស្សនា (វិសេសនបុព្វបទកម្មធារយសមាស)។**

*សេចក្តីតាមន័យ ដំបូងថា "បញ្ញាឃើញច្បាស់ការរលត់ទៅ" និងតាមន័យ ទី ២ ថា "បញ្ញាឃើញច្បាស់ ដើម្បីឲ្យសង្ខាររលត់ទៅ" ដែលពោលទុកក្នុងគម្ពីរដីកានេះ ស្របគ្នាជាមួយនឹងពាក្យអធិប្បាយរបស់* ***និរោសព្ទ*** *ក្នុងពាក្យថា* ***និរោធានុបស្សី*** *ដែលពោលទុកក្នុងគម្ពីរអដ្ឋកថារឿង****អានាបានកថា*** *។*

*ម្យ៉ាងទៀត ក្នុងគម្ពីរវិសុទ្ធិមគ្គ បានអធិប្បាយសេចក្តីអំពីគម្ពីរបដិសម្ភិទាមគ្គថា* **និរោធេតិ នោ សមុទេតិ ។ និរោធេន្តោ សមុទយំ បជហាតិ***( រមែងញុំាងរាគៈរលត់ទៅ រមែងមិនរាគៈកើតឡើង របស់រាគៈបាន ) ដូចនេះថា :*

**[១] សោ ឯវំ អរជ្ជន្តោ លោកិកេនេវ តាវ ញាណេន រាគំ និរោធេតិ, នោ សមុទេតិ ។ សមុទយំ ន ករោតីតិ អត្ថោ ។ [២] អថ វា សោ ឯវំ វិរត្តោ យថា ទិដ្ឋំ សង្ខារគតំ តថា អទិដ្ឋម្បិ អន្វយញាណវសេន និរោធេតិ ។ នោ សមុទេតិ ។ និរោធតោវ មនសិករោតិ, និរោធមេវស្ស បស្សតិ, នោ សមុទយន្តិ អត្ថោ ។**

*"១. កាលអ្នកបដិបត្តិធម៌នោះ មិនកំណត់យ៉ាងនេះក៏ធ្វើរាគៈក្នុងសង្ខារ រលត់ទៅ ដោយញាណថ្នាក់លោកិយ៍មុន មានន័យថា ធ្វើមិនកើតឡើង។*

*៣. ន័យម្យ៉ាងទៀត លោកជាអ្នកប្រាសចាកតម្រេកយ៉ាងនេះហើយ*

៤. រមែងកំណត់ដឹងការរលត់ទៅក្នុងសង្ខារ ក្នុងបច្ចុប្បន្ន ដែលខ្លួនឃើញហើយ មិនកំណត់ដឹងថាការកើតឡើង ដោយញាណ ដែលស្របតាមញាណ ដែល ឃើញច្បាស់ ដូច្នោះ សេចក្ដីសម្គាល់ ក៏គឺជាការកំណត់ដឹងថារលត់ទៅ តែម្យ៉ាង គឺឃើញតែការរលត់តែម្យ៉ាង របស់សង្ខារនោះ មិនឃើញនូវ ការកើត” ។

ពាក្យថា និរោធេតិ មានន័យ ២ ប្រការគឺ :

-រលត់ទៅ = **និ បទមុខ+រុធធាតុ** =រលត់ទៅ+**ណេ ការិត បច្ច័យ+តិ វិភត្តិ** ។

-កំណត់ដឹងការរលត់ទៅ= **និ បទមុខ+និរោធស័ព្ទ+ណេ បច្ច័យ ឬ ឥបច្ច័យក្នុងន័យថា កំណត់ ដឹង+តិ វិភត្តិ** ។

តាមគោលភាសាចុះ **ណេបច្ច័យចុងនាមធាតុ គឺ និរោធ សព្ទដោយ ច សព្ទ** ក្នុងសូត្ររបស់ កច្ចាយនវេយ្យាករណ៍ ( សូត្រ ៤៣៩ ) ថា **រូបេ នាមស្មា ណយោ ច** ( កាលមានរូបធាតុចុះណយបច្ច័យចុង **នាមសព្ទ និងតាំងឈ្មោះថា ការិតបច្ច័យ** ) **ឬចុះ ឥបច្ច័យ**ដោយសូត្រក្នុងមោគល្លានវេយ្យាករណ៍ ( **បរិច្ឆេទ ទី៥ សូត្រ ១២ ) ថា ធាត្វត្ថេ នាមស្មិ ( ចុះ ឥបច្ច័យចុងនាមសព្ទក្នុងអត្ថ របស់ធាតុ) ។**

សូម្បីក្នុងអដ្ឋកថា នឹងសម្ដែងសេចក្ដីសំដៅ របស់និរោធានុបស្សនា ទុក ២ ន័យ តែមិនបានសំដៅ សេចក្ដីថាមាន ២ យ៉ាង ពិតហើយ មានត្រឹមតែម្យ៉ាង គឺ មុញ្ចិតុកម្យតាញាណ ដែលមានកម្លាំងចាស់ក្លា

ពោល គឺតាមន័យដំបូង ពោលថា រលត់រាគៈដោយមិនបញ្ជាក់ថា ជាការចម្រើនធម៌ណាដោយវិធីណា ទើបនឹងធ្វើរាគៈរលត់និងមិនបានបញ្ជាក់ថា រាគៈដែលនឹងត្រូវលះនោះ កើតក្នុងចិត្តដួងណា ត្រឹមតែជាកំណត់ដឹងសេចក្ដីរលត់របស់សង្ខារ ដែលជាបច្ចុប្បន្ន អតីត និង អនាគត ហើយលះរាគៈដែលវង្វេងប្រតោង ភ្ជាប់ក្នុងសង្ខារទាំងនោះអស់ទៅ ម្យ៉ាងដូចគ្នាជាមួយន័យទី ២ នោះឯង ។

ន័យទី ២ លោកមិនបញ្ជាក់ថា នឹងត្រូវធ្វើកិលេសណារលត់ទៅ ត្រឹមតែរាគៈរលត់ទៅដូច ដែលសម្ដែងទុកហើយក្នុងន័យទី ១ កាលបើបុគ្គលបានកំណត់ដឹងនូវការរលត់របស់សង្ខារហើយ រាគៈដែលប្រតោងភ្ជាប់ក្នុងសង្ខារ ក៏មិនកើតឡើង ដូចនោះន័យទី ២ ទើបមានន័យដូចគ្នាជាមួយន័យទី ១ ដែរ ការពោលថា ធ្វើរាគៈរលត់នៅសំដៅ សេចក្ដីដល់ការធ្វើកិលេសដទៃ កម្មដែលមានរាគៈជាមូលហេតុ និងវិបាកខន្ធ ដែលជាផលកម្មរលត់ចុះផង ដូចនោះន័យទី ១ និង ទី ២ ដែលពោលទុកក្នុងគម្ពីរដីកាខាងដើមទើបស្របជាមួយន័យទី ២ និងទី ១ របស់គម្ពីរអដ្ឋកថាដែលនាំមកសម្ដែងទុកនោះ ។

សរុបសេចក្ដីថា **និរោធានុបស្សនា** បែងចេញជា ២ ប្រភេទគឺ :

១.បច្ចក្ខញាណ បញ្ញាឃើញច្បាស់ថារូបនាម ក្នុងបច្ចុប្បន្នរលត់ទៅរូបនាមត្រឹមតែជាសភាវធម៌ មិនមែនជាអត្តាតួខ្លួន ក្រោយពីយល់ថារូបនាម ដែលប្រាកដតាមទ្វារទាំង ៦ មិនទៀង ជាទុក្ខ ឬបន្ដាប់បញ្ជា

មិនបាន ។

២. អនុមានញាណ បញ្ញាដែលអនុមានដឹងថារូបនាម ក្នុងអតីត ឬអនាគតរលត់ទៅដូចរូបនាម ក្នុងបច្ចុប្បន្ន ដោយយល់តាមបញ្ញា ដែលឃើញច្បាស់ពីការជំនាញរបស់ខ្លួនហើយ រមែងកើតឡើងកាល បច្ចក្ខញាណមានកម្លាំងចាស់ក្លា ក្នុងកន្លែងខ្លះហៅថា **អន្វយញាណ** គឺបញ្ញាស្របតាមបញ្ញាឃើញច្បាស់ ។

មានសេចក្ដីទាក់ទងជាមួយរឿយនេះក្នុងគម្ពីរវិសុទ្ធិមគ្គថា:

**[១] យថា ទិដ្ឋំ សម្បតិ ឧបដ្ឋិតំ សង្ខារគតំ និរោធេតិ, និរោធំ មនសិករោតិ , [២] ឯវំ អទិដ្ឋម្បិ អតីតានាគតំ អន្វយញាណវសេន យថា ឥទំ ឯតរហិ, ឯវំ ឥតរេបីតិ អនុមិនន្តោ និរោធេតិ, មនសិកតស្សាបិ និរោធំ មនសិករោតិ ។**

“១. អ្នកបដិបត្តិធម៌ រមែងកំណត់ដឹងថា រលត់ទៅក្នុងកងសង្ខារ ដែល ប្រាសចាកក្នុងបច្ចុប្បន្ន ដែលខ្លួនឃើញហើយយ៉ាងណា ។

២. រមែងអនុមានកំណត់ដឹងសង្ខារ ដែលជាអតីត និងអនាគត ដែលខ្លួនមិនបានឃើញហើយថា រលត់ទៅ គឺធ្វើទុកក្នុងចិត្ត ការរលត់ទៅរបស់កងសង្ខារ ដែលខ្លួនធ្វើទុកក្នុងចិត្តថា សូម្បីសង្ខារ ដទៃក៏រលត់ ទៅដូចកងសង្ខារនេះក្នុងបច្ចុប្បន្ន ដូច្នោះ” ។

ម្យ៉ាងទៀត អាចពោលបានថា វិភាគានុបស្សនាជា មុញ្ចិតុកម្យ-

តាញាណ យ៉ាងទន់ខ្សោយ ( តរុណវិបស្សនា ) ព្រោះគម្ពីរមហាដីកាខាងដើមបញ្ជាក់ថា និរោធានុបស្សនា ជាមុញ្ចិតុកម្យតាញាណ យ៉ាងចាស់ក្លា ( ពលវវិបស្សនា ) ក្រៅពីនោះការលះរាគៈជាដើម ដែលគួរកើតឡើងក្នុងសង្ខារ ដែលកំណត់ដឹងដោយអនុមានញាណ ជាការលះបង់ ដោយវិក្ខម្ភនបហាន ព្រោះបុគ្គលមិនអាចកំចាត់អនុស័យ ដែលដេកត្រាំហើយ ឬនឹងដេកត្រាំក្នុងរូបនាមផ្នែកអតីត ឬអនាគត ដែលមិនឃើញច្បាស់បានដោយវិបស្សនាថ្នាក់លោកិយ៍ តែកំចាត់បានដោយមគ្គញាណ ថ្នាក់លោកុត្តរៈប៉ុណ្ណោះ ដូចគម្ពីរមហាដីការបស់វិសុទ្ធិមគ្គពោលថា:

**[១] រាគំ និរោធេតីតិ រាគំ វិក្ខម្ភននិរោធំ ធាបេតិ ។ [២] សាវិក្ខម្ភេតីតិ អត្ថោ ។**

“១. ពាក្យថា **រាគំ និរោធេតិ** ( ធ្វើរាគៈរលត់ ) មានន័យថា ធ្វើរាគៈដល់ការរលត់ដោយ ឃុំគ្រងទុក ។

២. សំដៅសេចក្តី គឺឃុំគ្រងរាគៈទុក” ។

## ៧. បដិនិស្សគ្គានុបស្សនា

ពាក្យអធិប្បាយ អនុបស្សនានេះ ប្រាកដក្នុងគម្ពីរមហាដីកា វិសុទ្ធិមគ្គថា

**[១] សង្ខារានំ បដិនិស្សជ្ជនាការេន បវត្តា អនុបស្សនា បដិនិស្សគ្គានុបស្សនា ។ [២] បដិសង្ខា សន្តិដ្ឋនា ហិ អយំ ។**

"១. បញ្ញាឃើញច្បាស់ដែលដំណើរទៅ ដោយលក្ខណៈលះបោលសង្ខារ កិលេសដែលសម្គាល់ ថាទៀង ជាសុខ ជាតួខ្លួន ឈ្មោះថា បដិនិស្សគ្គានុបស្សនា ។

២. ដែលពិតហើយ បដិនិស្សគ្គានុបស្សនា ជាបដិសង្ខារញាណ ដែលកំណត់ដឹងទៀត និងសង្ខារុបេក្ខាញាណដែលព្រងើយ" ។

សេចក្តីថា "បញ្ញាដឹងច្បាស់ ដែលដំណើរទៅ ដោយលក្ខណៈលះបោលសង្ខារ" ជាសំនួន ដែលពោល ដោយអម ( **នេយ្យត្ថ** ) មិនមែនសេចក្តី ដែលពោល ដោយត្រង់ ( **នីតត្ថ** ) ព្រោះសំដៅដល់ បញ្ញាឃើញច្បាស់ទីដំណើរទៅ ដោយការលះបោលកិលេស ដែលចសម្គាល់ថា ទៀង ជាសុខ ជាតួខ្លួន ដូចព្រះពុទ្ធតម្រាស់ថា:

**[១] រូបំ ភិក្ខវេ ន តុម្ហាកំ ។ តំ បជហាថ ។ [២] តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ ។**

"១. ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នក ចូរលះរូបនោះ ។

២. រូបដែលអ្នកលះបានហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ សុខរហូតអស់រាត្រីយូរ" ។

សូម្បីព្រះពុទ្ធវចនៈខាងដើម នឹងត្រាស់ដល់ការលះរូប តែរូប មិនមែនធម៌ ដែលគួរលះ ធម៌ដែលគួរលះគឺ ឆន្ទរាគៈ ដែលអាស្រ័យរូប កើតឡើង ដូចនោះការលះរូប ទើបជាការលះឆន្ទរាគៈ ដូចពោល ។

សេចក្តីដែលជួបក្នុងព្រះត្រៃបិដក បែកជាពីរប្រភេទគឺ :

១. **នីតត្ថៈ** សេចក្ដីដោយត្រង់ ដូច **រូបំ អនិច្ចំ** ( រូបមិនទៀង ) **វេទនា អនិច្ចា** ( វេទនាមិនទៀង ) ២. **នេយ្យត្ថៈ** សេចក្ដីដោយអម ដូច **រូបំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ ។ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ** ( ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់អ្នក ចូរលះរូបនោះ រូបដែលអ្នកលះបាន ហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍សុខរហូតរាត្រីដ៏យូរ ) ពាក្យថា **តំ** ( រូបនោះ ) ជាសេចក្ដីដោយអម ព្រោះរូបជាទុក្ខសច្ចៈ ដែលរាប់ចូលក្នុងបរិញ្ញេយ្យធម៌ គឺធម៌ដែលគួរកំណត់ដឹង តែក្នុងទីនេះសំដៅដល់រាគៈ ដែលកើតឡើងដោយអាស្រ័យរូប ការប្រើពាក្យក្នុងលក្ខណៈនេះ ជាសំនួនផ្សំភាសា ដែលហៅថា **ឋានូបចារៈ**គឺសេចក្ដីសម្គាល់ការកំបាំង ដែលបានពីពាក្យសំដែងទីកន្លែង ក្នុងភាសាបាលីមានការប្រើភាសាលក្ខណៈម្យ៉ាង ដែលអ្នកនិយាយពោលដល់ទីកន្លែងតែចេតនាសំដៅដល់ អ្នកដែលនៅក្នុងទីកន្លែងនោះ ដូច **សព្វោ គាមោ អាគតោ** តាមរូបពាក្យហើយប្រែថា "ស្រុកទាំងអស់មក" តាមប្រក្រតីហើយស្រុកមកមិនបាន សំដៅសេចក្ដីដែលពិតរបស់ប្រយោគនេះ ក៏គឺ "អ្នកស្រុកទាំងអស់មក" ក្នុងភាសាខ្មែរមានការប្រើពាក្យលក្ខណៈនេះដូចគ្នា តួយ៉ាងដូច "សាលាកាត់ក្ដី" ពាក្យថាសាលាជាកន្លែង នឹងជាអ្នកកាត់ក្ដីមិនបាន អ្នកកាត់ក្ដីដែលពិតប្រាកដ គឺអ្នកពិភាក្សាដែលជាអ្នកនៅត្រង់សាលា ក្នុងទីនេះជាការពោលដល់រូប ដែលជាទីតាំងរបស់រាគៈតែចេតនាសំដៅដល់រាគៈ ដែលអាស្រ័យរូបកើតឡើង ។

ឧបមាថា អ្នកដែលត្រូវការនឹងកាត់កាលពីបុត្រអាក្រក់ថោកទាប ដែលបង្កទុកគ្រួសារ កាលអាចកាត់ចិត្តបានថា គេមិនមែនកូនរបស់យើងហើយ ក៏នឹងលះសេចក្តីទុក្ខក្នុងចិត្ត ដែលកើតពីបុត្ររបស់ខ្លួនបាន ក្នុងទំនងជាមួយគ្នាកាលអ្នកបដិបត្តិធម៌ ឃើញច្បាស់ត្រៃលក្ខណ៍ តាមសេចក្តីពិតហើយ លះកិលេស ដែលប្រកាន់មាំថា ទៀង ជាសុខ ជាតួខ្លួនក្នុងសង្ខារបាន ក៏រាប់ថាបានលះសង្ខារទៅផង ក្នុងគម្ពីរដីកាទើបពោលថា សេចក្តីក្នុងព្រះសូត្រ ជាសំនួនផ្លូវកាសាយ៉ាងណាក៏ដោយ ក្នុងគម្ពីរវិសុទ្ធិមគ្គពោលដល់ការលះកិលេស ដោយត្រង់ថា :

**[១] អយម្បិ អនិច្ចាទិអនុបស្សនា តទង្គប្បហានវសេន សទ្ធិំ ខន្ធាភិសង្ខារេហិ កិលេសានំ បរិច្ចជនតោ, សង្ខតទោសទស្សនេន ច តព្ពិបរីតេ និព្ពានេ តន្និន្នតាយ បក្ខន្ទនតោ "បរិច្ចាគបដិនិស្សគ្គោ ចេវ បក្ខន្ទនបដិនិស្សគ្គោ ចា"តិ វុច្ចតិ ។ [២] តស្មា តាយ សមន្នាគតោ ភិក្ខុ យថាវុត្តេន នយេន កិលេសេ ច បរិច្ចជតិ, និព្ពានេ ច បក្ខន្ទតិ ។ នាបិ និព្វត្តនវសេន កិលេសេ អាទិយតិ, ន អទោសទស្សិតាវសេន សង្ខតារម្មណំ ។ [៣] តេន វុច្ចតិ "បដិនិស្សជ្ជតិ នោ អាទិយតី"តិ។**

"១. សូម្បីបញ្ញាឃើញច្បាស់ការមិនទៀងជាដើម នេះក៏ហៅថា ការរលាស់ចោលទៅ ដោយការលះព្រោះលះកិលេសព្រមទាំងខន្ធ និង អភិសង្ខារ ( កម្ម ) ដោយតទង្គបហាន ( លះមួយគ្រា ) និងហៅថា ការរលាស់ចោលទៅ ដោយការរត់ចូលទៅ ព្រោះរត់ចូលទៅក្នុងព្រះនិព្វាន

ដែលផ្ទុយគ្នាជាមួយនឹងសង្ខតធម៌ ដោយការបង្អោនទៅក្នុងព្រះនិព្វាននោះ ដោយការឃើញទោសរបស់សង្ខតធម៌ គឺព្រះត្រៃលក្ខណ៍ ។

២. ដូចនោះ ភិក្ខុអ្នកប្រកបដោយបញ្ញាឃើញច្បាស់នោះ ទើបលះកិលេស និងរត់ចូលទៅក្នុងព្រះនិព្វានដោយន័យ ដូចពោលហើយ ទាំងមិនប្រកបភ្ជាប់កិលេសទុក ដោយការធ្វើកើតទៀតមិនប្រកាន់ ភ្ជាប់អារម្មណ៍

របស់សង្ខតធម៌ ដោយសេចក្ដីជាអ្នកមិនឃើញទោស ។

៣. ដូច្នោះ ទើបពោលទុក ក្នុងគម្ពីរបដិសម្ភិទាមគ្គថា **បដិនិស្សជ្ជតិ នោ អាទិយតិ** ( រលាស់ចោលទៅ មិនប្រកាន់ភ្ជាប់ទុក )" ។

សេចក្ដីខាងដើម អធិប្បាយបានថា វិបស្សនាញាណទាំងពីរ គឺ **បដិសង្ខាញាណ** និង**សង្ខារុបេក្ខាញាណ** ឈ្មោះថា **បដិនិស្សគ្គានុបស្សនា** ( បញ្ញាឃើញច្បាស់ការលះចោល ) ព្រោះលះកិលេស និងព្រោះរត់ចូលទៅក្នុងព្រះនិព្វាន ដោយការបង្អោនទៅក្នុងព្រះនិព្វាននោះ ដោយពាក្យថា **បដិនិស្សគ្គ** ( រលាស់ចោល ) សំដៅដល់ការលះវត្ថុ ដែលមិនត្រូវការ ឬការបណ្ដោយទៅកាន់ទីដែលខ្លួន ត្រូវការបែបដំបូង ជាការរលាស់ចោលទៅដោយការលះ ( **បរិច្ចាគបដិនិស្សគ្គ** ) បែបខាងក្រោយ ជាការរលាស់ចោលដោយការរត់ចូលទៅ ( **បក្ខន្ទនបដិនិស្សគ្គ** ) ។

ការរលាស់ចោលដោយការលះ គឺការលះកិលេស ដែលប្រកាន់មាំថា **ទៀង ជាសុខ ជាតួខ្លួន** ក្នុងសង្ខារដែលកំណត់ដឹង ទាំងលះ

កុសលកម្ម និងអកុសលកម្ម ដែលមានកិលេសជាហេតុ ព្រមដោយវិបាកខន្ធ ដែលផលកម្ម ដោយតទង្គបហាន ។

ការលះបង់ចោល ដោយការរត់ចូលទៅ គឺការបង្អោនទៅកាន់ព្រះនិព្វាន ដែលមានសភាពទៀង ជាសុខ ជាបរមត្ថ ដែលផ្ទុយគ្នាជាមួយនឹងសង្ខារវិបស្សនាញាណទាំងពីរ នេះឃើញទោសរបស់សង្ខារ ដូចមនុស្សដែលឃើញភ័យក្នុងទីកន្លែងណាមួយ ហើយត្រូវការនឹងទៅកាន់កន្លែងដទៃ ។ ម្យ៉ាងទៀតការបង្អោនទៅកាន់ព្រះនិព្វាន ត្រឹមតែជាសេចក្ដីត្រូវការនឹងរលត់សង្ខារ មិនមែនការទទួលយកព្រះនិព្វានជា អារម្មណ៍ ។

សេចក្ដីថា "ទាំងមិនប្រកាន់ភ្ជាប់កិលេសទុកដោយការធ្វើកើតទៀត" អធិប្បាយបានថា កាលបុគ្គលមិនឃើញច្បាស់ព្រះត្រៃលក្ខណ៍ កិលេសរមែងមានឱកាសកើតឡើងក្នុងអារម្មណ៍ ដែលមិនបានដឹងច្បាស់ត្រៃលក្ខណ៍ និងកាលកិលេសមានឱកាសកើតឡើង បុគ្គលក៏ឈ្មោះថា ប្រកាន់ភ្ជាប់នូវកិលេស ធ្វើឲ្យកើតកិលេស ចំណែកអ្នកបដិបត្តិធម៌ ដែលឃើញច្បាស់ត្រៃលក្ខណ៍ហើយ រមែងមិនឱកាសឲ្យកើតកិលេសក្នុងអារម្មណ៍បច្ចុប្បន្ន ដែលខ្លួនកំពុងកំណត់ដឹង ទើបមិនឈ្មោះថា ប្រកាន់ ភ្ជាប់កិលេសធ្វើឲ្យកើតកិលេស ព្រោះកិលេសមិនបានឱកាសកើតឡើងទេ ។

សេចក្ដីថា "មិនប្រកាន់ភ្ជាប់អារម្មណ៍ របស់សង្ខតធម៌ ដោយការៈជាអ្នកមិនឃើញទោស" អធិប្បាយបានថា អ្នកដែលមិនឃើញទោសមានសេចក្ដីមិនទៀងជាដើម រមែងឈ្មោះថា ទទួលយកសង្ខារ ជាអារម្មណ៍

ដើម្បីការប្រកាន់មាំ ដោយកិលេសក្នុងគ្រប់ខណៈ ដែលគិតដល់សង្ខារធម៌ ចំណែកអ្នកដែលឃើញច្បាស់ត្រៃលក្ខណ៍ហើយ រមែងឃើញទោសដូច ពោលទើឈ្មោះថា មិនប្រកាន់ភ្ជាប់អារម្មណ៍របស់សង្ខតធម៌ ព្រោះមិន ប្រកាន់មាំ ដោយកិលេស ។!

# មហាវិបស្សនា ១៨ រាប់ចូលក្នុងអនុបស្សនា ៧

កាលអនុបស្សនា ៧ ផ្ដើមតាំងពីអនិច្ចានុបស្សនារហូតដល់ បដិនិស្សគ្គានុបស្សនាប្រាកដបរិបូរណ៍ហើយវិបស្សនា ១០ ប្រការដែល នឹងពោលតទៅក៏ប្រាកដបរិបូរណ៍ទៅផង ដូចពោលទុកក្នុងគម្ពីរ អដ្ឋកថា ច្រើនកន្លែងថា " អ្នកចម្រើនវិបស្សនា គួរចម្រើនវិបស្សនា ៧" សូម្បីក្នុង គម្ពីរបដិសម្ភិទាមគ្គ ២ ក៏ពោលដល់អនុបស្សនា ៧ ទុកច្រើនកន្លែង ។

ក្រៅពីនោះ បើអនុបស្សនា ៣ គឺ **អនិច្ចានុបស្សនា ទុក្ខានុបស្សនា** និង**អនត្តានុបស្សនា** ប្រាកដ បរិបូរណ៍ដល់អ្នកចម្រើនវិបស្សនាហើយ **និព្វិទានុបស្សនា វិរាគានុបស្សនា និរោធានុបស្សនា** និង **បដិនិស្សគ្គា-នុបស្សនា** រមែងប្រាកដបរិបូរណ៍បានឯង ដូចនោះ ព្រះអង្គទើបរមែង បញ្ជាក់ការចម្រើន អនុបស្សនា៣ខាងដើម ដូចសេចក្ដីក្នុងគម្ពីរមហាដីកា របស់វិសុទ្ធិមគ្គថា:

**សត្តធា អដ្ឋារសធាតិអាទិនា វិភត្តាបិ ហិ អនុបស្សនាបការា អនិច្ចានុបស្សនាទីស្វេវ តីសុ អន្តោគធាតិ មត្ថកប្បត្តា វិបស្សនា តាសំ ឯវ វសេន តិដ្ឋតិ ។**

*“ដែលពិតហើយ ប្រភេទរបស់អនុបស្សនាដែលចែកជា ៧ និង ១៨ ប្រការខាងដើម រមែងរាប់ ចូលក្នុងអនុបស្សនា ៣ មានអនិច្ចានុបស្សនាជាដើម ដូចនោះ អនុបស្សនា ដែលសម្រេចដល់សេចក្តីប្រសើរ បំផុតទើបស្ថិតនៅដោយ ជាប់ដោយអនុបស្សនា ៣ នោះឯង” ។*

*សេចក្តីនេះអធិប្បាយបានថា សូម្បីវិបស្សនានឹងពោល ចែកបានច្រើន ជាអនុបស្សនា ៧ មហាវិបស្សនា ១៨ វិបស្សនា ៤០ ជាដើម ក៏អាចរាប់ចូលក្នុងអនុបស្សនា ៣ គឺ អនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា បើចម្រើនអនុបស្សនា ៣យ៉ាងបរិបូរណ៍ វិបស្សនាដទៃទាំងអស់ ក៏ជាការបរិបូរណ៍ទៅផង ដូចនោះ វិបស្សនាដែលដល់ការប្រសើរបំផុតទើបតាំងនៅ ដោយការឃើញច្បាស់ការមិនទៀង ជាទុក្ខ មិនមែនតួខ្លួន ដូចសេចក្តីក្នុងគម្ពីរបដិសម្ភិទាមគ្គថា:*

**[១] យា ច អនិច្ចានុបស្សនា យា ច អនិមិត្តានុបស្សនា, ឥមេ ធម្មា ឯកត្ថា, ព្យញ្ជនមេវ នានំ ។ [២] យា ច ទុក្ខានុបស្សនា យា ច អប្បណិហិតានុបស្សនា, ឥមេ ធម្មា ឯកត្ថា, , ព្យញ្ជនមេវ នានំ ។ [៣] យា ច អនត្តានុបស្សនា យា ច សុញ្ញតានុបស្សនា, ឥមេ ធម្មា ឯកត្ថា, ព្យញ្ជនមេវ នានំ ។**

*“១. អនុបស្សនាទាំងនេះ គឺអនិច្ចានុបស្សនា និង អនិមិត្តានុប-ស្សនា មានសភាពដូចគ្នា ផ្សេងគ្នាត្រឹមតែសព្ទ ។*

*២. អនុបស្សនាទាំងនេះ គឺទុក្ខានុបស្សនា និង អប្បណិហិតានុប-*

ស្សនា មានសភាពដូចគ្នាតែម្យ៉ាងផ្សេងគ្នាត្រឹមស័ព្ទ ។

៣. អនុបស្សនាពួកនេះ គឺអនត្តានុបស្សនា និងសុញ្ញតានុបស្សនា មានសភាពដូចគ្នាតែម្យ៉ាង ផ្សេងគ្នាត្រឹមតែស័ព្ទ" ។

ដោយហេតុនេះ កាលអនិច្ចានុបស្សនាប្រាកដបរិបូរណ៍ហើយ អនិមិត្តានុបស្សនាក៏ប្រាកដ បរិបូរណ៍កាលទុក្ខានុបស្សនាប្រាកដបរិបូរណ៍ កាលអនត្តានុបស្សនាប្រាកដបរិបូរណ៍ហើយ សុញ្ញតានុបស្សនាក៏ប្រាកដ បរិបូរណ៍ ។

ម្យ៉ាងទៀត កាលបើអនុបស្សនា ៣ ប្រាកដបរិបូរណ៍ហើយ អធិបញ្ញាធម្មវិបស្សនា គឺបញ្ញាឃើញ ច្បាស់ធម៌ដែលជាអធិបញ្ញា បញ្ញាដឹងច្បាស់ការរលត់ទៅរបស់អារម្មណ៍បច្ចុប្បន្ន និងវិបស្សនាចិត្ត ដែលកំណត់ដឹងអារម្មណ៍នោះ ហើយយល់សេចក្ដីសោះសូន្យជាដើម ដោយអំណាចកន្លញាណ រមែងប្រាកដ បរិបូរណ៍ចំណែកបញ្ញា ឃើញច្បាស់តាមសេចក្ដីពិត ( **យថាភូតញ្ញាណទស្សនៈ** ) រមែងប្រាកដមុន ព្រោះជាហេតុរបស់អនុបស្សនាទាំងនោះ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :

**[១] អធិបញ្ញាធម្មវិបស្សនា បន សព្វាបិ វិបស្សនា ។ [២] យថាភូតញ្ញាណទស្សនំ កង្ខាវិតរណវិសុទ្ធិយា ឯវ សង្គហិតំ ។**

"១. អធិបញ្ញាធម្មវិបស្សនា ក៏គឺវិបស្សនាទាំងពួង ។

២. បញ្ញាឃើញច្បាស់តាមសេចក្ដីពិត ក៏រាប់ចូលក្នុង កង្ខាវិតរណវិសុទ្ធិនោះឯង" ។

ចំណែកវិបស្សនាដ៏សេស ១០ ប្រការទៀត ក៏គប្បីជ្រាបថា កាលអនិច្ចានុបស្សនាប្រាកដបរិបូរណ៍ ហើយ និរោធានុបស្សនា **ខយា-នុបស្សនា វយានុបស្សនា** និង**វិបរិណាមានុបស្សនា** ក៏ប្រាកដបានទៀតផង កាលទុក្ខានុបស្សនាប្រាកដបរិបូរណ៍ហើយ និព្វិទានុបស្សនា វិរាគានុបស្សនា និងអាទីនវានុបស្សនាក៏ប្រាកដបាន ដូចគម្ពីរមហាដីការបស់វិសុទ្ធិមគ្គថា:

**[១] អនិច្ចានុបស្សនាយ ហិ សិទ្ធាយ និរោធានុបស្សនា ខយានុបស្សនា វយានុបស្សនា វិបរិណាមានុបស្សនា ច ឯកទេសេន សិទ្ធា នាម ហោន្តិ ។ [២] ទុក្ខានុបស្សនា សិទ្ធាយ និព្វិទានុបស្សនា វិរាគានុបស្សនា អាទីនវានុបស្សនា ច ។ [៣] អនត្តានុបស្សនាយ សិទ្ធាយ ឥតរា ។**

"១. ដោយពិតហើយ កាលអនិច្ចានុបស្សនាប្រាកដបរិបូរណ៍ហើយ និរោធានុបស្សនា ខយានុបស្សនា វយានុបស្សនា និង វិបរិណាមានុបស្សនា ឈ្មោះថា ប្រាកដជាចំណែកខ្លះ ។

២. កាលទុក្ខានុបស្សនាប្រាកដបរិបូរណ៍ហើយ **និព្វិទានុបស្សនា វិរាគានុបស្សនា** និង**អាទីនវានុបស្សនា** ឈ្មោះថា ប្រាកដជាចំណែកខ្លះ ។

៣.កាលអនត្តានុបស្សនាប្រាកដបរិបូរណ៍ហើយ បដិនិស្សគ្គានុបស្សនា **បដិសង្ខានុបស្សនា** និង**វិវដ្តានុបស្សនា** ឈ្មោះថា ប្រាកដជាចំណែកខ្លះ" ។

សេចក្ដីថា "ប្រាកដជាចំណែកខ្លះ" សំដៅដល់ការប្រាកដរបស់អនុបស្សនា ចំណែកខ្លះក្នុងលំដាប់ សម្មសនញាណ តែក្នុងលំដាប

កន្តញាណ ជាដើមទៅ អនុបស្សនារមែងប្រាកដបរិបូរណ៍ ។

ក្នុងគម្ពីរមហាដីការបស់វិសុទ្ធិមគ្គ ច្បាប់ស៊ីករឹតច្រើនច្បាប់ មិនជួប វិរាគានុបស្សនាក្នុងរឿង ទុក្ខានុបស្សនា តែគិតជាគង់នឹងធ្លាក់ទៅពីការ ចារស៊ីករឹតតៗគ្នាមក ព្រោះវិរាគានុបស្សនាពោលទុកក្នុង គម្ពីរបដិសម្ភិទាមគ្គ ថាលះកាមុបាទាន ដូច**ទុក្ខានុបស្សនា** មិនបានពោលថាលះ**ទិដ្ឋុបាទាន សីលព្វតុបាទាន** និង**អត្តវាទុបាទាន**ដូចអនត្តានុបស្សនា ដូចនោះ វិរាគា-នុបស្សនា ទើបគួរចាត់ចូលក្នុងក្រុមទុក្ខានុបស្សនា ដែលមានការលះកិលេស មួយគូជាមួយគ្នា ។

អនុបស្សនាទាំង ៣ គឺ អនិច្ចានុបស្សនា ទុក្ខានុបស្សនា និង អនត្តានុបស្សនា រមែងប្រាកដបរិបូរណ៍ ដោយការឃើញច្បាស់សេចក្តី រលត់ទៅរបស់រូបនាម ដែលកំណត់ដឹងក្នុងវេលា ដែលញាណឃើញ ច្បាស់សេចក្តីរលត់ចាស់ក្លាប៉ុណ្ណោះ ដូចសេចក្តីក្នុងគម្ពីរមហាដីកា របស់ វិសុទ្ធិមគ្គថា:

**[១] កេចិ បនេត្ថ កេចិ បនេត្ថ "អនិច្ចតោ អនុបស្សតិ នោ និច្ចតោអាទិនា វិសុំ ឧស្សុក្កិច្ចំ នត្ថិ, ភង្គឧស្សនេនេវ សព្វំ ទិដ្ឋំ ហោតី"តិ វទន្តិ ។ [២] តំ ភង្គានុបស្សនាយ មត្ថកប្បត្តិយំ យុត្តំ ។ [៣] តតោ បន បុព្វភាគេ អនេកាការវោការា អនុបស្សនា ឥច្ឆិតព្វារ ។**

"១. ម្យ៉ាងទៀត មានអ្នកពោលថា នាទីក្នុងការឃើញច្បាស់ ដោយ

ចំពោះតាមន័យថា រមែងឃើញច្បាស់ថា មិនទៀង មិនឃើញច្បាស់ថាទៀងជាដើម មិនមានក្នុងកង្ខាញាណនេះ លក្ខណៈមិន ទៀងទាំងអស់នោះជាការដែលបុគ្គលឃើញបាន ដោយការឃើញច្បាស់នូវសេចក្ដីរលត់តែម្យ៉ាង ។

២.ពាក្យពោលនោះសាកសម ក្នុងកាលបញ្ញាឃើញច្បាស់នូវការរលត់ដល់ភាពប្រសើរបំផុត ។

៣. តែអនុបស្សនា ដែលច្របូកច្របល់គ្នាដោយលក្ខណៈផ្សេងៗ រមែងមានបានដោយពិតក្នុងខាងដើម មុននឹងដល់សេចក្ដីប្រសើរបំផុត ដូចដូចពោល" ។

សូម្បីព្រះដីកាចារ្យ នឹងពោលថា ជាការឃើញរបស់អ្នកខ្លះ ( កេចិវាទៈ ) ក្នុងទំនងជំទាស់ ក៏ត្រឹមតែជំទាស់សេចក្ដីឃើញ ដែលសំដៅដល់កង្ខាញាណយ៉ាងទន់ខ្សោយ មិនបានជំទាស់ដោយសំដៅដល់កង្ខាញាណលំដាប់ចាស់ក្លា ទើបចាត់ជាការឃើញ ដែលលោកព្រមទទួល ដូចគម្ពីរបដិសម្ភិទាមគ្គពោលថា:

**វយលក្ខណុបដ្ឋា នេកត្តេ វិបស្សនាកានំ ។**

"សេចក្ដីជាម្យ៉ាង ដែលប្រាកដដោយលក្ខណៈរលត់ទៅ របស់សង្ខារ ជាសេចក្ដីជាវិបស្សនាចិត្តម្យ៉ាង ដែលប្រាសចាកកិលេសជំទាស់គ្នា របស់អ្នកចម្រើនវិបស្សនាទាំងឡាយ" ។

# ៨.ខយានុបស្សនា

*ខយានុបស្សនា គឺបញ្ញាឃើញច្បាស់ការអស់ទៅ ដែលជាសេចក្ដីរលត់ទៅក្នុងបច្ចុប្បន្នខណៈ របស់រូបនាមដែលកំពុងកំណត់ដឹង (ខនភង្គ) ខយានុបស្សនានេះក៏គឺ ភង្គញាណដែលឃើញច្បាស់ការរលត់ទៅរបស់អារម្មណ៍ដែលខូនកំណត់ដឹង និងវិបស្សនាចិត្តក្នុងខណៈនោះ បញ្ញត្តិដែលជារូបរាងសណ្ឋាន រមែងអន្តរធានទៅ មានត្រឹមការរលត់ទៅរបស់រូបនាមដែលជាសភាវធម៌ប៉ុណ្ណោះ ដូចប្រាកដសេចក្ដីថា*

**ខយានុបស្សនន្តិ សង្ខារានំ ខណភង្គានុបស្សនំ ។**

*"ពាក្យថា ខយានុបស្សនំ ( បញ្ញាឃើញច្បាស់ការអស់ទៅ ) គឺបញ្ញាឃើញច្បាស់ការរលត់ទៅ ក្នុងខណៈបច្ចុប្បន្នខណៈ របស់សង្ខារទាំងឡាយ" ។*

**ខយានុបស្សនាតិ បច្ចុប្បន្នានំ រូបក្ខន្ធាទីនំ ភង្គទស្សនញ្ច តំ តំ ខន្ធភង្គទស្សនានន្តរំ តទារម្មណចិត្តចេតសិកភង្គទស្សនញាណញ្ច ។**

*"ខយានុបស្សនា គឺបញ្ញា ដែលឃើញច្បាស់ការរលត់ទៅរបស់រូបខន្ធជាដើម ដែលជាបច្ចុប្បន្ន និងបញ្ញាដែលឃើញច្បាស់ការរលត់ទៅរបស់ចិត្តចេតសិក ដែលមានការរលត់ទៅនោះ ជាអារម្មណ៍ក្នុងលំដាប់បន្ទាប់ពីការរលត់ទៅរបស់ខន្ធនោះៗ" ។*

**ខយានុបស្សនាតិ ឃន យនវិនិព្ភោគំ កត្វា អនិច្ចំ ខយដ្ឋេនាតិ ឯវំ ខយំបស្សតោ ញាណំ ។**

*“ខយានុបស្សនា គឺបញ្ញារបស់អ្នកឃើញច្បាស់ ការអស់ទៅ ដោយធ្វើការបំបែកក្រុមចេញទៅ យ៉ាងនេះថា មិនទៀងព្រោះមានសភាព អស់ទៅ” ។*

*អ្នកបដិបត្តិ ដែលសម្រេចភង្គញាណលំដាប់ចាស់ក្លាហើយ រមែង ឃើញច្បាស់ការរលត់ទៅយ៉ាង ជាក់ច្បាស់ ដូចខណៈគូដៃរមែងឃើញ ច្បាស់ ការរលត់ទៅជាថ្នាក់ៗ យ៉ាងល្អិតរបស់សភាវៈគូ ទើបជ្រាបថា សភាវៈគូអស់ទៅជានិច្ច ក្រៅពីនោះ នៅឃើញវិបស្សនាចិត្ត ដែលរលត់ ទៅតមកពិសភាវៈកម្រើកបានទៀតផង គេមិនជួបរូបរាងសណ្ឋានរបស់ដៃ ដែលកម្រើក ដូចមនុស្សទូទៅ ដែលយល់ថារូបរាងមានជានិច្ច និងមិន ជួបចិត្ត ដែលតាំងនៅជានិច្ច ដូចដែលមនុស្សទូទៅគេយល់ សញ្ញាវិបល្លាស ជាដើម ដែលសំគាល់ខុស ថាជាយ៉ាងដូចគ្នា ទើបមិនប្រាកដដល់គេ ដូចនោះ អ្នកដែលចម្រើនអនុបស្សនានេះ ទើបអាចលះសេចក្ដី សំគាល់ ថាជាក្រុម ( ឃនសញ្ញា ) បានដូចសេចក្ដីពោលថា:*

**[១] ភង្គានុបស្សនាតោ បដ្ឋាយ តស្សា ធារិប្ពីរតិ ឃនសញ្ញាយ បហានំ ហោតិ ។ [២] តតោ បុព្វេ បរិបុណ្ណតាយ តំ ន ហោតិ ។ [៣] ឯវមញ្ញត្ថាបីតិ បរិបុណ្ណាបរិបុណ្ណតា បហានតីរណាបរិញ្ញាសុ ទដ្ឋព្វា ។**

*“១. សេចក្ដីបរិបូរណ៍របស់ខយានុបស្សនានោះ មានបាន តាំងតែ បញ្ញាឃើញច្បាស់ការរលត់ជា ដើមទៅ ដូចនោះ ទើបលះសេចក្ដីសំគាល់ថា*

ជាក្រុមបាន ។

២. ការលះសេចក្តីសម្គាល់ថា ជាក្រុមនោះរមែងមិនមានព្រោះ ខយានុបស្សនានៅមិនបរិបូរណ៍ មុននឹងសម្រេចកង្ខញាណនោះ ។

៣. សូម្បីក្នុងអនុបស្សនាដទៃក៏ដូចគ្នា ដូចនោះសេចក្តីបរិបូរណ៍ និងសេចក្តីមិនបរិបូរណ៍របស់វិបស្សនាញាណ គប្បីជ្រាបក្នុងមហាបរិញ្ញា និងតីរណបរិញ្ញា” ។

វិបស្សនាញាណក្នុងលំដាប់តីរណបរិញ្ញា គឺសម្មនញាណ និង ឧទយព្វយញាណ មានកម្លាំងមិនបរិបូរណ៍ អនិច្ចានុបស្សនាជាដើម ដែលកើតក្នុងលំដាប់ដូចពោល ទើបលះសេចក្តីសម្គាល់ថាទៀង ( និច្ចសញ្ញា ) ជាដើមមិនបាន ដោយមិនមានសេសសល់ ព្រោះអ្នកបដិបត្តិធម៌ ដែលសម្រេចកង្ខញាណហើយ នឹងអាចលះសេចក្តីសម្គាល់ថាជាក្រុមបាន ។

# ៩. ខយានុបស្សនា

***ខយានុបស្សនា*** គឺបញ្ញាឃើញច្បាស់ការសូន្យទៅ ពោលគឺអ្នកដែលឃើញច្បាស់ ការរលត់ទៅក្នុងគ្រប់ខណៈ របស់រូបនាម ដែលកំណត់ដឹង ក្នុងខណៈនោះ រមែងយល់ដោយអនុមានដឹងថា រូបនាមក្នុងអតីត ឬអនាគតក៏មានសភាពរលត់ទៅ ដូចរូបនាមក្នុងបច្ចុប្បន្ន លំដាប់នោះ

គេរមែងដឹងច្បាស់ថា រូបនាមទាំងអស់រលត់ទៅគ្រប់ខណៈ មិនតាំងនៅជានិច្ច ដោយមានការរលត់ទៅទេ ។

អនុបស្សនានេះ រមែងលះសេចក្តីខ្វល់ខ្វាយដើម្បីការនៅដោយល្អមានសេចក្តីសុខ ( **អាយូហនៈ** ) ពោលគឺអ្នកដែលមិនឃើញច្បាស់ថារូបនាមរលត់ទៅជានិច្ច ក៏នឹងសម្គាល់ខុសថាខ្លួននិងអ្នក ដទៃមាននៅយ៉ាងពិតប្រាកដ ទើបខ្វល់ខ្វាយដើម្បីសង្ខារដែលសម្គាល់ថាជាខ្លួន និងអ្នកដទៃនៅ

ដោយល្អមានសេចក្តីសុខទាំងក្នុងភពនេះ និងភពមុខចំណែកអ្នកចម្រើនវិបស្សនា ដែលឃើញច្បាស់ថាៈ

សង្ខារសូន្យទៅជានិច្ចដោយវយានុបស្សនា រមែងមិនខ្វល់ខ្វាយដើម្បីសង្ខារ ដែលធ្លាប់សម្គាល់ខុសថាទៀង នៅដោយល្អមានសេចក្តីសុខ ដូចអ្នកដែលខ្វល់ខ្វាយធ្វើការងារដើម្បីចិញ្ចឹមបីបាច់បុត្រធីតា ដែលកំពុងចម្រើនធំធាត់មានសេចក្តីសុខ តែគេមិនចង់ខ្វល់ខ្វាយ ធ្វើការងាររកទ្រព្យកាលជ្រាបថាបុត្រធីតា អស់ជីវិតទៅហើយ ។

មានសេចក្តីទាក់ទងរឿងនេះ ក្នុងគម្ពីរវិសុទ្ធិមគ្គថាៈ

**វយានុបស្សនាតិ**

**អារម្មណអន្វយេន ឧភោ ឯកវវត្ថនា**

**និរោធេ អធិមុត្តតា វយលក្ខណាវិបស្សនាតិ**

**ឯវំ វុត្តា បច្ចក្ខតោ ចេវ អន្វយតោ ច សង្ខារានំ ភង្គំ**

**ទិស្វា តស្មិញ្ញេវ ភង្គសង្ខាតេ និរោធេ អធិមុត្តតា តាយ អាយូហនស្ស បហានំ ហោតិ ។ "យេសញ្ហិ អត្ថាយ អាយូហេយ្យ, តេ ឯវំ វយធម្មា"តិ វិបស្សតោ អាយូហនេ ចិត្តំ ន នមតិ ។**

*“វយានុបស្សនាគឺការបង្អោនទៅ ក្នុងនិរោធដែលហៅថាការរលត់ទៅនោះ នុ៎ះឯង ដោយ ឃើញច្បាស់ការរលត់ទៅរបស់សង្ខារទាំងឡាយ ដោយជាក់ច្បាស់ និងដោយញាណដែលស្របតាមដែលពោល ទុក ក្នុងគម្ពីរបដិសម្ភិទាមគ្គ ដូចនេះថា*

*ញាណដែលដល់ព្រមដោយអង្គ២ទាំងនេះ គឺការកំណត់ដោយសភាពយ៉ាងដូចគ្នា គឺការរលត់ ក្នុងអារម្មណ៍ទាំងពីរ គឺអារម្មណ៍ ដែលឃើញច្បាស់ដែលបានដល់បច្ចុប្បន្ន និងអារម្មណ៍ ដែលមិនឃើញច្បាស់ ដែលបានដល់អតីត និងអនាគត ដោយអនុមានដឹង ដែល ស្របតាមអារម្មណ៍ ដែលជាបច្ចុប្បន្ន និងការបង្អោនចិត្តទៅក្នុងការរលត់ជាកង្គញាណដែលឃើញច្បាស់លក្ខណៈរលត់ទៅ ។*

*ការលះសេចក្ដីខ្វល់ខ្វាយ រមែងមានបានដោយវយានុបស្សនានោះ ព្រោះកាលអ្នកបដិបត្តិធម៌ ឃើញច្បាស់ថា បុគ្គលគប្បីខ្វយខ្វាយដើម្បីប្រយោជន៍ ដល់សង្ខារពួកណា សង្ខារទាំងនោះមានការរលត់ទៅ ជាធម្មតាយ៉ាងនេះ” ។*

# ១០. វិបរិណាមានុបស្សនា

*វិបរិណាមានុបស្សនា* គឺបញ្ញាឃើញច្បាស់ការប្រែប្រួលទៅ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា:

**[១] វិបរិណាមានុបស្សនាតិ រូបសត្តកាទិវសេន តំ តំ បរិច្ឆេទំ អតិក្កម្ម អញ្ញថាបវត្តិទស្សនំ ។ [២] ឧប្បន្នស្ស វា ជរាយ ចេវ មរណេន ច ទ្វីហាការេហិ វិបរិណាមទស្សនំ ។**

"១. វិបរិណាមានុបស្សនា ( បញ្ញាឃើញច្បាស់ការប្រែប្រួលទៅ ) គឺការឃើញច្បាស់សេចក្តី ប្រព្រឹត្តទៅយ៉ាងដទៃកន្លងផុតខេត្តដែននោះៗ ដោយចំណែកជារូបសត្តក:ជាដើម ។

២. ឬការឃើញច្បាស់ ការប្រែប្រួលរបស់រូបនាមដែលកើតឡើងហើយ ដោយលក្ខណ:ទាំងពីរ គឺការចាស់និងការស្លាប់" ។

សេចក្តីនេះ សម្តែងលក្ខណ:របស់វិបរិណាមានុបស្សនា ដោយចែកជា ២ ន័យ ដូច្នេះ :

១. ការពិចារណារូបនាមដោយរូបសត្តក: ( រូប ៧ ពួក ) តាមដែលពោលទុកក្នុងសម្មសនញាណ បែងចេញជា :

-ការពិចារណាយ៉ាងគ្រោតគ្រាត ដូចរូបដែលប្រព្រឹត្តទៅក្នុងបឋមវ័យ មិនទាន់ដល់មជ្ឈិមវ័យ ក៏រលត់ទៅក្នុងបឋមវ័យនោះឯង ដូចនោះ រូបក្នុងបឋម ទើបផ្សេងពីរូបក្នុងមជ្ឈិមវ័យ និងរូបក្នុងមជ្ឈិមវ័យ ទើបមិនដូចជាមួយនឹងរូបក្នុងបច្ឆិមវ័យ ។

-ការពិចារណាយ៉ាងល្អិត ដូចរូបដែលប្រព្រឹត្តទៅក្នុងខណៈដើរទៅខាងមុខ នៅមិនទាន់ថយត្រ ឡប់ក៏រលត់ទៅក្នុងខណៈដើរទៅខាងមុខនោះឯង ដូចនោះក្នុងខណៈដើរទៅខាងមុខ ទើបផ្សេងពីរូបក្នុង ខណៈថយត្រឡប់ ។

២.ការពិចារណា រូបនាមដោយសេចក្ដីប្រែប្រួល ដោយការអាប់ហើយរលត់ទៅ ( ការអាប់ គឺ ការចាស់ ឬឋិតិខណៈ ការរលត់ គឺការស្លាប់ ឬភង្គខណៈ ) បែងចេញជា :

-ការពិចារណាយ៉ាងគ្រោតគ្រាត ដូចរូបនាមប្រែប្រួល ដោយការចាស់ ប្រែប្រួលដោយការស្លាប់ ដូចនោះ រូបនាមគ្រប់យ៉ាងទើបប្រែប្រួលមិនតាំងនៅជានិច្ច ដោយលក្ខណៈទាំងពីរ ។

-ការពិចារណាយ៉ាងល្អិត ដូចរូបនាមប្រែប្រួលពីខណៈកើតឡើងទៅកាន់ខណៈតាំងនៅ និងប្រែប្រួលពីខណៈតាំងនៅទៅ កាន់ខណៈរលត់ទៅ ដូចនោះ រូបនាមគ្រប់យ៉ាង ទើបប្រែប្រួលមិនតាំងនៅជានិច្ច ។

បញ្ញាឃើញច្បាស់ការប្រែប្រួល ទៅរបស់រូបនាមដូចពោលដោយត្រង់ ( **បច្ចក្ខញាណ** ) ឬដោយអនុមានដឹង ( **អន្វយញាណ** ) ឈ្មោះថា **វិបរិណាមានុបស្សនា** រមែងលះសេចក្ដីសម្គាល់ថាទៀង ពិតមិនប្រែប្រួលដែលហៅថាធុវ សញ្ញាបាន ។

ម្យ៉ាងទៀត ក្នុងអដ្ឋកថារបស់បដិសម្ភិទាមគ្គពោលថា បញ្ញាឃើញច្បាស់ការប្រែប្រួលទៅរបស់រូបនាមដោយអនុមានដឹង ( **អន្វយញាណ** )

ចាត់ជាវយានុបស្សនា ចំណែកបញ្ញាដែលឃើញច្បាស់ ដោយអំណាច **វយានុបស្សនា**ថា សភាវធម៌ទាំងអស់មានសភាពប្រែប្រួលទៅ ចាត់ជាវិបរិណាមានុបស្សនាប្រាកដឡើង កាលបើសម្រេចភង្គញាណ លំដាប់ចាស់ក្លាហើយ ការឃើញខាងដើម ពោលទុកដោយអាស្រ័យ លំដាប់ដែលវយានុបស្សនានៅខាងមុខ និងអធិបញ្ញាធម្មវិបស្សនា នៅខាងក្រោយអនុបស្សនានេះ ដូចសេចក្តីក្នុងគម្ពីរនោះថា:

**[១] វយានុបស្សនាតិ បច្ចុប្បន្នានំ ខន្ធានំ ភង្គទស្សនានន្តរំ តទន្វយេនេវ អតីតានាគតខន្ធានំ ភង្គទស្សនញាណំ ។ [២] វិបរិណាមានុបស្សនាតិ តស្មិំ ភង្គសង្ខាតេ និរោធេ អធិមុត្តត្តា អថ សព្វេបិ អតីតានាគតបច្ចុប្បន្នា ខន្ធា វិបរិណាមវន្តោតិ សព្វេសំ វិបរិណាមទស្សនញាណំ ។**

"១. **វយានុបស្សនា** គឺ បញ្ញាឃើញច្បាស់ការរលត់របស់ខន្ធក្នុងអតីត និងអនាគត ដោយស្របតាមញាណ ដែលដឹងច្បាស់ខន្ធក្នុងបច្ចុប្បន្ននោះក្នុងលំដាប់ បន្ទាប់ពីការឃើញច្បាស់នូវការរលត់របស់ខន្ធក្នុងបច្ចុប្បន្ន ។

២. វិបរិណាមានុបស្សនា គឺបញ្ញាឃើញច្បាស់ការផ្លាស់ប្តូរទៅរបស់ខន្ធទាំងពួងថា ខន្ធដែលជា អតីត អនាគត និងបច្ចុប្បន្នទាំងពួងមានសភាពផ្លាស់ប្តូរទៅ ព្រោះបង្អោនទៅក្នុងនិរោធដែលហៅថាការ រលត់នោះ" ។

# ១១. អនិមិត្តានុបស្សនា

***អនិមិត្តានុបស្សនា*** *ក៏គឺអនិច្ចានុបស្សនា នោះឯង សំដៅដល់បញ្ញាឃើញច្បាស់ថា មិនមាននិមិត្តរូបរាង ដូចគម្ពីរអដ្ឋកថា និងដីកាអធិប្បាយថា :*

**និមិត្តន្តិ សង្ខារនិមិត្តំ ។**

*"ពាក្យពោលថា និមិត្តំ ( និមិត្ត វត្ថុដែលប្រាកដដូចមានពិត ) សំដៅដល់និមិត្ត គឺសង្ខារ" ។*

**សង្ខារនិមិត្តន្តិ សង្ខារានំ សមូហាទិឃនវសេន សកិច្ចបរិច្ឆេទ-តាយ ច សវិគ្គហានំ វិយ បដ្ឋានំ ។**

*"ពាក្យពោលថា សង្ខារនិមិត្ត ( និមិត្តគឺសង្ខារ ) សំដៅដល់ការប្រាកដរបស់សង្ខារដោយភាពជាក្រុម ដោយកងរូបជាដើម ដល់អ្នកមិនបានចម្រើនភាវនា និងការប្រាកដរបស់សង្ខារ ដោយខេត្តគឺ នាទីរបស់ខ្លួនដល់អ្នកមិនបានចម្រើនភាវនា" ។*

*មនុស្សទូទៅ ដែលមិនបានចម្រើនវិបស្សនាភាវនារ មែងសម្គាល់ថា មានរូបរាងសណ្ឋាន ដែលតាំងនៅជានិច្ចក្នុងអាកប្បកិរិយាផ្លូវកាយ ដូចការដើរ ឈរ ដេក អង្គុយ សណ្ដូក អោន ឬវត្ថុដែល ចិត្តទទួលដឹង ដូចការឃើញ បានឮ ដឹងក្លិន ភ្លក្សរសប៉ះខ្ទប់សម្ផស្ស នឹកគិតរឿងរាវផ្សេងៗ រួមទាំងវត្ថុ ដែលមានប្រាកដតាមទ្វារទាំង៦ គឺរូប សម្លេង ក្លិន រស សម្ផស្ស និងធម្មារម្មណ៍ ទាំងអស់នោះជាឃន បញ្ញត្តិដែលហៅថា*

សង្ខារនិមិត្ត និច្ចនិមិត្ត ( និមិត្តថាទៀង ) ធុវនិមិត្ត ( និមិត្តថា យឺនយូរ ) និងសស្សតនិមិត្ត ( និមិត្តថា ស្ថិតស្ថេរមាំមួន ) ។

ក្នុងករណីផ្ទុយគ្នា អ្នកចម្រើនវិបស្សនារហូតទាំងបានប្រាកដ អនិមិត្តានុបស្សនា ក្នុងលំដាប់កង្ខញាណ រមែងឃើញច្បាស់ថា អាកប្បកិរិយា ផ្លូវកាយ វត្ថុដែលចិត្តទទួលដឹង និងវត្ថុដែលមកប្រាកដផ្លូវ ទ្វារទាំង៦ ត្រឹមតែ ជាសភាវធម៌ ដែលកើតឡើងហើយរលត់ទៅភ្លាម មិនប្រាកដ រូបរាងសណ្ឋាន ទាំងកិលេស កម្ម និង វិបាកខន្ធ ដែលជាកម្មក៏មិនកើតឡើង ដោយការប្រកាន់មាំរូបរាងសណ្ឋាន ព្រោះអនិមិត្តានុបស្សនាលះបង់សង្ខារ និមិត្តបាន ដូចគម្ពីរវិសុទ្ធិមគ្គពោលថា:

**[១] យស្មា បនេស អនិច្ចានុបស្សនាយ សង្ខារានំ ឃនវិនិព្ភោគំ កត្វា និច្ចនិមិត្តធុវនិមិត្តសស្សតនិមិត្តានិ បជហន្តោ អាគតោ ។ [១] តស្មា អនិមិត្តោ ។**

“ម្យ៉ាងទៀត មគ្គនេះលះនិមិត្តថាទៀង យឺនយូរ និងស្ថិតស្ថេរមាំទាំ ដោយធ្វើការបំបែកក្រុម របស់សង្ខារដោយអនិច្ចានុបស្សនា ដូចនោះ ទើប ឈ្មោះថា **អនិមិត្តវិមោក្ខ**” ។

អ្នកចម្រើនវិបស្សនា រហូតទាំងសម្រេចអនិមិត្តានុបស្សនាហើយ រមែងឃើញច្បាស់ថា មានត្រឹមសភាវធម៌ ក្នុងបច្ចុប្បន្ន ដែលដំណើរទៅ តាមនាទី សភាវ: ខណ: និងអារម្មណ៍ ដែលបែកផ្សេងគ្នា ដែលកើត រលត់យ៉ាងដាច់រហ័ស មិនមានរូបរាងសណ្ឋាន ដូចនោះ ខ្ទឹមសារក្នុង

រូបនាម ទើបមិនមាន ដូចមនុស្សពុះអុសដែលមិនមានខ្លឹម រឹតតែពុះទៅ ក៏នឹងជួបតែគ្មានខ្លឹមរឿយៗ ទៅ ការពិតអ្នកឃើញថា រូបនាមមិនទៀង រមែងនឹងឃើញច្បាស់ថា រូបនាមអស់ទៅ និងឃើញច្បាស់សង្ខារថាត្រឹមតែជាសភាវធម៌ ដែលមិនមែនរូបរាងសណ្ឋាន ដូចសេចក្តីក្នុងគម្ពីរបដិសម្ភិទាមគ្គថា:

**[១] អនិច្ចតោ មនសិករោតោ ខយតោ សង្ខារា ឧបដ្ឋហន្តិ ។**

*"សង្ខារទាំងឡាយ រមែងប្រាកដថា អស់ទៅដល់អ្នកឃើញច្បាស់ថា មិនទៀង" ។*

**អនិច្ចតោ មនសិករោន្តោ និមិត្តំ យថាភូតំ ជានាតិ បស្សតិ ។**

*"អ្នកឃើកច្បាស់ថា មិនទៀង រមែងឃើញច្បាស់និមិត្ត គឺសង្ខារតាមសេចក្តីពិត" ។*

# ១២. អប្បណិហិតានុបស្សនា

តណ្ហាដែលកើតកើនគ្រេកអរក្នុងរូប ព្រោះសម្គាល់ខុសថា រូបនាមដែលប្រាកដក្នុងខណៈឈរ ដើរ អង្គុយ ដេក ឃើញ បានឮ ។ល។ ជាវត្ថុដែលគួរស្រលាញ់រាក់ទាក់ ពេញចិត្ត ហៅថា បណិធិ ឬបណិហិតៈ តែអ្នកដែលឃើញច្បាស់ថា រូបនាមកំពុងកើតរលត់ រមែងយល់ថាជាទុក្ខ មិនមែនវត្ថុល្អស្អាត ការឃើញច្បាស់ដូចនេះឈ្មោះថា **អប្បណិហិតានុបស្សនា** គឺបញ្ញាឃើញច្បាស់ថាមិនគួរប្រាថ្នា រមែងលះបង់សេចក្តីសុខ ( បណិធិ ) និងបានឈ្មោះថា **ទុក្ខានុបស្សនា** គឺបញ្ញាឃើញច្បាស់ថា ជាទុក្ខទៀតផង ។

## ១៣. សុញ្ញតានុបស្សនា

មនុស្សទូទៅរមែងសម្គាល់ខុសថា មានតួខ្លួនដែលធ្វើអាកប្បកិរិយា មានការឈរ ដើរ អង្គុយ ដេក ។ល។ តែអ្នកចម្រើនវិបស្សនា រហូតបានសម្រេចភង្គញាណ និងប្រាកដអនត្តានុបស្សនាហើយ រមែងយល់ថា មានត្រឹមតែសភាវធម៌ដែលកើតឡើងហើយរលត់ទៅ មិនមានបុគ្គល យើង របស់យើង ទើបមិននៅក្នុងអំណាចរបស់អ្នកណា កាលបើឃើញច្បាស់យ៉ាងនេះ ឈ្មោះថា **សុញ្ញតានុបស្សនា** បញ្ញាឃើញច្បាស់ថា សូន្យទទេ ឬអនត្តានុបស្សនា គឺបញ្ញាឃើញច្បាស់ថាមិនមែនតួខ្លួន រមែងលះការប្រកាន់មាំថាជាតួខ្លួន ( អភិនិវេសៈ ) ។

## ១៤. អធិបញ្ញាធម្មវិបស្សនា

អធិបញ្ញាធម្មវិបស្សនា គឺបញ្ញាដែលដ៏ក្រៃលែងដែលឃើញច្បាស់សភាវធម៌ថា សង្ខាររលត់ទៅ ព្រោះឃើញច្បាស់ការរលត់ទៅរបស់សង្ខារ ដែលជាអារម្មណ៍ និងវិបស្សនាចិត្តដែលដឹងអារម្មណ៍ ពោលគឺអ្នកដែលសម្រេចភង្គញាណលំដាប់ចាស់ក្លាហើយ រមែងឃើញច្បាស់ថា រូបនាមតែម្យ៉ាង រលត់ទៅយ៉ាង ឆាប់រហ័ស ទាំងនៅឃើញច្បាស់ថា វិបស្សនាចិត្តដែលដឹងអារម្មណ៍ ដូចពោលបានរលត់ទៅ អ្នកដែលអាចឃើញការរលត់ទៅរបស់រូបនាម និវិបស្សនាចិត្តចាស់ក្លាទៅនេះ រមែងយល់ថាវត្ថុដែលកំពុងរលត់ទៅ ត្រឹមតែជាសង្ខារ មិនមែនតួខ្លួនយើង របស់យើង ការឃើញច្បាស់យ៉ាងនេះឈ្មោះថា **អធិបញ្ញាធម្មវិបស្សនា** លះសេចក្តី

*ប្រកាន់មាំថា អត្តាជាខ្លឹមសារ ព្រោះឃើញច្បាស់ថា មិនមានអត្តាជាខ្លឹមសារ យ៉ាងពិតប្រាកដ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា:*

**អធិបញ្ញាធម្មវិបស្សនាតិ**

**"អារម្មណញ្ច បដិសង្ខា ភង្គញ្ច អនុបស្សតិ**
**សុញ្ញតោ ច ឧបដ្ឋានំ អធិប្បញ្ញាវិបស្សនា"តិ**

**ឯវំ វុត្តា រូបាទិអារម្មណំ ជានិត្វា តស្ស ច អារម្មណស្ស តទារម្មណស្ស ច ចិត្តស្ស ភង្គំ ទិស្វា "សង្ខារាវ ភិជ្ជន្តិ, សង្ខារានំ មរណំ, អញ្ញោ កោចិ អត្ថី"តិ ភង្គវសេន សុញ្ញតំ គហេត្វា បវត្តា វិបស្សនា ។ សា អធិប្បញ្ញា ច ធម្មេសុ ច វិបស្សនាតិ កត្វា អធិប្បញ្ញាធម្មវិបស្សនាតិ វុច្ចតិ, តាយ និច្ចសារាភាវស្ស ច អត្តសារាភាវស្ស ច សុដ្ឋុ ទិដ្ឋត្តា សារាទានាភិនិវេស បហានំ ហោតិ ។**

*"**អធិបញ្ញាធម្មវិបស្សនា** ( បញ្ញាដ៏ក្រៃលែង ដែលឃើញច្បាស់សភាវធម៌ថា សង្ខាររលត់ទៅ ព្រោះឃើញច្បាស់ការរលត់ទៅរបស់សង្ខារ ដែលជាអារម្មណ៍ និងវិបស្សនាចិត្ត ដែលដឹងអារម្មណ៍ ) គឺ វិបស្សនា ដែលដឹងអារម្មណ៍មានរូបជាដើមហើយ ឃើញច្បាស់ការរលត់ទៅរបស់អារម្មណ៍នោះនិងការរលត់របស់ចិត្ត ដែលមានរូបជាដើមនោះជាអារម្មណ៍ ហើយដំណើរទៅទទួលយកការសូន្យទទេជាដើម ដោយអំណាចភង្គញាណថា សង្ខារនោះឯងបែករលត់ទៅ សេចក្តីស្លាប់មាននៅដល់សង្ខារ មិនមាន*

*អ្នកដទៃដែលពោលទុក ក្នុងគម្ពីរបដិសម្ភិទាមគ្គ ដូចនេះថា:*

*"សេចក្តីប្រាកដដោយការសួនទ្យទទេ រមែងឃើញច្បាស់អារម្មណ៍ថារលត់ទៅ និងការរលត់ទៅរបស់វិសប្បនាចិត្ត ឈ្មោះថា **វិបស្សនា** ដែលមានបញ្ញាដ៏ក្រៃលែង" ។*

## ១៥. យថាភូតញ្ញាណទស្សន

*យថាភូតញ្ញាណទស្សនៈ គឺបញ្ញាឃើញច្បាស់តាម សេចក្តីពិតក្នុងរូបនាម ព្រមដោយហេតុបច្ច័យ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :*

**យថាភូតញ្ញាណទស្សនៈ សប្បច្ចយនាមរូបបរិគ្គហោ ។ តេន "អហោសិ នុ ខោ អហំ អតីតមទ្ធាន"ន្តិអាទិវសេន ចេវ "ស្សរតោ លោកោ សម្ភោតី"តិអាទិវសេន ច បវត្តស្ស សម្មោហាភិនិវេសស្ស បហានំ ហោតិ ។**

*"**យថាភូតញ្ញាណទស្សនៈ** គឺការកំណត់ដឹងរូបនាម ព្រមដោយហេតុបច្ច័យ ធ្វើលះការប្រកាន់ ខុសដែលដំណើរទៅដោយន័យជាដើមថា "យើងធ្លាប់កើតមកពីមុនយ៉ាងតក្លាប់ក្នុងភព ដែលកន្លងហើយ មកពីមុននឹងដល់ភពនេះ ឬទេ និងដោយន័យជាដើមថា **សត្វលោកកើតពីព្រះជាម្ចាស់ជាអ្នកបង្កើត**" ។*

*អ្នកដែលចម្រើនវិបស្សនា រហូតប្រាកដញាណនេះ រមែងឃើញ*

ច្បាស់ថាមានត្រឹមរូបនាមកើត ឡើងដោយសេចក្ដីជាហេតុ និងផល ទើប យល់ថា រូបនាមក្នុងបច្ចុប្បន្នកើតពីហេតុ គឺអវិជ្ជា តណ្ហា ឧបាទាន និង កម្មក្នុងភពមុន សូម្បីរូបនាមក្នុងអតីត និងអនាគត ក៏នឹងកើតពីហេតុ ទាំងនេះ ក្នុងកាលទាំង ៣ ទើបមានត្រឹមរូបនាម ដែលជាហេតុនិងផល របស់គ្នានិងគ្នា អនុបស្សនានេះ រមែងលះការប្រកាន់មាំ គឺការវង្វេង ដោយទិដ្ឋិ ដែលប្រកាន់ខុសថា មានអ្នកនិមិត្តពួកសត្វ និងវិចិកិច្ឆាដែល សង្ស័យថា យើងធ្លាប់ កើតមកពីមុនឬទេ?

# ១៦. អាទីនវានុបស្សនា

***អាទីនវានុបស្សនា*** *គឺបញ្ញាឃើញច្បាស់នូវទោស រមែងលះសេចក្ដី ប្រកាន់មាំដោយការពាក់ព័ន្ធ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា:*

**អាទីនវានុបស្សនាតិ ភយតុបដ្ឋានវសេន ឧប្បន្នំ សព្វភវាទីសុ អាទីនវទស្សនញ្ញាណំ តេន យំ កិញ្ចិ អល្លីយិតព្វំ ន ទិស្សតី"តិ អាលយាភិនិវេសស្ស បហានំ ហោតិ ។**

*"**អាទីនវានុបស្សនា** គឺញាណដឹងច្បាស់នូវទោសក្នុងភពទាំងអស់ ជាដើម ដែលកើតឡើងដោយ ប្រាកដជាគួរខ្លាច ធ្វើលះការប្រកាន់មាំ ដោយសេចក្ដីជាប់ជំពាក់ថា វត្ថុណាៗដែលគប្បីនឹងបានមិនមាន" ។*

*មនុស្សទូទៅសូម្បីនឹងលំបាកក្រខ្សត់យ៉ាងណា ក៏អាចលះភពជាតិ បាន ទើបត្រូវការស្វែងរកសេក្ដីសុខដោយវិធីផ្សេងៗ ដូចមនុស្សឈឺធ្ងន់ ត្រូវការ នឹងជាអំពីរោគ មនុស្សក្រខ្សត់ត្រូវការនឹងមាន ទ្រព្យ សូម្បីមិន*

បានវត្ថុ ដែលត្រូវការក្នុងជាតិនេះ ក៏នឹងត្រូវការបានក្នុងជាតិតទៅ ឬប្រសិន បើគិតថា ជីវិតមនុស្សមានទុក្ខ ក៏ត្រូវការនឹងទៅកើតជាទេវតា ឬព្រហ្ម ឬ ត្រូវការនឹងទៅកើតជាសេដ្ឋី ក្សត្រ ទេវតា ឬព្រហ្មរហូតទៅ មិនត្រូវការ នឹងរលត់ទុក្ខ គឺរូបនាមដោយអំណាចការជាប់ជំពាក់គឺតណ្ហា ។

អ្នកដែលសម្រេចភង្គញាណលំដាប់ចាស់ក្លាហើយ រមែងយល់ថា សង្ខារទាំងអស់ជាទីពឹងមិនបាន ដោយសង្ខារ គឺអារម្មណ៍ដែលកំណត់ដឹង វិបស្សនាចិត្តដែលឃើញច្បាស់អារម្មណ៍នោះ អារម្មណ៍ដែល ពិចារណា និងចិត្ត ដែលពិចារណាអារម្មណ៍នោះ មិនមែនទីពឹងយ៉ាងពិតប្រាកដ គេ មិនឃើញច្បាស់ទីពឹងយ៉ាងណាមួយក្នុងរូបនាម ដែលជាប់ដោយភព ៣ គឺកាមភព រូបភព និងអរូបភព ដូចនោះ អនុបស្សនានេះ ទើបលះការ ពាក់ព័ន្ធក្នុងភព ។

## ១៧. បដិសង្ខានុបស្សនា

***បដិសង្ខារវិបស្សនា*** គឺ បញ្ញាកំណត់ដឹងទៀតដើម្បីកំណត់សង្ខារ ចាត់ជាបដិសង្ខារញាណ ដែលប្រាកដដល់អ្នក ដែលបានសម្រេច***មុញ្ចិតុ-កម្យតាញាណ***ហើយដើម្បីកំណត់សង្ខារ ម្យ៉ាងទៀតសេចក្តីថា :

"កំណត់" និង"ផុតទៅ" មានន័យដូចគ្នា ក្នុងគម្ពីរអដ្ឋកថាខ្លះ ទើបពោលដល់សេចក្តីទាំងពីរ ទុកក្នុងរឿងមុញ្ចិតុកម្យតាញាណ ដូចគម្ពីរ

*វិសុទ្ធិមគ្គ និងមហាដីកាអធិប្បាយថា :*

**បដិសង្ខានុបស្សនាតិ មុញ្ចនស្ស ឧបាយករណំ បដិសង្ខាញាណំ តេន អប្បដិសង្ខាយ បហានំ ហោតិ ។**

*“**បដិសង្ខារនុបស្សនា** គឺបញ្ញាកំណត់ដឹងទៀតដែលធ្វើនូវហេតុនៃការលះបង់នូវសង្ខារ ធ្វើលះមោហៈ ដែលមិនកំណត់ដឹងទៀត” ។*

**សង្ខារានំ មុញ្ចនស្ស ឧបាយភូតំ បដិសង្ខាញាណំ បដិសង្ខានុបស្សនា តាយ អនិច្ចាទីសុ អប្បដិសង្ខាតត្តា បដិសង្ខា-នស្ស បដិបក្ខភូតំ អវិជ្ជំ បជហាតិ ។**

*បញ្ញាកំណត់ដឹងទៀត ដែលធ្វើនូវហេតុនៃការលះសង្ខារ ឈ្មោះថា **បដិសង្ខានុបស្សនា** ធ្វើនាទីលះបង់នូវអវិជ្ជា ដែលជាបដិបក្ខ ចំពោះការកំណត់ដឹងទៀត ព្រោះការមិនកំណត់ដឹងទៀតក្នុងសេចក្ដី មិនទៀងជាដើម” ។*

*មនុស្សទូទៅ ដែលមិនឃើញច្បាស់ត្រៃលក្ខណ៍ រមែងកើតការត្រេកអរភ្ញើតភ្ញើនក្នុងសង្ខារ កាលជួបជាមួយសេចក្ដីទុក្ខ របស់ទុក្ខវេទនា សេចក្ដីប្រែប្រួលរបស់សុខវេទនា និងការបែកធ្លាយទៅរបស់ សង្ខារគ្រប់យ៉ាងរមែងរលត់ចិត្តខ្លាច គេនៅកំណត់សង្ខារមិនបាន ព្រោះនៅប្រកាន់ភ្ជាប់នៅជាប់ជំពាក់ ។*

*អ្នកដែលឃើញច្បាស់ថា សង្ខារធ្លាប់នៅក្នុងបញ្ញត្តិ របស់ត្រៃលក្ខណ៍ហើយ រមែងមិនសម្គាល់ថា សង្ខារគួរត្រេកអររីករាយ មិនសម្គាល់ថាជា*

យើង របស់យើង មិនសង្ឃឹមសង្ខារដែលខ្លួនត្រូវការនោះជា សុខ មិនសង្ឃឹម សង្ខារសូន្យទៅ អស់ទៅ មិនកន្លល់ថា សង្ខារនឹងជាទុក្ខ ដូចការព្រងើយមិនប្រាថ្នា ឬកន្លល់ក្នុងថ្នូខ្សាប់ដែលមិនទាក់ទង់នឹងខ្លួន ។

ពិតហើយ អ្នកដែលរួចផុតពីសង្ខារ ដោយមិនមានសេសសល់ត្រូវជាព្រះអរហន្តប៉ុណ្ណោះ តែអ្នកបាននូវចម្រើនវិបស្សនា ដែលសម្រេចសង្ខារុបេក្ខាញាណ ដែលប្រកបដោយឆឡង្គុបេក្ខា ( បេក្ខាមានអង្គ ៦ គឺការព្រងើយមិនត្រេកអររីករាយក្នុងអារម្មណ៍ ៦ ដែលមានប្រាកដតាមទ្វារទាំង៦ ) ក៏ចាត់ថារួចផុតពីសង្ខារបានយ៉ាងល្អ ដូចនោះ ការកំណត់សង្ខារដោយមុញ្ចិតុកម្យតាញាណ ទើបនៅមិនសម្បូរណ៍ ត្រូវព្យាយាមកំណត់ដឹងតទៅទៀតដោយបដិសង្ខារញាណ ទើបនឹងរួចផុតពីសង្ខារដោយសង្ខារុបេក្ខាញាណដូចពោល អនុបស្សនានេះ រមែងលះការមិនកំណត់ដឹងទៀតដែលបានដល់អវិជ្ជាដែលមិនឃើញ ច្បាស់ត្រៃលក្ខណ៍ ។

# ១៨. វិវដ្ដានុបស្សនា

វិវដ្ដានុបស្សនា គឺបញ្ញាឃើញច្បាស់ ដែលថយត្រឡប់ចេញពីសង្ខារទាំងអស់ សំដៅដល់ សង្ខារុបេក្ខាញាណ និងអនុលោមញាណ ដូចគម្ពីរវិសុទ្ធិមគ្គមហាដីកាអធិប្បាយថា :

**វិវដ្ដានុបស្សនាតិ សង្ខារុបេក្ខា ចេវ អនុលោមញ្ច ។ តទា ហិស្ស ចិត្តំ ឦសកបោណេ បទុមបលាសេ ឧទកពិន្ទុ វិយ សព្វស្មា សង្ខារគតា បតិលីយតិ, បតិវត្តតីតិ វុត្តំ ។ តស្មា តាយ**

**សំយោគាភិនិវេសស្ស បហានំ ហោតិ ។**

*វិវដ្ដានុបស្សនា គឺបញ្ញាឃើញច្បាស់ ដែលថយត្រឡប់ចេញពីសង្ខារ ទាំងអស់សំដៅដល់សង្ខារុបេក្ខាញាណ និងអនុលោមញាណ ដូចបានពោលទុកថា ក្នុងកាលនោះ ចិត្តរបស់អ្នកបដិបត្តិធម៌នោះ រមែងថយត្រឡប់ វិលត្រឡប់ ពីសង្ខារទាំងពួង ដូចកំណាត់ទឹកលើស្លឹកឈូកដែលកណ្ដាប់ស្លឹកកោង បន្តិចបន្តួច ដូចនោះ ទើបធ្វើលះការប្រកាន់មាំដែលប្រកបក្នុងសង្ខារ" ។*

***[១] យថា ចិត្តំ សង្ខារេ មុញ្ចិត្វា វិវដ្ដំ និព្វានំ បក្ខន្ទតិ, តថា បវត្តនតោ សង្ខារុបេក្ខា ច អនុលោមញ្ច "វិវដ្ដានុបស្សនា"តិ វុត្តំ ។[២] និវដ្ដភាវេន ឱគាឡ្ហភាវេន បវត្តសំយោជនាទិកលេសា ឯវ កិលេសាភិនិវេសោ ។***

*"១. **សង្ខារុបេក្ខាញាណ** និង**អនុលោមញាណ** ហៅថា **វិវដ្ដានុបស្សនា** ព្រោះដំណើរទៅដោយ ចិត្ត គឺគោត្រភូចិត្ត មគ្គចិត្ត និងផលចិត្ត កំណាត់ដឹងសង្ខារហើយរត់ទៅកាន់ព្រះនិព្វាន ដែលប្រាសចាកវដ្ដៈ ។*

*២. កិលេសដែលមានសំយោជនៈជាដើម ដែលដំណើរទៅ ដោយការតាំងមាំស្អុងចុះ ក្នុងសង្ខារ ឈ្មោះថា ការប្រកាន់មាំដោយកិលេស" ។*

*អ្នកដែលសម្រេចសង្ខារុបេក្ខាញាណ និងអនុលោមញាណហើយ រមែងឃើញច្បាស់ការរលត់ទៅរបស់សង្ខារ គឺអារម្មណ៍ដែលកំណាត់ដឹងវិបស្សនាចិត្តដែលឃើញច្បាស់អារម្មណ៍នោះ អារម្មណ៍ដែល ពិចារណា*

និងចិត្តដែលពិចារណាអារម្មណ៍នោះ ទើបព្រងើយក្នុងសង្ខារ ប្រាសចាកសេចក្តីត្រេកអររីករាយ គឺមិនត្រេកអរក្នុងសង្ខារ ដូចក្នុងវិបស្សនាញាណថ្នាក់ដើម និងប្រាសចាកសេចក្តីខ្វាច ស្អប់ខ្ពើមនឿយណាយ និងត្រូវការកំណត់ ដូចក្នុងលំដាប់កយញ្ញាណជាដើម តែនឹងឃើញច្បាស់នូវការរលត់ទៅរបស់សង្ខារ យ៉ាងជាក់ច្បាស់ ក្នុងខណៈនោះវិបស្សនាចិត្ត នឹងដូចថយត្រឡប់ចេញពីសង្ខារ ដូចដំណក់ទឹកលើស្លឹកឈូក ដែលរមៀលធ្លាក់ចុះទៅពីស្លឹកឈូក ។

កាលសង្ខារុបេក្ខាញ្ញាណចាស់ក្លាហើយ ក៏កើតអនុលោមញ្ញាណព្រមដោយគោត្រភូញ្ញាណ មគ្គញ្ញាណ និងផលញ្ញាណ រមែងប្រាកដឡើង កំណត់សង្ខារទាំងអស់រត់ចូលទៅកាន់ការរលត់រូបនាម គឺនិព្វានអនុបស្សនា ដែលថយត្រឡប់ពីសង្ខារទាំងអស់រត់ចូលកាន់ព្រះនិព្វាននេះឈ្មោះថា វិវដ្តានុបស្សនា រមែងលះបង់សេចក្តីប្រកាន់មាំ ដែលប្រកបក្នុងសង្ខារដែលបានដល់ សេចក្តីត្រេកអរក្នុងកាម ( កាមរាគសំយោជនៈ ) និង ការថ្នាំងថ្នាក់ចិត្ត មិនពេញចិត្ត ( បដិឃសំយោជនៈ ) ជាដើម ដោយហេតុនេះ អ្នកដែលសម្រេចសង្ខារុបេក្ខាញ្ញាណ សូម្បីនឹងគិតដល់រឿងដែលខ្វួនពេញចិត្ត ឬមិនពេញចិត្ត ក៏រមែងព្រងើយកន្តើយ និងមិនគិតដល់រឿងនោះជាវេលាយូរ ។

ក្នុងគម្ពីរអដ្ឋកថារបស់បដិសម្ភិទាមគ្គ បានសំដែងនូវការឃើញថាគោត្រភូញ្ញាណដែលកើតពីអនុលោមញ្ញាណ ឈ្មោះថា **វិវដ្តានុបស្សនា**

ហើយពោលថា សេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គជំទាស់ជាមួយនឹងសេចក្តីក្នុគម្ពីរបដិសម្ភិទាមគ្គ ពោលគឺចរិយាកថា របស់គម្ពីរបដិសម្ភិទាមគ្គពោលថា **អាវជ្ជនចិត្ត** រមែងមានបានក្នុង **អនុបស្សនា**ដទៃ **ពីវិវដ្តនុបស្សនា** ដោយពាក្យថា "អាវជ្ជនចិត្ត ដែលពិចារណាដើម្បីអនិច្ចានុបស្សនា ជាវិញ្ញាណចរិយា ( ការកើតឡើងនៃចិត្ត ) ចំណែកអនិច្ចានុបស្សនាជា ញាណចរិយា..... អាវជ្ជនចិត្តដែលពិចារណាដើម្បីបដិសង្ខានុបស្សនា ជាវិញ្ញាណចរិយា" ។

យ៉ាងណាក៏ដោយ ក្នុងវិវដ្តានុបស្សនា មិនបានពោលដល់អាវជ្ជនចិត្តដោយពាក្យថា"វិវដ្តានុបស្សនា ជាញាណចរិយា" បើសង្ខារុបេក្ខាញាណនិងអនុលោមញាណ ជាវិវដ្តានុបស្សនាក៏គួរពោល ថាវិវដ្តានុបស្សនាមានអាវជ្ជនចិត្តនៅមុខ ព្រោះញាណទាំងពីរ ត្រូវមានអាវជ្ជនចិត្តនាំមុខដូចនោះ វិវដ្តានុបស្សនាទើគួរជាគោត្រភូញាណតែម្យ៉ាង ។

# ពាក្យសរុប

**ភាវេតព្វា យោគីហិយា ឧជ្ជុតា ច បច្ចក្ខតោ**
**វណ្ណិតា តា អដ្ឋារស មហាវិបស្សនា មយា**
**ឧត្វាធំ សុពោធេតុង យោគីនំ សុតវុទ្ធិយា ។**

"ខ្ញុំបានអធិប្បាយ មហាវិបស្សនា ១៨ ជាធម៌ ដែលប្រារព្ធនូវសេចក្តីព្យាយាម គួរចម្រើននិងដឹងច្បាស់ ដោយប្រចក្ស ដើម្បីបន្ថែមនូវ

ការយល់ដល់អ្នកប្រារព្ធនូវសេចក្ដីព្យាយាម ដោយអធិប្បាយនូវសេចក្ដីដែលយល់លំបាកយល់ងាយ” ។

យតោ ច ភិក្ខុ អាតាបី សម្បជញ្ញំ ន រិញ្ចតិ
តតោ សោ វេទនា សព្វា បរិជានាតិ បណ្ឌិតោ ។
សោ វេទនា បរិញ្ញាយ ទិដ្ឋេ ធម្មេ អនាសវោ
កាយស្ស ភេទា ធម្មដ្ឋោ សង្ខ្យំ នោបេតិ វេទគូ ។

( សំ. សឡា. ១៨.២៥២.១៩២ )

ភិក្ខុអ្នកបំពេញព្យាយាមមិនដាច់ សម្បជញ្ញៈជាអ្នកមានបញ្ញាស្គាល់ឃើញវេទនាទាំងពួង អ្នកស្គាល់ឃើញវេទនាហើយ រមែងជាអ្នករកអាសវៈមិនបានក្នុងបច្ចុប្បន្នជាតិ លោកអ្នកមានបញ្ញាតាំងមាំ នៅក្នុងធម៌ កាលបើអស់ជីវិតហើយ រមែងមិនដល់ការរាប់ ក្នុងសម្មតិបញ្ញត្តិណាៗ ។

# និគមកថា

១.នគរេ មឹងឡាំយែ នាមេ មណ្ឌលាចលធានកេ
គិញ្ជកាវាសអារាមំ យោ ថេរោ ចិរមាវាសី ។
២.បុរត្ថិ យំ ជយដ្ឋានំ អយ្យ អងជេយ្យៈ រាជិនោ
តស្ស បច្ឆិមភាគេ យោ អាវាសោ និគមោ សតំ។
៣.មហាភេរីវិហារស្មឹ ឯតស្មា បច្ឆិមុត្តរេ
សាលនាយមហាកូប- វរស្សាបិ ឧបន្តិកេ ។

៤.វសន្តោ សោភណោ នាម វីសវស្សោ តថេសកោ
ឧទាសកេហិ សទ្ធម្ម- រតចិត្តេហិ យាចិតោ ។
៥.ហិតត្ថាយ ហិតេសីនំ វុឌ្ឍិយា សាសនស្ស ច
វិបស្សនានយំ នាម យំ គន្ថំ កាតុមារភី ។
៦. សោ និដ្ឋិតោ សត្តិ សត្តសីតិមេ
វស្សេ ចតុវីសសតេហិ បច្ចតោ
សាកេន បញ្ចាធិកាតរសេ សតេ
មាឃស្ស សម្បុណ្ណទិនម្ហិ និដ្ឋិតោ ។
៧.យថា ចាយំ គតោ សិទ្ធិ- ននត្តរាយេន កេវលី
តថា កល្យាណសង្កប្បា សិជ្ឈន្តុ សព្វជន្តុនំ ។
សោភណមហាថេរោ

# ពាក្យចុងក្រោយ

*១-៥. ព្រះថេរៈរូបណាស្នាក់នៅតែចង ( វត្តផុះថ្ម ) ជិតជើងភ្នំតង រាយ ( ភ្នំមូលៈ ) ក្នុងខេត្តម៉ងឡាំយៃ ជាវេលាយូរ ព្រះថេរៈអ្នកមាននាមថា* ***សោភណៈ****នោះ មានវស្សា ២០ អ្នកស្វែងរកមគ្គដ៏ត្រឹមត្រូវបានទៅនៅក្នុងវត្តមហាសី ( វត្តស្គរធំ ) ជិតទឹងមហាស្តូបឥនចិនតរ ( ព្រៃស្អុក ) ផ្លូវទិសខាងកើតចៀងខាងជើងរបស់ស្រុកចិកខូន ( ចំណាតពន្ធដារ ) ដែលជាទីពុំនាក់របស់សប្បុរសនៅក្នុង កើតរបស់ក្រុង* ***ជរោកោ*** *ដែលព្រះ*

បានអង់ជេយ្យ: ទ្រង់ស្ថាបនាឡើង ជ័យជំនះ ដែលគណៈបាសក អ្នកមានចិត្តត្រេកអរក្នុងព្រះសទ្ធម្មអង្វរ សុំហើយ ទើបប្រារព្ធដើមចងក្រងគម្ពីរឈ្មោះវិបស្សនាន័យ ដើម្បីប្រយោជន៍ដ៏សំខាន់ ដល់អ្នកស្វែងរកប្រយោជន៍ និងដើម្បីសេចក្តីចម្រើនរុងរឿងនៃព្រះសាសនា ។

៦. គម្ពីរនោះចប់ហើយក្នុងថ្ងៃពេញបូណ៌មីខែ ៣ ពុទ្ធសករាជ ២៤៨៧ ខាងក្រោយអំពីព្រះបរមសាស្តា ស្តេចរំលត់ខន្ធបរិនិព្វានហើយ រាប់ជាចុល្លសករាជ ១៣០៥ ។

៧. ម្យ៉ាងទៀត គម្ពីរនេះចប់ដោយបរិបូណ៌ ដោយប្រាសចាកសេចក្តីអន្តរាយយ៉ាងណា សូមសេចក្តីត្រិះរិះពេញចិត្តរបស់ជនទាំងមូល ចូរសម្រេចសម តាមសេចក្តីប្រាថ្នាយ៉ាងនោះ ។

ព្រះសោភណមហាថេរ:

**យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ**
**ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ**
**ឯវម្បិ តណ្ហានុសយេ អនូហតេ**
**និព្វត្តតី ទុក្ខមិទំ បុនប្បុនំ ។**

( ខុ. ធ. ២៥. ៧៥. ៣៣៨ )

កាលឫសប្រាសចាកអន្តរាយតាំងនៅមាំ ដើមឈើដែលត្រូវកាត់ហើយ រមែងត្រឡប់ដុះឡើង បានយ៉ាងណា កាលបុគ្គលដកខ្សែតណ្ហា

*មិនទាន់បាន ទុក្ខនេះរមែងកើតឡើងរឿយៗយ៉ាងនោះ ។*

# ការលះសក្កាយទិដ្ឋិរបស់ព្រះសោតាបន្ន

*កិលេសសំខាន់មួយប្រការ ដែលធ្វើមនុស្សទូទៅ ប្រកាន់មាំក្នុងតួខ្លួន ឈ្មោះថា* ***សក្កាយទិដ្ឋិ*** *ដែលអាចជាការ សម្គាល់ខុសថា មានវិញ្ញាណ ឬកាយទិព្វកំបាំងនៅខាងក្នុងរាងកាយ ឬសូម្បីនឹងយល់បានត្រឹមត្រូវថា មនុស្សសត្វទាំងឡាយប្រកបដោយរូប និងនាមដោយមិនមានវិញ្ញាណ តែក៏នៅប្រកាន់មាំថា តួខ្លួននោះជាយើង របស់យើង បុរស ឬស្ត្រីការប្រកាន់មាំដូចពោល មាននៅជានិច្ចដល់បុថុជ្ជន ដោយ អំណាចសក្កាយទិដ្ឋិ ធ្វើសាងបុណ្យបាបដើម្បីខ្លួននៅដោយល្អ មានសេចក្តីសុខរហូតទៅ ។*

*អ្នកលះអស់សក្កាយទិដ្ឋិបាន គឺព្រះសោតាបន្ន ដែលនឹងអាចលះបាន ដោយសោតាបត្តិមគ្គ ក្រោយពីសម្រេចធម៌ហើយ ត្រឹមខណៈដែលបិទភ្នែកចុះ នឹងដឹងត្រឹមដូចបន្តិលចូលកាន់និមិត្តមួយទៀត បានឯងស្រដៀងនឹងការចូលដល់ញាណ ១១ ( ជាញាណលំដាប់ខ្ពស់បំផុតរបស់បុថុជ្ជន អ្នកដែលសម្រេច ញាណនេះ នឹងដឹងត្រឹមដូចរត់ចូលកាន់និមិត្តមួយទៀតដែលស្ងប់សុខ និងសភាវធម៌បច្ចុប្បន្ន ដែលកំពុងតែកំណត់ដឹងដូចសភាវៈប៉ះខ្ទប់ ឬប៉ោងស្រេក នឹងល្អិតឡើងជាលំដាប់ ដូចសំឡី ឬសំឡីកប្បាសរាំងមិនមាន សេចក្តីរាយមានរំខានចិត្ត ដោយឥតមានសេសសល់ ) ក្នុងខណៈនោះនឹងទទួលដឹងនូវការរលត់ទៅ របស់រូបកាយ*

ទាំងអស់ ជាការចូរទំនេរយ៉ាងក្រៃលែង មិនថានឹងពិចារណា រាងកាយចំណែកណា ក៏នឹងជួបត្រឹមការទំនេរ នឹងទទួលដឹងចំពោះចំណែកខ្លះដែលមានសភាវៈប៉ះខ្ទប់ ដូចដៃ ដែលត្រូវអាវ តែជាការប៉ះខ្ទប់អណ្តែតៗ ដែលមិនជ្រាបថា អ្វីប៉ះខ្ទប កាលបើកភ្នែកឡើង ក៏នឹងទទួលដឹងដល់ការបង្អិលចេញទៅកាន់និមិត្តមួយ ទៀតដែលមានការសម្លឹងមើល ឬការឃើញ ចំណែកផ្សេងៗ របស់រាងកាយប្រាកដឡើង ទើបទទួលដឹងបានថារាងកាយនៅមាន ។

ក្រៅពីនោះ សភាវៈកើតរលត់ផ្លូវកាយ និងចិត្ត រមែងប្រាកដដល់លោករហូតវេលា ដូចជា :

-ខណៈដើរចង្រ្កម អាចដឹងត្រឹមថាសភាវៈអណ្តែតទៅរបស់ជើង ឬ ខ្លួនដែលបង្អិលទៅនោះ ជាសភាវៈអណ្តែត ដែលឈប់ជាចន្លោះ ៗ ស្រដៀងនឹងរលត់សមុទ្រ ដែលកម្រើកជារលកស្រាលៗលើទឹក កាលបើសង្កេតនឹងឃើញជាសភាវៈស្រាល ដែលប្រាកដហើយបាត់ទៅ រហូតសភាវៈកម្រើកដល់ទីបំផុត គ្រាខ្លះ អាចដឹងត្រឹមដល់សភាវៈកើត រលត់របស់សភាវៈស្រាលខ្លាំងដែលដាច់ចន្លោះល្អិតក្រៃលែង គ្រាខ្លះ ក៏ដឹងត្រឹមដល់សភាវៈញ័រកម្រើកខាងក្នុងជើង តែដឹងមិនប្រាកដថាជាចំណែកណា ដឹងត្រឹមថា វត្ថុ ដែលកម្រើកនៅតែមិនមែនជើង របស់យើង តែជាទ្រវែងវែងៗ ប្រសិនបើទៅមកនៅកម្រើក ។

-ខណៈអង្គុយកម្មដ្ឋាន អាចដឹងត្រឹមដល់ការខ្ញីកម្រើកល្អិត ក្រៃលែង

ខាងក្នុងរាងកាយដូចសីសៈ រាងកាយចំណែកខាងលើ រាងកាយចំណែកខាងក្រោម គ្រាខ្លះអាចដឹងត្រឹមថា សភាវៈប៉ះខ្ទប់ផ្លូវ រាងកាយកម្រើកល្អិតក្រៃលែង គ្រាខ្លះនឹងជាចង្វាក់លោតឃើញឃឹតៗ និងមិនដឹងត្រឹមថាមានរូបរាងសណ្ឋានរបស់រាងកាយទាំងអស់ ឬចំណែកខ្លះ ដោយសេចក្តីធូរទំនេរ ជាវត្ថុ ដែលប្រាកដជាក់ច្បាស់ ។

ក្នុងខណៈខ្លះ ដែលសមាធិមានកម្លាំងច្រើនឡើង ក៏នឹងទទួលដឹងការរលត់របស់ចិត្តថា ដូចជាដួងមូលៗដែលចាប់ផ្តើមចូលចេញ មានពន្លឺផូរផង់នៅជុំវិញកើតរលត់ឃើញ គ្រាខ្លះក៏បែកខ្លួន ចេញជាសភាពភ្លឺក្រៃលែងៗ ដូចបំណែកផ្កាយ ដែលបំបែកចេញលោតទៅមក មានពន្លឺហើយបាត់ទៅ ដដែលៗ នៅជិតគ្នារហូត គ្រាខ្លះ តាមមើលមិនទាន់ គ្រាខ្លះក៏ជាផ្កាយធំៗ កើតរលត់ឃើញច្រើនជាងជា ផ្កាយតូចៗ ផ្លាស់ប្តូរនឹងការងងឹត គ្រាខ្លះ ដូចឃើញបណ្តើរកូន ដែលមានលក្ខណៈកម្រើកញ័រឬឃើញចិត្ត លោភកើតឡើងហើយបាត់ទៅ ផ្លាស់គ្នារហូត សេចក្តីលោភរលត់ ដោយហេតុដែលចិត្តជាសភាវៈដឹង អារម្មណ៍ ការឃើញច្បាស់នូវការកើតរលត់របស់ចិត្ត ទើបដូចបានឃើញច្បាស់ពន្លឺភ្លឺ ប្រាកដឡើងហើយរលត់ ទៅ គ្រាខ្លះ អាចឃើញច្បាស់ការកើតរលត់ របស់ចិត្តភ្ញាក់ទៀតផង ដោយដឹងត្រឹមថា ដូចជាដុំភ្លើងដែល ឡើងមកហើយរលត់វុបទៅ ។

-ខណៈកំណត់វេទនា អាចដឹងត្រឹមដល់សភាវៈរមាស់ ដែលកម្រើក

ទៅមកហើយបាត់ទៅមាន លក្ខណៈកំចាត់ចេញ ដូចផ្កាយកំចាត់ចូលមក ជំនួសទីផ្លាស់គ្នាទៅ គ្រាខ្លះនឹងឃើញសភាវៈរមាស់នោះរីកធំឡើង មាន រូបរាងដូចខ្នងជន្លេនចាប់ផ្តើមទៅមក មានពន្លឺដូចមាសៗ កម្រើកទៅមកឃើញ តែមិនទទួល ដឹងសភាវៈរមាស់បានជាក់ច្បាស់ ក្នុងខណៈឃើញនោះ កាលសភាពនោះ កម្រើករហូតបាត់ទៅ សភាវៈរមាស់ ទើបរលត់ គ្រាខ្លះ នឹងឃើញការរីកចេញ និងរួញបាត់ទៅរបស់សភាវៈរមាស់ ។

ក្នុងខណៈខ្លះ ពេលដើរចង្ក្រម ឬធ្វើឥរិយាបថតូចតាច នឹងមាន ចិត្តដែលគិតចង់នឹងស្វែងរក សភាវៈដើរថា មានអ្វីក្នុងសភាវៈនោះ កាល ដើរកំណត់ទៅរឿយៗ ក៏ជួបថា វត្ថុដែលព្យាយាមស្វែងរក នោះមិនមាន មានត្រឹមសភាវៈកម្រើកកើតរលត់បន្តគ្នាទៅ ទាំងនៅអាចកំណត់ដឹងចិត្ត បញ្ញាបានទៀតថា មានត្រឹមចិត្តដែលត្រូវការ និងធ្វើអាកប្បកិរិយាផ្សេងៗ ដូចសណ្តូក កោង កើត រលត់បន្តគ្នាទៅ គ្រោតគ្រាតខ្លះ ល្អិតខ្លះ មិនមានប្រាថ្នា មិនមានអ្វី ក្រៅពីចិត្តបញ្ញា និងរាងកាយ ដែលធ្វើតាម ចិត្តបញ្ញា ។

កាលផ្តើមសម្រេចធម៌ ចិត្តរបស់លោក រមែងធ្លាក់ចុះកាន់ការ រលត់រូបនាម ការចូលកាន់សេចក្តី រលត់រូបនាម ដូចពោល ក៏គឺការចូល ផលសមាបត្តិ នោះឯង ក្នុងខណៈនោះ នឹងដឹងត្រឹមដល់ការស្ងប់ ត្រជាក់ គឺ មិនក្តៅអន្ទះអន្ទែងដោយកិលេស និងស្រឡះស្រឡំចិត្ត ព្រោះ បានទទួលទីពឹង ដែលស្វែងរក មកច្រើនកប្ប ក្រោយពីចេញ ពីការ

រលត់ហើយទើបដឹងត្រឹមដល់សេចក្ដីសុខ ដែលមិនធ្លាប់បានទទួលមក ពីមុន ក្នុងជីវិត ដែលហៅថា **និព្វានសុខនោះឯង** ។

ក្នុងចន្លោះដំបូងៗ រមែងចូលផលសមាបត្តិបាន មិនយូរ ព្រោះកម្លាំងសមាធិនៅមានមិនច្រើន តមកកាលសមាធិមានកម្លាំងច្រើនឡើង ក៏នឹងនៅបានយូររាបម៉ោង ក្នុងខណៈខ្លះសូម្បីកំពុងបរិភោគ ផឹក ក៏ដឹងត្រឹមដូចចង់ធ្លាក់ចុះកាន់ការរលត់ និងអាចធ្លាក់ចុះ ទៅបានថ្ងៃខ្លះភ្ញាក់ពីដេក មកកណ្ដាលយប់ ក៏ដឹងត្រឹមដូចយ៉ាងនោះ និងអាចធ្លាក់ចុះទៅបានដូចគ្នា ។

កាលចេញអំពីកម្មដ្ឋាន ហើយត្រឡប់ទៅនៅជាមួយក្រុម គ្រួសារធ្វើការងារ ។ល។ រមែងចូលផលសមាបត្តិបានលំបាក ព្រោះមាន សម្លេងអឺងកង បន្ទាប់ពីសម្លេងអឺងកងបាត់ទៅ សូម្បីត្រឹមមិនយូរ លោកនឹងអាចចូលផលសមាបត្តិបានដូចដើម តែនឹងតាំងនៅបានយូរត្រឹមណា ក៏ឡើងនៅជាមួយសមាធិក្នុងខណៈៗ ក្នុងខណៈខ្លះដែលមានអនិដ្ឋារម្មណ៍ ច្រើនប៉ះខ្ទប់ចិត្ត លោកនឹងអាចកំណត់ដឹងសេចក្ដីស្រអាប់ របស់ចិត្តបានភ្លាមដោយទោសៈមិនអាចគ្របសង្កត់ចិត្តលោកបាន ទើបមិនធ្វើអាកប្បកិរិយាផ្លូវកាយ ឬវាចាដោយអំណាចទោសៈ ។

សេចក្ដីទាំងអស់នេះ សរសេរតាមជំនាញក្នុងការបដិបត្តិធម៌ដោយកត់ត្រាពីពាក្យរាយការណ៍ របស់អ្នកបដិបត្តិធម៌ អ្នកខ្លះ ក្នុងខណៈបង្រៀនកម្មដ្ឋាន របស់អ្នករៀបរៀងសង្ឃឹមថា នឹងមានប្រយោជន៍

ដល់អ្នកអាននឹងធ្វើចិត្តមាំទាំផ្លូវចម្រើនសតិបដ្ឋាន ៤ នេះជាអំណោយផល សម្រេចធម៌បាន យ៉ាងពិតប្រាកដ ៕

# វិបស្សនាន័យ

# ចប់ដោយបរិបូណ៌ ៕

*១៥ កើត ខែ អស្សុជ ឆ្នាំឆ្លូវ ឯកស័ក ព. ស. ២៥៥៣*

អមរាភិរំស: **ថោន សីលា**

សូមថ្លែងអំណរគុណ ចំពោះពុទ្ធបរិស័ទ ដែលបានចូលរួមបោះពុម្ព សៀវភៅ **វិបស្សនានយ័** ភាគទី ៣ ដែលជាភាគបញ្ចប់នេះ តាមរយៈ

-តាមរយៈ កិត្តិអ៊ី **ចាន់អៀង** គង់នៅតាផេម រាជធានីភ្នំពេញ

-តាមរយៈ ឧ.សិ. **លឹម ចន្ទន** ខេត្ត សៀមរាប

-តាមរយៈ ឧ.សិ. **ប៉ូ យ៉ុន** ខេត្ត សៀមរាប

-តាមរយៈ ឧ.សិ. **អ៊ុំ ឈីវហ៊ុន** ខេត្ត សៀមរាប

-តាមរយៈ ឧ.សិ. **ស៊ូវឡា** ខេត្ត សៀមរាប

-តាមរយៈ ឧ.សិ. **ឱម សារ៉ូន** ខេត្ត សៀមរាប

-តាមរយៈ ឧ.សិ. **យ៉ាវ កុសល** វត្តអូញ្ញារ បាត់ដំបង

-តាមរយៈ ឧ.សិ. **ណៃ ស៊ីម** (ខេត្ត កំពង់ស្ពឺ)

-តាមរយៈ ឧ.សិ. **គីម ម៉ាក់វ៉ៃ** ខេត្ត សៀមរាប

-តាមរយៈ ឧ.សិ.**សួន សារ៉េន** ខេត្ត សៀមរាប

-តាមរយៈ ឧ.សិ. **ចន្ទូ** (វត្តអណ្តើក) ខេត្តបាត់ដំបង

-តាមរយៈ ឧ.សិ. **ទិត្រ ដាវី (សាលាសតិប្បដ្ឋានា)** ខេត្តបាត់ដំបង

-តាមរយៈ ឧ.សិ. **ស៊ុំ ស៊ុណាត និង** .ឧ.សិ. **វណ្ណៈ ភាព** ( សៀមរាប )

-តាមរយៈ ព្រះតេជគុណ. **ញឹម សុគា** ( វត្តកំផែង )

-តាមរយៈ អ្នកគ្រូពេទ្យ **ចន្ថា និងអ្នកគ្រូ មីន** ( ប៉ោយប៉ែត )

-តាមរយៈ ឧ.ស. **ព្រហ្មលី** ( **USA** ) -តាមរយៈ ឧ.ស. **ធាត ឈុន្នី ( ប៉.ប៉.)**

-តាមរយៈឧ.សិ. **ស្រីណា** និង ឧ.សិ. **ស្រីលក្ខណ៍** (ក.ព.)

-តាមរយៈ ឧ.សិ. **ស្រីនាងតូច** និង ឧ.សិ. **ស្រីនាងធំ ភ្នំពេញ** ......។

-ព្រមទាំងពុទ្ធបរិស័ទខេត្តសៀមរាប ។

សូមពុទ្ធបរិស័ទទាំងឡាយ បានសមប្រកជួបប្រទះជាមួយនឹងពុទ្ធពរ ៤ ប្រការ គឺ អាយុ ១ វណ្ណៈ ១ សុខ ១ ពលៈ ១ ព្រមទាំងមានបញ្ញា ចាក់ធ្លុះសច្ចធម៌ គ្រប់ព្រះអង្គ គ្រប់គ្នា.. សូមអនុមោទនា.. សូមអនុមោទនា.. សូមអនុមោទនា!!!

**សព្វទានំ ធម្មទានំ ជិនាតិ** ធម្មទាន ឈ្នះអស់ទានទាំពួង ។




សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ធម្មគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ សង្ឃគតា សតិ ។
សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះពុទ្ធគុណ អស់កាលជានិច្ចទាំងយប់ ទាំងថ្ងៃ
ជនពួកនេះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃសព្វកាល ។
សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះធម្មគុណ អស់កាលជានិច្ចទាំងយប់ ទាំងថ្ងៃ
ជនពួកនេះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃសព្វកាល ។
សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះសង្ឃគុណ អស់កាលជានិច្ចទាំងយប់ ទាំងថ្ងៃ
ជនពួកនេះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃសព្វកាល ។
សម្រាប់ជាធម្មទាន......!!!